# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០


**វិទ្យាស្ថានជាតិស្ថិតិ**

**ក្រសួងផែនការ**



រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២០

# របាយការណ៍
# អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០

**វិទ្យាស្ថានជាតិស្ថិតិ**
**ក្រសួងផែនការ**

គាំទ្រផ្នែកបច្ចេកទេសពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida)

រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២០

# បុព្វកថា

ខ្ញុំមានសេចក្ដីសោមនស្សរីករាយ នឹងបង្ហាញនូវរបាយការណ៍ស្ដីពី លទ្ធផលអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាផ្ដល់នូវសំណុំទិន្នន័យមួយដែលអាចយកទៅប្រើប្រាស់ជាភស្តុតាងដ៏សំខាន់ផ្នែកស្ថិតិ សម្រាប់ដំណើរការនៃការធ្វើការសម្រេចចិត្ត/ការធ្វើគោលនយោបាយ សំដៅរួមចំណែកកែលម្អកម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ដែលជាអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាលើកទី១៧ គិតចាប់តាំងពីឆ្នាំ១៩៩៣មក ត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា មិនត្រូវបានរៀបចំធ្វើឡើងដោយទៀងទាត់រៀងរាល់ឆ្នាំនោះទេ នៅក្នុងចន្លោះឆ្នាំ១៩៩៣ដល់ឆ្នាំ២០០៤ ប៉ុន្តែអង្កេតនេះត្រូវបានរៀបចំធ្វើឡើងដោយទៀងទាត់រៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១៧។ ដោយឡែក អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ ត្រូវបានរៀបចំធ្វើឡើង ដោយមានជំនួយបច្ចេកទេសពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ(UNDP) និងស្ថិតិស៊ុយអែត។

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាលើកទី១៧ ដែលមានការគាំទ្រផ្នែកថវិកាទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជានិងការគាំទ្រផ្នែកបច្ចេកទេសពីធនាគារពិភពលោក (WB) និងស្ថិតិស៊ុយអែត គឺជាអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាចុងក្រោយដែលមានសំណាកគំរូធំ។ ដូចដែលបានរៀបចំគិតគូរដោយវិទ្យាស្ថានជាតិស្ថិតិ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាដែលត្រូវបានគ្រោងឡើងសម្រាប់សំណាកគំរូធំ(១២០០០គ្រួសារ) ត្រូវរៀបចំធ្វើឡើង រៀងរាល់ពីរឆ្នាំម្ដង ចាប់ពីឆ្នាំ២០១៩ តទៅ ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីរាជរដ្ឋាភិបាលកម្ពុជា និងកិច្ចសហប្រតិបត្តិការបច្ចេកទេសពីធនាគារពិភពលោក (WB) និងស្ថិតិស៊ុយអែត។

គោលបំណងចម្បងនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា គឺផ្ដល់នូវសំណុំសូចនាករមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ស្ដីពីស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជា ដោយគ្របដណ្ដប់លើទិដ្ឋភាពសង្គម-សេដ្ឋកិច្ចជាច្រើន ដូចជាស្ថានភាពសមាជិកគ្រួសារ ស្ថានភាពសុខភាព ស្ថានភាពអប់រំ ស្ថានភាពលំនៅដ្ឋាន សកម្មភាពសេដ្ឋកិច្ច ការទទួលការរងគ្រោះដោយការរំលោភបំពានភាពងាយរងគ្រោះ និងផ្សេងៗទៀត។ រាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច នេះ ដើម្បីតាមដានត្រួតពិនិត្យការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គអចក) និង ដើម្បីរៀបចំគោលនយោបាយប្រកប ដោយប្រសិទ្ធភាពសម្រាប់ការកាត់បន្ថយ និងការលុបបំបាត់ភាពក្រីក្រនៅកម្ពុជា គណនាផលិតផលក្នុង

ស្រុកសរុប (គណនេយ្យជាតិ) និង ធ្វើការវិភាគអំពីស្ថានភាពសន្តិសុខស្បៀង, គណនេយ្យជាតិនៃការបង្វែរផ្ទេរក្នុងសេដ្ឋកិច្ចតាមជំនាន់, ភាគលាភប្រជាសាស្ត្រ, និងឱនភាពតាមវដ្តជីវិត។ ក្រៅពីរាជរដ្ឋាភិបាលកម្ពុជា វិស័យឯកជន, អង្គការមិនមែនរដ្ឋាភិបាល, អ្នកស្រាវជ្រាវតាមសាកលវិទ្យាល័យ, សេដ្ឋវិទូ, អ្នកវិភាគ, និស្សិតសាកលវិទ្យាល័យ ប្រើប្រាស់លទ្ធផលអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ក្នុងដែនវិជ្ជាជីវៈរបស់ខ្លួន ដើម្បីស្វែងយល់និងវិភាគអំពីស្ថានភាពសង្គម-សេដ្ឋកិច្ច នៅកម្ពុជា។

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ត្រូវបានគិតគូររៀបចំនិងធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពី ស្ថិតិស៊ុយអែត និង ធនាគារពិភពលោក (WB)។ ខ្លឹមសារនៃលទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានរៀបចំតាក់តែងឡើងដោយមានការកិច្ចសហការជាមួយនឹង អ្នកមានចំណែកពាក់ព័ន្ធ និង អ្នកប្រើប្រាស់ទិន្នន័យសំខាន់ៗ នៅក្នុងគោលបំណងឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ។ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ត្រូវបានធ្វើហិរញ្ញប្បទានទាំងស្រុងដោយរាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីការបញ្ចប់ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ដៃគូអភិវឌ្ឍន៍។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida), ស្ថិតិស៊ុយអែត, ធនាគារពិភពលោក (WB) ព្រមទាំង ដៃគូអភិវឌ្ឍន៍ដទៃទៀត ដែលបានរួមចំណែកក្នុងការធ្វើឱ្យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាបានបញ្ចប់ទៅដោយជោគជ័យ។ ខ្ញុំក៏សូមអរគុណផងដែរចំពោះ ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញវិភាគតាមប្រធានបទ, មន្ត្រីសម្ភាសន៍, អ្នកគ្រប់គ្រង, មន្ត្រីត្រួតពិនិត្យ, និង ប្រជាជនដែលត្រូវបានសម្ភាសន៍ ដែលបានធ្វើកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងដែនភារកិច្ចរបស់ខ្លួននិងមានភាពស្មោះត្រង់ចំពោះចម្លើយរបស់ខ្លួន ព្រមទាំងចំពោះមន្ត្រីទាំងឡាយរបស់វិទ្យាស្ថានជាតិស្ថិតិនិងក្រសួងផែនការ ដែលបានបំពេញការងារដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ហើយខ្ញុំក៏សូមអរគុណចំពោះដល់អស់អ្នកទាំងឡាយណា ដែលបានរួមចំណែកដល់ជោគជ័យក្នុងការធ្វើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងផែនការ

ក្រសួងផែនការ
រាជធានីភ្នំពេញ
ខែ ធ្នូ ឆ្នាំ២០២០

កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ សូមបង្ហាញនូវរបាយការណ៍លទ្ធផល នៃការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បន្ទាប់ពីបានបញ្ចប់នៃការសម្ភាសកត់ត្រាទិន្នន័យចាប់ពីខែកក្កដា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២០។ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៧ ហើយនិងការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាពីមុនៗកន្លងមក គឺត្រូវបានចាប់អនុវត្តនៅក្នុងឆ្នាំ១៩៩៣/៩៤ ១៩៩៦ ១៩៩៧ ១៩៩៩ និងឆ្នាំ២០០៤ ដោយមានការធ្វើអង្កេតសំណាកគំរូទ្រង់ទ្រាយធំ នៅក្នុងឆ្នាំ២០០៤ ២០០៩ ២០១៤ និង ២០១៩/២០។

ដំណើរសកម្មភាពការងារអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ត្រូវបានអនុវត្តរៀងរាល់ពីរឆ្នាំម្តងដែលមានទំហំសំណាកគំរូធំ(១២០០០គ្រួសារ)នៅទូទាំងប្រទេស ដោយចាប់អនុវត្តពីឆ្នាំ២០១៩ តទៅ។ អង្កេតនេះអាចនឹងត្រូវបានយកប្រើប្រាស់សម្រាប់កំណត់រាល់បញ្ហា និងការធ្វើសេចក្តីសម្រេចនានាដោយផ្អែកលើទិន្នន័យស្ថិតិ។

គោលបំណងចម្បង នៃការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺដើម្បីប្រមូលនូវព័ត៌មានស្ថិតិអំពីកម្រិតជីវភាពរស់នៅរបស់ប្រជារាស្ត្រកម្ពុជា និងវិសាលភាពនៃភាពក្រីក្រ។ ទិន្នន័យអង្កេតនេះ បានបង្ហាញអំពីវិស័យសេដ្ឋកិច្ច សង្គមកិច្ច ដែលមានដប់ប្រធានបទ ដូចជាទំហំនិងស្ថានភាពនៃសមាសភាគគ្រួសារ ចំណាយប្រើប្រាស់ម្ហូបអាហារ និងមិនមែនម្ហូបអាហារ យុទ្ធសាស្ត្រដោះស្រាយសន្តិសុខស្បៀងនិងអាហារ ស្ថានភាពលំនៅដ្ឋាន ការអប់រំ សុខាភិបាល សកម្មភាពសេដ្ឋកិច្ច ការទទួលរងគ្រោះ ចំណូល និងឥណទានបំណុលគ្រួសារ សំណង់ កម្លាំងពលកម្ម ភាពងាយរងគ្រោះ និងព័ត៌មានផ្សេងៗទៀត ដែលមានស្រដៀងគ្នានឹងការអង្កេតលើកមុនដែរ ដោយប្រើបញ្ជីសំណួរមានបួនទម្រង់គឺ៖ ទម្រង់ទី១. បញ្ជីសំណួរភូមិ ទី២.បញ្ជីសម្រង់គ្រួសារនៅក្នុងភូមិ ទី៣. បញ្ជីសំណួរសម្រាប់គ្រួសារ និងទី៤.តារាងកត់ត្រាព័ត៌មានប្រចាំថ្ងៃអំពីការប្រើប្រាស់ផលិតផលផ្ទាល់ខ្លួន ការចំណាយ និងចំណូល។

អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា គឺជាការអង្កេតមួយដែលមានលក្ខណៈទូលំទូលាយហើយអាចផ្តល់នូវទិន្នន័យស្ថិតិ ដើម្បីប្រើប្រាស់ក្នុងគោលបំណងជាច្រើនផ្សេងៗគ្នា។ អ្នកប្រើប្រាស់ទិន្នន័យជាចម្បងគឺរាជរដ្ឋាភិបាលកម្ពុជា ប្រើប្រាស់ទិន្នន័យអង្កេតក្នុងការជួយគាំទ្រដល់ការតាមដានត្រួតពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ តាមរយៈសូចនាករសេដ្ឋកិច្ច សង្គមកិច្ចជាច្រើនខុសៗគ្នា។ អ្នកប្រើប្រាស់ទិន្នន័យផ្សេងៗទៀត ដូចជាអ្នកស្រាវជ្រាវតាមសកលវិទ្យាល័យ អ្នកវិភាគនៃអង្គការអន្តរជាតិនានា រួមមានធនាគារពិភពលោក និងអង្គការក្រៅរដ្ឋាភិបាល។ល។ ឯកសារទិន្នន័យអង្កេតត្រូវបានរៀបចំឡើង សម្រាប់ការស្រាវជ្រាវ និងការវិភាគដោយយោងទៅតាមនីតិវិធីដែលបានចែងក្នុងច្បាប់ស្ថិតិកម្ពុជាឆ្នាំ២០១៥ និងគោលនយោបាយអំពីការផ្សព្វផ្សាយទិន្នន័យស្ថិតិ។

ជាទីបញ្ចប់ ខ្ញុំសូមសំដែងនូវការកោតសរសើរអស់ពីចិត្ត ចំពោះការអនុវត្តការងាររបស់មន្ត្រី នៃវិទ្យាស្ថាន-ជាតិស្ថិតិនៃក្រសួងផែនការ មន្ទីរផែនការរាជធានី ខេត្ត និងមន្ត្រីពាក់ព័ន្ធទាំងអស់ដែលបានធ្វើការដោយមានការយកចិត្តទុកដាក់ខ្ពស់លើការងារអង្កេតនេះ ទទួលបានទិន្នន័យប្រកបដោយគុណភាព ប្រសិទ្ធភាពកាន់តែល្អប្រសើរ។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រុមគ្រួសារ និងប្រជារាស្ត្រទាំងអស់ដែលបានចូលរួមសហការឆ្លើយតបនឹងសំណួរអង្កេតនេះ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ជំនាញការនៃស្ថិតិស៊ុយអែត និងធនាគារពិភពលោក ចំពោះកិច្ចសហការជួយគាំទ្រការងារបច្ចេកទេសក្នុងការពង្រឹងគុណភាពអង្កេតឱ្យសម្រេចលទ្ធផលបានជោគជ័យ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក**
**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ក្រសួងផែនការ**
**រាជធានីភ្នំពេញ**
**ខែ ធ្នូ ឆ្នាំ២០២០**

**ហង់ លីណា**

# មាតិកា


| លេខរៀង | ខ្លឹមសារ | ទំព័រ |
|---|---|---|
| | បុព្វកថា | i |
| | អារម្ភកថា | iii |
| | មាតិកា | iv |
| | ផែនទី នៃព្រះរាជាណាចក្រកម្ពុជា | ix |
| | សេចក្តីសង្ខេប | x |
| **ផ្នែកទី១** | **សេចក្តីផ្តើម** | **១** |
| | ១.១ សេចក្តីផ្តើម | ១ |
| | ១.២ គោលបំណងនៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | ២ |
| | ១.៣ ព័ត៌មានបន្ថែមសម្រាប់អ្នកអាន | ២ |
| | ១.៤ ការរៀបចំ និង ការធ្វើផែនការអង្កេត | ៣ |
| | ១.៥ ការជ្រើសរើសសំណាកគំរូ និងការប៉ាន់ស្មាន | ៤ |
| | ១.៦ គុណភាពនៃការប៉ាន់ស្មានលទ្ធផលពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | ៩ |
| | ១.៧ ការរៀបចំតារាងសំណួរ-ចម្លើយ | ១៣ |
| | ១.៨ ការបណ្តុះបណ្តាល និង ការចុះប្រតិបត្តិការសម្ភាសន៍នៅតាមមណ្ឌលអង្កេត | ១៥ |
| | ១.៩ ប្រព្រឹត្តិកម្មទិន្នន័យអង្កេត ( Data processing ) | ១៧ |
| | ១.១០ ភាពអាចប្រៀបធៀបបាននៃទិន្នន័យអង្កេត | ១៩ |
| | ១.១១ ការផ្សព្វផ្សាយទិន្នន័យ | ២១ |
| | ១.១២ ភាពសម្ងាត់នៃព័ត៌មានទិន្នន័យ | ២១ |
| | ១.១៣ មន្ត្រីជំនាញចូលរួមការងារវិភាគទិន្នន័យ | ២២ |
| | ១.១៤ ការកំណត់និយមន័យ និង ចំណាត់ថ្នាក់ | ២២ |
| **ផ្នែកទី២** | **ចរិតលក្ខណៈប្រជាសាស្ត្រ** | **២៥** |
| | ២.១. ការសិក្សាស្រាវជ្រាវអំពីប្រជាជនក្នុងការធ្វើអង្កេត | ២៥ |
| | ២.២ ចំនួនប្រជាជននៅទីប្រជុំជន និងជនបទ | ២៦ |

២.៣ សមាមាត្រភេទ ២៧
២.៤ បំណែងចែកចំនួនគ្រួសារ តាមតំបន់ទីប្រជុំជន និងជនបទ ២៧
២.៥ ប្រជាជនបែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ ២៨
២.៦ ចំនួនប្រជាជនបែងចែកតាមជនជាតិ ៣១
២.៧ ការចុះអត្រានុកូលដ្ឋាន ៣៣
**ផ្នែកទី៣ លំនៅដ្ឋាន ៣៥**
៣.១ សេចក្តីផ្តើម ៣៥
៣.២ សម្ភារសាងសង់លំនៅដ្ឋាន (ដំបូល ជញ្ជាំង និង កម្រាល) ៣៥
៣.៣ កម្មសិទ្ធិលំនៅដ្ឋាន ៤០
៣.៤. ផ្ទៃក្រឡាលំនៅដ្ឋានបែងចែកតាមគ្រួសារ ៤១
៣.៥ ទឹកបរិភោគ ៤៣
៣.៦. បង្គន់អនាម័យ ៤៧
៣.៧ ឧបករណ៍លាងដៃ ៤៨
៣.៨ ប្រភពថាមពលសម្រាប់បំភ្លឺ និងចម្អិនអាហារ ៥០
**ផ្នែកទី៤ កសិកម្ម ៥៣**
៤.១ សេចក្តីផ្តើម ៥៣
៤.២ កម្មសិទ្ធិដីធ្លី ៥៤
៤.៣ ការដាំដុះដំណាំ (រួមមានផ្លែឈើ និងបន្លែ) ៦១
៤.៤ ការចំណាយសម្រាប់ដាំដុះដំណាំ (រួមមានផ្លែឈើ និងបន្លែ) ៦២
៤.៥ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ៦៦
៤.៦ ការចិញ្ចឹមត្រី និងការនេសាទ ៧១
៤.៧ ផលិតផលព្រៃឈើ និងការបរបាញ់សត្វ ៧៣
**ផ្នែកទី៥ ការសិក្សាអប់រំ ៧៦**
៥.១ សេចក្តីផ្តើម ៧៦
៥.២ អក្ខរកម្ម ៧៧

| | | |
|---|---|---|
| | ៥.៣. ការសិក្សានៅសាលារៀន | ៨០ |
| | ៥.៤. ការទទួលបានការសិក្សាអប់រំ | ៩២ |
| | ៥.៥ ការចំណាយសម្រាប់ការសិក្សាអប់រំ | ៩៧ |
| | ៥.៦ សន្ទស្សន៍យុគភាពយេនឌ័រអប់រំ | ៩៨ |
| **ផ្នែកទី៦** | **កម្លាំងពលកម្ម** | **១០០** |
| | ៦.១. សេចក្តីផ្តើម | ១០០ |
| | ៦.២ និយមន័យ | ១០១ |
| | ៦.៣ កម្លាំងពលកម្ម | ១០៤ |
| | ៦.៤ កម្រិតសិក្សាអប់រំ នៃកម្លាំងពលកម្ម | ១០៧ |
| | ៦.៥ ស្ថានភាពការងារ | ១០៩ |
| | ៦.៦ ការងារបែងចែកតាមមុខរបរ | ១១១ |
| | ៦.៧ ការងារបែងចែកតាមវិស័យសេដ្ឋកិច្ច | ១១៣ |
| | ៦.៨ ការងារមានប្រាក់ឈ្នួលរបស់ស្ត្រី | ១១៦ |
| | ៦.៩ ការងាររបស់កុមារ | ១១៧ |
| **ផ្នែកទី៧** | **សុខភាព និងជនមានពិការភាព** | **១១៩** |
| | ៧.១ សេចក្តីផ្តើម | ១១៩ |
| | ៧.២ ជនមានពិការភាព | ១២០ |
| | ៧.៣ ជំងឺ របួស ឬ បញ្ហាសុខភាពផ្សេងៗក្នុងរយៈពេល៣០ថ្ងៃកន្លងមក | ១២៣ |
| | ៧.៤ ការពិនិត្យសុខភាព | ១២៥ |
| | ៧.៥ អ្នកផ្តល់សេវាថែទាំសុខភាព | ១២៦ |
| | ៧.៦ ប្រភពថវិកាចំណាយសម្រាប់ការថែទាំសុខភាព | ១២៨ |
| | ៧.៧ អាហារូបត្ថម្ភរបស់កុមារ | ១២៨ |
| | ៧.៨ សុខភាពរបស់កុមារ | ១២៩ |
| **ផ្នែកទី៨** | **ការទទួលរងគ្រោះ** | **១៣១** |
| | ៨.១ សេចក្តីផ្តើម | ១៣១ |

| | | |
|---|---|---|
| | ៨.២. ការទទួលរងគ្រោះសរុប | ១៣១ |
| | ៨.៣ អ្នកទទួលរងគ្រោះដោយសារអំពើហិង្សា | ១៣២ |
| | ៨.៤ គ្រួសារដែលរងគ្រោះដោយបទល្មើសទ្រព្យសម្បត្តិ | ១៣៩ |
| | ៨.៥ អារម្មណ៍សុវត្ថិភាព | ១៤០ |
| | ៨.៦ គ្រួសារដែលរងគ្រោះដោយឧបទ្ទវហេតុ (គ្រោះថ្នាក់) | ១៤១ |
| **ផ្នែកទី៩** | **ប្រាក់ចំណូល និង ចំណាយគ្រួសារ** | **១៤២** |
| | ៩.១ និយមន័យ និងវិធីសាស្ត្រនៃការចងក្រងស្ថិតិចំណូលគ្រួសារ | ១៤២ |
| | ៩.២ ប្រាក់ចំណូលគ្រួសារនៅកម្ពុជា | ១៤៧ |
| | ៩.៣ បំណុលរបស់គ្រួសារនៅកម្ពុជា | ១៥៩ |
| **ផ្នែកទី១០** | **ការចំណាយប្រើប្រាស់របស់គ្រួសារ** | **១៦៩** |
| | ១០.១ សេចក្តីផ្តើម | ១៦៩ |
| | ១០.២ វិធីសាស្ត្រគណនាចំណាយប្រើប្រាស់ | ១៦៩ |
| | ១០.៣ ការកែប្រែលើវិសាលភាពនៃនិយមន័យរបស់មុខចំណាយមិនមែនម្ហូបអាហារខ្លះមួយចំនួន | ១៧០ |
| | ១០.៤ ការចំណាយប្រើប្រាស់ប្រចាំខែគិតជាមធ្យម | ១៧១ |
| | ១០.៥ សមាសភាពនៃការចំណាយប្រើប្រាស់ | ១៧២ |
| | ១០.៦ ការចំណាយលើម្ហូបអាហារ និងការចំណាយប្រើប្រាស់សរុបប្រចាំខែ | ១៧៦ |
| | ១០.៧ សម្ភារប្រើប្រាស់បានយូរ | ១៧៧ |
| **ផ្នែកទី១១** | **ការប្រើប្រាស់ស្បៀងអាហាររបស់គ្រួសារ** | **១៧៩** |
| | ១១.១ ការប្រើប្រាស់ម្ហូបអាហារនៅក្នុងគ្រួសារ | ១៧៩ |
| | ១១.២ ភាពងាយរងគ្រោះក្នុងគ្រួសារ( យុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហា) | ១៨១ |
| **ផ្នែកទី១២** | **តារាងឧបសម្ព័ន្ធ** | **១៨៣** |
| | ឧបសម្ព័ន្ធ១ តារាងទិន្នន័យបន្ថែមផ្នែកចរិតលក្ខណៈប្រជាសាស្ត្រ | ១៨៤ |
| | ឧបសម្ព័ន្ធ២ តារាងទិន្នន័យបន្ថែមផ្នែកលំនៅដ្ឋាន | ១៩០ |
| | ឧបសម្ព័ន្ធ៣ តារាងទិន្នន័យបន្ថែមផ្នែកកសិកម្ម | ១៩៥ |

ឧបសម្ព័ន្ធ៤ តារាងទិន្នន័យបន្ថែមផ្នែកការសិក្សាអប់រំ ២០៧

ឧបសម្ព័ន្ធ៥ តារាងទិន្នន័យបន្ថែមផ្នែកកម្លាំងពលកម្ម ២១២

ឧបសម្ព័ន្ធ៦ តារាងទិន្នន័យបន្ថែមផ្នែកសុខភាព ២១៦

ឧបសម្ព័ន្ធ៧ តារាងទិន្នន័យបន្ថែមសម្រាប់ចំណូលគ្រួសារ ២១៨

ឧបសម្ព័ន្ធ៨ តារាងទិន្នន័យបន្ថែមសម្រាប់ចំណាយប្រើប្រាស់ ២២០

**ផ្នែកទី១៣ ឧបសម្ព័ន្ធបញ្ជីសំណួរ ចម្លើយ ២២៣**

ឧបសម្ព័ន្ធ១ តារាងសំណួរភូមិ ២២៤

ឧបសម្ព័ន្ធ២ បញ្ជីសម្រង់គ្រួសារនៅក្នុងភូមិ ២៣៤

ឧបសម្ព័ន្ធ៣ បញ្ជីសំណួរសម្រាប់គ្រួសារ ២៣៨

ឧបសម្ព័ន្ធ៤ តារាងកត់ត្រាព័ត៌មានប្រចាំថ្ងៃអំពីការប្រើប្រាស់ផលិតផលផ្ទាល់ខ្លួន ការចំណាយ និងចំណូល ២៩៧-៣០១

# ផែនទី នៃព្រះរាជាណាចក្រកម្ពុជា



# សេចក្ដីសង្ខេប

អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ (CSES) គឺជាការងារអង្កេតលើកទី១៧ ដែលបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។ ដំណើរការងារអង្កេតនេះ មានការឧបត្ថម្ភគាំទ្រថវិកាទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា និងជំនួយផ្នែកបច្ចេកទេសរយៈពេលខ្លីពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត ស្ថិតិស៊ុយអែត និងធនាគារពិភពលោក។ យោងតាមគម្រោងផែនការនៃការងារអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានគ្រោងអនុវត្តធ្វើអង្កេតជារៀងរាល់ពីរឆ្នាំម្តង គិតចាប់ឆ្នាំ២០១៩តទៅ ដែលមានទំហំសំណាកគំរូធំ (ប្រមាណជាង១0000គ្រួសារ) គ្របដណ្តប់ទូទាំងប្រទេស ដែលនឹងគាំទ្រថវិកាទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា និងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍។

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានសូចនាករពហុវិស័យសំខាន់ៗ អំពីលក្ខណៈស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាដែលទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច រួមមាន៖ ស្ថានភាពគ្រួសារ ស្ថានភាពលំនៅដ្ឋាន ការសិក្សាអប់រំ សុខភាព សកម្មភាពសេដ្ឋកិច្ច(កម្លាំងពលកម្ម) ការទទួលរងគ្រោះ ចំណូលនិងឥណទាន(បំណុល)គ្រួសារ ការចំណាយប្រើប្រាស់ ភាពងាយរងគ្រោះនៃគ្រួសារនិងព័ត៌មានផ្សេងៗទៀត។ សូចនាករទាំងនេះ សម្រាប់ជាធាតុចូលដ៏សំខាន់ ក្នុងការតាមដាន ត្រួតពិនិត្យ វាយតម្លៃអំពីវឌ្ឍនភាពអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) របស់រាជរដ្ឋាភិបាលកម្ពុជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ និងបង្កើតចេញនូវគោលនយោបាយដ៏មានប្រសិទ្ធភាព សម្រាប់ការកាត់បន្ថយ និងលុបបំបាត់ភាពក្រីក្រនៅកម្ពុជា គណនាកំណើនសេដ្ឋកិច្ច (គណនេយ្យជាតិ) វិភាគសន្តិសុខស្បៀងអាហារ វិភាគគណនេយ្យបង្វែរសេដ្ឋកិច្ចជាតិតាមវ័យ វដ្តជីវិតសេដ្ឋកិច្ច និងភាគលាភប្រជាសាស្ត្រ។ អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយក្រៅពីរាជរដ្ឋាភិបាលកម្ពុជាមានដូចជាអ្នកស្រាវជ្រាវ អ្នកវិភាគ និងអង្គការក្រៅរដ្ឋាភិបាលនានាក៏អាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលអង្កេតនេះក្នុងការស្វែងយល់ឱ្យបានកាន់តែប្រសើរថែមទៀត អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចនៅកម្ពុជា។

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺជាអង្កេតគំរូតំណាងទូទាំងប្រទេសនៃប្រជាជនចំនួន ១.០០៨ភូមិនៅក្នុងឯកតាជ្រើសរើសសំណាកគំរូ(ភូមិ) ដែលចែកចេញជាសំណាកគំរូប្រចាំខែ (ចំនួន១២ខែ) ដែលមាន១០.០៨០គ្រួសារនៅក្នុងរាជធានីខេត្តទាំង២៥។ ការរៀបចំជ្រើសរើសសំណាកគំរូ ត្រូវបានគណនាប៉ាន់ស្មានសម្រាប់នៅរាជធានីភ្នំពេញ ទីប្រជុំជន និងជនបទ។ អង្កេតនេះក៏បានគណនាប៉ាន់ស្មានសម្រាប់តំបន់អេកូឡូស៊ីចំនួនបួនផ្សេងទៀត ដូចជាវាលទំនាប ទន្លេសាប តំបន់មាត់សមុទ្រ/តំបន់ភ្នំ/ខ្ពង់រាបផងដែរ។ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០១៩ ត្រូវបានប្រើប្រាស់ជាក្របខ័ណ្ឌជ្រើសរើសសំណាកគំរូ។

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានតារាងសំណួរបួនទម្រង់។ ទម្រង់ទី១-តារាងចុះបញ្ជីគ្រួសារនៅក្នុងភូមិ ទម្រង់ទី២-តារាងសំណួរភូមិ ទម្រង់ទី៣-តារាងសំណួរគ្រួសារ ទម្រង់ទី៤-តារាងសំណួរកត់ត្រាប្រចាំថ្ងៃ។ តារាងសំណួរត្រូវបានរៀបចំដោយប្រុងប្រយ័ត្ន និងមានការកែសម្រួលមួយចំនួនពីអង្កេតមុនៗ ដោយបញ្ចូលលម្អិតបន្ថែមអំពីការចំណាយប្រើប្រាស់លើមុខទំនិញម្ហូបអាហារ និងមិនមែនម្ហូបអាហារ។

អ្នកសម្ភាស និងអ្នកត្រួតពិនិត្យនៅតាមមូលដ្ឋានមណ្ឌលអង្កេត ត្រូវបានជ្រើសរើសចេញពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ មន្ទីរផែនការខេត្ត និងការិយាល័យស្ថិតិ សម្រាប់សម្ភាសន៍គ្រួសារសំណាកគំរូនៅក្នុងរាជធានីខេត្តទាំង២៥។ អ្នកសម្ភាសនិងអ្នកត្រួតពិនិត្យតាមមណ្ឌលអង្កេតមានពីរក្រុមដែលបានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល

ដប់ថ្ងៃដោយក្រុមទី១ ត្រូវបានបណ្តុះបណ្តាលនៅក្នុងខែមិថុនា ឆ្នាំ២០១៩ និងក្រុមទី២បានទទួលការបណ្តុះបណ្តាលនៅក្នុងខែមករា ឆ្នាំ២០២០ សម្រាប់ការចុះសម្ភាសន៍និងកត់ត្រាទិន្នន័យត្រូវបានធ្វើឡើងមានលក្ខណៈជារង្វិលកាលសម្រាប់រយៈពេល១២ខែ គឺចាប់ពីខែកក្កដា ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២០។

របាយការណ៍លទ្ធផលចុងក្រោយនៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានបង្ហាញនូវសូចនាករសំខាន់ៗចំនួនដប់ផ្នែក ដូចខាងក្រោម៖

**ផ្នែកប្រជាសាស្ត្រ៖** លទ្ធផលនៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បង្ហាញថាប្រជាជនកម្ពុជាមានចំនួនប្រមាណ ១៥,៩លាននាក់ ក្នុងនោះស្ត្រីចំនួនប្រមាណ ៨,២ លាននាក់ ចំណែកបុរសមានចំនួន៧,៨ លាននាក់ និងមានផលធៀបអនុបាតភេទស្មើ៩៤,៩។ គ្រួសារសរុបដែលរស់នៅកម្ពុជាមានចំនួនប្រមាណ៣,៦ លានគ្រួសារ។ ក្នុងចំណោមគ្រួសារទាំងនេះមាន១,៤លានគ្រួសារ រស់នៅតំបន់ទីប្រជុំជន។

**ផ្នែកស្ថានភាពលំនៅដ្ឋាន៖** ផ្អែកទិន្នន័យអង្កេតនៅក្នុងឆ្នាំ២០១៩/២០ ឃើញថាគ្រួសារកម្ពុជាមានលំនៅដ្ឋានដែលជាកម្មសិទ្ធកាន់កាប់ផ្ទាល់ខ្លួនប្រមាណ៩២ភាគរយ។ នៅក្នុងឆ្នាំ២០១៩/២០នេះ ក៏បានសង្កេតឃើញថា គ្រួសារកម្ពុជាទទួលបានទឹកបរិភោគដែលបានកែលំអ គឺមានប្រមាណ ៧៩,៧ ភាគរយ នៅទូទាំងប្រទេស។ ចំពោះគ្រួសារដែលទទួលបានការប្រើប្រាស់បង្គន់ដែលបានកែលំអ គឺមានប្រមាណ ៨០,៤ ភាគរយនៅទូទាំងប្រទេស។ ទិន្នន័យអង្កេត ក៏បានបង្ហាញអំពីគ្រួសារដែលប្រើប្រាស់សម្ភារលាងសម្អាតដៃមានប្រមាណ៨៩ភាគរយ ហើយនិងគ្រួសារដែលប្រើប្រាស់ចរន្តអគ្គិសនីសាធារណៈមានប្រមាណ៨៥,៧ភាគរយ។

**ផ្នែកកសិកម្ម៖** ផ្អែកលើលទ្ធផលអង្កេតបានបង្ហាញថា ១១,៧ភាគរយនៃដីកសិកម្ម ត្រូវបានកាន់កាប់ដោយមេគ្រួសារជាស្ត្រី និងមាន ៨៨,៣ភាគរយទៀត ត្រូវបានកាន់កាប់ដោយមេគ្រួសារជាបុរស។ ទិន្នផលដំណាំជាចម្បងនៅកម្ពុជានៅក្នុងឆ្នាំ២០១៩/២០ ទី១គឺដំណាំធញ្ញជាតិដែលមានប្រមាណ ៦៩,២ ភាគរយ ទី២គឺដំណាំហូបផ្លែដែលមានប្រមាណ៩,៧ភាគរយ និងទី៣ គឺដំណាំមើមដែលមានប្រមាណ៨,១ភាគរយ។ តម្លៃបន្ថែមនៃផលដំណាំដាំដុះមានប្រមាណ៤៥ភាគរយនៃទិន្នផលសរុប ខណៈដែលការចំណាយផលិតកម្មមានប្រមាណ ៥៤,៣ភាគរយ។

**ផ្នែកការសិក្សាអប់រំ៖** នៅក្នុងឆ្នាំ២០១៩/២០ អត្រាអក្ខរកម្មនៃប្រជាជនដែលមានអាយុចាប់ពី៦ឆ្នាំឡើងគឺមានប្រមាណ ៨០,៧ ភាគរយ (ទាំងពីរភេទ) ស្ត្រីមានចំនួនប្រមាណ៧៧,៣ភាគរយ និងបុរសមានប្រមាណ៨៤,៤ ភាគរយ។ កុមារកម្ពុជាដែលមានអាយុពី៦ ដល់១៤ឆ្នាំ បានចូលរៀននៅសាលាក្នុងកំលុងឆ្នាំ២០១៩/២០ មានប្រមាណ៩៣ភាគរយ។ ផ្អែកទិន្នន័យអង្កេតបានបង្ហាញថា ប្រជាជនកម្ពុជាដែលបានទទួលការអប់រំភាគច្រើន គឺមានការសិក្សាអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាមានប្រមាណ ៧៧,៤ភាគរយ និងនៅកម្រិតមធ្យមសិក្សាបច្ចេកទេសឬសញ្ញាបត្រមានតម្លៃស្មើ ប្រមាណ ១០,៨ ភាគរយ ចំណែកនៅកម្រិតសិក្សាអប់រំជំនាញឯកទេសថ្នាក់កម្រិតខ្ពស់ គឺមានប្រមាណ ៥,៩ភាគរយ នៃចំនួនប្រជាជនដែលទទួលបានការសិក្សាអប់រំ។

**ផ្នែកកម្លាំងពលកម្ម៖** កម្លាំងពលកម្មដែលមានអាយុពី១៥ ដល់៦៤ឆ្នាំនៅកម្ពុជា គឺមានប្រមាណ ៩,០ លាននាក់នៅក្នុងកំលុងឆ្នាំ២០១៩/២០។ អត្រាចូលរួមក្នុងកម្លាំងពលកម្ម (កម្លាំងពលកម្មទាក់ទងនឹងប្រជាជនដែលគ្រប់អាយុធ្វើការងារ) ជាទូទៅមានប្រមាណ៨៧,៤ភាគរយ ដែលក្នុងនោះប្រមាណ៨៤ភាគរយសម្រាប់ស្ត្រី និងមាន៩១ភាគរយសម្រាប់បុរស។ ក្នុងការគណនាវាស់វែងអត្រានិកម្មភាពនៃលទ្ធផលទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ត្រូវបានធ្វើបច្ចុប្បន្នភាពដោយផ្អែកតាមវិធីសាស្ត្រ និងនិយមន័យនៃការវាស់វែងកម្លាំងពលកម្មរបស់អង្គការអន្តរជាតិខាងការងារ (ILO) បានបង្ហាញថាអត្រានិកម្មភាពមានប្រមាណ ២,៤ ភាគរយនៅក្នុងឆ្នាំ២០១៩/២០។ ចំនួនអ្នកចូលរួមការងារដែលមានអាយុពី១៥ ដល់៦៤ឆ្នាំនៅកម្ពុជាគឺមានចំនួន៨,៨លាន

នាក់ ដែលក្នុងនោះកម្លាំងពលកម្មស្ថិតនៅក្នុងវិស័យសេដ្ឋកិច្ចចម្បង គឺវិស័យកសិកម្ម (៣៥,៥ភាគរយ) វិស័យឧស្សាហកម្ម(២៦,១ភាគរយ) និងវិស័យសេវាកម្ម(៣៨,៤ភាគរយ)។

**ផ្នែកសុខភាពនិងជនមានពិការភាព៖** លទ្ធផលទិន្នន័យអង្កេត បានបង្ហាញថាជនមានជម្ងឺក្នុងរយៈពេល៣០ថ្ងៃកន្លងមកមាន១៦ភាគរយនៃប្រជាជនទាំងអស់ ក្នុងនោះមានស្ត្រី ១៩ភាគរយ និងបុរស ១៣ភាគរយ។ ករណីមានជម្ងឺជាក់លាក់មានចំនួន២,៥លាននាក់ដែលមានបញ្ហាសុខភាពក្នុងអំឡុងពេល៣០ថ្ងៃកន្លងមកត្រឹមថ្ងៃសម្ភាសន៍។ អ្នកជម្ងឺនៅទីជនបទមានអត្រាខ្ពស់ជាងនៅរាជធានីភ្នំពេញ និងទីប្រជុំជន។ ផ្អែកតាមលទ្ធផលអង្កេតបង្ហាញថាជនមានពិការភាពមានប្រមាណ៤ភាគរយ (ប្រហែល ៧២២ ៦៤៣នាក់) នៃចំនួនប្រជាជនសរុប។ ផ្អែកតាមលទ្ធផលអង្កេតក៏បង្ហាញថាស្ត្រីដែលមានកូនបានប្រើប្រាស់សេវាថែទាំ ក្នុងអំឡុងពេលមានផ្ទៃពោះ សម្រាប់ការសម្រាលកូននាពេលថ្មីៗមានប្រមាណ៨២ ភាគរយ។ បំណែងចែកភាគរយក្នុងចំណោមកុមារតូចដែលកើតចុងក្រោយអាយុពី០ដល់២៣ខែ មានប្រមាណ៩៤,២ ភាគរយ ដែលបាន ទទួលការបំបៅទឹកដោះម្តាយនៅពេលដំបូង ហើយនិងក្នុងចំណោមកុមារតូចដែលមានអាយុពី០ ដល់ ២៣ខែ បានចាក់វ៉ាក់សាំងការពារមានប្រមាណ៩៨ភាគរយ។ ចំណែកកុមារតូចដែលស្ថិតនៅតំបន់ជនបទ បានទទួលការចាក់វ៉ាក់សាំងប្រមាណជាង ៩៨ភាគរយ នៅក្នុងឆ្នាំ២០១៩/២០។

**ផ្នែកការទទួលរងគ្រោះ៖** នៅក្នុងឆ្នាំ២០១៩/២០ ភាគរយនៃគ្រួសារ ដែលទទួលរងគ្រោះដោយសារចោរលួច លបចូលលួច ឬប្លន់ នៅក្នុងរយៈពេល១២ ខែកន្លងមក មានចំនួន ៩ ភាគរយ អំពើហិង្សាក្នុងគ្រួសារចំនួន១ភាគរយ និងគ្រោះថ្នាក់ចំនួន ៤ភាគរយ។ ដូចបានសង្កេតនៅក្នុងលទ្ធផលអង្កេតមានអំពើហិង្សាប្រាំប្រភេទដែលសមាជិកគ្រួសារជួបប្រទះគឺ ការរុញ ច្រាន គ្រវី ឬគប់អ្វីមួយទៅលើជនរងគ្រោះមានចំនួន១៤,៧ភាគរយ ការប្រើដៃដើម្បីទះ/ប្រើដំបងវាយដំមានចំនួន១៤,៤ភាគរយ និងការប្រើកណ្តាប់ដៃ ឬរបស់អ្វីមួយដូចជាកាំបិត ឬសព្វាវុធ មានប្រមាណ៦៨,០ភាគរយ គួរឱ្យកត់សំគាល់នៅក្នុងឆ្នាំ២០១៩/២០។

**ចំណូលនិងឥណទាន(បំណុល)គ្រួសារ៖** ផ្អែកតាមលទ្ធផលទិន្នន័យអង្កេតបានបង្ហាញថាចំណូលប្រចាំខែក្នុងមួយគ្រួសារនៅកម្ពុជាក្នុងឆ្នាំ២០១៩/២០ បានមកពីប្រភពសំខាន់ៗផ្សេងៗគ្នា ដែលក្នុងនោះមាន ៩១,៣ភាគរយនៃចំណូលបានពីចំណូលសកម្មភាពចម្បង ដែលរួមមាន ៥៤,៨ភាគរយ បានពីប្រាក់ឈ្នួល និងបៀវត្សរ៍ ហើយនិង៣៦,៤ភាគរយបានពីការងារដែលប្រើប្រាស់ទុនផ្ទាល់ខ្លួន (ដូចជាចំណូលពីកសិកម្ម ចំណូលមិនមែនកសិកម្ម ផ្ទះជួលឱ្យគេ) ៨,៧ភាគរយបានពីប្រាក់ចំណូលបង្វែរចន្ត និងចំណូលពីការវិនិយោគមូលធនមានតិចជាង១ភាគរយ។

**ផ្នែកចំណាយប្រើប្រាស់របស់គ្រួសារ៖** ការចំណាយរបស់គ្រួសារនៅកម្ពុជានៅក្នុងឆ្នាំ២០១៩/២០ ត្រូវបានគណនាដោយប្រើទិន្នន័យរំលឹកឡើងវិញពីបញ្ជីសំណួរគ្រួសារ។ ដូចបានសង្កេតចេញពីលទ្ធផលម្ហូបអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹង ដែលគ្រួសារបានចំណាយមានចំណែកច្រើនជាងគេស្មើនឹង ៤៣,៦ភាគរយ ហើយចំណាយបន្ទាប់គឺលំនៅដ្ឋាន ទឹក ភ្លើង និងឥន្ធនៈផ្សេងទៀត ដែលមានចំណែកស្មើនឹង២៤,៨ភាគរយ ចំណែកមុខចំណាយលើសុខភាពមាន ៥,៩ភាគរយ ចំណាយលើការដឹកជញ្ជូននិងគមនាគមន៍មាន ១២,៣ភាគរយ និងការចំណាយលើសិក្សាអប់រំមាន ២,១ភាគរយ និងចំណាយលើមុខទំនិញមិនមែនម្ហូបអាហារផ្សេងៗមាន ១១,៣ភាគរយ។

**ផ្នែកការប្រើប្រាស់ស្បៀងអាហាររបស់គ្រួសារ៖** ការប្រើប្រាស់ម្ហូបអាហារសម្រាប់រយៈពេល៧ថ្ងៃកន្លងមករបស់គ្រួសារកម្ពុជា គឺមានលក្ខណៈញឹកញាប់លើមុខទំនិញគ្រាប់ធញ្ញជាតិ។ ចំណែកករណីសួរអំពីយុទ្ធសាស្ត្រដោះស្រាយនៃការប្រើប្រាស់ម្ហូបអាហារក្នុងអំឡុងពេល៧ថ្ងៃគិតមកត្រឹមថ្ងៃសម្ភាសន៍ គឺមានប្រមាណ២ភាគរយសម្រាប់ម្ហូបអាហារដែលមានថ្លៃទាប និងមានចំណូលចិត្តតិចតួច។ គ្រួសារនៅទីជនបទបានប្រើប្រាស់ម្ហូបអាហារដែលមានតម្លៃទាបហើយនិងមានចំណូលចិត្តតិចតួច គឺមានច្រើនជាងគ្រួសាររស់នៅរាជធានីភ្នំពេញ និងទីប្រជុំជន។ គ្រួសារបានប្រើវិធីក្នុងការខ្ចីស្បៀងអាហារពីមិត្តភក្តិ ឬសាច់ញាតិ (១,២ភាគរយ) និងការបន្ថយទំហំនៃចំណែកប្រើប្រាស់ស្បៀងអាហារមានប្រមាណ ០,៧ភាគរយ។៚

# ផ្នែកទី១ សេចក្ដីផ្ដើម

## ១.១ សេចក្ដីផ្ដើម

ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ឬហៅកាត់ថា "អសសក(CSES)" គឺជាដំណើរការអង្កេតសម្ភាសន៍កត់ត្រាព័ត៌មានទិន្នន័យគ្រួសារកម្ពុជាដែលមានទំហំសំណាកគំរូធំជាងដប់ពាន់គ្រួសារ ដែលត្រូវបានជ្រើសរើសតាមវិធីសាស្ត្រស្ថិតិដោយចៃដន្យ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំង២៥ រាជធានី ខេត្ត។ ការសម្ភាសគ្រួសារ ត្រូវបានប្រើប្រាស់តារាងសំណួរ-ចម្លើយ សម្រាប់សួរសម្ភាសន៍ដល់សមាជិកគ្រួសារអំពីប្រជាសាស្ត្រ ស្ថានភាពលំនៅដ្ឋាន ការសិក្សាអប់រំ សកម្មភាពសេដ្ឋកិច្ច(កម្លាំងពលកម្ម ផលិតកម្មកសិកម្ម ឧស្សាហកម្ម សេវាកម្ម) ចំណូលនិងបំណុលគ្រួសារ ការចំណាយប្រើប្រាស់ម្ហូបអាហារ និងមិនមែនម្ហូបអាហារ និងសម្ភារប្រើប្រាស់បានយូររបស់គ្រួសារ ស្ថានភាពសុខភាព ការទទួលរងគ្រោះផ្សេងៗ និងភាពងាយរងគ្រោះស្បៀងអាហារ ជាដើម។

ចាប់តាំងពីឆ្នាំ១៩៩៣មក អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាត្រូវបានរៀបចំធ្វើឡើងចំនួន១៧លើករួចមកហើយ។ ដំណើរការអង្កេតនេះ ត្រូវបានធ្វើជាលើកដំបូងនៅក្នុងឆ្នាំ១៩៩៣ បន្ទាប់ពីមានការបោះឆ្នោតថ្នាក់ជាតិ ហើយបានបន្តធ្វើនៅក្នុងឆ្នាំ១៩៩៦ ១៩៩៧ ១៩៩៩ និងឆ្នាំ២០០៤ ដែលមានការគាំទ្រមូលនិធិពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (ឬហៅថា UNDP) និងមានស្ថិតិស៊ុយអែតបានជួយទៅលើផ្នែកបច្ចេកទេស។ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានដំណើរការធ្វើជារៀងរាល់ឆ្នាំ ដោយមានការផ្ដល់មូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត(ឬហៅថា SIDA)ចាប់ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១៧។

ទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា មានសូចនាករពហុវិស័យសំខាន់ៗ អំពីលក្ខណៈស្ថានភាពជីវភាពរស់នៅរបស់ប្រជារាស្ត្រកម្ពុជាដែលទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច បរិស្ថាន និងសង្គមកិច្ច។ សូចនាករទាំងនេះសម្រាប់ជាមូលដ្ឋានគ្រឹះធាតុចូលដ៏សំខាន់ក្នុងការវាស់វែង តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) របស់រាជរដ្ឋាភិបាលកម្ពុជា គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(កន្លងមក) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ លើសពីនេះ ទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាជាធាតុចូលក្នុងការបង្កើតចេញនូវគោលនយោបាយដ៏មានប្រសិទ្ធភាព សម្រាប់ការកាត់បន្ថយ និងលុបបំបាត់ភាពក្រីក្រនៅកម្ពុជា គណនាកំណើនសេដ្ឋកិច្ច(គណនេយ្យជាតិ) វិភាគសន្តិសុខស្បៀងអាហារ វិភាគគណនេយ្យជាតិនៃការផ្លាស់ប្ដូរសេដ្ឋកិច្ចតាមវ័យ វដ្ដជីវិតសេដ្ឋកិច្ច និងភាគលាភប្រជាសាស្ត្រ។ អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយក្រៅពីរាជរដ្ឋាភិបាលកម្ពុជាមានដូចជាអ្នកស្រាវជ្រាវ អ្នកវិភាគ និងអង្គការក្រៅរដ្ឋាភិបាលនានា ក៏អាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលអង្កេតនេះ ក្នុងការស្វែងយល់ឱ្យបានកាន់តែប្រសើរថែមទៀត អំពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនៅកម្ពុជាផងដែរ។

សំណុំទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានរក្សាសិទ្ធិដោយវិទ្យាស្ថានជាតិស្ថិតិ សម្រាប់ដាក់បម្រើជូនដល់អ្នកវិភាគ និងអ្នកស្រាវជ្រាវនានា មកពីមជ្ឈដ្ឋានខាងក្រៅផងដែរ។ សំណួរស្រាវជ្រាវអាចមានច្រើននៅក្នុងទិន្នន័យអង្កេត។ វិទ្យាស្ថានជាតិស្ថិតិទទួលស្វាគមន៍ដល់ការស្រាវជ្រាវថ្មីៗ ដោយផ្អែកលើទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា។ ក្រៅពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺនៅមានជំរឿន និងអង្កេតគ្រួសារជាច្រើនទៀតដែលបានធ្វើឡើង ដោយវិទ្យាស្ថានជាតិស្ថិតិនៅក្នុងកំលុងពេលជាង២០ឆ្នាំចុងក្រោយនេះ មានដូចជា

ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ ២០០៨ និងឆ្នាំ២០១៩ ជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១១ អង្កេតចន្លោះជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៤ អង្កេតចន្លោះជំរឿនប្រជាពលរដ្ឋកម្ពុជាឆ្នាំ២០០៤ និងនៅឆ្នាំ២០១៣ ជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៣ អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០០០ ២០០៥ ២០១០ និងឆ្នាំ២០១៤ ជាដើម។

ការវិភាគទិន្នន័យរួមទាំងការផ្តល់មតិយោបល់អំពីលទ្ធផលអង្កេត គឺត្រូវបានរៀបចំដោយក្រុមមន្ត្រីជំនាញតាមប្រធានបទនីមួយៗរបស់វិទ្យាស្ថានជាតិស្ថិតិ ដោយមានកិច្ចសហការ និងការណែនាំលើផ្នែកបច្ចេកទេសពីអ្នកជំនាញការទីប្រឹក្សារយៈពេលខ្លីមកពីស្ថិតិស៊ុយអែត និងទីប្រឹក្សារបស់ធនាគារពិភពលោក។

## ១.២. គោលបំណងនៃការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា

គោលបំណងសំខាន់ នៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺប្រមូលទិនន្ន័យព័ត៌មានអំពីលក្ខណៈស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ដែលទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច បរិស្ថាន និងសង្គមកិច្ច សម្រាប់ជាធាតុចូលដ៏សំខាន់ក្នុងការវាស់វែង តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីវឌ្ឍនភាពអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ)របស់រាជរដ្ឋាភិបាលកម្ពុជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ គោលនយោបាយកាត់បន្ថយនិងលុបបំបាត់ភាពក្រីក្រនៅកម្ពុជា គណនាកំណើនសេដ្ឋកិច្ច(គណនេយ្យជាតិ) និងសូចនាករសេដ្ឋកិច្ចសង្គមកិច្ចផ្សេងៗទៀត ដូចជាវិភាគសន្តិសុខស្បៀងអាហារ វិភាគគណនេយ្យជាតិនៃការបង្វែរផ្ទេរសេដ្ឋកិច្ចតាមវ័យវដ្តជីវិតសេដ្ឋកិច្ច និងភាគលាភប្រជាសាស្ត្រ។ អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយក្រៅពីរាជរដ្ឋាភិបាលកម្ពុជា មានដូចជាអ្នកស្រាវជ្រាវ អ្នកវិភាគ ដូចជាធនាគារពិភពលោក និងអង្គការក្រៅរដ្ឋាភិបាលនានា ក៏អាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលអង្កេតនេះ ក្នុងការស្វែងយល់ឱ្យបានកាន់តែប្រសើរថែមទៀត អំពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចនៅកម្ពុជាផងដែរ។ ធនាគារពិភពលោកបានប្រើប្រាស់ទិន្នន័យអង្កេតសម្រាប់ការវិភាគភាពក្រីក្រនៅកម្ពុជា និងសូចនាករសង្គមកិច្ច។ ក្នុងន័យនេះ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ នៅតែជាឧបករណ៍ដ៏សំខាន់បំផុតក្នុងការបន្តគាំទ្រដល់អ្នកប្រើប្រាស់ពាក់ព័ន្ធ។

## ១.៣ ព័ត៌មានបន្ថែមសម្រាប់អ្នកអាន

គ្រប់អង្កេតស្ថិតិទាំងអស់តែងតែមានភាពលម្អៀង ហើយក្នុងករណីភាគច្រើនលទ្ធផលប៉ាន់ស្មានពីការធ្វើអង្កេត គឺមិនមែនសុទ្ធសឹងតែជាតម្លៃពិតប្រាកដជាក់លាក់គ្រប់ចំណុចដៅទាំងអស់នោះទេ។ ប៉ុន្តែបើសិនមានការរៀបចំ និងដំណើរការប្រព្រឹត្តទៅនៃអង្កេតល្អឥតខ្ចោះដោយគ្របដណ្តប់លើប្រជាជនទាំងមូលដែលមិនមែនជាសំណាកគំរូនោះ ការប៉ាន់ស្មាននៃលទ្ធផលអង្កេតអាចឈានទៅដល់តម្លៃពិតប្រាកដជាក់លាក់បាន។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការអង្កេតមិនអាចមានភាពល្អឥតខ្ចោះនោះទេ ពីព្រោះគេមិនអាចជ្រើសរើសយកប្រជាជនទាំងអស់មកធ្វើការសម្ភាសន៍ទាំងស្រុងបាន លើកលែងតែការធ្វើជំរឿនប្រជាពលរដ្ឋប៉ុណ្ណោះ។ ដូច្នេះហើយបានជាការប៉ាន់ស្មាននៃលទ្ធផលអង្កេតតែងតែមានភាពមិនពិតប្រាកដ។ ភាពលម្អៀងមានច្រើនប្រភេទដែលកើតឡើងនៅក្នុងដំណើរការធ្វើអង្កេត ឧទាហរណ៍ដូចជា ភាពលម្អៀងលើផ្នែកវាស់វែង ភាពលម្អៀងលើវិសាលភាពគ្របដណ្តប់ និងការមិនឆ្លើយតប ភាពលម្អៀងលើប្រព្រឹត្តិកម្មទិន្នន័យ ហើយនៅក្នុងអង្កេតសំណាកគំរូក៏មានភាពលម្អៀងនៃការជ្រើសរើសសំណាកគំរូផងដែរ។ ដូច្នេះនៅពេលរៀបចំដំណើរការធ្វើអង្កេតមានសារៈសំខាន់ណាស់ក្នុង

ការត្រួតពិនិត្យមើលរាល់កម្រិតនៃភាពលម្អៀងទាំងអស់នោះ ដើម្បីធ្វើឱ្យការគណនាប៉ាន់ស្មាននៃលទ្ធផលអង្កេតទទួលបានភាពត្រឹមត្រូវ ជឿជាក់ប្រកបដោយគុណភាពខ្ពស់។

វិទ្យាស្ថានជាតិស្ថិតិ ក៏បានខិតខំព្យាយាមយ៉ាងខ្លាំងក្នុងការកាត់បន្ថយនូវរាល់កម្រិតនៃភាពលម្អៀងទាំងនេះ ដោយផ្តល់ការពន្យល់ណែនាំដល់អ្នកអានទាំងឡាយឱ្យយល់ដឹងអំពីភាពមិនពិតប្រាកដនៃការប៉ាន់ស្មានលើលទ្ធផលអង្កេត។ ភាពលម្អៀងស្តង់ដារនៃការប៉ាន់ស្មាន គឺជាវិធីវាស់វែងនៃភាពមិនពិតប្រាកដ។ ការពិភាក្សាលើគុណភាពនៃការប៉ាន់ស្មានពីលទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានបង្ហាញជូននៅក្នុងចំណុចទី១.៦បង្ហាញអំពីគុណភាពនៃការប៉ាន់ស្មានលទ្ធផលពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា។

ដោយសារលទ្ធផលនៅក្នុងរបាយការណ៍នេះ គឺជាតម្លៃប៉ាន់ស្មាន រាល់ភាគរយ និងចំនួនទាំងអស់ គឺត្រូវបានបង្គ្រប់។ ចំនួនត្រូវបានបង្គ្រប់ទៅក្បែរខ្ទង់រយ/ខ្ទង់ពាន់ រីឯភាគរយវិញបង្គ្រប់ក្បែរលេខទសភាគ១ខ្ទង់។ ភាគច្រើនភាគរយដែលបានគណនាពីទិន្នន័យដើមត្រូវបានបង្គ្រប់ ជាហេតុធ្វើឱ្យមានលក្ខណៈខុសគ្នាបន្តិច។ តួលេខ "០,០" (សូន្យក្បៀសសូន្យ) មានន័យថាការប៉ាន់ស្មានដែលបានគណនាមានតម្លៃតិចជាង០,០៥។ ម៉្យាងទៀតតួលេខនៅក្នុងតារាងមួយចំនួនដែលបង្ហាញជាភាគរយ ពេលសរុបបញ្ចូលគ្នាទៅមិនគ្រប់១០០ភាគរយទេ។ នៅក្នុងតារាងខ្លះទៀតនិមិត្តសញ្ញា (-) ត្រូវបានប្រើជំនួសឱ្យការសង្កេតដែលមានតួលេខតិចតួចបំផុត ឬក៏គ្មានតួលេខសោះ។ ក្នុងដំណើរការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺមានការផ្លាស់ប្តូរសំណួរខ្លះ ជាពិសេសសំណួរលម្អិតផ្នែកការចំណាយប្រើប្រាស់មុខទំនិញម្ហូបអាហារ និងមិនមែនម្ហូបអាហារ និងមានការកែសម្រួលសំណួរតិចតួចលើផ្នែកសកម្មភាពសេដ្ឋកិច្ច (កម្លាំងពលកម្ម) និងសុខភាព បើសិនជាធ្វើការប្រៀបធៀបទៅនឹងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៧ និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាមុនៗ។

## ១.៤ ការរៀបចំ និង ការធ្វើផែនការអង្កេត

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ បានបង្កើតក្រុមការងារអនុវត្តគម្រោងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាចាប់តាំងពីឆ្នាំ២០០៦ សម្រាប់ដំណើរការរៀបចំអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ហើយចាប់តាំងពីពេលនោះមកក្រុមការងារនេះបាននិងកំពុងរៀបចំធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ រហូតដល់ ឆ្នាំ២០១៩/២០។ ក្រុមការងារដឹកនាំគម្រោងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានសមាជិកចំនួន៦នាក់ ដែលមានភារកិច្ចទទួលខុសត្រូវលើការរៀបចំធ្វើផែនការ និងរាល់ដំណើរការនៃសកម្មភាពអង្កេតតាមដំណាក់កាលនីមួយៗដែលបានគ្រោងទុក រួមទាំងការងារចុះត្រួតពិនិត្យមើលការប្រមូលទិន្នន័យនៅតាមមូលដ្ឋាន ការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានាដើម្បីពិគ្រោះយោបល់ជាមួយដៃគូរ និងអ្នកពាក់ព័ន្ធទាំងឡាយលើការរៀបចំតារាងសំណួរ ការវិភាគទិន្នន័យ ការផ្សព្វផ្សាយលទ្ធផលអង្កេត និងការរៀបចំសរសេររបាយការណ៍ជូនគណៈកម្មាធិការប្រឹក្សាស្ថិតិ។ល។ លើសពីនេះទៀត ក្រុមការងារដឹកនាំគម្រោងក៏ទទួលខុសត្រូវផងដែរ ចំពោះការវិភាជន៍លើការប្រើប្រាស់ថវិកា និងការដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលកើតមានឡើងនៅក្នុងអំឡុងពេលប្រតិបត្តិការអង្កេត។
ក្រៅពីក្រុមការងារដឹកនាំគម្រោង ក៏មានមន្ត្រីវិភាគ និងសរសេររបាយការណ៍តាមប្រធានបទចំនួន៣៣នាក់ មន្ត្រីប្រព្រឹត្តកម្មទិន្នន័យចំនួន២៧នាក់ មន្ត្រីបច្ចេកវិទ្យាព័ត៌មានវិទ្យា និងការផ្សព្វផ្សាយទិន្នន័យចំនួន៣នាក់ និងមន្ត្រីគ្រប់គ្រងធនធានមនុស្ស និងការសម្របសម្រួលចំនួន៤នាក់ ដែលបានចូលរួមក្នុងដំណើរការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០។

ចំពោះការងារចុះប្រមូលទិន្នន័យនៅតាមមូលដ្ឋានដែលជាផ្នែកមួយដ៏សំខាន់ក្នុងដំណើរការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០។ វិទ្យាស្ថានជាតិស្ថិតិបានជ្រើសរើសមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យដែលធ្លាប់មានបទពិសោធន៍ក្នុងការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជានាពេលមុនៗ ការធ្វើជំរឿន និងអង្កេតគំរូផ្សេងៗទៀតសម្រាប់អនុវត្តអង្កេតនៅឆ្នាំ២០១៩/២០។ ការជ្រើសរើសមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ គឺត្រូវបានធ្វើឡើងនៅចុងឆ្នាំ២០១៨ ដើម្បីឱ្យចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់ចុះប្រមូលទិន្នន័យ។ មន្ត្រីសម្ភាសន៍និងមន្ត្រីត្រួតពិនិត្យ ត្រូវបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រមូលទិន្នន័យផងដែរ។ មន្ត្រីត្រៀមបម្រុងមួយចំនួនក៏ត្រូវបានទទួលការបណ្តុះបណ្តាលក្នុងវគ្គនេះ សម្រាប់ធ្វើការជំនួសអ្នកសុំលាលែងដោយប្រការណាមួយក្នុងអំឡុងពេលប្រតិបត្តិការអង្កេត។

## ១.៥ ការជ្រើសរើសសំណាកគំរូ និងការប៉ាន់ស្មាន

ផ្នែកពិពណ៌នាអំពីគ្រោងការនៃការជ្រើសរើសសំណាកគំរូ និងការជ្រើសរើសសំណាកគំរូសម្រាប់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០។ ជាទូទៅ ការសម្រេចចិត្តពាក់ព័ន្ធនឹងគ្រោងការនៃការជ្រើសរើសសំណាកគំរូត្រូវបានធ្វើឡើងតាមគោលការណ៍បីសំខាន់ៗរួមមាន៖ ក).ភាពដែលអាចប្រៀបធៀបជាមួយនឹងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៧-២០១៧។ ខ). សុខដុមនីយកម្មជាមួយនឹងអង្កេតផ្សេងៗទៀតដែលបានធ្វើនៅកម្ពុជាដោយផ្អែកលើគ្រោងនៃបញ្ជីភូមិតាមតំបន់ និងក្រុម។ គ).តម្រូវឱ្យមានភាពត្រឹមត្រូវលើការប៉ាន់ស្មាននៃអថេរសំខាន់ៗស្របទៅតាមការកម្រិតនៃថវិកាចំណាយសម្រាប់ការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាទ្រង់ទ្រាយធំ។ គោលការណ៍ចុងក្រោយនៃការសម្រេចចិត្តនេះ គឺជាចំណុចគន្លឹះមួយដែលនឹងមានផលប៉ះពាល់យ៉ាងខ្លាំងផងដែរទៅលើការរៀបចំធ្វើអង្កេតជាទូទៅ ជាពិសេសការបញ្ចូលឡើងវិញនូវតារាងសំណួរកំណត់ត្រាព័ត៌មានប្រចាំថ្ងៃ ការបង្កើតក៏ដូចជាការពង្រីកនូវផ្នែកខ្លះៗ ហើយក៏មានការកាត់បន្ថយផ្នែកមួយចំនួនផងដែរ នៅក្នុងតារាងសំណួរគ្រួសារ។

### ១.៥.១ សកលគោលដៅ និងបញ្ជីសម្រាប់ជ្រើសរើសសំណាកគំរូភូមិ

សកលគោលដៅនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា រួមមាន៖

- ភូមិទាំងអស់នៅក្នុងប្រទេសកម្ពុជា (សម្រាប់អង្កេតសំណាកគំរូភូមិ)។
- គ្រួសារធម្មតាទាំងអស់នៅក្នុងប្រទេសកម្ពុជា(សម្រាប់អង្កេតសំណាកគំរូគ្រួសារ)។ គ្រួសារធម្មតា គឺជាគ្រួសារដែលមិនមែនជាគ្រួសារស្ថាប័ន មិនមែនជាគ្រួសារគ្មានផ្ទះសម្បែង មិនមែនជាគ្រួសាររស់នៅលើទូក ឬក៏គ្រួសារដែលគ្រាន់តែឆ្លងកាត់បណ្តោះអាសន្ន។ (គ្រួសារស្ថាប័នរួមមាន៖ លំនៅដ្ឋាន ឬផ្ទះជួលមានបម្រើម្ហូបអាហារ បន្ទាយទាហាន ពន្ធនាគារ អន្តេវាសិកដ្ឋានរបស់សិស្ស និងនិស្សិត ។ល។)
- មនុស្សទាំងអស់ដែលរស់នៅក្នុងគ្រួសារធម្មតានៅក្នុងប្រទេសកម្ពុជា (សម្រាប់អង្កេតសំណាកគំរូគ្រួសារ)។
- ផ្នែក ឬសកលរងនៃសកលស្ថិតិខាងលើ។

បញ្ជីសម្រាប់ជ្រើសរើសសំណាកគំរូ(sampling frame) គឺជាបញ្ជីឈ្មោះភូមិទូទាំងប្រទេសដោយមានបែងចែកជាមណ្ឌលជំរឿន (EA) ដែលបានរៀបចំចងក្រងសម្រាប់ការធ្វើជំរឿនប្រជាជនទូទៅនៅកម្ពុជាឆ្នាំ២០១៩។ ឯកតានៃការចុះបញ្ជីទាំងឡាយ គឺជាភូមិ។ ក្នុងភូមិនីមួយៗ មាននូវព័ត៌មានជាចំនួនគ្រួសារ និងចំនួនមណ្ឌលជំរឿនដោយមានព្រំប្រទល់របស់វានៅក្នុងផែនទីនៃភូមិនីមួយៗ ដែលត្រូវបានបង្កើតឡើងក្នុងប្រតិបត្តិការគូសផែនទីសម្រាប់ត្រៀមធ្វើជំរឿនប្រជាជនទូទៅនៅកម្ពុជាឆ្នាំ២០១៩។ បញ្ជីនេះក៏មានផងដែរនូវព័ត៌មានរដ្ឋបាលស្តីពីខេត្ត/

រាជធានី ស្រុក/ក្រុង/ខណ្ឌ ឃុំ/សង្កាត់ និងការបែងចែកជាតំបន់ទីប្រជុំជន និងជនបទនៃភូមិនីមួយៗ។ នៅក្នុងប្រតិបត្តិការគូសផែនទីសម្រាប់ត្រៀមធ្វើជំរឿនប្រជាជននេះ ព្រំប្រទល់ភូមិ ចំនួនមណ្ឌលជំរឿន និងចំនួនគ្រួសារក៏ត្រូវបានធ្វើបច្ចុប្បន្នភាពផងដែរ។ ការគូសផែនទីសម្រាប់ត្រៀមធ្វើជំរឿនប្រជាជនទូទៅនៅកម្ពុជាឆ្នាំ២០១៩នេះ ត្រូវបានធ្វើនៅចុងឆ្នាំ២០១៧ ។

ភូមិទាំងឡាយ តំណាងឱ្យឯកតាសំណាកគំរូបឋម(PSUs) ដោយមានការលើកលែងខ្លះៗចំពោះភូមិធំៗមួយចំនួន(ភូមិដែលមានចំនួនគ្រួសារច្រើន)នៅក្នុងរាជធានីភ្នំពេញ ដែលត្រូវតំណាងឱ្យឯកតាសំណាកគំរូបឋមច្រើនជាងមួយ។ បញ្ជីសម្រាប់ជ្រើសរើសសំណាកគំរូភូមិនេះ ក៏មានព័ត៌មានបន្ថែមអំពីភូមិនីមួយៗ។ វាមាននូវអថេរដែលអាចត្រូវបានប្រើសម្រាប់ការបែងចែកជាផ្នែកៗមុនធ្វើការជ្រើសរើសសំណាកគំរូ ដូចជាព័ត៌មានអំពីទីតាំងនៃខេត្ត ថាជាតំបន់ទីប្រជុំជន ឬជនបទ។ បញ្ជីនេះ ក៏មានផងដែរនូវទំហំនៃភូមិទាំងឡាយ ជាចំនួនគ្រួសារនៅក្នុងភូមិ។ ចំនួនគ្រួសារនៅក្នុងភូមិនីមួយៗនេះ ត្រូវបានប្រើជារង្វាស់ទំហំនៅក្នុងការជ្រើសរើសសំណាកគំរូភូមិនៅក្នុងដំណាក់កាលទី១តាមវិធីសាស្ត្រប្រូបាបប៊ីលីតេសមាមាត្រទៅនឹងរង្វាស់ទំហំនៃភូមិជាលក្ខណៈប្រព័ន្ធ (ឬហៅកាត់ថា Systematic PPS)។

## ១.៥.២ ការបែងចែកបញ្ជីសំណាកគំរូជាក្រុមៗ និងការបែងចែកទំហំសំណាកគំរូទៅតាមក្រុមនីមួយៗ

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ អនុញ្ញាតឱ្យអាចធ្វើការប៉ាន់ស្មានស្ថិតិទៅតាមតំបន់ភូមិសាស្ត្រដែលមានកម្រិតទាបជាងកម្រិតថ្នាក់ជាតិ។ នៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ បញ្ជីសម្រាប់ជ្រើសរើសសំណាកគំរូ ត្រូវបានបែងចែកជា១៩ក្រុមខេត្ត/រាជធានី និងជាតំបន់ទីប្រជុំជន ឬជនបទ[1]។ ការបែងចែកនេះ បានផ្លាស់ប្តូរសម្រាប់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ដើម្បីអនុញ្ញាតឱ្យអាចធ្វើការប៉ាន់ស្មានស្ថិតិបានទៅតាមកម្រិតកាន់តែលម្អិតជាងមុន។ បញ្ជីសម្រាប់ជ្រើសរើសសំណាកគំរូ ត្រូវបានបែងចែកជា ២៤ខេត្ត និង១រាជធានី(ភ្នំពេញ) ជាមួយនឹងការបែងចែកបន្តជាតំបន់ទីប្រជុំជន និងជនបទ។ ការបែងចែកនេះ បង្កើតបានជា៤៩ក្រុម ឬស្រទាប់ ដោយសារ រាជធានីភ្នំពេញលែងមានតំបន់ជនបទ ហើយការជ្រើសរើសសំណាកគំរូ នឹងត្រូវបានធ្វើនៅក្នុងក្រុម ឬស្រទាប់នីមួយៗ ដោយឯករាជ្យពីគ្នា។

ការបែងចែកសំណាកគំរូសរុបក្នុងចំណោមក្រុម ឬស្រទាប់នីមួយៗ ត្រូវបានធ្វើក្នុងបីដំណាក់កាល។ នៅដំណាក់កាលទី១ សំណាកគំរូសរុបត្រូវបានបែងចែកទៅតាមខេត្តនីមួយៗ និងរាជធានីភ្នំពេញ ផ្អែកតាមវិធាននៃការបែងចែកតាមស្វ័យគុណ(power allocation)នៃចំនួនគ្រួសារនៅក្នុងខេត្ត/រាជធានីនីមួយៗ ជាមួយនឹងស្វ័យគុណ(q)ស្មើនឹង០,៦។ ទំនាក់ទំនងនេះបង្ហាញតាមរូបមន្ត: $n_h = n \cdot \frac{M_h^q}{\sum M_h^q}$ ដែល $M_h$ ជាចំនួនគ្រួសារក្នុងខេត្ត/រាជធានី $h$ ហើយ $n$ ជាចំនួនសំណាកគំរូសរុបដែលត្រូវជ្រើសរើសឯកតាសំណាកគំរូដំបូង(PSUs) និង $n_h$ ជាចំនួនសំណាកគំរូដែលត្រូវបែងចែកតាមខេត្ត/រាជធានី $h$។ មានការកែតម្រូវដោយដៃខ្លះទៅលើលទ្ធផលបឋមនៃចំនួនសំណាកគំរូដែលត្រូវបានបែងចែកតាមវិធានស្វ័យគុណខាងលើ ដើម្បីបង្កើនចំនួនសំណាកគំរូ រហូតដល់ចំនួន២០ភូមិ ចំពោះខេត្តណាដែលទទួលបានចំនួនសំណាកគំរូតិចជាង២០។ ដើម្បីរក្សាឱ្យបាននូវចំនួនសំណាកគំរូសរុប១.០០៨ យើងចាំបាច់ត្រូវកាត់បន្ថយចំនួនសំណាកគំរូនៅក្នុងខេត្ត ដែលទទួលបានចំនួនសំណាកគំរូច្រើន

[1] សម្រាប់ព័ត៌មានលម្អិតនៃគ្រោងការជ្រើសរើសសំណាកគំរូនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ សូមមើលរបាយការណ៍នៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ បន្ថែម។

ជាងគេ។ ជាលទ្ធផល ចំនួនសំណាកគំរូត្រូវបានបង្កើននៅក្នុងខេត្តចំនួន៤ និងកាត់បន្ថយវិញនៅក្នុងខេត្តចំនួន៧។ ចំនួនសំណាកគំរូសម្រាប់ខេត្តដែលតូចបំផុត(ខេត្តកែប)ពុំត្រូវបានកែតម្រូវឡើយ។

នៅក្នុងដំណាក់កាលទី២ ចំនួនសំណាកគំរូសម្រាប់ខេត្តទាំងនេះ ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនគ្រួសារនៅក្នុងតំបន់ទីប្រជុំជន និងជនបទនៅក្នុងខេត្តនីមួយៗ។ នៅក្នុងដំណាក់កាលទី៣ ការបែងចែកនៃចំនួនសំណាកគំរូរវាងតំបន់ទីប្រជុំជន និងជនបទ ត្រូវបានកែតម្រូវដើម្បីឱ្យតំបន់ទីប្រជុំជនទទួលបាននូវចំនួនសំណាកគំរូសរុបប្រមាណ៣០ភាគរយនៃចំនួនសំណាកគំរូសរុបទូទាំងប្រទេស។ ផ្អែកតាមបញ្ជីឈ្មោះភូមិទូទាំងប្រទេសដែលត្រូវបានប្រើដើម្បីរៀបចំជ្រើសរើសសំណាកគំរូនេះ ឃើញថាមានប្រមាណ២៤ភាគរយនៃគ្រួសារកម្ពុជាសរុបរស់នៅក្នុងភូមិដែលត្រូវបានចាត់ថ្នាក់ជាតំបន់ទីប្រជុំជន។ ដើម្បីធានាឱ្យមានសុក្រឹតភាពគ្រប់គ្រាន់ក្នុងការប៉ាន់ស្មានស្ថិតិ ដែលទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច និងធ្វើឱ្យការប៉ាន់ស្មានដទៃទៀតក្នុងតំបន់ទីប្រជុំជនកាន់តែមានសុក្រឹតភាពបន្ថែម ដូចដែលធ្លាប់បានធ្វើនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ច២០១៤ដែរ សំណាកគំរូប្រមាណ ៣០ភាគរយ (ឬ៣០២ភូមិ) នៃសំណាកគំរូសរុបចំនួន ១.០០៨ ត្រូវបានកែតម្រូវបែងចែកទៅក្នុងតំបន់ទីប្រជុំជន នៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០នេះ។

លើសពីនេះ តាមរយៈវិធីសាស្ត្រនៃការជ្រើសសំណាកគំរូ (ដែលនឹងត្រូវបានពិពណ៌នានៅក្នុងផ្នែកបន្ទាប់) បញ្ជីសម្រាប់ជ្រើសរើសសំណាកគំរូ ត្រូវបានបែងចែកជា៤៩បញ្ជីភូមិ ហើយនៅក្នុងបញ្ជីភូមិនីមួយៗ ក៏មានការរៀបជាលំដាប់កើនឡើងនៃភូមិទៅតាមលេខកូដទីតាំងភូមិសាស្ត្រនៅក្នុងខេត្តនីមួយៗ តាមរយៈលំដាប់នៃលេខកូដខ័ណ្ឌ/ស្រុក សង្កាត់/ឃុំ និងភូមិជាមុន ពីព្រោះដោយសារតែវិធីសាស្ត្រនៃការជ្រើសរើសសំណាកគំរូជាលក្ខណៈប្រព័ន្ធ(Systematic Sampling) នឹងត្រូវបានប្រើនៅពេលបន្ទាប់។ ការបែងចែកនៃចំនួនភូមិនៅក្នុងបញ្ជីភូមិ និងចំនួនសំណាកគំរូភូមិក្នុងខេត្តនីមួយៗ ត្រូវបានបង្ហាញដោយសង្ខេបនៅក្នុងតារាង១ខាងក្រោម៖

**តារាង១. ចំនួនភូមិសរុបក្នុងបញ្ជីភូមិ និងចំនួនសំណាកគំរូភូមិដែលត្រូវបានបែងចែកទៅតាមក្រុមនីមួយៗ**

| ឈ្មោះខេត្ត/រាជធានី | ចំនួនភូមិក្នុងបញ្ជីភូមិសរុប | | | ចំនួនសំណាកគំរូភូមិ | | |
|---|---|---|---|---|---|---|
| | ទីប្រជុំជន | ជនបទ | សរុប | ទីប្រជុំជន | ជនបទ | សរុប |
| បន្ទាយមានជ័យ | ១០៩ | ៥៦១ | ៦៧០ | ១៨ | ៣២ | ៥០ |
| បាត់ដំបង | ១១១ | ៧០១ | ៨១២ | ១៦ | ៤២ | ៥៨ |
| កំពង់ចាម | ១១៧ | ៨០៣ | ៩២០ | ១១ | ៤៦ | ៥៧ |
| កំពង់ឆ្នាំង | ២៦ | ៥៤៣ | ៥៦៩ | ៤ | ៣៥ | ៣៩ |
| កំពង់ស្ពឺ | ៩៥ | ១.២៨៥ | ១.៣៨០ | ៦ | ៤២ | ៤៨ |
| កំពង់ធំ | ៥០ | ៧៣០ | ៧៨០ | ៦ | ៤០ | ៤៦ |
| កំពត | ៣២ | ៤៥៦ | ៤៨៨ | ៥ | ៣៧ | ៤២ |
| កណ្ដាល | ២២០ | ៧៩០ | ១.០១០ | ២២ | ៤១ | ៦៣ |
| កោះកុង | ២៥ | ៩៥ | ១២០ | ១០ | ១១ | ២១ |
| ក្រចេះ | ២២ | ២៣៦ | ២៥៨ | ៤ | ២៧ | ៣១ |

| | | | | | | |
|---|---|---|---|---|---|---|
| មណ្ឌលគិរី | ១៤ | ៨៤ | ៩៨ | ៤ | ១៦ | ២០ |
| រាជធានីភ្នំពេញ | ៩៤៨ | ០ | ៩៤៨ | ៩៣ | ០ | ៩៣ |
| ព្រះវិហារ | ២០ | ២១៥ | ២៣៥ | ៤ | ២០ | ២៤ |
| ព្រៃវែង | ៣៣ | ១.១១៧ | ១.១៥០ | ៣ | ៥៤ | ៥៧ |
| ពោធិ៍សាត់ | ៧៥ | ៤៣៦ | ៥១១ | ៧ | ៣០ | ៣៧ |
| រតនៈគិរី | ១៩ | ២២៤ | ២៤៣ | ៤ | ១៧ | ២១ |
| សៀមរាប | ១៣៤ | ៨១៧ | ៩៥១ | ១៩ | ៣៨ | ៥៧ |
| ក្រុងព្រះសីហនុ | ៤០ | ៧១ | ១១១ | ១៥ | ១០ | ២៥ |
| ស្ទឹងត្រែង | ១៧ | ១១១ | ១២៨ | ៥ | ១៤ | ១៩ |
| ស្វាយរៀង | ៧៨ | ៦១២ | ៦៩០ | ៨ | ៣៤ | ៤២ |
| តាកែវ | ៤០ | ១.០៧៩ | ១.១១៩ | ៣ | ៤៨ | ៥១ |
| ឧត្តរមានជ័យ | ៧៧ | ២៦០ | ៣៣៧ | ៨ | ១៧ | ២៥ |
| កែប | ៧ | ១១ | ១៨ | ៦ | ៤ | ១០ |
| ប៉ៃលិន | ៤៥ | ៥១ | ៩៦ | ១៣ | ៩ | ២២ |
| ត្បូងឃ្មុំ | ៨០ | ៧៩២ | ៨៧២ | ៨ | ៤២ | ៥០ |
| សរុប | ២.៤៣៤ | ១២.០៨០ | ១៤.៥១៤ | ៣០២ | ៧០៦ | ១.០០៨ |

### ១.៥.៣. ការជ្រើសរើសសំណាកគំរូ

ក្រៅពីការបែងចែកទៅក្រុមៗដូចបានពិពណ៌នាខាងលើ ការជ្រើសរើសសំណាកគំរូនៅក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ត្រូវបានធ្វើឡើងជាបីដំណាក់កាលដែលមានរចនាសម្ព័ន្ធទូទៅដូចគ្នាទៅនឹងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាមុនៗដែរ។

**ដំណាក់កាលទី១៖** ផ្ដើមចេញពីបញ្ជីសម្រាប់ជ្រើសរើសសំណាកគំរូទាំង៤៩ ដែលត្រូវបានបែងចែកដាច់ដោយឡែកពីគ្នារួច ឯកតាសំណាកគំរូបឋម(PSUs) សម្រាប់ក្រុមនីមួយៗ ត្រូវបានជ្រើសរើសដោយឯករាជ្យពីគ្នានៅក្នុងក្រុមនីមួយៗ ដោយប្រើវិធីសាស្ត្រប្រូបាបប៊ីលីតេសមាមាត្រទៅនឹងរង្វាស់ទំហំនៃភូមិជាលក្ខណៈប្រព័ន្ធដោយគ្មានការជំនួស(Systematic PPS without Replacement)។ រង្វាស់ទំហំនៃភូមិដែលត្រូវបានប្រើប្រាស់គឺជាអថេរស្ដីអំពីចំនួនគ្រួសារក្នុងភូមិនីមួយៗ ដែលទទួលបានពីប្រតិបត្តិការគូសផែនទីសម្រាប់ជំរឿនទូទៅប្រជាជនកម្ពុជាឆ្នាំ២០១៩។

**ដំណាក់កាលទី២៖** ផ្ដើមចេញពីភូមិ/ឯកតាសំណាកគំរូបឋម(PSUs)នីមួយៗ ដែលបានជ្រើសរើសមណ្ឌលជំរឿនមួយត្រូវបានជ្រើសរើស ដោយប្រើវិធីសាស្ត្រជ្រើសរើសសំណាកគំរូចៃដន្យបែបសាមញ្ញ(SRS)។ នៅក្នុងក្រុមនៃតំបន់ទីប្រជុំជន រាជធានីភ្នំពេញ ដែលមានភូមិខ្លះមានទំហំធំខ្លាំង ត្រូវបានបំបែកទៅជាឯកតាសំណាកគំរូបឋម(PSUs)ច្រើនជាងមួយ ហើយដែលក្រោយមកត្រូវបានជ្រើសរើសដោយស្វ័យប្រវត្តិ។ នៅក្នុង

ឯកតាសំណាកគំរូបឋមនីមួយៗ ដែលត្រូវបានបំបែកទាំងនេះ មណ្ឌលជំរឿនមួយត្រូវបានជ្រើសរើស។ ករណីនេះមានន័យថាអាចនឹងមានការជ្រើសរើសច្រើនជាងមួយមណ្ឌលជំរឿនចេញពីភូមិធំៗទាំងនេះ។

**ដំណាក់កាលទី៣៖** នៅក្នុងមណ្ឌលជំរឿននីមួយៗដែលបានជ្រើសរើសនៅក្នុងដំណាក់កាលទី២ ការគូសផែនទី និងការចុះបញ្ជីគ្រួសារធម្មតាទាំងអស់ត្រូវបានធ្វើឡើង។ ក្នុងដំណាក់កាលទី៣នេះ គ្រួសារចំនួន១០ត្រូវបានជ្រើសរើសចេញពីមណ្ឌលជំរឿននីមួយៗ តាមវិធីសាស្ត្រជ្រើសរើសសំណាកគំរូជាលក្ខណៈប្រព័ន្ធបែបរង្វង់ (ឬហៅកាត់ថា CSS)។

ការជ្រើសរើសចំនួន១០គ្រួសារក្នុងមួយមណ្ឌលជំរឿននៅក្នុងដំណាក់កាលទី៣ គឺផ្អែកលើការកម្រិតនៃថវិកា និងការប៉ាន់ស្មានស្ថិតិពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំមុនៗ ជាមួយនឹងគោលបំណងធ្វើយ៉ាងណាឱ្យការជ្រើសរើសសំណាកគំរូមានលក្ខណៈល្អប្រសើរបំផុត សម្រាប់ការប៉ាន់ស្មានទាំងលើអត្រានៃភាពក្រីក្រ និងលើសកម្មភាពសេដ្ឋកិច្ចផងដែរ (ផ្អែកលើឯកសារឆ្នាំ២០១១ ដែលពិពណ៌នាដោយលោកបណ្ឌិត Han Pettersson ទីប្រឹក្សាស្ថិតិស៊ុយអែតរយៈពេលវែងប្រចាំនៅវិទ្យាស្ថានជាតិស្ថិតិ)។ ចំនួនសំណាកគំរូគ្រួសារសរុបក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានចំនួន១០.០៨០គ្រួសារ ក្នុងនោះមាន ៣.០២០ គ្រួសារនៅទីប្រជុំជន និង៧.០៦០គ្រួសារនៅទីជនបទ។ យ៉ាងណាមិញមានតែ១០.០៧៥គ្រួសារទេដែលបានចូលរួមសម្ភាសជាក់ស្តែងនៅក្នុងការអង្កេតនេះ ដោយមានការបដិសេធមិនចូលរួមចំនួនប្រាំគ្រួសារនៅរាជធានីភ្នំពេញ។

សម្រាប់គ្រួសារនីមួយៗ រាល់សមាជិកទាំងអស់ត្រូវបានកត់ត្រាចូលក្នុងតារាងសំណួរគ្រួសារ ហើយការសម្ភាសត្រូវបានធ្វើ ហើយទិន្នន័យត្រូវបានកត់ត្រា ផ្អែកទៅតាមតម្រូវការនៃម៉ូឌុលផ្សេងៗគ្នាដែលមានក្នុងតារាងសំណួរគ្រួសារ។ ជាមួយនឹងទំហំគ្រួសារជាមធ្យមប្រមាណ៤,៥ ដែលត្រូវបានប៉ាន់ស្មានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤។ យើងរំពឹងថាចំនួនមនុស្សដែលនឹងត្រូវសម្ភាសនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ នឹងមានចំនួនច្រើនជាង៤៥.០០០នាក់ ។

### ១.៥.៤. សំណាកគំរូប្រចាំខែ

ការប្រមូលទិន្នន័យសម្រាប់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ត្រូវបានធ្វើឡើងក្នុងឆមាសទីពីរនៃឆ្នាំ២០១៩ និងក្នុងឆមាសទីមួយនៃឆ្នាំ២០២០។ សំណាកគំរូប្រចាំឆ្នាំត្រូវបានបំបែកជា១២ចំណែកស្មើៗគ្នាតាមវិធីសាស្ត្រចៃដន្យដែលមួយចំណែកៗមានចំនួន ៨៤ ឯកតាសំណាកគំរូបឋម(PSUs)។ បន្ទាប់មក ឯកតាសំណាកគំរូបឋមទាំង១២ ចំណែក ត្រូវបានបែងចែកដោយចៃដន្យជាសំណាកគំរូប្រចាំខែ ក្នុងបំណងជានាឱ្យក្រុមនៃរាជធានីខេត្តនីមួយៗ មានតំណាងជាសំណាកគំរូនៅក្នុងគ្រប់៦ខែនៃចុងឆ្នាំ២០១៩ និងគ្រប់៦ខែនៃដើមឆ្នាំ២០២០។ ក្នុងមួយខែៗ ក្រុមការងារនីមួយៗត្រូវចុះបំពេញភារកិច្ចចំនួន៤ឯកតាសំណាកគំរូបឋម(PSUs) ឬភូមិ ហើយចម្ងាយពីភូមិមួយទៅភូមិមួយ មិនអាចឆ្ងាយពេកបានទេ។ ដោយសារតែបញ្ហាប្រឈមខ្លះៗទើបការបែងចែកឯកតាសំណាកគំរូបឋម(PSUs)សម្រាប់ខែទាំងអស់ក្នុងតំបន់ភូមិសាស្ត្រនីមួយៗ មានពេលខ្លះត្រូវបានធ្វើការកែតម្រូវដោយដៃ។ ទោះជាយ៉ាងនេះក្តី សំណាកគំរូប្រចាំខែ នៅតែតំណាង និងមានទំហំធំគ្រប់គ្រាន់សម្រាប់ការប៉ាន់ស្មានស្ថិតិក្នុងកម្រិតថ្នាក់ជាតិ ទីប្រជុំជន ជនបទ និងរាជធានីភ្នំពេញ ហើយករណីខ្លះ ក៏អាចប៉ាន់ស្មានស្ថិតិដល់កម្រិតក្រោមនេះផ្សេងៗទៀត។ ការបែងចែកនេះក៏អនុញ្ញាតឱ្យយើងអាចប៉ាន់ស្មានស្ថិតិប្រចាំត្រីមាសបានផងដែរ ប្រសិនបើមានតម្រូវការ។

## ១.៦ គុណភាពនៃការប៉ាន់ស្មានលទ្ធផលពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា

គ្រប់ទិន្នន័យអង្កេតទាំងអស់រមែងតែងមានភាពលម្អៀងដែលកើតចេញពីប្រភពនានា។ ភាពលម្អៀងអាចកើតមានឡើងនៅដំណាក់កាលណាមួយក្នុងអំឡុងពេលនៃដំណើរការអង្កេត។ ភាពខុសគ្នាជាទូទៅ និងសំខាន់នៃភាពលម្អៀង គឺមានភាពលម្អៀងដោយការជ្រើសរើសសំណាកគំរូ និងភាពលម្អៀងមិនមែនដោយការជ្រើសរើសសំណាកគំរូ។ គុណភាពនៃការប៉ាន់ស្មាន ឬលទ្ធផលនៃការអង្កេត គឺអាស្រ័យទៅលើភាពលម្អៀងទាំងពីរនេះ។

### ១.៦.១. ភាពលម្អៀងដោយការជ្រើសរើសសំណាកគំរូ

ជានិច្ចកាល ភាពមិនប្រាកដប្រជានៅក្នុងលទ្ធផល(ការប៉ាន់ស្មាន)ពីការធ្វើអង្កេត គឺបណ្តាលមកពីមូលហេតុដោយសារតែគ្រួសារ ឬមនុស្សទាំងអស់ដែលមាននៅក្នុងប្រទេសកម្ពុជា មិនត្រូវបានសួរនៅក្នុងការធ្វើអង្កេត។ ភាពមិនប្រាកដប្រជាត្រូវបានចង្អុលបង្ហាញតាមរយៈលម្អៀងស្តង់ដារនៃការប៉ាន់ស្មាន។ កាលណាលម្អៀងស្តង់ដារកាន់តែធំ មានន័យថាភាពមិនប្រាកដប្រជានៃការប៉ាន់ស្មានក៏កាន់តែធំដែរ។ ភាពមិនប្រាកដប្រជា ក៏អាចត្រូវបានបង្ហាញផងដែរតាមរយៈចន្លោះនៃកម្រិតជឿជាក់(កម្រិតលម្អៀង "margin of error") នៅជុំវិញតម្លៃប៉ាន់ស្មាន។ ចន្លោះនៃកម្រិតជឿជាក់៩៥ភាគរយនៅជុំវិញតម្លៃប៉ាន់ស្មាន គឺជាចន្លោះដែលទទួលបានដោយការដក១,៩៦នៃតម្លៃលម្អៀងស្តង់ដារចេញពីតម្លៃប៉ាន់ស្មាន (ឬស្មើនឹងដែនកំណត់ខាងក្រោមនៃចន្លោះ) ហើយបូកបន្ថែម១,៩៦នៃតម្លៃលម្អៀងស្តង់ដារទៅលើតម្លៃប៉ាន់ស្មាន(ឬស្មើនឹងដែនកំណត់ខាងលើនៃចន្លោះ)។ ចន្លោះនៃកម្រិតជឿជាក់ គឺជាចន្លោះដែលស្ថិតនៅក្នុងដែនកំណត់ ដែលក្នុងនោះតម្លៃពិតនៃសកលស្ថិតិត្រូវបានគេសន្មតដោយសមហេតុផលថាស្ថិតនៅក្នុងចន្លោះនោះ។ ឧទាហរណ៍ ដូចជា ៖

> ការប៉ាន់ស្មានជាភាគរយ នៃចំនួនគ្រួសារដែលមានបង្គន់អនាម័យបានកែលម្អ សម្រាប់គ្រួសារនៅក្នុងប្រទេសកម្ពុជាស្មើនឹង៨០,៤% ហើយលម្អៀងស្តង់ដារស្មើនឹង០,៤%។ ដូច្នេះ ចន្លោះនៃកម្រិតជឿជាក់ត្រូវស្មើនឹង៨០,៤% +/- (១,៩៦ *០,៤%) ដែលជាលទ្ធផល គឺស្ថិតនៅក្នុងចន្លោះរវាង [៧៩,៦% ដល់ ៨១,២%]។ ចន្លោះនេះ គ្របដណ្តប់នូវភាគរយពិតដែលយើងមិនដឹងនៃគ្រួសារទាំងអស់នៅប្រទេសកម្ពុជាដែលមានបង្គន់អនាម័យបានកែលម្អ ជាមួយនឹងកម្រិតជឿជាក់ខ្ពស់(៩៥%)នៃការប៉ាន់ស្មាន។

តម្លៃនៃលម្អៀងស្តង់ដារ ឬចន្លោះនៃកម្រិតជឿជាក់ សម្រាប់តម្លៃប៉ាន់ស្មានសំខាន់ៗមួយចំនួន ត្រូវបានគណនាដោយប្រើប្រាស់វិធីសាស្ត្រលីនៀអ៊ែរ របស់ លោកតៃល័រ(Taylor Linearization Method)។ កម្មវិធី(Software) ដែលត្រូវបានប្រើសម្រាប់ការវិភាគទិន្នន័យ អង្កេតនេះគឺកម្មវិធី STATA និង SPSS។

ម៉្យាងវិញទៀត ប្រសិនបើអ្នកអានរកមិនឃើញលម្អៀងស្តង់ដារ និង ចន្លោះនៃកម្រិតជឿជាក់នៅក្នុងឧបសម្ព័ន្ធទី១ អ្នកអាចរកមើលតម្លៃប៉ាន់ស្មាននៃកម្រិតលម្អៀងសម្រាប់កម្រិតជឿជាក់ ៩៥ភាគរយ ឬជា១,៩៦លម្អៀងស្តង់ដារក្នុងករណីដែលការប៉ាន់ស្មានស្ថិតិ គឺជាភាគរយ។ ក្នុងករណីនេះ យើងអាចចងក្រងតម្លៃប៉ាន់ស្មាននៃកម្រិតលម្អៀង ដោយផ្អែកលើភាគរយ និងទំហំសំណាកគំរូនៃក្រុមនីមួយៗ ដែលភាគរយរបស់វាត្រូវបានគណនា។ ការប៉ាន់ស្មានតម្លៃនៃកម្រិតលម្អៀងសម្រាប់កម្រិតនៃភាគរយ និងសកលគោលផ្សេងៗគ្នា ត្រូវបានបង្ហាញនៅក្នុងតារាង២។ សកលគោល គឺជាក្រុមដែលការប៉ាន់ស្មានជាភាគរយត្រូវបានធ្វើដោយធៀបទៅនឹងវា។

ឧទាហរណ៍៖ ភាគរយនៃស្ត្រីនៅកម្ពុជាដែលបានរៀបការរួច/រស់នៅជាមួយគ្នា ត្រូវបានប៉ាន់ស្មានថាមានប្រមាណ៦០,៧ភាគរយ។ សកលគោល គឺជា "ស្ត្រីទាំងអស់នៅកម្ពុជា" ។ ក្នុងករណីនេះ សូមពិនិត្យមើលលើ

បន្ទាត់ជួរដេកចុងក្រោយទី៤ក្នុងតារាង ហើយរកឱ្យឃើញនូវពាក្យថា៖ "កម្ពុជា (ស្ត្រីទាំងអស់)" បន្ទាប់មក សូមពិនិត្យទៅមើលបង្គោលទី៨ នៅត្រង់ "៤០% ឬ ៦០%" ដើម្បីស្វែងរកកម្រិតលម្អៀងរបស់វាដែលស្មើនឹង១,០ភាគរយ។ ដូចនេះ ចន្លោះនៃកម្រិតជឿជាក់៩៥ភាគរយនៃការប៉ាន់ស្មាននេះ គឺ៖ ៦០,៧ +/- ១,០ ភាគរយ។

ឧទាហរណ៍មួយទៀត៖ ភាគរយនៃគ្រួសារនៅរាជធានីភ្នំពេញមានទូរទស្សន៍ប្រើប្រាស់ ត្រូវបានប៉ាន់ស្មានថាមានប្រមាណ៨៣,០ភាគរយ។ សកលគោល គឺជា "គ្រួសារទាំងអស់នៅរាជធានីភ្នំពេញ"។ ក្នុងករណីនេះ សូមចូលទៅមើលបន្ទាត់ជួរដេកទី៣ក្នុងតារាងដែលមានពាក្យថា៖ "រាជធានីភ្នំពេញ (គ្រួសារទាំងអស់)" ហើយសូមមើលទៅបង្គោលទី៦ត្រង់កម្រិតភាគរយ "២០ភាគរយ ឬ ៨០ភាគរយ" ដើម្បីស្វែងរកកម្រិតលម្អៀងរបស់វាដែលស្មើនឹង៣,៦ភាគរយ។ ដូចនេះ ចន្លោះនៃកម្រិតជឿជាក់៩៥ភាគរយ នៃការប៉ាន់ស្មាននេះ គឺ៖ ៨៣,០ភាគរយ +/- ៣,៦ភាគរយ។

**តារាង២. តម្លៃប៉ាន់ស្មាននៃកម្រិតលម្អៀងជាមួយនឹងកម្រិតជឿជាក់៩៥% សម្រាប់កម្រិតនៃភាគរយនីមួយៗ**

| ការប៉ាន់ស្មានជាភាគរយ<br><br>សកលគោល | ២% ឬ ៩៨%<br>+/- | ៥% ឬ ៩៥%<br>+/- | ១០% ឬ ៩០%<br>+/- | ១៥% ឬ ៨៥%<br>+/- | ២០% ឬ ៨០%<br>+/- | ៣០% ឬ ៧០%<br>+/- | ៤០% ឬ ៦០%<br>+/- | ៥០%<br>+/- |
|---|---|---|---|---|---|---|---|---|
| កម្ពុជា (គ្រួសារទាំងអស់) | ០,៤ | ០,៦ | ០,៨ | ១,០ | ១,១ | ១,៣ | ១,៤ | ១,៤ |
| រាជធានីភ្នំពេញ (គ្រួសារទាំងអស់) | ១,៣ | ២,០ | ២,៧ | ៣,២ | ៣,៦ | ៤,២ | ៤,៥ | ៤,៥ |
| ប្រជុំជនផ្សេងៗ (គ្រួសារទាំងអស់) | ០,៨ | ១,៣ | ១,៨ | ២,២ | ២,៤ | ២,៨ | ៣,០ | ៣,០ |
| ជនបទផ្សេងៗ (គ្រួសារទាំងអស់) | ០,៥ | ០,៧ | ១,០ | ១,២ | ១,៣ | ១,៥ | ១,៦ | ១,៦ |
| រាជធានីភ្នំពេញ (គ្រួសារទាំងអស់) | ១,៣ | ២,០ | ២,៧ | ៣,២ | ៣,៦ | ៤,២ | ៤,៥ | ៤,៥ |
| តំបន់វាលទំនាប (គ្រួសារទាំងអស់) | ០,៧ | ១,១ | ១,៥ | ១,៧ | ២,០ | ២,២ | ២,៤ | ២,៥ |
| តំបន់ទន្លេសាប (គ្រួសារទាំងអស់) | ០,៧ | ១,១ | ១,៦ | ១,៨ | ២,១ | ២,៤ | ២,៥ | ២,៦ |
| តំបន់ឆ្នេរសមុទ្រ (គ្រួសារទាំងអស់) | ១,២ | ១,៩ | ២,៧ | ៣,២ | ៣,៥ | ៤,១ | ៤,៣ | ៤,៤ |
| តំបន់ខ្ពង់រាប និងភ្នំ (គ្រួសារទាំងអស់) | ០,៨ | ១,៣ | ១,៨ | ២,២ | ២,៤ | ២,៨ | ៣,០ | ៣,០ |
| កម្ពុជា (មនុស្សទាំងអស់) | ០,២ | ០,៣ | ០,៤ | ០,៥ | ០,៦ | ០,៧ | ០,៧ | ០,៧ |
| រាជធានីភ្នំពេញ (មនុស្សទាំងអស់) | ០,៧ | ១,១ | ១,៥ | ១,៨ | ២,០ | ២,៣ | ២,៥ | ២,៥ |
| ទីប្រជុំជនផ្សេងៗ (មនុស្សទាំងអស់) | ០,៤ | ០,៦ | ០,៨ | ១,០ | ១,១ | ១,៣ | ១,៤ | ១,៤ |
| ជនបទផ្សេងៗ (មនុស្សទាំងអស់) | ០,៣ | ០,៤ | ០,៦ | ០,៧ | ០,៧ | ០,៨ | ០,៩ | ០,៩ |
| កម្ពុជា (បុរសទាំងអស់) | ០,៣ | ០,៥ | ០,៦ | ០,៨ | ០,៨ | ១,០ | ១,០ | ១,១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| រាជធានីភ្នំពេញ (បុរសទាំងអស់) | ១,០ | ១,៦ | ២,២ | ២,៦ | ២,៩ | ៣,៤ | ៣,៦ | ៣,៧ |
| ទីប្រជុំជនផ្សេងៗ (បុរសទាំងអស់) | ០,៦ | ០,៩ | ១,២ | ១,៤ | ១,៦ | ១,៨ | ១,៩ | ២,០ |
| ទីប្រជុំជនផ្សេងៗ (បុរសទាំងអស់) | ០,៤ | ០,៦ | ០,៨ | ០,៩ | ១,១ | ១,២ | ១,៣ | ១,៣ |
| កម្ពុជា (ស្ត្រីទាំងអស់) | ០,៣ | ០,៤ | ០,៦ | ០,៧ | ០,៨ | ០,៩ | ១,០ | ១,០ |
| រាជធានីភ្នំពេញ (ស្ត្រីទាំងអស់) | ១,០ | ១,៥ | ២,១ | ២,៥ | ២,៨ | ៣,២ | ៣,៤ | ៣,៥ |
| ទីប្រជុំជនផ្សេងៗ (ស្ត្រីទាំងអស់) | ០,៥ | ០,៨ | ១,២ | ១,៤ | ១,៥ | ១,៨ | ១,៩ | ១,៩ |
| ជនបទផ្សេងៗ (ស្ត្រីទាំងអស់) | ០,៤ | ០,៦ | ០,៨ | ០,៩ | ១,០ | ១,២ | ១,៣ | ១,៣ |

### ១.៦.២. ភាពលម្អៀងមិនមែនដោយការជ្រើសរើសសំណាកគំរូ

ភាពលម្អៀងផ្សេងៗក្រៅពីការជ្រើសរើសសំណាកគំរូ គឺជាប់ទាក់ទងយ៉ាងសំខាន់ជាមួយនឹងការងារចុះប្រមូលទិន្នន័យនៅមូលដ្ឋាន និងការធ្វើប្រព្រឹត្តកម្មទិន្នន័យ។ ភាពលម្អៀងមិនមែនដោយការជ្រើសរើសសំណាកគំរូនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺជាភាពលម្អៀងនៃការមិនឆ្លើយតប ភាពលម្អៀងនៃការឆ្លើយតប និងភាពលម្អៀងនៃការកែច្នៃទិន្នន័យ។ តារាងខាងក្រោម ផ្តល់នូវការពិពណ៌នាអំពីប្រភេទនៃភាពលម្អៀងផ្សេងៗគ្នា ព្រមទាំងបង្ហាញអំពីការវាយតម្លៃលើផលប៉ះពាល់នៃភាពលម្អៀងទាំងនេះមកលើលទ្ធផលអង្កេត។

**តារាង៣. ពិពណ៌នា និងការវាយតម្លៃនៃភាពលម្អៀង**

| ប្រភេទនៃភាពលម្អៀង | ការពិពណ៌នានៃភាពលម្អៀង | ការវាយតម្លៃនៃភាពលម្អៀង |
|---|---|---|
| ភាពលម្អៀងនៃការមិនឆ្លើយតប | គ្រួសារមួយចំនួនដែលបានជ្រើសរើសពុំបានចូលរួមសហការនៅក្នុងដំណើរការអង្កេតទេ ពីព្រោះតែគេបដិសេធ ឬក៏មិនអាចផ្តល់ការសម្ភាសបាន។ ម៉្យាងវិញទៀតប្រហែលជាគ្រួសារទាំងនោះមិនអាចឆ្លើយតប ឬក៏មិនចង់ឆ្លើយទៅនឹងសំណួរអង្កេត។ | អត្រាលម្អៀងនៃការមិនឆ្លើយតប មានកម្រិតទាបបំផុត គឺមានតែ៥គ្រួសារប៉ុណ្ណោះនៅក្នុងចំណោម ១០.០៨០ គ្រួសារដែលបានជ្រើសរើស ហើយមិនបានឆ្លើយតបនឹងសំណួរអង្កេត។ ដូចនេះ ផលប៉ះពាល់នៃភាពលម្អៀងលើការមិនឆ្លើយតប មិនមានជាបញ្ហាដល់ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ឆ្នាំ២០១៩/២០នោះទេ។ |
| ភាពលម្អៀងនៃការឆ្លើយតប (លម្អៀងលើការវាស់វែង) | ភាពលម្អៀងក្នុងការឆ្លើយតបពីគ្រួសារមានដូចខាងក្រោម៖<br>– មិនយល់នឹងសំណួរឱ្យបានត្រឹមត្រូវ។ | វាមានការលំបាកណាស់ ដើម្បីវាយតម្លៃលើភាពលម្អៀងនៃការឆ្លើយតបដែលកើតមានឡើងក្នុងការធ្វើអង្កេត។ ភាពលម្អៀងនៃការឆ្លើយតបមួយចំនួនត្រូវបានរកឃើញ ហើយបានកែតម្រូវដោយស្វ័យប្រវត្តិតាមការត្រួតពិនិត្យក្នុងដែនកំណត់ជាក់ |

| | | |
|---|---|---|
| | – មិនដឹងពីចម្លើយដែលត្រូវឆ្លើយតបឱ្យបានត្រឹមត្រូវ ឬក៏មិនចងចាំ(ភ្លេច)។<br>– មិនចង់ផ្តល់ចម្លើយឱ្យបានត្រឹមត្រូវចំពោះសំណួរវេទយិត(ជាសំណួរមានភាពរសើបឬធាប់ញោចអារម្មណ៍)។<br>– មានការធុញទ្រាន់នឹងការឆ្លើយតបសំណួរ ឬក៏មិនចង់សហការផ្តល់ការសម្ភាសរហូតដល់ចប់។<br><br>ភាពលម្អៀងក៏អាចកើតឡើងផងដែរពីសំណាក់មន្ត្រីសម្ភាសន៍នៅពេលពួកគេកត់ត្រាចម្លើយពីអ្នកឆ្លើយតបមិនបានត្រឹមត្រូវ។ | លាក់ដោយប្រើវិធីសាស្ត្រតក្កវិជ្ជាដែលបានរៀបចំនៅក្នុងដំណាក់កាលវាយបញ្ចូលទិន្នន័យ និងក្នុងដំណាក់កាលបន្តបន្ទាប់។<br><br>ភាពលម្អៀងមួយចំនួនផ្សេងទៀតដែលមាននៅក្នុងអង្កេតមិនអាចរកឃើញបានទេ លុះត្រាតែមានការពិនិត្យមើលយ៉ាងហ្មត់ចត់ ជាពិសេសទៅលើគុណភាព មានដូចជា៖ ការចុះសម្ភាសន៍ឡើងវិញ ការចុះបញ្ជីគ្រួសារ ឬជាការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យទល់មុខគ្នា។<br><br>អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាត្រូវបានរៀបចំធ្វើឡើងចំនួន១៦ដងរួចមកហើយមុនអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាបច្ចុប្បន្ននេះ។ ក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងមកនេះភាពលម្អៀង និងភាពមិនច្បាស់លាស់កើតមាននៅក្នុងកម្រងសំណួរ ក៏ដូចជានិយមន័យ និងទស្សនទាន ត្រូវបានដោះស្រាយ និងធ្វើការកែតម្រូវជាបន្តបន្ទាប់។<br><br>ដូច្នេះ ភាពលម្អៀងនៃការឆ្លើយតបដែលអាចលេចចេញពីប្រភពជាច្រើនត្រូវបានលុបបំបាត់។ តែយ៉ាងណា ក៏នៅតែមានភាពលម្អៀងសេសសល់ខ្លះទៀតដែរនៅក្នុងប្រព័ន្ធទិន្នន័យ។ ភាពលម្អៀងទាំងនេះមានឥទ្ធិពលមានកំណត់ទៅលើការប៉ាន់ស្មានភាគច្រើន ប៉ុន្តែប្រហែលជាអាចមានវិសាលភាពធំទៅលើការប៉ាន់ស្មានមួយចំនួន ដូចជា៖ ការប៉ាន់ស្មានចំណាយទៅលើផលិតផល ដែលមានការទិញនៅក្នុងកម្រិតប្រហ្វេកង់ទាប។ |
| លម្អៀងនៃការធ្វើប្រព្រឹត្តិកម្មទិន្នន័យ | កំហុសកើតពីមន្ត្រីវាយបញ្ចូលទិន្នន័យ មន្ត្រីកែដៃទិន្នន័យក៏មានកំហុសដោយប្រការខ្លះដែរ ដូចជាការដាក់លេខកូដអាចខុសចំពោះចម្លើយទៅនឹងសំណួរ | ការត្រួតពិនិត្យមួយផ្នែកធំនៅក្នុងដែនកំណត់ជាក់លាក់តាមវិធីសាស្ត្រតក្កវិជ្ជា និងស្វ័យប្រវត្តិត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលវាយបញ្ចូលទិន្នន័យ និងក្នុងដំណាក់កាលបន្ទាប់ក្រោយការវាយបញ្ចូល |

| | | |
|---|---|---|
| | បើកហើយគ្មានកំណត់ ដូចជា៖ សំណួរដែល សួរទាក់ទងនឹងមុខរបរ ជាដើម ។ល។ | ទិន្នន័យ។ ម៉្យាងវិញទៀត មន្ត្រីវិភាគទិន្នន័យតាមប្រធានបទនីមួយៗ ក៏បានធ្វើការត្រួតពិនិត្យបន្ថែមផងដែរនូវតម្លៃទិន្នន័យទាំងឡាយណាដែលពុំមានលក្ខណៈច្បាស់លាស់ និងមិនស៊ីសង្វាក់គ្នា។<br><br>ការត្រួតពិនិត្យទិន្នន័យប្រកបដោយការប្រុងប្រយ័ត្ន អាចបញ្ជាក់ច្បាស់ថា ភាពលម្អៀងនៃទិន្នន័យតាមរយៈការកែច្នៃទិន្នន័យអាចលុបបំបាត់ និងកែតម្រូវបានច្រើនគួរសម លើកលែងតែភាពលម្អៀងលើការដាក់លេខកូដប៉ុណ្ណោះ។<br><br>ភាពលម្អៀងលើការដាក់លេខកូដ អាចលុបបំបាត់បានតែតាមរយៈការពិនិត្យមើលយ៉ាងហ្មត់ចត់មានដូចជា ការដាក់លេខកូដឡើងវិញ ដោយក្រុមមន្ត្រីដាក់លេខកូដផ្សេងទៀត និងការបន្សុីគ្នារវាងលេខកូដដែលមានលក្ខណៈខុសប្លែកគ្នា។ ម៉្យាងទៀត ទោះជាគ្មានការពិនិត្យមើលយ៉ាងហ្មត់ចត់បែបនេះក៏ដោយ ក៏នៅមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាលដល់មន្ត្រីដាក់លេខកូដឱ្យបានត្រឹមត្រូវ។ ធ្វើបែបនេះ ទើបអាចបញ្ជាក់ច្បាស់ថាកម្រិតលម្អៀងនៃការដាក់លេខកូដ ត្រូវបានកាត់បន្ថយបានយ៉ាងច្រើន។ |

## ១.៧ ការរៀបចំតារាងសំណួរ-ចម្លើយអង្កេត

តារាងសំណួរអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺត្រូវបានរៀបចំឡើងវិញផ្អែកលើតារាងសំណួរអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ ដើម្បីបំពេញតម្រូវការអ្នកប្រើប្រាស់ទាំងនៅខាងក្នុងនិងក្រៅអង្គភាព។ អ្នកប្រើប្រាស់ខាងក្នុងមានដូចជាគណនេយ្យជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កម្លាំងពលកម្ម និងស្ថានភាពអំពីសេដ្ឋកិច្ច-សង្គមកិច្ចផ្សេងៗទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពទិន្នន័យ។ ការកែសម្រួលតារាងសំណួរគ្រួសារសម្រាប់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ អាចមានផលប្រយោជន៍ក្នុងការប្រៀបធៀបគ្នាបានគ្រប់ពេល។ តារាងសំណួរអង្កេតលើកមុនៗសួរអំពីការចំណាយប្រើប្រាស់ម្ហូបអាហារនិងមិនមែនម្ហូបអាហារមានលក្ខណៈជាសរុប ខណៈដែលតារាងសំណួរថ្មីមានការកែសម្រួលផ្នែកនេះដោយសួរលម្អិត។ នៅក្នុងតារាងសំណួរអង្កេតលើកមុនៗមានសួរអំពីការចំណាយប្រើប្រាស់ម្ហូបអាហារចំនួន ២២ មុខទំនិញ និងមាន២៣ មុខទំនិញមិនមែនជាម្ហូបអាហារ។ ដោយឡែកតារាងសំណួរអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺ

ត្រូវបានបញ្ចូលលម្អិតនូវមុខទំនិញម្ហូបអាហារចំនួន ៦៤មុខ និងមុខទំនិញមិនមែនម្ហូបអាហារចំនួន ៤០មុខ។ តារាងសំណួរគ្រួសារថ្មីអាចមានទំនាក់ទំនងក្នុងការប្រើប្រាស់ទាំងថ្មីនិងចាស់ផងដែរដែលមានលក្ខណៈជាប៉ាក់ឡែលគ្នា។ ការបន្ថែមម៉ូឌីលនេះត្រូវបានប្រើសម្រាប់វាស់វែងលើការចំណាយប្រើប្រាស់ដូចកាលពីមុនៗដែរ។ ការស្នើឱ្យមានកែសម្រួលតារាងសំណួរត្រូវបានរំពឹងថា ដើម្បីពង្រឹងគុណភាពទិន្នន័យ។ តារាងសំណួរដែលបានស្នើកែសម្រួលនេះត្រូវបានធ្វើការសាកល្បងអង្កេតគ្រួសារសំណាកគំរូដែលមានកម្រិតកំណត់មួយកាលពីនៅដើមឆ្នាំ ២០១៩។ ការសាកល្បងតារាងសំណួរនេះ គឺត្រូវបានគាំទ្រមូលនិធិដោយទីភ្នាក់ងារស៊ីដា (Sida)។ បន្ទាប់ពីការសាកល្បងរួចមក កិច្ចប្រជុំពិភាក្សាជាមួយដៃគូពាក់ព័ន្ធដូចជាធនាគារពិភពលោក អង្គការស្បៀងអាហារពិភពលោក (WFP) អង្គការយូនីសេហ្វ (UNICEF) និងដៃគូអភិវឌ្ឍន៍ដទៃទៀត ត្រូវបានរៀបចំឡើងដើម្បីប្រជុំពិភាក្សាលម្អិតលើករណីដែលអាចកែសម្រួលបាន។ ទោះជាយ៉ាងណា ទម្រង់គំរូស្តង់ដារនៃតារាងសំណួរអង្កេតត្រូវបានផ្អែកលើមូលដ្ឋានគ្រឹះនៃតារាងសំណួរអង្កេតលើកមុនៗ ក្នុងគោលបំណងដើម្បីអាចធ្វើការប្រៀបធៀបគ្នាបានពីអង្កេតមួយទៅអង្កេតមួយផងដែរ។ ដោយសារអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ គឺជាអង្កេតទ្រង់ទ្រាយធំដែលតម្រូវឱ្យមានការពិនិត្យតារាងសំណួរឡើងវិញ។ ដូច្នេះមានសំណួរជាច្រើនបានកែសម្រួលទៅតាមការស្នើសុំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ។ តារាងសំណួរដែលប្រើប្រាស់ក្នុងដំណើរការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានបួនទម្រង់គឺ ទម្រង់ទី១-តារាងចុះបញ្ជីគ្រួសារនៅក្នុងភូមិ ទម្រង់ទី២-តារាងសំណួរភូមិ ទម្រង់ទី៣-តារាងសំណួរគ្រួសារ ទម្រង់ទី៤-តារាងសំណួរកត់ត្រាប្រចាំថ្ងៃ។

### ទម្រង់១. តារាងចុះបញ្ជីគ្រួសារនៅក្នុងភូមិ

តារាងចុះបញ្ជីគ្រួសារនៅក្នុងភូមិ ប្រើប្រាស់សម្រាប់ចុះបញ្ជីគ្រួសារធម្មតាទាំងអស់នៅក្នុងមណ្ឌលអង្កេតរបស់ភូមិសំណាកគំរូ។ តារាងចុះបញ្ជីគ្រួសារក៏ត្រូវបានប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការជ្រើសរើសគ្រួសារសំណាកគំរូចៃដន្យដើម្បីសម្ភាសន៍ផងដែរ។ ការជ្រើសរើសគ្រួសារសំណាកគំរូចៃដន្យក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺមានចំនួនដប់គ្រួសារក្នុងមណ្ឌលអង្កេតនីមួយៗ។ តារាងចុះបញ្ជីគ្រួសារនេះ មានផែនទីភូមិ និងមណ្ឌលអង្កេតសម្រាប់គូសសម្គាល់ព្រំដែនតំបន់។ ព័ត៌មានដែលបានប្រមូលក្នុងទម្រង់តារាងនេះមានអគារ/ផ្ទះ ឈ្មោះមេគ្រួសារ អាសយដ្ឋានគ្រួសារ ចំនួនសមាជិកគ្រួសារ និងសកម្មភាពសេដ្ឋកិច្ចរបស់មេគ្រួសារ ឬការប្រើប្រាស់អគារ/ផ្ទះ (សូមមើលក្នុងឧបសម្ព័ន្ធ២)។

### ទម្រង់២. តារាងសំណួរភូមិ

តារាងសំណួរភូមិត្រូវបានសម្ភាសន៍ជាមួយប្រធានភូមិ ឬអ្នកតំណាងភូមិនិងអ្នកដែលធ្វើការពាក់ព័ន្ធនឹងទីផ្សារ ហាងលក់ទំនិញក្នុងភូមិមានដូចជា ក្រុមអាជីវករលក់រាយ ឬអ្នកលក់ដូរផ្សេងទៀត។ល។ ចំពោះអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មានផ្នែកមួយចំនួនត្រូវបានដកចេញដោយបញ្ចូលមកវិញតាមបរិបទសង្គមបច្ចុប្បន្ន។ ទោះជាយ៉ាងណា ការកែសម្រួលតារាងសំណួរអាចធ្វើការប្រៀបធៀបគ្នាទៅនឹងស៊េរីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាលើកមុនៗដែរ។ សម្រាប់ផ្នែកដែលបានរក្សាទុក ដើម្បីប្រមូលយកព័ត៌មានអំពីប្រជាសាស្ត្រ សេដ្ឋកិច្ចនិងហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកថ្លៃលក់រាយលើមុខទំនិញដែលជាម្ហូបអាហារ មុខទំនិញមិនមែនម្ហូបអាហារ និងថ្នាំពេទ្យ។ (សូមមើលក្នុងឧបសម្ព័ន្ធ១)។

**ទម្រង់៣. តារាងសំណួរគ្រួសារ**

តារាងសំណួរគ្រួសារត្រូវបានសម្ភាសន៍ជាមួយមេគ្រួសារ ប្តី ឬប្រពន្ធមេគ្រួសារ ឬក៏សមាជិកគ្រួសារពេញវ័យដទៃទៀត។ តារាងសំណួរគ្រួសារ ត្រូវបានប្រើប្រាស់ដើម្បីប្រមូលយកព័ត៌មានអំពីស្ថានភាពលំនៅដ្ឋាន ផលិតផលដំណាំនិងសកម្មភាពកសិកម្មដទៃទៀត សកម្មភាពសេដ្ឋកិច្ចផ្សេងៗរបស់គ្រួសារ បំណុលគ្រួសារ សម្ភារប្រើប្រាស់បានយូរ សកម្មភាពសាងសង់ និងចំណូលគ្រួសារពីប្រភពដទៃទៀតក្រៅពីសកម្មភាពសេដ្ឋកិច្ច។ តារាងសំណួរគ្រួសាររួមបញ្ចូលផងដែរនូវព័ត៌មានសម្រាប់សមាជិកគ្រួសារម្នាក់ៗដែលសួរអំពីការសិក្សាអប់រំនិងអក្ខរភាព ការចំណាយទៅលើការស្វែងរកសេវាដើម្បីថែទាំសុខភាព ពិការភាព សកម្មភាពសេដ្ឋកិច្ចបច្ចុប្បន្ន សកម្មភាពសេដ្ឋកិច្ចធម្មតា ស្ថានភាពការងារ និងការទទួលរងគ្រោះ។ ដោយឡែកសម្រាប់ផ្នែក (ម៉ូឌីល) សុខភាពមាតានិងកុមារ ត្រូវបានដកចេញពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ដោយសារផ្នែកទាំងពីរនេះមានដាក់បញ្ចូលទៅក្នុងអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាផងដែរ។ តារាងសំណួរគ្រួសារថ្មីសម្រាប់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺមានការកែសម្រួលផ្នែកខ្លះផ្អែកលើតារាងសំណួរអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ (សូមមើលឧបសម្ព័ន្ធ៣)។

**ទម្រង់៤. តារាងសំណួរកត់ត្រាប្រចាំថ្ងៃ**

តារាងសំណួរកត់ត្រាប្រចាំថ្ងៃ គឺជាទម្រង់តារាងមួយក្នុងចំណោមទម្រង់តារាងសំណួរទាំងបួន ដែលត្រូវបានប្រើប្រាស់សម្រាប់សម្ភាសន៍ កត់ត្រាព័ត៌មានទិន្នន័យអំពីចំណូល និងចំណាយប្រចាំថ្ងៃរបស់គ្រួសារដែលបានជ្រើសរើសសម្ភាសន៍។ តារាងសំណួរមានពីរផ្នែក គឺផ្នែកទី១សម្រាប់កត់ត្រាចំណាយ និងផ្នែកទីពីរសម្រាប់កត់ត្រាចំណូលរបស់គ្រួសារ។ មន្ត្រីសម្ភាសន៍នីមួយៗ ត្រូវសួរសម្ភាសន៍គ្រួសារជារៀងរាល់ថ្ងៃក្នុងកំលុងពេលមួយសប្តាហ៍ដើម្បីពិនិត្យកត់ត្រាអំពីចំណូលនិងចំណាយរបស់គ្រួសារ។ (សូមមើលក្នុងឧបសម្ព័ន្ធ៤)។ តារាងកត់ត្រាប្រចាំថ្ងៃរួមមាន៖

- ព័ត៌មានអំពីការចំណាយ និងការប្រើប្រាស់ផលិតផលផ្ទាល់ខ្លួន
- ចំណូល និងការទទួលបានរបស់គ្រួសារ

## ១.៨ ការបណ្តុះបណ្តាល និង ការចុះប្រតិបត្តិការសម្ភាសន៍នៅតាមមណ្ឌលអង្កេត

### ១.៨.១ ការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យ

មុនពេលចាប់ផ្តើមចុះប្រមូលទិន្នន័យនៅតាមមូលដ្ឋាន វគ្គបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យត្រូវបានធ្វើឡើងដោយមានមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យសរុបចំនួន២៥២នាក់ ក្នុងនោះរួមទាំងមន្ត្រីត្រៀមបម្រុងមួយចំនួនផងដែរ ដែលត្រូវបានជ្រើសរើសយក ហើយចំនួនសរុបនៃមន្ត្រីទាំងនេះត្រូវបានបែងចែកចេញជាពីរក្រុមធំៗ ក្រុមទាំងពីរបានផ្លាស់វេនគ្នាក្នុងការចុះប្រមូលទិន្នន័យ ដោយក្រុមទី១បានចុះទៅប្រមូលទិន្នន័យនៅតាមមូលដ្ឋានក្នុងអំឡុងខែអង្កេតសេស (មានដូចជា ខែកក្កដា ខែកញ្ញា ខែវិច្ឆិកា ឆ្នាំ២០១៩ និងខែមករា ខែមីនា និងខែឧសភា ឆ្នាំ២០២០) ខណៈពេលដែលក្រុមទី២បានចុះប្រមូលទិន្នន័យក្នុងអំឡុងខែអង្កេតគូរ (មានដូចជា ខែសីហា ខែតុលា ខែធ្នូ ឆ្នាំ២០១៩ និង ខែកុម្ភៈ ខែមេសា និងខែមិថុនា ឆ្នាំ២០២០) ហើយវគ្គបណ្តុះបណ្តាលនេះ បានរៀបចំធ្វើឡើងចំនួនពីរដងនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។

ក្រុមទីមួយបានទទួលការបណ្តុះបណ្តាលចំនួន១០ថ្ងៃ នៅក្នុងខែមិថុនា ឆ្នាំ២០១៩ ខណៈដែលក្រុមទីពីរបានទទួលការបណ្តុះបណ្តាលចំនួនមួយសប្តាហ៍ផងដែរនៅក្នុងខែមករាឆ្នាំ២០២០។ វគ្គបណ្តុះបណ្តាលនេះក៏មានការចូលរួមសហការពីទីប្រឹក្សារបស់ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត មន្ត្រីជំនាញមកពីអង្គការកម្មវិធីស្បៀងអាហារពិភពលោក ធនាគារពិភពលោក មន្ត្រីដឹកនាំគម្រោង និងមន្ត្រីវិភាគតាមប្រធានបទបានធ្វើជាគ្រូបង្គោល ដោយបង្ហាត់ទៅតាមជំនាញលើប្រធានបទនីមួយៗដែលខ្លួនទទួលខុសត្រូវ។ ក្នុងពេលបណ្តុះបណ្តាលឯកសារណែនាំអំពីវិធីសាស្ត្រចុះប្រមូលទិន្នន័យត្រូវបានចែកឱ្យមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យគ្រប់គ្នាទាំងអស់ផងដែរ។

### ១.៨.២ ការចុះប្រតិបត្តិការប្រមូលទិន្នន័យតាមមូលដ្ឋាន

មន្ត្រីសម្ភាសន៍និងមន្ត្រីត្រួតពិនិត្យត្រូវបានបែងចែកជា ២១ក្រុម ដែលសរុបទាំងអស់មានចំនួន៤២ក្រុម សម្រាប់ការចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យនៅតាមមូលដ្ឋាន ហើយសម្រាប់ការចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យក្នុងខែនីមួយៗ គឺត្រូវប្រើចំនួន២១ក្រុមការងារ ដោយតម្រូវឱ្យសម្ភាសន៍១២គ្រួសារក្នុងមន្ត្រីសម្ភាសន៍ម្នាក់ និងយោងតាមផែនការកំណត់សម្រាប់រយៈពេលមួយខែ ក្រុមការងារនីមួយៗត្រូវធ្វើការសម្ភាសចំនួន៤៨គ្រួសារ។ សម្រាប់ខែចុះសម្ភាសន៍នីមួយៗ ក្រុមការងារធ្វើការរយៈពេល៧ថ្ងៃ (សប្តាហ៍ទីមួយ នៃខែ) ក្នុងមួយភូមិ ឬមណ្ឌលអង្កេតហើយត្រូវចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យចំនួន៤ ភូមិ ឬមណ្ឌលអង្កេតក្នុងមួយខែ។ ម្យ៉ាងទៀតមុនពេលចុះសម្ភាសន៍គ្រួសារ ក្រុមការងារនីមួយៗតម្រូវឱ្យទៅដល់ភូមិមុនពីរ ឬបីថ្ងៃ ដើម្បីបំពេញកិច្ចការមួយចំនួនមានដូចជាធ្វើការពិភាក្សាជាមួយអាជ្ញាធរភូមិ ដើម្បីធ្វើបច្ចុប្បន្នកម្មផែនទីភូមិ ផែនទីមណ្ឌលអង្កេត ឬក៏គូសផែនទីថ្មីឡើងវិញ ក្នុងករណីដែលពុំមានផែនទីស្រាប់ ការស្រង់បញ្ជីគ្រួសារនៅក្នុងភូមិ ឬមណ្ឌលអង្កេត ហើយបន្ទាប់មកជ្រើសរើសគ្រួសារគំរូមកធ្វើការសម្ភាសន៍។ ក្នុងពេលប្រតិបត្តិការសម្ភាសន៍ តារាងសំណួរភូមិត្រូវស្រង់ព័ត៌មានដោយមន្ត្រីត្រួតពិនិត្យ រីឯតារាងសំណួរគ្រួសារ និងតារាងកំណត់ត្រាព័ត៌មានប្រចាំថ្ងៃរបស់គ្រួសារលើការប្រើប្រាស់ផលិតផលផ្ទាល់ខ្លួននិងចំណូលចំណាយ ត្រូវស្រង់ដោយមន្ត្រីសម្ភាសន៍។

លើសពីនេះទៀត មន្ត្រីត្រួតពិនិត្យមានភារកិច្ចពិនិត្យមើលរាល់កំហុសទាំងឡាយដែលកើតមានឡើងក្នុងតារាងសំណួរទាំងអស់ដែលសម្ភាសន៍រួចតាមកាលបរិច្ឆេទកំណត់ជាក់លាក់ ហើយបើកាលណារកឃើញកំហុសនោះតម្រូវឱ្យមន្ត្រីសម្ភាសន៍ទៅជួបគ្រួសារ ដើម្បីធ្វើសម្ភាសន៍ឡើងវិញ។ នៅពេលបញ្ចប់ការងារចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យសម្រាប់ខែនីមួយៗ ក្រុមការងារត្រូវបញ្ជូនទម្រង់សំណួរទាំងបួនដែលបានសម្ភាសន៍បំពេញរួចទាំងអស់ពីភូមិ ឬមណ្ឌលអង្កេតដែលខ្លួនទទួលខុសត្រូវមកឱ្យវិទ្យាស្ថានជាតិស្ថិតិដើម្បីឱ្យក្រុមមន្ត្រីកែដៃទិន្នន័យធ្វើកិច្ចការបន្ត ដូចជាការពិនិត្យផ្ទៀងផ្ទាត់ ការដាក់លេខកូដ និងការវាយបញ្ចូលទិន្នន័យជាដើម។ល។

ម្យ៉ាងវិញទៀត ដើម្បីធានាឱ្យការចុះប្រមូលទិន្នន័យមានគុណភាពកាន់តែប្រសើរឡើង ក្រុមការងារទាំងអស់មុនពេលចុះទៅភូមិ ឬមណ្ឌលអង្កេត បានតម្រូវឱ្យចូលរួមប្រជុំរយៈពេលមួយថ្ងៃ ដើម្បីស្តាប់ការពន្យល់ណែនាំបន្ថែមអំពីការកែលម្អរាល់កំហុសឆ្គងបន្តិចបន្តួច ក៏ដូចជាការកែសម្រួលនូវចំណុចខ្លះ នៃវិធីសាស្ត្រសម្ភាសន៍ដែលអាចកើតមាន និងបានរកឃើញដោយសារការចុះត្រួតពិនិត្យផ្ទាល់ពីសំណាក់មន្ត្រីដឹកនាំគម្រោង និងមន្ត្រីវិភាគព្រមទាំងកំហុសឆ្គងខ្លះទៀត ដែលបានរកឃើញដោយមន្ត្រីកែដៃទិន្នន័យក្នុងពេលពិនិត្យផ្ទៀងផ្ទាត់ពេលកែកំហុស និងដាក់លេខកូដ និងការបញ្ចូលទិន្នន័យ។ល។

### ១.៨.៣. ការចុះត្រួតពិនិត្យតាមដានការងារ

ដោយសារវិសាលភាពនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវការនូវប្រព័ន្ធដ៏ទូលំទូលាយមួយសម្រាប់ការគ្រប់គ្រង និងការត្រួតពិនិត្យតាមដានលើគុណភាព ទើបរាល់កំហុសឆ្គងទាំងឡាយអាចត្រូវបានរកឃើញភ្លាមៗ។ ដូច្នេះហើយមានតែការទប់ស្កាត់កុំឱ្យមានបញ្ហា និងកំហុសឆ្គងក្នុងពេលប្រតិបត្តិការប្រមូលទិន្នន័យទាន់ពេលវេលាទេ ដែលអាចធានាបាននូវគុណភាពអង្កេត។ ក្រុមការងារដឹកនាំគម្រោងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជារបស់វិទ្យាស្ថានជាតិស្ថិតិ បានរៀបចំផែនការចុះត្រួតពិនិត្យតាមដានការងារប្រមូលទិន្នន័យតាំងពីពេលចាប់ផ្តើមនៃដំណាក់កាលដំបូង។

ដោយឡែក ក្រុមការងារដឹកនាំគម្រោងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជានៅក្នុងឆ្នាំ២០១៩/២០ រួមមានមន្រ្តីដឹកនាំគម្រោង និងមន្រ្តីវិភាគតាមប្រធានបទ បានចុះទៅត្រួតពិនិត្យជាក់ស្តែងនៅតាមមូលដ្ឋាន ចាប់ពីមួយសប្តាហ៍ ដល់ពីរសប្តាហ៍។ អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ បានចំណាយពេលពីបីទៅបួនថ្ងៃ រៀងរាល់ខែចុះត្រួតពិនិត្យជាមួយក្រុមការងារ។ ចំណែកទីប្រឹក្សារបស់ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែតប្រចាំនៅវិទ្យាស្ថានជាតិស្ថិតិរយៈពេលវែង មានពេលខ្លះក៏បានចូលរួមចុះត្រួតពិនិត្យមើលការងារ ប្រមូលទិន្នន័យនៅតាមមូលដ្ឋានផងដែរ។ ការចុះត្រួតពិនិត្យតាមដានការងារបានកំណត់តាមវិធីសាស្រ្តពីរយ៉ាង គឺវិធីសាស្រ្តចុះត្រួតពិនិត្យដោយបានជូនដំណឹងមុន និងការចុះត្រួតពិនិត្យដោយមិនបានជូនដំណឹងមុន។ ក្នុងអំឡុងពេលចុះត្រួតពិនិត្យក្រុមប្រមូលទិន្នន័យនីមួយៗ ត្រូវបានក្រុមការងារចុះទៅជួបយ៉ាងតិចក៏មួយម្តងដែរ ដើម្បីឆែកពិនិត្យមើលតារាងសំណួរទាំងអស់ដែលបានសម្ភាសន៍រួច។ ដូចនេះ សកម្មភាពចុះត្រួតពិនិត្យរបស់ក្រុមការងារមានគោលបំណងសំខាន់ជាច្រើន ជាពិសេស គឺដើម្បីពង្រឹងនូវគុណភាព។ ទន្ទឹមគ្នានេះដែរ ការតាមដានត្រួតពិនិត្យមើលលើវិន័យ និងគោលការណ៍អនុវត្តពេលបំពេញការងាររបស់មន្រ្តីត្រួតពិនិត្យ និងមន្រ្តីសម្ភាសន៍ ក៏មានសារៈសំខាន់ផងដែរ ពីព្រោះវាអាចស្វែងយល់អំពីចំណេះដឹង និងការទទួលខុសត្រូវលើការងារជាក់ស្តែងរបស់ពួកគេនៅតាមមូលដ្ឋាន។ ម្យ៉ាងទៀត ការផ្តល់ព័ត៌មានត្រឡប់ និងការលើកទឹកចិត្តដល់មន្រ្តីត្រួតពិនិត្យនិងមន្រ្តីសម្ភាសន៍ ក៏ជាវិធីសាស្រ្តដ៏មានសារៈសំខាន់មួយផងដែរ ព្រោះអាចជួយពួកគេបំពេញនូវចំណេះដឹងបន្ថែមក្រោយការបណ្តុះបណ្តាល តាមរយៈការផ្តល់ជាមតិយោបល់ ការពន្យល់ណែនាំ និងការបំពេញនូវសំណូមពរនានា ដើម្បីដោះស្រាយរាល់បញ្ហាដែលអាចកើតមានឡើងក្នុងកំលុងពេលប្រតិបត្តិការចុះប្រមូលទិន្នន័យ។

## ១.៩ ប្រព្រឹត្តិកម្មទិន្នន័យអង្កេត ( Data processing )

ការបញ្ចូលទិន្នន័យបានធ្វើនៅវិទ្យាស្ថានជាតិស្ថិតិ ដោយប្រើកម្មវិធី CSPro ដែលជាកម្មវិធីមួយអភិវឌ្ឍរួមគ្នាដោយការិយាល័យជំរឿនរបស់សហរដ្ឋអាមេរិក ( United States Census Bureau ) កម្មវិធីរបស់ ICF International និងកម្មវិធី Serpro S.A.។ កុំព្យូទ័រចំនួន ១៣ គ្រឿងដែលបានភ្ជាប់បណ្តាញ និង Server ត្រូវបានប្រើបញ្ចូលទិន្នន័យបានចាប់ផ្តើមនៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៩ ពីរខែបន្ទាប់ពីការកែដៃដាក់កូដដំបូងត្រូវបានធ្វើឡើង។ មន្រ្តីទទួលបន្ទុកបញ្ចូលទិន្នន័យបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអំពីបញ្ជីសំណួរសម្រាប់អ្នកសម្ភាសដើម្បីឱ្យពួកគេយល់អំពីឧបករណ៍អង្កេត។ មន្រ្តីប្រព្រឹត្តិកម្មទិន្នន័យ រួមមានប្រធានកែដៃទិន្នន័យមួយនាក់ អ្នករៀបចំកម្មវិធី CSPro មួយនាក់ អ្នកជំនួយការពីរនាក់ (មួយនាក់សម្រាប់សម្អាតទិន្នន័យ និងមួយនាក់ទៀតសម្រាប់ Network/Server ) និងអ្នកបញ្ចូលទិន្នន័យចំនួន ១៣នាក់ ។ បញ្ជីសំណួរដែលបានបំពេញរួច គឺត្រូវបានបញ្ជូនមកពីក្រុមកែដៃដាក់កូដ ដោយអ្នកកែដៃដាក់កូដ ។ ការបញ្ចូលទិន្នន័យត្រូវបានធ្វើនៅថ្ងៃទី១៨ ខែ

កញ្ញា ឆ្នាំ២០២០រហូតដល់ចប់ស្ថាពរ។ ការពិនិត្យផ្ទៀងផ្ទាត់ពីសង្គតិភាពផ្ទៃក្នុង និងការរៀបរៀងលើកទីពីរ សម្អាតទិន្នន័យនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០។

### ១.៩.១ ការបណ្ដុះបណ្ដាលមន្ត្រីអង្កេត

នៅខែមិថុនា ឆ្នាំ២០១៩ ក្រុមការងារកែដៃទិន្នន័យក៏បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលសម្រាប់មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យផងដែរ។ គោលបំណងសំខាន់នៃការបណ្ដុះបណ្ដាល គឺដើម្បីកំណត់ និងស្វែងរកវាល់បញ្ហា និងភាពមិនប្រក្រតីទាំងឡាយដែលមាននៅក្នុងតារាងសំណួរ និងដើម្បីពិភាក្សាលម្អិតលើទស្សនាទាន ក៏ដូចជាមតិយោបល់ដែលបានលើកឡើងជាក់ស្តែងក្នុងអំឡុងពេលបណ្ដុះបណ្ដាល ដើម្បីចៀសវាង និងកាត់បន្ថយនូវរាល់កំហុសឆ្គងផ្សេងៗ ឱ្យមានត្រឹមកម្រិតតិចតួចបំផុត ដែលអាចធ្វើទៅបានសម្រាប់ការចុះប្រមូលទិន្នន័យនាពេលបន្តបន្ទាប់ទៀត។ ដោយឡែកចាប់ពីខែមិថុនា ឆ្នាំ២០១៩ ក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ បានចូលរួមការត្រួតពិនិត្យបញ្ហាផ្សេងៗ ដែលបានលើកឡើងដោយមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យ ដែលបានរកឃើញកំហុស និងភាពមិនប្រក្រតីទាំងឡាយ ក្នុងអំឡុងពេលចុះសម្ភាសន៍ និតកត់ត្រាទិន្នន័យតាមមូលដ្ឋាន។

### ១.៩.២ ការពិនិត្យផ្ទៀងផ្ទាត់ និង ការដាក់លេខកូដទិន្នន័យ

ក្រុមការងារដាក់លេខទិន្នន័យ បានចាប់ផ្តើមការងារត្រួតពិនិត្យ និងដាក់លេខកូដនៅដើមខែកក្កដាឆ្នាំ ២០១៩ បន្ទាប់ពីទទួលបានការប្រមូលទិន្នន័យនៅខែដំបូងបានបញ្ចប់។ ក្រុមការងារនេះមានមន្ត្រីចូលរួមទាំងអស់ចំនួន ១៣នាក់ រួមបញ្ចូលមន្ត្រី២នាក់ សម្រាប់ការងារគ្រប់គ្រង និងត្រួតពិនិត្យលេខកូដ។ មន្ត្រីត្រួតពិនិត្យដែលវិលត្រឡប់មកពីមូលដ្ឋាន បានប្រគល់តារាងសំណួរបំពេញរួចទាំងអស់មកឱ្យក្រុមការងារកែច្នៃទិន្នន័យ និងដាក់លេខកូដនៅវិទ្យាស្ថានជាតិស្ថិតិ ហើយក្នុងដំណាក់កាល នៃការទទួលតារាងសំណួរ និងពិនិត្យទិន្នន័យដាក់លេខកូដ មានក្រុមការងារថ្នាក់កណ្ដាលដែលរួមមាន មន្ត្រីគ្រប់គ្រងគម្រោងអង្កេតបានជួយលើការងារសម្របសម្រួល និងជួយដោះស្រាយរាល់បញ្ហាពាក់ព័ន្ធទាំងឡាយដែលអាចកើតមានឡើងនៅពេលពិនិត្យតារាងសំណួរ។

### ១.៩.៣ ការណែនាំជាមូលដ្ឋាន

គ្រប់តារាងសំណួរទាំងអស់ដែលបានបំពេញរួចពីភូមិ ឬមណ្ឌលអង្កេតគំរូនីមួយៗ ត្រូវប្រគល់ឱ្យក្រុមការងារកែដៃ និងដាក់លេខកូដទិន្នន័យ ដោយមន្ត្រីត្រួតពិនិត្យពេលបញ្ចប់ការចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យសម្រាប់ខែនីមួយៗ។ ក្រុមការងារកែដៃ និងដាក់លេខកូដទិន្នន័យ គឺត្រូវទទួលខុសត្រូវក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងត្រួតពិនិត្យលេខកូដលើតារាងសំណួរដែលបានទទួលពីមន្ត្រីត្រួតពិនិត្យនៅតាមមូលដ្ឋាន នៅពេលផ្ទៀងផ្ទាត់ និងការដាក់លេខកូដ ដោយត្រូវប្រើប៊ិចពណ៌ក្រហមដើម្បីសរសេរលើតារាងសំណួរ។

### ១.៩.៤ ការរៀបចំលំហូរការងារនៅទីស្នាក់ការ

ការផ្ទៀងផ្ទាត់ និងការដាក់លេខកូដ គឺជាផ្នែកសំខាន់មួយនៃការកែច្នៃទិន្នន័យទូទៅសម្រាប់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩-២០។ ចំពោះដំណើរការផ្ទៀងផ្ទាត់ទិន្នន័យ និងដាក់កូដអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩នេះ គឺមានលក្ខណៈដូចគ្នាទៅនឹងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាមុនៗ (រួមមានអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ ដល់ ឆ្នាំ២០១៤)។ សូមមើលការបរិយាយដូចខាងក្រោម៖

- មន្ត្រីត្រួតពិនិត្យដែលចុះប្រមូលទិន្នន័យតាមមូលដ្ឋាន ត្រូវយកតារាងសំណួរដែលបានបំពេញរួចចប់សព្វគ្រប់មកប្រគល់ឱ្យក្រុមការងារកែច្នៃទិន្នន័យ។ តារាងសំណួរទាំងនោះ ត្រូវរៀបចំតាមភូមិ ឬមណ្ឌលអង្កេតគំរូនីមួយៗ រួមមានផែនទី តារាងចុះបញ្ជីគ្រួសារ តារាងសំណួរភូមិ តារាងសំណួរគ្រួសារ និងតារាងកត់ត្រាព័ត៌មានប្រចាំថ្ងៃរបស់គ្រួសារ បន្ទាប់មកក្រុមការងារកែច្នៃទិន្នន័យ (មន្ត្រីត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ) បានចាប់ផ្តើមពិនិត្យមើលតារាងសំណួរទាំងអស់ពីភូមិ ឬមណ្ឌលអង្កេតគំរូនីមួយៗ រួមទាំងការកែកំហុស ការដាក់លេខកូដ។ល។
- មន្ត្រីត្រួតពិនិត្យដែលចុះសម្ភាសន៍ និងកត់ត្រាទិន្នន័យតាមមូលដ្ឋាន ត្រូវរង់ចាំការផែកពិនិត្យមើលឯកសារពីក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ ប្រសិនបើមានបញ្ហាឬកំហុសឆ្គងណាមួយបានរកឃើញ ក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ ត្រូវសួរមន្ត្រីត្រួតពិនិត្យតាមមូលដ្ឋានភ្លាមៗ ដើម្បីឱ្យពួកគេដោះស្រាយនិងកែសម្រួលនូវកំហុសឆ្គងទាំងនោះ។ បន្ទាប់ពីបញ្ចប់ការកែសម្រួលរួច ក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ បានចាប់ផ្តើមដំណើរការដាក់លេខកូដ ក្រុមលេខកូដដែលបានប្រើរួមមាន លេខកូដផលដំណាំ លេខកូដមុខរបរ លេខកូដវិស័យសេដ្ឋកិច្ច លេខកូដចំណូលនិងចំណាយ និងលេខកូដឯកតា ជាដើម។ល។
- ពេលក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ បានរកឃើញកំហុសឆ្គងដែលមិនអាចកែសម្រួលបានដោយខ្លួនឯង ក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ គឺត្រូវធ្វើការពិភាក្សាជាមួយមន្ត្រីត្រួតពិនិត្យដែលចុះប្រមូលទិន្នន័យតាមមូលដ្ឋាន ឬក៏ទូរសព្ទ័ហៅមន្ត្រីសម្ភាសន៍មកសាកសួរផ្ទាល់។ បន្ទាប់ពីការកែសម្រួលនិងការដាក់លេខកូដបានបញ្ចប់ ក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ ត្រូវរៀបចំទុកដាក់ឯកសារទាំងអស់តាមភូមិ ឬមណ្ឌលអង្កេតគំរូនីមួយៗតាមលំដាប់លំដោយ ចូលទៅក្នុងប្រអប់ដែលមានបិទលេខសម្គាល់ជាស្រេច ទើបបញ្ជូនទៅឱ្យក្រុមការងារបញ្ចូលទិន្នន័យបន្តទៀត។
- ក្នុងករណីក្រុមការងារបញ្ចូលទិន្នន័យ បានរកឃើញនូវកំហុសឆ្គងណាមួយនៅពេលវាយបញ្ចូលទិន្នន័យ ពួកគេក៏ត្រូវបញ្ជូនតារាងសំណួរទាំងនោះត្រឡប់មកឱ្យក្រុមការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ ដើម្បីធ្វើការពិនិត្យមើលឡើងវិញ។ ការពិនិត្យផ្ទៀងផ្ទាត់ និងការដាក់លេខកូដ បានអនុវត្តជារៀងរាល់ខែ ហើយនិងត្រូវរៀបចំដំណើរការមួយសប្តាហ៍មុនការចាប់ផ្តើមបញ្ចូលទិន្នន័យ។
- ក្នុងអំឡុងពេលវិភាគទាញតារាងទិន្នន័យ ការពិនិត្យផ្ទៀងផ្ទាត់ និងសម្អាតទិន្នន័យ ក៏ត្រូវបានអនុវត្តផងដែរ ដោយក្រុមមន្ត្រីជំនាញវិភាគតាមប្រធានបទដែលទទួលខុសត្រូវតាមផ្នែកនីមួយៗ របស់វិទ្យាស្ថានជាតិស្ថិតិ ដោយមានការសហការជាមួយអ្នកជំនាញការរបស់ធនាគារពិភពលោក។

## ១.១០ ភាពអាចប្រៀបធៀបបាននៃទិន្នន័យអង្កេត

លទ្ធផលទិន្នន័យពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ អាចធ្វើការប្រៀបធៀបបានជាមួយនិងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាមុនៗ ដែលត្រូវបានធ្វើនៅក្នុងឆ្នាំ២០០៤ និងឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០១៧ កន្លងមក។ យ៉ាងណាមិញ ការផ្លាស់ប្តូរក្នុងការរៀបចំតារាងសំណួរក្នុងការអង្កេតនីមួយៗ ពិតជាមានផលប៉ះពាល់ទៅលើលទ្ធភាពនៃការប្រៀបធៀបពុំខានឡើយ។ ឧទាហរណ៍៖ ម៉ូឌុលនៃភាពរងគ្រោះ ពុំត្រូវបានរាប់បញ្ចូលក្នុងសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៨ឡើយ ហើយម៉ូឌុលដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពសេដ្ឋកិច្ចបច្ចុប្បន្ន មានការកែប្រែច្រើននៅក្នុងឆ្នាំ២០១០ ធៀបនឹងអង្កេតឆ្នាំមុនៗ។ នៅក្នុងអង្កេតឆ្នាំ២០១៤ប្រធានបទវិភាគខ្លះៗត្រូវបានបញ្ចូលថែមនិងធ្វើបច្ចុប្បន្នភាព។ ចំពោះការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាក្នុងឆ្នាំ២០១៩/២០ ក៏មានការកែប្រែខ្លះដែរ ជាពិសេសនៅក្នុងម៉ូឌុលនៃការចំណាយប្រើប្រាស់របស់គ្រួសារ (សម្រាប់ព័ត៌មានលម្អិត សូមមើលកថាខណ្ឌទី១.៧ អំពីការរៀបចំតារាងសំណួរ)។

នៅពេលដែលយើងធ្វើការប្រៀបធៀបលទ្ធផលចេញពីអង្កេត(អសសក ឬ CSES) រវាងឆ្នាំផ្សេងៗគ្នាជាសំខាន់ គឺយើងត្រូវទទួលស្គាល់ថា មានភាពលម្អៀងនៅក្នុងការប៉ាន់ស្មានស្ថិតិ។ នៅក្នុងអង្កេតសំណាកគំរូដូចជាការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជានេះអាចនឹងពុំមានសុក្រឹតភាពពេញលេញនៅក្នុងលទ្ធផលដែលបានប៉ាន់ស្មានឡើយ ដោយសារពុំបានសួរមនុស្ស ឬគ្រួសារទាំងអស់។ ទំហំនៃភាពមិនត្រឹមត្រូវ មិនអាចដឹងបានឡើយ ដែលជាហេតុនាំអោយមានភាពលម្អៀងកើតមានឡើងនៅក្នុងការប៉ាន់ស្មានស្ថិតិ។ ភាពលម្អៀងធម្មតានេះ ជាធម្មតាត្រូវបានបង្ហាញដោយអ្វីដែលគេហៅថា ចន្លោះនៃកម្រិតជឿជាក់ដែលស្ថិតនៅជុំវិញលទ្ធផលដែលបានប៉ាន់ស្មានរបស់វា។




ឧទាហរណ៍១៖ ចំនួនបន្ទប់ជាមធ្យមសម្រាប់មួយគ្រួសារ ក្នុងប្រទេសកម្ពុជា នៅក្នុង អសសក ឆ្នាំ២០១៤ ត្រូវបានប៉ាន់ស្មានស្មើនឹង១,៤៦ ហើយតម្លៃលម្អៀងរបស់វាគឺ ០,០០៦។ រីឯចំនួនបន្ទប់ជាមធ្យមក្នុងមួយគ្រួសារក្នុងប្រទេសកម្ពុជា នៅក្នុង អសសក ឆ្នាំ ២០១៩/២០ ត្រូវបានប៉ាន់ស្មានស្មើនឹង១,៦៥ ហើយតម្លៃលម្អៀងរបស់វា គឺ០,០១។ មានន័យថាចំនួនបន្ទប់ជាមធ្យមពិត សម្រាប់មួយគ្រួសារក្នុងប្រទេសកម្ពុជា នៅក្នុង អសសកឆ្នាំ២០១៤ គឺស្ថិតនៅក្នុងចន្លោះ១,៤៥ និង១,៤៧ ហើយនៅក្នុងឆ្នាំ២០១៩/២០ ស្ថិតនៅក្នុងចន្លោះ១,៦៣ និង១,៦៧។ ដោយសារតែតម្លៃនៃចន្លោះទាំងនេះមិនត្រួតស៊ីគ្នា យើងអាចសន្និដ្ឋានបានថាពិតជាមានការប្រែប្រួលបានកើតមានឡើងប្រាកដមែន ចំពោះចំនួនបន្ទប់ជាមធ្យមសម្រាប់មួយគ្រួសារក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០។




ឧទាហរណ៍២៖ ចំនួនបន្ទប់ជាមធ្យម សម្រាប់មួយគ្រួសារនៅរាជធានីភ្នំពេញនៅក្នុង អសសក ឆ្នាំ២០១៤ ត្រូវបានប៉ាន់ស្មានស្មើនឹង ២,០៥ ហើយតម្លៃលម្អៀងរបស់វាគឺ០,០២។ រីឯចំនួនបន្ទប់ជាមធ្យមសម្រាប់មួយគ្រួសារនៅរាជធានីភ្នំពេញ នៅក្នុង អសសក ឆ្នាំ២០១៩/២០ ត្រូវបានប៉ាន់ស្មានស្មើនឹង២,១៦ហើយតម្លៃលម្អៀងរបស់វាគឺ០,០៥។ មានន័យថាចំនួនបន្ទប់ជាមធ្យមពិតសម្រាប់មួយគ្រួសារនៅរាជធានីភ្នំពេញ នៅក្នុង អសសក ឆ្នាំ ២០១៤ គឺស្ថិតនៅក្នុងចន្លោះ ២,០១ និង ២,១០ ហើយនៅក្នុងឆ្នាំ២០១៩/២០ ស្ថិតនៅក្នុងចន្លោះ ២,០៧ និង ២,២៥។ ដោយសារតែតម្លៃនៃចន្លោះទាំងនេះត្រួតស៊ីគ្នា យើងមិនអាចសន្និដ្ឋានបានថា ពិតជាមានការប្រែប្រួលបានកើតមានឡើងប្រាកដចំពោះចំនួនបន្ទប់ជាមធ្យមក្នុងមួយគ្រួសារនៅរាជធានីភ្នំពេញក្នុងអំឡុងពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០។

ទោះជាយ៉ាងណា ការប្រៀបធៀបលទ្ធផលទិន្នន័យពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ជាមួយនឹងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជានៅមុនឆ្នាំ២០០៤ ដូចជា៖ ឆ្នាំ១៩៩៣/៩៤ ១៩៩៦ ១៩៩៧ និង ១៩៩៩ គឺពុំគួរត្រូវបានធ្វើការប្រៀបធៀបនោះឡើយ ដោយហេតុថាមានភាពខុសគ្នានៃគ្រោងការអង្កេត។

មេគុណប៉ាន់ស្មានស្ថិតិដែលបានប្រើប្រាស់ជាលើកដំបូងនៅក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាពីឆ្នាំ២០០៤ ត្រូវបានធ្វើការកែតម្រូវមេគុណដោយផ្អែកតាមជំរឿនទូទៅប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨ ដើម្បីធានាបានក្នុងការប្រៀបធៀបគ្នាបានជាមួយនិងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជារវាងពីឆ្នាំ២០០៤ និងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាសម្រាប់គ្រាបន្ទាប់ទៀត។

## ១.១១ ការផ្សព្វផ្សាយទិន្នន័យ

តារាងទិន្នន័យភាគច្រើនពីរបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានបង្ហាញនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ (http://www.nis.gov.kh)។ គេហទំព័រមានផ្ទុកនូវរាល់លទ្ធផលពីការធ្វើជំរឿន និងអង្កេតនានា ការបោះពុម្ពផ្សាយកំណត់តាមពេលវេលា (មានដូចជា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ គណនេយ្យជាតិ) និងឯកសារផ្សេងៗ ដែលបានផ្សព្វផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានឯកសារភាគច្រើនបំផុតអាចរកបាននៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ សម្រាប់ការទាញយកមកប្រើប្រាស់ដែលមាននៅក្នុងទម្រង់បែបបទស្ថិតិ។

ឯកសារផ្សេងៗនៃការធ្វើអង្កេត ត្រូវរក្សាទុកក្នុង NADA Toolkit (គេហទំព័រមួយផ្អែកតាមឧបករណ៍ពាក់ព័ន្ធ)។ NADA អាចប្រើប្រាស់ ដើម្បីរៀបចំឯកសារអេឡិចត្រូនិច (Online) និងអាចប្រើរួមគ្នា ជាមួយទិន្នន័យមីក្រូ (Microdata) ដែលផ្សព្វផ្សាយតាម CD/USB បន្ទាប់ពីមានការស្នើសុំជាផ្លូវការមកកាន់ក្រសួងផែនការ។ ទម្រង់ការបែបនេះ គឺជាវិធីសមស្របនិងនិយមប្រើប្រាស់សម្រាប់ធ្វើការផ្សព្វផ្សាយទិន្នន័យក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ ដើម្បីឱ្យលទ្ធផលចុងក្រោយនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ក៏ដូចជាមេតាទិន្នន័យអាចត្រូវបានទាញយកមកប្រើប្រាស់បាន។ សូចនាករមួយចំនួនពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ក៏ត្រូវបានបង្ហាញនៅក្នុង CamInfo ផងដែរ (លើកមុន)ដែលជាប្រព័ន្ធមូលដ្ឋានទិន្នន័យសេដ្ឋកិច្ចសង្គមកិច្ចរបស់ប្រទេសកម្ពុជា ហើយក្នុងនោះ CamInfo ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការត្រួតពិនិត្យលើវឌ្ឍនភាពឆ្ពោះទៅគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍(MDG)។ ប៉ុន្តែបច្ចុប្បន្នកម្រងសូចនាករទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាត្រូវបានប្តូរបង្ហាញជូននៅក្នុងប្រព័ន្ធកម្មវិធីខេមស្ដាត (CamStat) ដែលប្រើសម្រាប់ត្រួតពិនិត្យនិងវាស់វែងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(ឬហៅថា SDGs)។

## ១.១២ ភាពសម្ងាត់នៃព័ត៌មានទិន្នន័យ

ច្បាប់ស្ថិតិមាត្រាទី២២ បានបញ្ជាក់អំពីបញ្ហានៃភាពសម្ងាត់។ ច្បាប់បានចែងយ៉ាងច្បាស់ថា រាល់មន្ត្រីរាជការ បុគ្គលិកទាំងអស់ដែលបម្រើការផ្នែកស្ថិតិនៅក្នុងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា "ត្រូវធានានិងរក្សាការសម្ងាត់នូវរាល់ព័ត៌មានទាំងអស់ដែលទទួលបានមកពីការឆ្លើយតបរបស់បុគ្គល ឬ អ្នកឆ្លើយ លើកលែងតែនៅក្នុងករណីពិសេសចាំបាច់ណាមួយ ដែលមានការយល់ព្រម និងការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងផែនការ។ រាល់ព័ត៌មានដែលប្រមូលបាននៅក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅបម្រើឱ្យផ្នែកស្ថិតិប៉ុណ្ណោះ"។

## ១.១៣ មន្ត្រីជំនាញចូលរួមការងារវិភាគទិន្នន័យ

របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ត្រូវបានវិភាគតាមប្រធានបទសំខាន់ៗ ដោយមន្ត្រីជំនាញរបស់វិទ្យាស្ថានជាតិស្ថិតិ ដែលមានជប់ប្រធានបទ ដូចមានរាយនាមទទួលបន្ទុកខាងក្រោម៖

- ផ្នែកប្រជាសាស្ត្រ៖ វិភាគដោយលោក ប៉ែន សុជាតិ លោកជំទាវ សូរ្យ សុវណ្ណចរិយា និងកញ្ញា ហង់ ផល្លី
- ផ្នែកលំនៅដ្ឋាន៖ វិភាគដោយលោក ប៉ូ ម៉ៅ លោក ម៉ក់ សុវិជ្ជា និងលោក សោម បូនី
- ផ្នែកកសិកម្ម៖ វិភាគដោយឯកឧត្តម គង់ សេង លោក សូ តូនែរ លោកស្រី នង សុគន្ធារី និងលោក ឃឹម សុជាតិ
- ផ្នែកអប់រំ៖ វិភាគដោយលោក ឡិញ ហ៊ាង កញ្ញា ច័ន្ទ លក្ខិណា និង កញ្ញា ជួន សុគន្ធា
- ផ្នែកកម្លាំងពលកម្ម៖ វិភាគដោយលោក ខៀវ ខេមរិទ្ធ លោកស្រី លឹម ផូវ៉ត្ថមាលា និងលោកស្រី ប៉ែន សោភា
- ផ្នែកសុខភាព៖ វិភាគដោយលោក ផន ចិន្តា លោក ថោង វណ្ណដេត និងលោក ទុយ វណ្ណពន្លក
- ផ្នែកការទទួលរងគ្រោះ៖ លោក អ៊ុកចាយ បញ្ញារិទ្ធ និងលោកស្រី ព្រហ្ម ម៉ាឡា
- ផ្នែកចំណូល និងឥណទាន(បំណុល)របស់គ្រួសារ៖ លោក ឃឹម សៅនីត និងលោក អ៊ុន សារិន
- ផ្នែកចំណាយប្រើប្រាស់របស់គ្រួសារ៖ វិភាគដោយលោក អឿ សុផល លោក សំ សុខសុជារុជ លោក ហួរ ឡុងផេង លោក លី សុផានិត និងលោក ជា ធី
- ផ្នែកភាពងាយរងគ្រោះ៖ វិភាគដោយលោកស្រី យិត វីរិយ៉ា លោកស្រី ម៉ី សុខម៉ារ៉ាឌី និងលោក ទេព ស័ក្តមករា

អ្នកវិភាគផ្សេងទៀតរបស់វិទ្យាស្ថានជាតិស្ថិតិ ដែលបានចូលរួមចំណែកលើការងារបច្ចេកទេសរួមមាន៖

- សេចក្តីផ្តើម៖ សរសេរដោយឯកឧត្តម ណោ វ៉ាន់ឌី និងលោក គឹម ណេត
- ការរៀបចំ និងការធ្វើផែនការអង្កេត៖សរសេរដោយឯកឧត្តម ណោ វ៉ាន់ឌី
- ការជ្រើសរើសសំណាកគំរូអង្កេត៖ សរសេរដោយឯកឧត្តម ណោ វ៉ាន់ឌី លោក វ៉ុន ធី លោកសូ តូនែរ និងលោក សុខ បូរិទ្ធ
- ការរៀបចំតារាងសំណួរអង្កេត៖ សរសេរដោយលោក គឹម ណេត លោក ប៉ូ ម៉ៅ និងលោក ម៉ក់ សុវិជ្ជា
- ការបណ្តុះបណ្តាល និងការចុះប្រតិបត្តិការនៅតាមមូលដ្ឋាន៖ សរសេរដោយឯកឧត្តម ណោ វ៉ាន់ឌី លោក គឹម ណេត និងលោក សូ តូនែរ។
- ប្រព្រឹត្តិកម្មទិន្នន័យអង្កេត៖ លោក នឹម សៅមុនី លោកស្រីជុំ ពុទ្ធីវណ្ណ និងលោក ម៉ៅ ធឹម
- បច្ចេកវិទ្យាព័ត៌មានវិទ្យា៖ ឯកឧត្តម សាំង ឡុងឌី លោកស្រីជុំ ពុទ្ធីវណ្ណ និងលោក ចាវ ភាវ
- ការផ្សព្វផ្សាយទិន្នន័យអង្កេត៖ ឯកឧត្តម សាំង ឡុងឌី ឯកឧត្តម ណោ វ៉ាន់ឌី និងលោកស្រីជុំ ពុទ្ធីវណ្ណ

## ១.១៤ ការកំណត់និយមន័យ និង ចំណាត់ថ្នាក់

### កម្រិតនៃការបំបែកតាមតំបន់ភូមិសាស្ត្រ

ក្រៅពីការបង្ហាញលទ្ធផលសម្រាប់ប្រទេសកម្ពុជាទាំងមូល របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ក៏មានបង្ហាញនូវលទ្ធផលតាមកម្រិតនៃការបំបែកតាមតំបន់ភូមិសាស្ត្រផ្សេងៗផងដែរ។ ការបំបែកតាមតំបន់ភូមិសាស្ត្រសម្រាប់អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ត្រូវបានអនុវត្តដោយយោងតាមការ

បំបែកតំបន់ភូមិសាស្ត្រ ដែលកំណត់ដោយជំរឿនប្រជាជាពលរដ្ឋកម្ពុជានៅឆ្នាំ២០០៨[2] និងជំរឿនប្រជាពលរដ្ឋកម្ពុជានៅឆ្នាំ២០១៩។ ក្នុងការកំណត់ចំណាត់ថ្នាក់របស់ជំរឿនប្រជាពលរដ្ឋឆ្នាំ២០១៩ បានបញ្ជាក់ថារាល់ឃុំទាំងអស់ដែលអាចកំណត់ជាទីប្រជុំជនបានត្រូវផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

- ដង់ស៊ីតេប្រជាពលរដ្ឋលើសពី២០០នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។
- ភាគរយបុរសដែលធ្វើការនៅក្នុងវិស័យកសិកម្មមានអត្រាក្រោម៥០%។
- ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងឃុំត្រូវលើសពី២.០០០នាក់។

### ទីកន្លែងរស់នៅ (កម្រិតនគរូបនីយកម្ម)

កម្រិតថ្នាក់ក្រោមជាតិបន្ទាប់ពីថ្នាក់ជាតិ (ប្រទេស) ហើយមានសារៈសំខាន់បំផុតនោះ ដែលអាចចាត់ជាទីកន្លែងរស់នៅត្រូវបានបំបែកជាពីរផ្នែកដូចខាងក្រោម ៖

- ទីប្រជុំជន
- ជនបទ

### ទីតាំងភូមិសាស្ត្រ

របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានបំបែកចេញជាស្ថានភាពភូមិសាស្ត្រមានបីទីតាំងសំខាន់ៗដូចខាងក្រោម ៖

- រាជធានីភ្នំពេញ
- ទីប្រជុំជនផ្សេងៗ
- ជនបទ

ចំពោះរាជធានីភ្នំពេញ រួមបញ្ចូលទាំងទីប្រជុំជន និងជនបទសម្រាប់ការអង្កេតមុនៗ។ ដោយឡែកសម្រាប់ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ពុំមានជនបទនោះទេ។

### តំបន់

សម្រាប់កម្រិតថ្នាក់ក្រោមជាតិទីបី ដែលមិនសូវបានយកប្រើប្រាស់នៅក្នុងរបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា បានបំបែកចេញតាមទីតាំងភូមិសាស្ត្រ និងបានកំណត់ជាប្រាំតំបន់ដូចខាងក្រោម ៖

- ភ្នំពេញ (រាជធានីភ្នំពេញ)
- តំបន់វាលទំនាប (ខេត្តកំពង់ចាម ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តតាកែវ)
- តំបន់ទន្លេសាប (ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់)
- តំបន់ឆ្នេរសមុទ្រ (ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកោះកុង)
- តំបន់ភ្នំ និងខ្ពង់រាប (ខេត្តកំពង់ស្ពឺ ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តរតនៈគិរី ខេត្តស្ទឹងត្រែង ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន)

[2] ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ២០០៨។ របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ ខែសីហា ឆ្នាំ២០០៩។

## អាយុ

អាយុត្រូវបានកំណត់ជាឆ្នាំសុរិយគតិពេញលេញ។ ការកំណត់ គឺគិតជាចន្លោះពេលវេលាប៉ាន់ស្មានមួយ រវាងកាលបរិច្ឆេទនៃកំណើតរបស់សមាជិកគ្រួសារម្នាក់ៗ និងកាលបរិច្ឆេទនៃការចុះសម្ភាសន៍នៅពេលជួបគ្រួសារលើកដំបូង។ ព័ត៌មានអាយុត្រូវធ្វើការកត់ត្រាឱ្យបានលម្អិតអំពីកាលបរិច្ឆេទថ្ងៃខែឆ្នាំកំណើត របស់សមាជិកគ្រួសារម្នាក់ៗ។ នៅក្នុងអំឡុងពេលចុះប្រមូលទិន្នន័យតារាងបង្វែរអាយុឆ្នាំប្រតិទិនជាឆ្នាំខ្មែរ(ឆ្នាំសត្វ)ត្រូវបានផ្តល់ឱ្យមន្ត្រីសម្ភាសន៍ ដើម្បីធ្វើការគិតបង្វែរអាយុទៅជាឆ្នាំសកល។

## គ្រួសារ

ការអង្កេតគ្របដណ្តប់គ្រួសារដែលមានមនុស្សចាប់ពីមួយនាក់ឡើងទៅ។ គ្រួសារដែលត្រូវបានដកចេញពីការធ្វើអង្កេតរួមមាន៖

- មនុស្សដែលរស់នៅក្នុងស្ថាប័ន ដូចជារស់នៅក្នុងមន្ទីរពេទ្យរយៈពេលវែង ពន្ធនាគារ វត្តអារាម ទីកន្លែងដែលបានផ្តល់ឱ្យកងទ័ពរស់នៅ។
- គ្រួសារស្ថានទូត និងគ្រួសាររបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។
- កងកម្លាំងប្រដាប់អាវុធដែលរស់នៅក្នុងមូលដ្ឋានទ័ព។

គ្រួសារត្រូវបានកំណត់តាមនិយមន័យថា គឺជាក្រុមមនុស្ស ឬមនុស្សម្នាក់ដែលជម្មតារស់នៅជាមួយគ្នា និងទទួលទានជាមួយគ្នា ដូចជាប្រើប្រាស់ចង្ក្រានតែមួយ ឬប្រើប្រាស់ថវិកាសម្រាប់ម្ហូបអាហាររួមគ្នា។ អ្នកទាំងនោះ គឺអាចជាសាច់ញាតិ ឬអាចមិនមែនជាសាច់ញាតិនឹងគ្នា(ជាអ្នកដទៃ)ដោយរួមបញ្ចូលទាំងអ្នកបម្រើ ឬនិយោជិតផ្សេងទៀតដែលរស់នៅជាមួយនិយោជក(ថៅកែ)។

## អនុបាតភេទ (ផលធៀបភេទ)

អនុបាតភេទ ត្រូវបានកំណត់នូវចំនួនបុរសធៀបក្នុងចំនួនស្ត្រី១០០នាក់។ បើសិនជាអនុបាតភេទស្មើនឹង១០០នោះបញ្ជាក់ថាភេទទាំងពីរមានចំនួនស្មើគ្នា។ បើសិនជាអនុបាតភេទលើស១០០បញ្ជាក់ថាចំនួនបុរសលើសចំនួនស្ត្រី ប៉ុន្តែបើសិនលទ្ធផលទាបជាង១០០នោះ ចំនួនស្ត្រីត្រូវលើសពីចំនួនបុរសវិញ។ ហេតុដូចនេះ បើចំនួនបុរសលើសចំនួនស្ត្រីកាន់តែច្រើនទៅៗនោះ បញ្ជាក់ថាអនុបាតភេទកាន់តែខ្ពស់ទៅៗ ប៉ុន្តែបើចំនួនស្ត្រីលើសចំនួនបុរសកាន់តែច្រើនទៅៗវិញ នោះបញ្ជាក់ថាអនុបាតភេទក៏កាន់តែទាបទៅៗដែរ។

## សមាមាត្រ

សមាមាត្រ គឺជាចំនួនប្រៀបធៀបមួយដែលកំណត់នូវទំហំនៃក្រុមរងមួយធៀបទៅនឹង ចំនួនសរុបនៃក្រុមរងទាំងអស់ដែលមានផលធៀបស្មើនឹង១។ នៅពេលទំហំនៃក្រុមរងទាំងអស់ត្រូវបានបង្ហាញជាភាគរយលទ្ធផលនោះត្រូវប្រើពាក្យថា "ការបែងចែកជាភាគរយ"។ បើកំណត់តាមវិធីមួយបែបទៀត សមាមាត្រ គឺជាប្រភេទនៃអនុបាតពិសេសដែលក្នុងនោះ ភាគយកមាននៅក្នុងភាគបែង។ ម្យ៉ាងវិញទៀត បើពិនិត្យលើចរិតលក្ខណៈទាក់ទងទៅនឹងអាយុនោះការបែងចែកមនុស្សតាមក្រុមអាយុនីមួយៗ ត្រូវបានហៅថា "ការបែងចែកតាមអាយុ" ឬក៏អាចហៅម្យ៉ាងទៀតថា "សមាសភាពអាយុនៃប្រជារាស្ត្រ"។

# ផ្នែកទី២ ចរិតលក្ខណៈប្រជាសាស្ត្រ

## ២.១. ការសិក្សាស្រាវជ្រាវអំពីប្រជាជនក្នុងការធ្វើអង្កេត

កំណើនប្រជាជនកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ ហើយត្រូវបានប៉ាន់ស្មានថា នឹងកើនបន្ថែមទៀត ដោយសារការផ្លាស់ប្តូររចនាសម្ព័ន្ធប្រជាជនដែលកំពុងលេចចេញជាបញ្ហាសំខាន់មួយ គឺការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុ រចនាសម្ព័ន្ធជំនាញ ការសិក្សាអប់រំ សុខភាព និងបំណែងចែកតាមលក្ខណៈភូមិសាស្ត្រ។ ចំនួនប្រជាជនសរុបបង្ហាញអំពីទំហំប្រជាជននៅទូទាំងប្រទេសកម្ពុជា តាមរយៈវិធីសាស្ត្រវាស់វែងជាលក្ខណៈទូទៅមួយ។ តារាង១ បង្ហាញអំពីចំនួនប្រជាជនដែលបានគណនាប៉ាន់ស្មាននៅក្នុងលទ្ធផលអង្កេត។ ចំនួនប្រជាជនដែលបានគណនាប៉ាន់ស្មានក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺមិនមានធ្វើការប្រៀបធៀបគ្នាដោយផ្ទាល់នោះទេ ជាមួយនឹងចំនួនប្រជាជនប៉ាន់ស្មានក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាទាំងបួនលើក។ តួលេខដែលបានពីជំរឿនប្រជារាស្ត្រកម្ពុជាបានរាប់បញ្ចូលនូវចំនួនប្រជាជនសរុប ចំណែកឯអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាវិញគឺរាប់តែចំនួនប្រជាជនដែលរស់នៅក្នុងគ្រួសារធម្មតា[3]។ គួរកត់សម្គាល់អំពីកិច្ចការសំខាន់ផងដែរចំពោះចំនួនប្រជាជនប៉ាន់ស្មាននៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺជាចំនួនប៉ាន់ស្មានផ្អែកលើរចនាសម្ព័ន្ធទិន្នន័យជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៩ និងផ្អែកលើទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គ្រួសារដែលបានចុះបញ្ជីគ្រួសារក្នុងភូមិសំណាកគំរូក្នុងប្រតិបត្តិការអង្កេត។

រូបភាព១. ចំនួនប្រជាជនប៉ាន់ស្មាននៅប្រទេសកម្ពុជា គិតជាពាន់នាក់




ព័ត៌មានទាន់ពេលវេលា និងភាពត្រឹមត្រូវ អំពីនិន្នាការប្រជាជននៅតែបន្តមានតម្រូវការប្រើប្រាស់ខ្ពស់។ ចំណេះដឹងអំពីទំហំប្រជាជន និងរចនាសម្ព័ន្ធបច្ចុប្បន្ន របស់ប្រជាជនក្នុងប្រទេស គឺចាំបាច់សម្រាប់ការបង្កើតនិង

[3] គ្រួសារធម្មតា គឺជាគ្រួសារដែលមិនរាប់បញ្ចូលគ្រួសារដែលរស់នៅក្នុងស្ថាប័ន គ្រួសារគ្មានផ្ទះសម្បែង គ្រួសាររស់នៅលើទូក ឬគ្រួសាររស់នៅបណ្ដោះអាសន្ន។ គ្រួសារស្ថាប័ន គឺជាគ្រួសារដែលរស់នៅក្នុងបន្ទាយទាហាន រស់នៅក្នុងពន្ធនាគារ(គុក) សយនដ្ឋាន(កន្លែងស្នាក់នៅរបស់សិស្សនិស្សិត។ល។)

អនុវត្តគោលនយោបាយ កម្មវិធីស្មើតែនៅគ្រប់វិស័យសាធារណៈទូទៅ។ គោលបំណងសំខាន់នៃទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ដែលមាននៅក្នុងផ្នែកនេះ គឺដើម្បីបង្ហាញអំពីលក្ខណៈប្រជាសាស្ត្រជាប្រវត្តិលទ្ធផលដែលត្រូវបានប្រើប្រាស់សម្រាប់វិភាគទិន្នន័យនៅក្នុងប្រធានបទដទៃទៀត នៃរបាយការណ៍អង្កេតនេះផងដែរ។ គួរកត់សម្គាល់ផងដែរអំពីចំនួនប្រជាជននៅក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺត្រូវបានគណនាប៉ាន់ស្មានតាមរយៈការធ្វើចំណោលប្រជាជនផ្អែកលើទិន្នន័យបច្ចុប្បន្នភាពដែលមាន។

## ២.២ ចំនួនប្រជាជននៅទីប្រជុំជន និងជនបទ

ចំនួនប្រជាជននៅទីប្រជុំជន និងជនបទ សំដៅលើប្រជាជនដែលរស់នៅក្នុងទីប្រជុំជន និងជនបទ ដែលបានកំណត់ដោយវិទ្យាស្ថានស្ថិតិជាតិ។ ដើម្បីគណនាអត្រានៃចំនួនប្រជាជននៅទីប្រជុំជន ធៀបនឹងចំនួនប្រជាជននៅជនបទ ត្រូវបានគណនាដោយយកចំនួនប្រជាជននៅទីប្រជុំជន១០០នាក់ធៀបនឹងចំនួនប្រជាជននៅជនបទ។

តារាង១បង្ហាញអំពីចំនួនប្រជាជនកម្ពុជាពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧ គឺជាលទ្ធផលទិន្នន័យបានពីការធ្វើចំណោលប្រជាសាស្ត្រដោយផ្អែកលើលទ្ធផលការធ្វើជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ២០០៨ រួមជាមួយនឹងទិន្នន័យលទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជានៅក្នុងឆ្នាំថ្មីៗចុងក្រោយ ដោយធ្វើការសន្មតតាមកម្រិតនគរូបនីយកម្មទៅតាមពេលវេលា។ នៅក្នុងឆ្នាំ២០១៩/២០ ប្រជាជនរស់នៅទីប្រជុំជនមានប្រមាណ ៣៩ភាគរយ ចំណែកឯប្រជាជននៅតំបន់ជនបទមានប្រមាណ ៦១ភាគរយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បើប្រៀបធៀបនឹងការអង្កេតលើកមុនៗ ប្រជាជននៅក្នុងតំបន់ទីប្រជុំជនបានកើនឡើងខ្ពស់នៅឆ្នាំ២០១៩/២០ ដោយសារមានការធ្វើចំណាត់ថ្នាក់តំបន់ទីប្រជុំជននៅក្នុងជំរឿនទូទៅនូវប្រជាសាស្ត្រកម្ពុជាឆ្នាំ២០១៩ ដែលនាំឱ្យមានការកើនឡើងនូវចំនួនប្រជាជននៅតំបន់ទីប្រជុំជនផ្សេងៗ។ ដោយឡែកចំពោះប្រជាជននៅទីប្រជុំជនផ្សេងៗមានអត្រាកំណើនប្រចាំឆ្នាំប្រមាណ ១ភាគរយ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៧ ដោយផ្អែកតាមរបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាដូចមានបង្ហាញនៅក្នុងតារាង១។

តារាង១. ការប៉ាន់ស្មានពីចំនួនប្រជាជនតាមតំបន់ គិតជាពាន់

| តំបន់ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | |
|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| កម្ពុជា | ១៥.១៨៤ | ១៥.៤០៥ | ១៥.៦២៦ | ១៥.៨៤៨ | ១៥.៩៥៤ |
| ទីប្រជុំជន | ៣.៤១២ | ៣.៥៤១ | ៣.៦៧០ | ៣.៨០១ | ៦.២៩៣ |
| ជនបទ | ១១.៧៧២ | ១១.៨៦៥ | ១១,៩៥៦ | ១២.០៤៧ | ៩.៦៦១ |
| ទីប្រជុំជន/ជនបទ | ២៩,០ | ២៩,៨ | ៣០,៧ | ៣១,៦ | ៦៥,១ |
| | ភាគរយ | | | | |
| កម្ពុជា | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ទីប្រជុំជន | ២២,៥ | ២៣,០ | ២៣,៥ | ២៤,០ | ៣៩,៤ |
| ជនបទ | ៧៧,៥ | ៧៧,០ | ៧៦,៥ | ៧៦,០ | ៦០,៦ |

*ការប៉ាន់ស្មានចំនួនប្រជាជនសរុបឆ្នាំ២០១៤-២០១៧ គឺទាបជាងចំនួនដែលបានបង្ហាញនៅក្នុងរបាយការណ៍CSES២០១៩/២០។ ការពិនិត្យឡើងវិញអំពីនីតិវិធីប៉ាន់ស្មានឆ្នាំ២០១៩/២០បានបង្ហាញថានីតិវិធីនេះមានភាពលំអៀងបន្តិច។ ដូច្នេះនីតិវិធីត្រូវបានកែតម្រូវការប៉ាន់ស្មានឆ្នាំ២០១៩/២០ ត្រូវបានធ្វើបច្ចុប្បន្នភាពផងដែរ។

## ២.៣ សមាមាត្រភេទ

ចំនួនសមាមាត្រភេទនៅពេលកើត និងសមាមាត្រភេទរបស់ប្រជាជន គួរឱ្យកត់សម្គាល់នៅក្នុងចំនួនប្រជាជនសរុបមានការប្រែប្រួលកើតឡើងដោយសារធម្មជាតិ។ ឧទាហរណ៍ ការសម្រាលកូនប្រុសៗមួយចំនួនត្រូវបានគេរាយការណ៍ថាកើតឡើងបន្ទាប់ពីសង្គ្រាមស៊ីវិល។ ក្នុងតារាង២ មានបង្ហាញអំពីការបែងចែកប្រជាជនកម្ពុជាទៅតាមភេទ និងសមាមាត្រភេទ។ សមាមាត្រភេទ គឺត្រូវបានកំណត់នូវចំនួនបុរសធៀបនឹងចំនួនស្ត្រី១០០នាក់។ (សូមមើលតារាង២ សម្រាប់ព័ត៌មានបន្ថែម)

តារាង២. ការគណនាវាស់វែងចំនួនប្រជាជនតាមភេទ គិតជាពាន់នាក់

| | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | |
|---|---|---|---|---|---|
| ភេទ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| ស្ត្រី | ៧.៧៤៨ | ៧.៨៦៣ | ៧.៩៥៩ | ៨.០៦៥ | ៨.១៨៦ |
| បុរស | ៧.៤៣៦ | ៧.៥៤២ | ៧.៦៦៨ | ៧.៧៨៤ | ៧.៧៦៨ |
| ទាំងពីរភេទ | ១៥.១៨៤ | ១៥.៤០៥ | ១៥.៦២៦ | ១៥.៨៤៨ | ១៥.៩៥៤ |
| អនុបាតភេទ | ៩៦,០ | ៩៥,៩ | ៩៦,៣ | ៩៦,៥ | ៩៤,៩ |

## ២.៤ បំណែងចែកចំនួនគ្រួសារ តាមតំបន់ទីប្រជុំជន និងជនបទ

សូមពិនិត្យទិដ្ឋភាពផ្សេងៗនៃចំនួនគ្រួសារដែលបានគណនាវាស់វែង។ ចំនួនគ្រួសារទាំងនៅទីប្រជុំជន និងជនបទ គឺមានការកើនឡើងបន្តិចបន្តួច ហើយនិងមាននិន្នាការកើនឡើងច្រើនជាងរាល់ឆ្នាំ បើធៀបទៅនឹងទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាប្រចាំឆ្នាំ២០១៤ ដល់ ២០១៧ និងឆ្នាំ២០១៩/២០។

ជារួមនៅក្នុងតារាង៣ បានបង្ហាញអំពីនិន្នាការនៃចំនួនគ្រួសារនៅទីប្រជុំជន និងជនបទ នៅក្នុងប្រទេសកម្ពុជា។ ចំនួនគ្រួសារនៅទីប្រជុំជនកំពុងកើនឡើងតាមអត្រាប្រចាំឆ្នាំមានប្រមាណ ៣ភាគរយ ខណៈដែលអត្រាគ្រួសារនៅជនបទមានប្រមាណ ២ភាគរយ លើកលែងតែនៅក្នុងឆ្នាំ២០១៩/២០ ចំនួនគ្រួសារនៅទីប្រជុំជនបានកើនបន្តិច ដោយសារមានការប្រែប្រួលនូវរចនាសម្ព័ន្ធប្រជាជន។(សូមមើលតារាងទី៣សម្រាប់ព័ត៌មានបន្ថែម)

តារាង៣. ការគណនាវាស់វែងចំនួនគ្រួសារតាមទីប្រជុំជន និងទីជនបទ គិតជាពាន់នាក់

| | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | |
|---|---|---|---|---|---|
| តំបន់ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| កម្ពុជា | ៣.២៦១ | ៣.៣០៨ | ៣.៣៩០ | ៣.៤៣៨ | ៣.៦៣៦ |
| ទីប្រជុំជន | ៦៩៦ | ៧០៩ | ៧០៥ | ៧១៥ | ១.៣៧៤ |
| ជនបទ | ២.៥៦៥ | ២.៥៩៩ | ២.៦៨៤ | ២.៧២៣ | ២.២៦២ |

ក្នុងតារាង៤ បង្ហាញពីសមាមាត្រនៃមេគ្រួសារជាស្ត្រី ដែលគិតជាភាគរយនៃចំនួនគ្រួសារសរុប។ តាមទិន្នន័យបង្ហាញថា នៅឆ្នាំ២០១៩/២០ នេះក្នុងចំណោមប្រាំគ្រួសារ គឺមានមួយគ្រួសារដែលស្ត្រីជាមេគ្រួសារ។ ម៉្យាងវិញទៀត បើពិនិត្យមើលក្នុងអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ឃើញថាសមាមាត្រនៃគ្រួសារដែលមានស្ត្រីជា

មេគ្រួសារមានការកើនឡើងក្នុងកំលុងឆ្នាំ២០១៤ និងឆ្នាំ២០១៥ ប៉ុន្តែវាបានថយចុះបន្តិចចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩/២០។ (សូមមើលតារាង៤ សម្រាប់ព័ត៌មានបន្ថែម)។

តារាង៤. គ្រួសារដែលមានស្ត្រីជាមេគ្រួសារ នៃគ្រួសារសរុប គិតជាភាគរយ

| តំបន់ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | |
|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| កម្ពុជា | ២២,៣ | ២៣,៥ | ២២,២ | ២២,១ | ២១,៥ |
| រាជធានីភ្នំពេញ | ២៥,០ | ២៩,៤ | ២៥,៦ | ២៦,១ | ៣០,៣ |
| ទីប្រជុំជនផ្សេងៗ | ២២,៥ | ២១,៩ | ២២,៤ | ២១,៨ | ២០,៦ |
| ជនបទផ្សេងៗ | ២១,៩ | ២២,៩ | ២១,៦ | ២១,៦ | ១៩,៨ |

## ២.៥ ប្រជាជនបែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍

ការសិក្សាលើបំណែងចែកប្រជាជនតាមស្ថានភាពអាពាហ៍ពិពាហ៍ គឺមានសារៈសំខាន់ដើម្បីយល់ដឹងពីផ្នែកមួយនៃចរិតលក្ខណៈប្រជាជន។ ស្ថានភាពអាពាហ៍ពិពាហ៍ គឺមិនមែនជាចរិតលក្ខណៈតាមជីវសាស្ត្រនោះទេ ហើយក៏មិនមែនមានលក្ខណៈដូចគ្នានឹងភេទ ឬអាយុនោះឡើយ ក៏ប៉ុន្តែស្ថានភាពអាពាហ៍ពិពាហ៍ចាំបាច់ត្រូវតែយកមកធ្វើការសិក្សាផងដែរ។ ការសិក្សាអំពីស្ថានភាពអាពាហ៍ពិពាហ៍របស់ប្រជាជនមានប្រយោជន៍ច្រើនដោយយោងតាមហេតុផលផ្សេងៗ ជាពិសេសកត្តាសំខាន់នោះគឺទាក់ទងទៅនឹងឱណាមិករបស់ប្រជាជនដែលអាចជះឥទ្ធិពលក្នុងកម្រិតខ្លះដល់លទ្ធផលបង្កើតកូន មរណភាព ក៏ដូចជាការធ្វើចំណាកស្រុក។ នៅក្នុងសង្គមកម្ពុជាការបន្តពូជបានភាគច្រើនស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍។ បើនិយាយអំពីអាពាហ៍ពិពាហ៍របស់ប្រជាជនកម្ពុជា គឺជាទូទៅរៀបចំតាមរបៀបព្រះពុទ្ធសាសនាដែលជាប្រពៃណីរៀបការមួយមានការប្រារព្ធពិធីបែបសាសនាច្រើនដំណាក់កាល។ ទោះជាយ៉ាងនេះក្តី នីតិវិធីផ្លូវការគឺត្រូវទៅចុះបញ្ជីរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។

បើពិនិត្យលើស្ថានភាពអាពាហ៍ពិពាហ៍នៃអ្នករៀបការ/អ្នករស់នៅជាមួយដៃគូ ក្នុងចំណោមប្រជាជនកម្ពុជាអាយុ១៥ឆ្នាំឡើង ចំណែកភាគរយ នៃអ្នកមិនដែលរៀបការ/អ្នកមិនដែលរស់នៅជាមួយដៃគូ អ្នកលែងលះគ្នា/បែកបាក់គ្នា និងអ្នកពោះម៉ាយក៏សឹងតែពុំមានការប្រែប្រួលនៅក្នុងកំលុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ម្យ៉ាងទៀតបើសង្កេតមើលស្ថានភាពអាពាហ៍ពិពាហ៍នៅតាមតំបន់ភូមិសាស្ត្រនីមួយៗបញ្ជាក់ថា ភាគរយនៃអ្នករៀបការ/អ្នករស់នៅជាមួយដៃគូរនៅតាមតំបន់ជនបទភូមិសាស្ត្រទូទៅមានលក្ខណៈខ្ពស់ជាងរាជធានីភ្នំពេញ និងនៅតាមទីប្រជុំជនផ្សេងៗ។ ស្ថានភាពដូចៗគ្នាបែបនេះ មានលក្ខណៈពិតប្រាកដជាក់ស្តែងសម្រាប់គ្រប់ឆ្នាំទាំងអស់។ (សូមមើលតារាង៥ សម្រាប់ព័ត៌មានបន្ថែម)

តារាង៥. ប្រជាជនមានអាយុចាប់ពី១៥ឆ្នាំឡើង បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ និងតំបន់ ឆ្នាំ២០១៤ - ២០១៩/២០ គិតជាភាគរយ

| ស្ថានភាព អាពាហ៍ពិពាហ៍ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០) | | | |
|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទផ្សេងៗ |
| **២០១៤** | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៦,៨ | ៥១,០ | ៥៧,៥ | ៥៧,៨ |
| លែងលះ/បែកបាក់ | ១,៦ | ១,៥ | ១,៧ | ១,៦ |
| ពោះម៉ាយ/មេម៉ាយ | ៨,០ | ៧,៣ | ៧,៤ | ៨,២ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួដៃគូ | ៣៣,៦ | ៤០,១ | ៣៣,៤ | ៣២,៥ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៥** | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៨,០ | ៥៣,៣ | ៥៥,០ | ៥៩,៣ |
| លែងលះ/បែកបាក់ | ១,៦ | ០,៨ | ១,៨ | ១,៧ |
| ពោះម៉ាយ/មេម៉ាយ | ៨,៦ | ៩,១ | ៧,៩ | ៨,៦ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួដៃគូ | ៣១,៨ | ៣៦,៧ | ៣៥,៣ | ៣០,៤ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៦** | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៨,០ | ៥៤,២ | ៥៣,៥ | ៥៩,៤ |
| លែងលះ/បែកបាក់ | ១,៨ | ១,៣ | ២,៣ | ១,៨ |
| ពោះម៉ាយ/មេម៉ាយ | ៨,៤ | ៨,៨ | ៧,២ | ៨,៥ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ៣១,៩ | ៣៥,៦ | ៣៦,៩ | ៣០,៣ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៧** | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៣,២ | ៥០,៥ | ៥១,៩ | ៥៣,៩ |
| លែងលះ/បែកបាក់ | ១,៦ | ០,៧ | ២,១ | ១,៧ |
| ពោះម៉ាយ/មេម៉ាយ | ៧,៧ | ៨,៣ | ៧,៧ | ៧,៥ |

| | | | | |
|---|---|---|---|---|
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ៣៧,៥ | ៤០,៤ | ៣៨,៤ | ៣៦,៨ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៩/២០** | | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៦៣,២ | ៥៦,៩ | ៦៣,៣ | ៦៤,៨ |
| លែងលះ/បែកបាក់ | ១,៧ | ១,២ | ១,៨ | ១,៨ |
| ពោះម៉ាយ/មេម៉ាយ | ៨,៦ | ៨,៦ | ៨,២ | ៨,៧ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២៦,៥ | ៣៣,២ | ២៦,៧ | ២៤,៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

នៅក្នុងការផ្លាស់ប្តូររចនាសម្ព័ន្ធប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមបច្ចុប្បន្ន នាំឱ្យមានការប្រែប្រួលអំពីការរស់នៅរបស់យុវវ័យ។ ឱកាសការសិក្សាបានកើនឡើង ហើយក៏ដូចការផ្តល់ឱកាសការងារដល់ស្ត្រីផងដែរ។ ផ្ទុយទៅវិញក៏វាអាចធ្វើឱ្យមានការពន្យាពេលនៃការរៀបអាពាហ៍ពិពាហ៍ ដែលនាំឱ្យមានការកើនឡើងចំនួនបុរសនិងស្ត្រីដែលមិនធ្លាប់រៀបការផងដែរ។

តារាង៦ បង្ហាញអំពីស្ថានភាពអាពាហ៍ពិពាហ៍បែងចែកតាមភេទ។ តាមទិន្នន័យបញ្ជាក់ថាចំនួនបុរសដែលបានរៀបការ/រស់នៅជាមួយដៃគូមានចំនួនច្រើនជាងស្ត្រីដែលបានរៀបការ/រស់នៅជាមួយដៃគូ។ ដោយឡែកភាគរយស្ត្រីក្នុងស្ថានភាពជាស្ត្រីមេម៉ាយមានអត្រាខ្ពស់ជាងបុរសជាពោះម៉ាយ។ (សូមមើលតារាង៦ សម្រាប់ព័ត៌មានបន្ថែម)

តារាង៦. ស្ថានភាពអាពាហ៍ពិពាហ៍បែងចែកតាមភេទសម្រាប់ប្រជាជនអាយុ១៥ឆ្នាំឡើង (គិតជាភាគរយ)

| ស្ថានភាព អាពាហ៍ពិពាហ៍ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០) | | |
|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ |
| **២០១៤** | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៤,៣ | ៥៩,៥ | ៥៦,៧ |
| លែងលះ/បែកបាក់ | ២,៥ | ០,៦ | ១,៦ |
| ពោះម៉ាយ/មេម៉ាយ | ១៣,២ | ២,៣ | ៨,០ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២៩,៩ | ៣៧,៦ | ៣៣,៦ |
| សរុប | ១០០ | ១០០ | ១០០ |
| **២០១៥** | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៥,៤ | ៦០,៨ | ៥៨,០ |
| លែងលះ/បែកបាក់ | ២,៤ | ០,៧ | ១,៦ |
| ពោះម៉ាយ/មេម៉ាយ | ១៤,១ | ២,៥ | ៨,៦ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២៨,១ | ៣៥,៩ | ៣១,៨ |

| | | | |
|---|---|---|---|
| សរុប | ១០០ | ១០០ | ១០០ |
| **២០១៦** | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៦,១ | ៦០,០ | ៥៨,០ |
| លែងលះ/បែកបាក់ | ២,៧ | ០,៧ | ១,៨ |
| ពោះម៉ាយ/មេម៉ាយ | ១៣,៨ | ២,៦ | ៨,៤ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២៧,៤ | ៣៦,៧ | ៣១,៩ |
| សរុប | ១០០ | ១០០ | ១០០ |
| **២០១៧** | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៤,៥ | ៥៨,២ | ៥៦,៣ |
| លែងលះ/បែកបាក់ | ២,៧ | ០,៧ | ១,៧ |
| ពោះម៉ាយ/មេម៉ាយ | ១៣,៥ | ២,៣ | ៨,១ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២៩,៣ | ៣៨,៩ | ៣៣,៩ |
| សរុប | ១០០ | ១០០ | ១០០ |
| **២០១៩/២០** | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៦០,៧ | ៦៦,០ | ៦៣,២ |
| លែងលះ/បែកបាក់ | ២,៤ | ០,៩ | ១,៧ |
| ពោះម៉ាយ/មេម៉ាយ | ១៣,៧ | ៣,០ | ៨,៦ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២៣,៣ | ៣០,១ | ២៦,៥ |
| សរុប | ១០០ | ១០០ | ១០០ |

## ២.៦ ចំនួនប្រជាជនបែងចែកតាមជនជាតិ

ផ្អែកតាមលទ្ធផលទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បង្ហាញថាជនជាតិខ្មែរ គឺមានចំណែកធំបំផុតនៅក្នុងប្រទេសកម្ពុជា។ ភាគរយនៃជនជាតិខ្មែរ ត្រូវបានប៉ាន់ស្មានមានប្រមាណ៩៥,៤ភាគរយ នៃប្រជាជនកម្ពុជាសរុប។ បន្ទាប់មកក្រុមជនជាតិភាគតិចដែលមានចំនួនច្រើនជាងគេទីពីរនៅក្នុងប្រទេសកម្ពុជា គឺជនជាតិចាម។ (សូមមើលតារាង៧ សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៧. ចំនួនប្រជាជនបែងចែកតាមជនជាតិ និងភូមិសាស្ត្រឆ្នាំ ២០១៤ - ២០១៩/២០ គិតជាភាគរយ**

| ជនជាតិ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០) | | | |
|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទផ្សេងៗ |
| **២០១៤** | | | | |
| ខ្មែរ | ៩៦,៤ | ៩៧,៩ | ៩៧,៥ | ៩៥,៩ |
| ចាម | ១,៩ | ១,៨ | ២,៣ | ១,៨ |
| ចិន | ០,០ | ០,០ | ០,០ | ០,០ |

| | | | | |
|---|---|---|---|---|
| វៀតណាម | ០,៣ | ០,៣ | ០,២ | ០,៣ |
| ថៃ | ០,០ | ០,០ | ០,០ | ០,០ |
| ឡាវ | ០,០ | ០,០ | ០,០ | ០,០ |
| ជនជាតិផ្សេងៗ | ១,៤ | ០,០ | ០,០ | ១,៨ |
| មិនបានបញ្ជាក់ | ០,០ | ០,០ | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៥** | | | | |
| ខ្មែរ | ៩៦,១ | ៩៨,០ | ៩៩,០ | ៩៥,៣ |
| ចាម | ១,១ | ១,២ | ០,៦ | ១,២ |
| ចិន | ០,០ | ០,២ | ០,១ | ០,០ |
| វៀតណាម | - | - | - | - |
| ថៃ | - | - | - | - |
| ឡាវ | - | - | - | - |
| ជនជាតិផ្សេងៗ | ២,៦ | ០,៧ | ០,៤ | ៣,៥ |
| មិនបានបញ្ជាក់ | - | - | - | - |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៦** | | | | |
| ខ្មែរ | ៩៧,០ | ៩៥,៩ | ៩៨,៨ | ៩៦,៩ |
| ចាម | ១,៨ | ៣,៦ | ០,៨ | ១,៧ |
| ចិន | ០,៤ | ០,១ | ០,០ | ០,៥ |
| វៀតណាម | - | - | - | - |
| ថៃ | - | - | - | - |
| ឡាវ | - | - | - | - |
| ជនជាតិផ្សេងៗ | ០,៧ | ០,៣ | ០,៤ | ០,៩ |
| មិនបានបញ្ជាក់ | - | - | - | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៧** | | | | |
| ខ្មែរ | ៩៧,០ | ៩៥,៣ | ៩៨,១ | ៩៧,២ |
| ចាម | ២,៤ | ៤,០ | ០,៩ | ២,៤ |
| ចិន | ០,២ | ០,០ | ០,១ | ០,៣ |
| វៀតណាម | - | - | - | - |

| | | | | |
|---|---|---|---|---|
| ថៃ | - | - | - | - |
| ឡាវ | - | - | - | - |
| ជនជាតិផ្សេងៗ | ០,៣ | ០,៧ | ០,៨ | ០,១ |
| មិនបានបញ្ជាក់ | - | - | - | - |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| **២០១៩/២០** | | | | |
| ខ្មែរ | ៩៥,៤ | ៩៥,៣ | ៩៨,០ | ៩៤,៤ |
| ចាម | ២,៤ | ២,៩ | ១,២ | ២,៧ |
| ចិន | ១,៥ | ០,០ | ០,២ | ២,៤ |
| វៀតណាម | ០,២ | ០,៤ | ០,១ | ០,១ |
| ថៃ | ០,៥ | ១,៤ | ០,៥ | ០,៣ |
| ឡាវ | ០,០ | ០,០ | ០,០ | ០,០ |
| ជនជាតិផ្សេងៗ | ០,១ | ០,០ | ០,១ | ០,១ |
| មិនបានបញ្ជាក់ | ០,០ | ០,១ | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

## ២.៧ ការចុះអត្រានុកូលដ្ឋាន

ការចុះអត្រានុកូលដ្ឋាន ត្រូវបានអនុម័តឱ្យប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រដល់ផែនការជាតិ និងដើម្បីបង្ហាញភស្តុតាងនៃកំណើត ការស្លាប់ ការរលូតកូន និងការរៀបការ និងការផ្តល់នូវប្រភពទិន្នន័យ សម្រាប់រក្សាទុកសុវត្ថិភាព សម្រាប់កំណត់ត្រាសាធារណៈ។

ការចុះអត្រានុកូលដ្ឋាននៅកម្ពុជា ត្រូវបានទទួលស្គាល់តាមច្បាប់នៃប្រទេសកម្ពុជា លុះត្រាតែបានចុះបញ្ជីនៅសាលាឃុំ/សង្កាត់។ ការចុះអត្រានុកូលដ្ឋានត្រូវបានធ្វើឡើងក្នុងកំលុងរយៈពេល៣០ថ្ងៃ គិតចាប់ថ្ងៃកើត។

នៅអាជ្ញាធរមូលដ្ឋាន ការិយាល័យឃុំ/សង្កាត់ បានចេញលិខិតចុះអត្រានុកូលដ្ឋានបន្ទាប់ពីការបំពេញឯកសារត្រឹមត្រូវរួចរាល់។ សំបុត្រកំណើតអាចត្រូវបានចុះបញ្ជីដោយម្តាយនិងឪពុក ឬដោយម្តាយតែម្នាក់ឯងក៏បាន។ នៅពេលបញ្ចប់ការចុះឈ្មោះកំណើតច្បាប់ចម្លងនៃសំបុត្រកំណើតត្រូវបានផ្តល់ឱ្យឪពុក/ម្តាយ។

នៅក្នុងឆ្នាំ២០១៤ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាមានសំណួរថ្មី ស្តីពីការចុះឈ្មោះកំណើតត្រូវបានដាក់បន្ថែមនៅក្នុងកម្រងសំណួរ។ សំណួរមួយប្រសិនបើកុមារមានសំបុត្រកំណើតត្រូវបានសួរសម្រាប់កុមារទាំងអស់អាយុ០-៤ឆ្នាំ ថាតើពួកគេមានសំបុត្រកំណើតដែរឬទេ។ ក្នុងការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០១៩/២០ ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ មានកុមារប្រមាណ ៩២ ភាគរយ នៃកុមារទាំងអស់ដែលមានអាយុ ០-៤ ឆ្នាំ មានសំបុត្រកំណើតនៅប្រទេសកម្ពុជា។ ភាគរយនេះ គឺមានកម្រិតខ្ពស់បំផុតនៅរាជធានីភ្នំពេញប្រមាណ៩៥ ភាគរយ នៅទីប្រជុំជនផ្សេងៗមាន៩៣ភាគរយ និងនៅតំបន់ជនបទមាន៩១ភាគរយ។ (សូមមើលតារាង៨ សម្រាប់ព័ត៌មានលម្អិត)។

តារាង៨. កុមារអាយុ ០-៤ ឆ្នាំដែលបានចុះអត្រានុកូលដ្ឋាន បែងចែកតាមតំបន់ ឆ្នាំ ២០១៤-២០១៩/២០ គិតភាគរយ

| តំបន់ | សំបុត្រកំណើត | ការចុះបញ្ជី | មិនមាន | មិនដឹង | ចំនួនកុមារសរុប |
|---|---|---|---|---|---|
| ២០១៤ | | | | | |
| កម្ពុជា | ៧៣,៨ | ៨,៥ | ១៦,៥ | ១,២ | ១.៥៩២.៨០២ |
| រាជធានីភ្នំពេញ | ៩១,២ | ២,០ | ៦,១ | ០,៦ | ១៥១.២៤៤ |
| ទីប្រជុំជនផ្សេងៗ | ៧៧,៥ | ៩,៨ | ១២,៣ | ០,៥ | ២១៦.៤៧៣ |
| ជនបទផ្សេងៗ | ៧១,១ | ៩,០ | ១៨,៥ | ១,៤ | ១.២២៥.០៨៣ |
| ២០១៥ | | | | | |
| កម្ពុជា | ៧៦,៧ | ៨,៧ | ១៤,២ | ០,៤ | ១.៣៦៦.៦៧៩ |
| រាជធានីភ្នំពេញ | ៩២,៩ | ០,៨ | ៥,៤ | ១,០ | ១៤០.២៧៤ |
| ទីប្រជុំជនផ្សេងៗ | ៧៦,៦ | ៥,០ | ១៨,១ | ០,៣ | ១៤១.៤៤៧ |
| ជនបទផ្សេងៗ | ៧៤,៧ | ១០,១ | ១៤,៩ | ០,៣ | ១.០៨៤.៩៥៨ |
| ២០១៦ | | | | | |
| កម្ពុជា | ៨៤,៩ | ៣,៩ | ១០,៧ | ០,៤ | ១,៣៨៧,៨៥៩ |
| រាជធានីភ្នំពេញ | ៩៦,៤ | ០,៣ | ៣,២ | ០,៤ | ១៣៩,៨២៩ |
| ទីប្រជុំជនផ្សេងៗ | ៨៦,៣ | ១,៥ | ១២,២ | ០,០ | ១៥១,៣៧៧ |
| ជនបទផ្សេងៗ | ៨៣,៣ | ៤,៧ | ១១,៥ | ០,៥ | ១,០៩៦,៦៥៣ |
| ២០១៧ | | | | | |
| កម្ពុជា | ៨៨,៨ | ៣,១ | ៧,៧ | ០,៤ | ១,៤០៦,៣១៦ |
| រាជធានីភ្នំពេញ | ៩៧,៥ | ១,០ | ១,៥ | ០,០ | ១៣៤,៤១៧ |
| ទីប្រជុំជនផ្សេងៗ | ៨៨,១ | ៣,៨ | ៨,១ | ០,០ | ១៥៩,៦៣៣ |
| ជនបទផ្សេងៗ | ៨៧,៨ | ៣,៣ | ៨,៣ | ០,៥ | ១,១១២,២៦៦ |
| ២០១៩/២០ | | | | | |
| កម្ពុជា | ៩២,២ | ២,៩ | ៤,៦ | ០,៣ | ១,៤៦៤,៣១៧ |
| រាជធានីភ្នំពេញ | ៩៥,៤ | ៣,៣ | ០,៨ | ០,៥ | ១៧៦,០៦៧ |
| ទីប្រជុំជនផ្សេងៗ | ៩៣,៣ | ២,៩ | ៣,៦ | ០,២ | ៣៤៣,៨៣៥ |
| ជនបទ | ៩១,៣ | ២,៨ | ៥,៧ | ០,២ | ៩៤៤,៤១៤ |

# ផ្នែកទី៣ លំនៅដ្ឋាន

## ៣.១ សេចក្តីផ្តើម

ជំពូកនេះ មានគោលបំណងសំខាន់ គឺដើម្បីបង្ហាញនូវទិន្នន័យស្ថិតិស្តីពីលំនៅដ្ឋានរបស់គ្រួសារនៅក្នុងឆ្នាំ២០១៩/២០។ នៅឆ្នាំ២០១៩/២០ប្រទេសកម្ពុជាមានគ្រួសារប្រមាណជាង ៣,៦លានគ្រួសារ។ ដោយសារគ្រួសារនីមួយៗកាន់កាប់លំនៅដ្ឋានយ៉ាងតិចមួយដែលនាំឱ្យចំនួនលំនៅដ្ឋាននៅប្រទេសកម្ពុជាមានយ៉ាងតិចចំនួន ៣,៦លានខ្នងដែរ។ មានលំនៅដ្ឋានខ្លះនៅទំនេរដែលអាចបន្ថែមទៅនឹងចំនួនលំនៅដ្ឋានដែលកំពុងកាន់កាប់។

ការប្រមូលទិន្នន័យអំពីស្ថានភាពលំនៅដ្ឋាន រួមមានដូចជា ផ្ទៃក្រឡាកម្រាល ចំនួនបន្ទប់ដែលបានប្រើប្រាស់ដោយគ្រួសារ សម្ភារសាងសង់ប្រើប្រាស់សម្រាប់ធ្វើជាជញ្ជាំង កម្រាល និងដំបូល ប្រភពថាមពលសម្រាប់បំភ្លឺ ទឹកសម្រាប់បរិភោគ ការដាំ/ការបន្សុទ្ធទឹកសម្រាប់បរិភោគ បង្គន់អនាម័យ ឧបករណ៍ការលាងដៃ ឥន្ធនៈសម្រាប់ចម្អិនអាហារ ការចំណាយលើថ្លៃទឹក ភ្លើង ឥន្ធនៈ លូទឹកស្អុយ ការប្រមូលកាកសំណល់(សំរាម) ការចំណាយជួលផ្ទះ ការថែទាំ និងការជួសជុលផ្ទះបន្តិចបន្តួច។ បន្ថែមពីនេះទៀត តម្លៃជួលផ្ទះរបស់ម្ចាស់ផ្ទះដែលជាកម្មសិទ្ធិរបស់ខ្លួនក៏ត្រូវបានធ្វើការប៉ាន់ស្មានផងដែរ។

នៅក្នុងតារាងសំណួរអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ក្នុងផ្នែកលំនៅដ្ឋានមាន៣០សំណួរ (សូមមើលកម្រងសំណួរគ្រួសារក្នុងឧបសម្ព័ន្ធ៣) ដែលសំណួរភាគច្រើនត្រូវបានឆ្លើយដោយមេគ្រួសារនៅខែធ្វើសម្ភាសន៍។ ព័ត៌មានទិន្នន័យស្ថិតិ បានបង្ហាញអំពីស្ថានភាពលំនៅដ្ឋានដែលបែងចែកទៅតាមតំបន់ភូមិសាស្ត្រ ដោយលទ្ធផលបានបកស្រាយដាច់ដោយឡែកពីគ្នារវាងរាជធានីភ្នំពេញ តំបន់ទីប្រជុំជនផ្សេងៗ និងជនបទផ្សេងៗ។

នៅក្នុងឧបសម្ព័ន្ធ២បានបន្ថែមតារាងមួយចំនួន ដែលបែងចែកទៅតាមទីកន្លែងរស់នៅ គឺទីប្រជុំជន និងជនបទ។ ការបែងចែកនេះ គឺមានគោលបំណងសម្រាប់ប្រើប្រាស់នៅក្នុងឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា(គអចក) និងតម្រូវការរបស់អ្នកប្រើប្រាស់ និងដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការជាចាំបាច់ក្នុងការប្រើប្រាស់ទិន្នន័យពីការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា។ ឯកសារទាំងអស់នេះ មានសារៈសំខាន់បំផុត ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា។

## ៣.២ សម្ភារសាងសង់លំនៅដ្ឋាន (ដំបូល ជញ្ជាំង និង កម្រាល)

សម្ភារប្រើប្រាស់សម្រាប់ធ្វើជាដំបូល ជញ្ជាំង និងកម្រាល មានសារៈសំខាន់ណាស់ចំពោះការកំណត់នូវចរិតលក្ខណៈនៃគុណភាពរបស់លំនៅដ្ឋាន។ សម្ភារទាំងនេះ ត្រូវបានបែងចែកជាក្រុម ដូចជា សម្ភាររឹង/អចិន្ត្រៃយ៍ ឬសម្ភារទន់/បណ្តោះអាសន្ន ដែលអាស្រ័យទៅលើសមត្ថភាពរបស់វា ក្នុងការទប់ទល់ទៅនឹងខ្យល់ និងភ្លៀង។ ឧទាហរណ៍ សម្ភារដែលអាចចាត់ទុកជាសម្ភាររឹង/អចិន្ត្រៃយ៍ រួមមាន៖ ក្បឿង ហ្វីប្រូស៊ីម៉ងត៍ ស័ង្កសី/ដែកអាលុយមីញ៉ូម បេតុង ឥដ្ឋ ថ្ម ឈើ/ ក្តារបន្ទះសម្រាប់ធ្វើជញ្ជាំង និងថ្មលោង និងបន្ទះប្លាស្ទិក/កៅស៊ូសម្រាប់ធ្វើកម្រាល។ ដើមឫស្សីសម្រាប់ធ្វើជញ្ជាំង និងនោបឈើ ឬនោបឫស្សីសម្រាប់ធ្វើកម្រាល អាចចាត់ទុកជាសម្ភារទន់/បណ្តោះអាសន្ន។

## សម្ភារសម្រាប់ធ្វើជាដំបូលលំនៅដ្ឋាន

ជាទូទៅនៅប្រទេសកម្ពុជា មានលំនៅដ្ឋានប្រមាណ ៩៩ភាគរយក្នុងឆ្នាំ២០១៩/២០ មានដំបូលធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ និងលំនៅដ្ឋានត្រឹមតែ១ភាគរយប៉ុណ្ណោះមានដំបូលធ្វើពីសម្ភារទន់/បណ្តោះអាសន្ន។ ដោយឡែកសម្ភារធ្វើដំបូលជាស័ង្កសី/ដែកអាលុយមីញ៉ូម មានភាគរយច្រើនជាងគេប្រហែលជាង៥០ភាគរយនៃលំនៅដ្ឋានដែលបានកាន់កាប់សរុប បន្ទាប់មកគឺសម្ភារធ្វើដំបូលជាសន្លឹកក្បឿងដែលមានប្រមាណ ៣០ភាគរយ។ ចំណែកឯដំបូលធ្វើអំពីហ្វីប្រូស៊ីម៉ងត៍ គឺស្ថិតក្នុងលំដាប់ទីបីមានប្រមាណជា១២ភាគរយប៉ុណ្ណោះ។

តារាង១.ការកាន់កាប់លំនៅដ្ឋានតាមប្រភេទសម្ភារដំបូល និង បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| សម្ភារធ្វើជាដំបូល | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| **សម្ភាររឹង/អចិន្ត្រៃយ៍** | **៩៨,៦** | **៩៩,៦** | **៩៩,០** | **៩៨,២** |
| ក្បឿង | ៣០,៣ | ១២,៩ | ២៩,៥ | ៣៤,៧ |
| ហ្វីប្រូស៊ីម៉ងត៍ | ១១,៨ | ៩,៧ | ១៣,៧ | ១១,៦ |
| ស័ង្កសី/អាលុយមីញ៉ូម | ៥០,១ | ៤៥,០ | ៥២,៧ | ៥០,៣ |
| សម្ភារចម្រុះដែលភាគច្រើនជា ស័ង្កសី | ២,២ | ៩,១ | ០,៨ | ១,១ |
| បេតុង | ៤,២ | ២២,៩ | ២,២ | ០,៥ |
| **សម្ភារទន់/បណ្តោះអាសន្ន** | **១,៤** | **០,៤** | **១,០** | **១,៨** |
| ស្បូវ | ០,៩ | ០,០ | ០,៦ | ១,៣ |
| សម្ភារកែច្នៃផ្សេងៗ | ០,៤ | ០,៤ | ០,៤ | ០,៣ |
| សម្ភារចម្រុះដែលភាគច្រើនជា ស្បូវ | ០,១ | ០,០ | ០,០ | ០,២ |
| បន្ទះប្លាស្ទិក | ០,០ | ០,០ | ០,០ | ០,០ |
| ផ្សេងទៀត | ០,០ | ០,០ | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

គុណភាពលំនៅដ្ឋានរវាងតំបន់ភូមិសាស្ត្រមានភាពខុសគ្នាបន្តិចបន្តួច។ នៅរាជធានីភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងទៀត មានលំនៅដ្ឋានស្ទើរតែ១០០ភាគរយដែលមានដំបូលការពារធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍។ រីឯនៅតំបន់ទីជនបទមានប្រមាណ ៩៩ ភាគរយ។ នៅក្នុងរាជធានីភ្នំពេញលំនៅដ្ឋានប្រមាណ៤៥ភាគរយ ដែលមានដំបូលធ្វើពីស័ង្កសី/ដែកអាលុយមីញ៉ូម បន្ទាប់មកគឺធ្វើអំពីក្បឿងដែលមានប្រមាណ១៣ភាគរយ។ ហ្វីប្រូស៊ីម៉ងត៍មានប្រមាណ ១០ភាគរយ។ ស័ង្កសី/ដែកអាលុយមីញ៉ូមក៏ជាសម្ភារសម្រាប់ធ្វើដំបូលដែលគេនិយមប្រើនៅទីប្រជុំជនផ្សេងៗផងដែរដែលមានប្រមាណ ៥៣ ភាគរយ គឺមាន ៨ ចំណុចភាគរយ ខ្ពស់ជាងនៅរាជធានីភ្នំពេញ។ លំនៅដ្ឋានដែលមានដំបូលធ្វើពីក្បឿងនៅតំបន់ទីប្រជុំជនផ្សេងៗមានប្រមាណ ៣០ភាគរយ និងមាន១៧ចំណុចភាគរយ ខ្ពស់ជាងនៅរាជធានីភ្នំពេញ។ នៅតំបន់ជនបទ លំនៅដ្ឋានមានដំបូលធ្វើពីស័ង្កសី/ដែកអាលុយមីញ៉ូមមានប្រមាណ ៥០ភាគរយ និងធ្វើពីក្បឿងមានប្រមាណ ៣៥ ភាគរយ បន្ទាប់មក គឺដំបូលធ្វើពីហ្វីប្រូស៊ីម៉ងត៍មានប្រមាណ ១២ ភាគរយ។ (សម្រាប់ទិន្នន័យលម្អិត សូមមើលក្នុងតារាង១)

រូបភាព១. ជំបូលលំនៅដ្ឋានធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ ឆ្នាំ២០០៤ ២០០៩ ២០១៤ និង២០១៩/២០(គិតជាភាគរយ)




ភាគរយ នៃជំបូលលំនៅដ្ឋានធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍នៅកម្ពុជា មានការកើនឡើងគួរឱ្យកត់សម្គាល់ ចាប់ពីឆ្នាំ២០០៤មក។ ដូចបានបង្ហាញនៅក្នុងរូបភាព១ គឺភាគរយនៃជំបូលលំនៅដ្ឋានធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ នៅកម្ពុជា មានការកើនឡើង ២៤ភាគរយពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៤ ហើយបន្តកើន ៤ ភាគរយទៀត ពីឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៩/២០។

## សម្ភារសម្រាប់ធ្វើជាជញ្ជាំងលំនៅដ្ឋាន

ដូចបានបង្ហាញនៅក្នុងតារាង២ នៅឆ្នាំ២០១៩/២០នេះ មានលំនៅដ្ឋាននៅកម្ពុជាប្រមាណ ៩៤ភាគរយ ដែលបានកាន់កាប់ដោយគ្រួសារ លំនៅដ្ឋានមានជញ្ជាំងធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ ក្នុងនោះមានឈើ ឬ ក្តារបន្ទះ ជាសម្ភារធ្វើជញ្ជាំងដែលគេនិយមប្រើជាងគេ មានប្រមាណ ៤៧ភាគរយ។ ជញ្ជាំងធ្វើពីបេតុង ឥដ្ឋ ឬ ថ្ម មាន ប្រមាណ ២៧ភាគរយ នៃលំនៅដ្ឋានដែលបានកាន់កាប់សរុប។ សម្រាប់លំនៅដ្ឋានដែលមានជញ្ជាំងធ្វើពីសម្ភារ ទន់/បណ្តោះអាសន្ន គឺឫស្សី និងស្បូវ ត្រូវបានគេប្រើប្រាស់ ភាគច្រើនគឺមានប្រមាណ ៦ ភាគរយ។ បើយើង ពិនិត្យមើលភាពខុសគ្នាទៅតាមតំបន់នីមួយៗឃើញថា ជញ្ជាំងធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍មានចំនួនលើសលុប ជាងគេ ដូចជានៅក្នុងរាជធានីភ្នំពេញជញ្ជាំងធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍មានប្រមាណ ៩៩ភាគរយ ដែលក្នុងនោះ មានប្រមាណ ៧៦ភាគរយ គឺធ្វើពីបេតុង ឥដ្ឋ ឬ ថ្ម។ លំនៅដ្ឋាននៅតំបន់ទីប្រជុំជនផ្សេងៗ ដែលមានជញ្ជាំងធ្វើ ពីសម្ភាររឹង/អចិន្ត្រៃយ៍មានប្រមាណ ៩៦ភាគរយ ក្នុងនោះមានប្រមាណ៤១ភាគរយគឺធ្វើពីឈើឬក្តារបន្ទះ និង មានប្រមាណ ៣៤ភាគរយទៀត ធ្វើពីបេតុង ឥដ្ឋ ថ្ម។ សម្ភារធ្វើជញ្ជាំងសម្រាប់សាងសង់លំនៅដ្ឋាននៅតំបន់ ជនបទ គឺឈើ ឬ ក្តារបន្ទះ ដែលមានប្រមាណ ៥៧ ភាគរយ នៃលំនៅដ្ឋានដែលបានកាន់កាប់សរុប។ (សម្រាប់ ទិន្នន័យលម្អិត សូមមើលក្នុងតារាង២)។

តារាង២. ការកាន់កាប់លំនៅដ្ឋានតាមប្រភេទសម្ភារជញ្ជាំង និងបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| សម្ភារធ្វើជាជញ្ជាំង | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| **សម្ភាររឹង/អចិន្ត្រៃយ៍** | **៩៣,៩** | **៩៨,៧** | **៩៥,៨** | **៩២,០** |
| ឈើ ឬ ក្តារបន្ទះ | ៤៧,៤ | ១៦,៤ | ៤០,៦ | ៥៧,១ |
| ក្តារកុងប្លាកេ | ០,៨ | ០,៩ | ០,៧ | ០,៩ |
| បេតុង ឥដ្ឋ ថ្ម | ២៧,១ | ៧៦,១ | ៣៤,៤ | ១២,៩ |
| ស័ង្កសី/ដែកអាលុយមីញ៉ូម ឬបន្ទះលោហៈធាតុផ្សេងទៀត | ១៨,៣ | ៥,១ | ២០,១ | ២០,៨ |
| ហ្វីប្រូស៊ីម៉ងត៍ | ០,២ | ០,៣ | ០,១ | ០,៣ |
| **សម្ភារទន់/បណ្តោះអាសន្ន** | **៦,២** | **១,៣** | **៤,២** | **៨,០** |
| ឬស្សី/ស្បូវ/ស្លឹក/ស្មៅ | ៥,៩ | ០,៩ | ៤,១ | ៧,៧ |
| សម្ភារផ្សេងៗចម្រុះប្រើជំនួសបណ្តោះអាសន្ន | ០,១ | ០,០ | ០,១ | ០,២ |
| ដីឥដ្ឋ ចំបើងលាយអាចម៍សត្វ | ០,១ | ០,៤ | ០,០ | ០,០ |
| ផ្សេងទៀត | ០,១ | ០,០ | ០,០ | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

រូបភាព២. ជញ្ជាំងលំនៅដ្ឋានធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ ឆ្នាំ២០០៤ ២០០៩ ២០១៤ និង២០១៩/២០ (គិតជាភាគរយ)




ដូចគ្នាទៅនឹងសម្ភារធ្វើដំបូលដែរ ភាគរយនៃជញ្ជាំងធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍នៅកម្ពុជា មានការកើនឡើងជាលំដាប់នៅក្នុងរយៈពេលដប់ប្រាំឆ្នាំចុងក្រោយនេះ។ ដូចបានបង្ហាញនៅក្នុង រូបភាព២ ភាគរយនៃជញ្ជាំងលំនៅដ្ឋានធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍នៅកម្ពុជា មានការកើនឡើង ២៥ ភាគរយ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៤ ហើយបន្តកើន ១៣ភាគរយទៀត ពីឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៩/២០។

## សម្ភារសម្រាប់ធ្វើជាកម្រាលលំនៅដ្ឋាន

ដូចបានបង្ហាញនៅក្នុងតារាង៣ នៅឆ្នាំ២០១៩/២០មានលំនៅដ្ឋាននៅកម្ពុជាប្រមាណ ៦៣ ភាគរយ ដែលបានកាន់កាប់ដោយគ្រួសារ មានកម្រាលធ្វើពីសម្ភារទន់/បណ្ដោះអាសន្ន។ រនាបឈើ ជាសម្ភារធ្វើកម្រាលដែលគេនិយមប្រើជាងគេមានប្រមាណ ៤៦ ភាគរយ។ បន្ទាប់មក គឺកម្រាលធ្វើពីរនាបឫស្សី មានប្រមាណ ១២ ភាគរយ។ លំនៅដ្ឋានដែលមានកម្រាលធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ គឺឥដ្ឋការ៉ូត្រូវបានគេប្រើប្រាស់ភាគច្រើនមានប្រមាណ ២២ ភាគរយ។ បន្ទាប់មកគឺកម្រាលធ្វើពីបេតុងមានប្រមាណ ១២ ភាគរយ។ បើយើងពិនិត្យមើលភាពខុសគ្នាទៅតាមតំបន់នីមួយៗ ឃើញថាកម្រាលធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ នៅរាជធានីភ្នំពេញមានប្រមាណ ៨៤ ភាគរយ ក្នុងនោះមានប្រមាណ ៧០ ភាគរយ គឺធ្វើពីឥដ្ឋការ៉ូ។ នៅតំបន់ជនបទមានលក្ខណៈផ្ទុយពីនៅរាជធានីភ្នំពេញ គឺកម្រាលធ្វើពីសម្ភារទន់/បណ្ដោះអាសន្នមានចំនួនច្រើនលើសលុបប្រមាណ ៧៩ ភាគរយ ក្នុងនោះមានប្រមាណ ៥៦ ភាគរយ គឺធ្វើពីរនាបឈើ។ ដូចគ្នានេះដែរ សម្ភារធ្វើកម្រាលសម្រាប់សាងសង់លំនៅដ្ឋាននៅតំបន់ទីប្រជុំជនផ្សេងៗ គឺរនាបឈើដែលមានប្រមាណ ៣៩ ភាគរយ នៃលំនៅដ្ឋានដែលបានកាន់កាប់សរុប។ (សម្រាប់ទិន្នន័យលម្អិត សូមមើលក្នុងតារាង៣)។

តារាង៣. ការកាន់កាប់លំនៅដ្ឋានតាមប្រភេទសម្ភារកម្រាល និងបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| សម្ភារធ្វើជាកម្រាល | កម្ពុជា | រាជធានី ភ្នំពេញ | ទីប្រជុំជន ផ្សេងៗ | ជនបទ |
|---|---|---|---|---|
| **សម្ភាររឹង/អចិន្ត្រៃយ៍** | **៣៦,៧** | **៨៣,៨** | **៤៨,៥** | **២១,២** |
| បេតុង | ១១,៩ | ១០,៩ | ១៧,១ | ១០,១ |
| ការ៉ូឈើ ក្ដាររលោង | ៣,១ | ២,៦ | ៤,៤ | ២,៧ |
| ថ្មរលោង ថ្មដុស | ០,១ | ០,២ | ០,៣ | ០,១ |
| ប្លាស្ទិក | ០,០ | ០,០ | ០,០ | ០,០ |
| ឥដ្ឋការ៉ូ | ២១,៦ | ៧០,១ | ២៦,៧ | ៨,២ |
| **សម្ភារទន់/បណ្ដោះអាសន្ន** | **៦៣,៣** | **១៦,២** | **៥១,៥** | **៧៨,៨** |
| ដី/ដីឥដ្ឋ | ៥,៧ | ២,៨ | ៦,០ | ៦,២ |
| រនាបឈើ | ៤៥,៩ | ១២,៤ | ៣៩,១ | ៥៦,៣ |
| រនាបឫស្សី | ១១,៦ | ១,០ | ៦,៣ | ១៦,១ |
| ផ្សេងទៀត | ០,១ | ០,០ | ០,២ | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

រូបភាព៣. កម្រាលលំនៅដ្ឋានធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍ ឆ្នាំ២០០៤ ២០០៩ ២០១៤ និង២០១៩/២០ (គិតជាភាគរយ)




ដូចបានបង្ហាញនៅក្នុងរូបភាព៣ គឺជាភាគរយនៃកម្រាលលំនៅដ្ឋានធ្វើពីសម្ភាររឹង/អចិន្ត្រៃយ៍នៅកម្ពុជាមានការថយចុះតិចតួច គឺមានការថយចុះប្រមាណ ៣ ភាគរយ ពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០០៩ ហើយចាប់ផ្តើមកើនឡើងវិញប្រមាណ ២០ ភាគរយ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៩/២០។

## ៣.៣ កម្មសិទ្ធិលំនៅដ្ឋាន

នៅក្នុងឆ្នាំ២០១៩/២០នេះ ប្រទេសកម្ពុជាមានគ្រួសារ ៩២ ភាគរយ នៃគ្រួសារសរុប ដែលមានលំនៅដ្ឋានជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយនិងគ្រួសារជួលលំនៅដ្ឋានស្នាក់នៅមានប្រមាណ ៤ ភាគរយ។ ចំណែកគ្រួសារជាង ៣ ភាគរយទៀត មានការរស់នៅតាមរបៀបផ្សេងពីនេះគឺរស់នៅក្នុងលំនៅដ្ឋានដែលមិនមែនជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយក៏មិនបានបង់ថ្លៃឈ្នួលសម្រាប់ស្នាក់នៅផងដែរ។ ការកាន់កាប់លំនៅដ្ឋានជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់គ្រួសាររស់នៅរាជធានីភ្នំពេញ និងរស់នៅតាមតំបន់ទីប្រជុំជនផ្សេងៗ មានកម្រិតតិចជាងគ្រួសារដែលរស់នៅតាមតំបន់ជនបទ ដែលមានប្រមាណ ៧៥ ភាគរយ ៩២ ភាគរយ និង ៩៧ ភាគរយ សម្រាប់គ្រួសារនីមួយៗនៅតាមលំដាប់រៀង។ នៅរាជធានីភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងៗគ្រួសារដែលជួលលំនៅដ្ឋានគេសម្រាប់រស់នៅ មានអត្រាខ្ពស់គឺប្រមាណ ២១ ភាគរយ និងមាន ៤ ភាគរយ សម្រាប់គ្រួសារនិមួយៗនៅតាមលំដាប់រៀងគ្នា។(សម្រាប់ទិន្នន័យលម្អិតសូមមើលក្នុងតារាង៤)

**តារាង៤. លំនៅដ្ឋានដែលបានកាន់កាប់ បែងចែកតាមស្ថានភាពកម្មសិទ្ធិ និងតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ស្ថានភាពកម្មសិទ្ធិ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| លំនៅដ្ឋានកម្មសិទ្ធិផ្ទាល់ខ្លួន | ៩២,៣ | ៧៤,៦ | ៩១,៨ | ៩៦,៦ |
| លំនៅដ្ឋានមិនមែនកម្មសិទ្ធិតែរស់នៅមិនគិតថ្លៃ | ៣,៥ | ៤,២ | ៤,០ | ៣,១ |
| លំនៅដ្ឋានជួលគេ | ៤,៣ | ២១,២ | ៤,២ | ០,៣ |
| ផ្សេងទៀត | ០,០ | ០,០ | ០,១ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

## ៣.៤. ផ្ទៃក្រឡាលំនៅដ្ឋានបែងចែកតាមគ្រួសារ

### ផ្ទៃក្រឡាកម្រាលលំនៅដ្ឋាន

នៅប្រទេសកម្ពុជា ផ្ទៃក្រឡាកម្រាលលំនៅដ្ឋានគិតជាមធ្យមសម្រាប់មួយគ្រួសារនៅឆ្នាំ២០១៩/២០ គឺមានប្រមាណ ៥៥ ម៉ែត្រការ៉េ។ ផ្ទៃក្រឡាកម្រាលលំនៅដ្ឋានជាមធ្យមសម្រាប់គ្រួសាររស់នៅតាមតំបន់ជនបទគឺមាន ៥២មែត្រការ៉េ ក្នុងមួយគ្រួសារ និងមាន ៥៧មែត្រការ៉េក្នុងមួយគ្រួសារ នៅតំបន់ទីប្រជុំជនផ្សេងៗ។ ចំពោះគ្រួសារដែលរស់នៅក្នុងលំនៅដ្ឋានមានផ្ទៃក្រឡាលើសពី ១០០ មែត្រការ៉េ គឺមានប្រមាណ ១៩ ភាគរយ នៅរាជធានីភ្នំពេញ ៩ ភាគរយ តំបន់ទីប្រជុំជនផ្សេងៗ និងមានប្រមាណ ៥ភាគរយប៉ុណ្ណោះនៅតាមតំបន់ជនបទ។

**តារាង៥. ផ្ទៃក្រឡាកម្រាលបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ ២០១៩/២០ (គិតជាភាគរយ)មធ្យមភាគម៉ែត្រការ៉េក្នុងមួយគ្រួសារ**

| ផ្ទៃក្រឡាកម្រាល | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| ០០-១៩ | ៣,៤ | ៧,៧ | ២,៤ | ២,៨ |
| ២០-៣៩ | ២៩,៦ | ២០,៧ | ២៩,៩ | ៣១,៦ |
| ៤០-៥៩ | ៣៤,៦ | ២៥,២ | ៣៤,១ | ៣៧,០ |
| ៦០-៧៩ | ១៦,៧ | ១៩,០ | ១៥,៣ | ១៦,៧ |
| ៨០-៩៩ | ៧,៩ | ៨,៨ | ៩,៧ | ៧,០ |
| ១០០+ | ៧,៨ | ១៨,៧ | ៨,៧ | ៥,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| មធ្យមភាគមែត្រការ៉េក្នុងមួយគ្រួសារ | ៥៥,៤ | ៦៨,៧ | ៥៧,៣ | ៥១,៥ |

នៅក្នុងតារាង៥ ក៏បានបង្ហាញផងដែរថា មានគ្រួសារប្រមាណ ៣៤ ភាគរយ នៅតាមតំបន់ជនបទបានកាន់កាប់លំនៅដ្ឋានមានផ្ទៃក្រឡាកម្រាលតិចជាង៤០មែត្រការ៉េ បើប្រៀបធៀបជាមួយនឹងគ្រួសាររស់តំបន់ទី

ប្រជុំជនផ្សេងៗ គឺមានប្រមាណ ៣២ ភាគរយ និងគ្រួសាររស់នៅក្នុងរាជធានីភ្នំពេញ គឺមានប្រមាណ២៨ភាគរយ។ (សម្រាប់ទិន្នន័យលម្អិត សូមមើលតារាង៥)។

## ទំហំម៉ែត្រការ៉េសម្រាប់មនុស្សម្នាក់

តារាង៦ បានបង្ហាញអំពីទំហំម៉ែត្រការ៉េគិតជាមធ្យមសម្រាប់មនុស្សម្នាក់ដែលរស់នៅក្នុងលំនៅដ្ឋាននៅឆ្នាំ២០១៩/២០។ ជារួមនៅប្រទេសកម្ពុជា ផ្ទៃក្រឡាកម្រាលដែលកាន់កាប់ដោយមនុស្សម្នាក់ មានប្រមាណ ១៥ ម៉ែត្រការ៉េ។ នៅរាជធានីភ្នំពេញ ផ្ទៃក្រឡាកម្រាលសម្រាប់មនុស្សម្នាក់ មានប្រមាណ ១៩ម៉ែត្រការ៉េ ចំណែកនៅតាមតំបន់ទីប្រជុំជនផ្សេងៗ គឺមាន ១៥ម៉ែត្រការ៉េ និងនៅតាមតំបន់ជនបទ គឺមាន ១៤ម៉ែត្រការ៉េ សម្រាប់មនុស្សម្នាក់។

**តារាង៦. មធ្យមភាគផ្ទៃក្រឡាកម្រាលបែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាម៉ែត្រការ៉េក្នុងមនុស្សម្នាក់**

| មធ្យមភាគក្នុងមនុស្សម្នាក់ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| | ១៤,៦ | ១៨,៥ | ១៥,០ | ១៣,៥ |

## ចំនួនបន្ទប់ក្នុងលំនៅដ្ឋាន

តារាង៧ បង្ហាញថានៅប្រទេសកម្ពុជា មានលំនៅដ្ឋានប្រមាណ ៥៦ ភាគរយ មានមួយបន្ទប់ ហើយមានប្រមាណ ៣០ ភាគរយមាន២បន្ទប់ និងមាន ១ ភាគរយដែលមានចាប់ពី៥បន្ទប់ឡើងទៅ។ ការកំណត់និយមន័យទៅលើលក្ខណៈបន្ទប់ដែលបានកត់ត្រានៅក្នុងការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គឺយកតែបន្ទប់ទទួលភ្ញៀវ និងបន្ទប់ដេកតែប៉ុណ្ណោះ ដោយមិនបានរាប់បញ្ចូលនូវផ្ទះបាយ បង្គន់ បន្ទប់ទឹក ឬកន្លែងចតរថយន្ត ផ្ទៃក្រឡាផ្សេងទៀតថាជាបន្ទប់នោះទេ។

**តារាង៧. ចំនួនបន្ទប់បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាភាគរយ និងមធ្យមភាគ**

| ចំនួនបន្ទប់ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| ១បន្ទប់ | ៥៦,២ | ៣៨,២ | ៤៨,៥ | ៦៣,២ |
| ២បន្ទប់ | ២៩,៨ | ៣០,៤ | ៣២,៧ | ២៨,៥ |
| ៣បន្ទប់ | ៩,៤ | ១៧,០ | ១២,៥ | ៦,៥ |
| ៤បន្ទប់ | ៣,៤ | ១០,៨ | ៤,០ | ១,៤ |
| ៥បន្ទប់ឡើងទៅ | ១,៣ | ៣,៦ | ២,៣ | ០,៤ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនបន្ទប់ជាមធ្យមក្នុងមួយគ្រួសារ | ១,៦ | ២,១ | ១,៨ | ១,៥ |

តារាង៧ ក៏បានបង្ហាញផងដែរថា លំនៅដ្ឋានដែលមានតែមួយបន្ទប់ គឺមានអត្រាខ្ពស់ជាងគេនៅតាមតំបន់ជនបទគឺប្រហែល ៦៣ ភាគរយ បន្ទាប់មកនៅតាមទីប្រជុំជនផ្សេងៗ មានប្រមាណ ៤៩ ភាគរយ ហើយមានកម្រិតទាបជាងគេសម្រាប់គ្រួសារនៅក្នុងរាជធានីភ្នំពេញ គឺមានប្រមាណ ៣៨ ភាគរយ។ ជារួមនៅប្រទេសកម្ពុជា ចំនួនបន្ទប់ជាមធ្យមដែលកាន់កាប់ក្នុងមួយគ្រួសារ គឺមានប្រមាណ ១,៦ បន្ទប់។ នៅរាជធានីភ្នំពេញមាន

ប្រមាណ ២,១ បន្ទប់ក្នុងមួយគ្រួសារ ដែលមានអត្រាខ្ពស់ជាងតំបន់ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទដែលមាន ១,៨ និង១,៥ តាមលំដាប់រៀងៗគ្នា។

### ចំនួនមនុស្សក្នុងមួយបន្ទប់

តារាង៨ បង្ហាញថានៅប្រទេសកម្ពុជា មានចំនួនមនុស្សគិតជាមធ្យមក្នុងមួយបន្ទប់គឺមានគ្នា ៣ នាក់ ដែលរស់នៅក្នុងលំនៅដ្ឋានមួយ។

**តារាង៨. ចំនួនមនុស្សក្នុងមួយបន្ទប់បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ មធ្យមក្នុងមួយបន្ទប់**

| មនុស្សក្នុងមួយបន្ទប់ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| ចំនួនមនុស្សក្នុងមួយបន្ទប់ | ៣,២ | ២,៥ | ៣,០ | ៣,៥ |

នៅរាជធានីភ្នំពេញ ក្នុងមួយបន្ទប់មានមនុស្សរស់នៅគិតជាមធ្យមចំនួន ២,៥នាក់។ ចំនួននេះបើប្រៀបធៀបនឹងតំបន់ទីប្រជុំជនផ្សេងៗ គឺមាន ៣នាក់ ក្នុងមួយបន្ទប់ និងនៅតាមតំបន់ជនបទ មាន ៣,៥នាក់ ក្នុងមួយបន្ទប់។ តារាង៨ ក៏បានបង្ហាញផងដែរថា ចំនួនមនុស្សជាមធ្យមសម្រាប់មួយនាក់រស់នៅក្នុងមួយបន្ទប់នោះ គឺពុំទាន់អាចឃើញមាននៅឡើយ ទោះបីជានៅរាជធានីភ្នំពេញក៏ដោយ។

## ៣.៥ ទឹកបរិភោគ

សម្រាប់ប្រទេសកម្ពុជា លទ្ធភាពក្នុងការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវបានកំណត់ទៅតាមការធ្វើឱ្យប្រសើរឡើងនូវប្រភពទឹកស្អាតដែលមានស្រាប់។ ការធ្វើឱ្យប្រសើរឡើងនូវប្រភពទឹកស្អាត គឺមិនសំដៅទៅលើប្រភពទឹកដែលមានសុវត្ថិភាពនោះទេ ក៏ប៉ុន្តែសំដៅទៅលើប្រភពទឹកដែលទំនងជាអាចផ្តល់នូវទឹកស្អាតយកមកប្រើប្រាស់។

### ប្រភពទឹកសំខាន់ៗសម្រាប់បរិភោគ

តារាង៩ បង្ហាញអំពីប្រភពទឹកសំខាន់ៗសម្រាប់បរិភោគដែលប្រើប្រាស់ដោយគ្រួសារ។ តាមនិយមន័យនៃប្រភពទឹកដែលបានកែលម្អរួមមានៈ "ទឹកបណ្តាញនៅក្នុងលំនៅដ្ឋាន" "ទឹកបណ្តាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន" "ទឹកបំពង់សាធារណៈ" "ទឹកអណ្តូងស្នប់/អណ្តូងខួង" "ទឹកអណ្តូងជីកមានគម្របការពារ" "ទឹកចេញក្រោមដីមានការការពារ" "ទឹកភ្លៀង" និង "ទឹកដប/ទឹកពិសាដប"។

នៅទូទាំងប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩/២០ មានគ្រួសារប្រមាណ ៨០ ភាគរយមានលទ្ធភាពប្រើប្រាស់ប្រភពទឹកដែលបានកែលម្អ។

តារាង៩. ប្រភពទឹកសំខាន់ៗសម្រាប់បរិភោគបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| ប្រភពទឹក | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| **ប្រភពទឹកបានកែលម្អ** | **៧៩,៧** | **៩៤,៥** | **៨៣,៩** | **៧៤,៧** |
| ទឹកបំពង់បណ្តាញក្នុងលំនៅដ្ឋាន | ២៥,៨ | ៨១,៧ | ៣២,៩ | ១០,១ |
| ទឹកបំពង់បណ្តាញក្នុងទីធ្លា/បរិវេណលំនៅដ្ឋាន | ៣,៧ | ២,៦ | ៦,៤ | ៣,០ |
| ទឹកបំពង់សាធារណៈ | ១,០ | ០,១ | ១,៩ | ០,៨ |
| អណ្តូងស្នប់/អណ្តូងខួង | ៣០,១ | ៤,៥ | ២៤,០ | ៣៨,៤ |
| អណ្តូងជីកមានគម្របការពារ | ៤,១ | ១,៣ | ២,៧ | ៥,4 |
| ទឹកភ្លៀង | ៥,៨ | ០,០ | ៤,៤ | ៧,៧ |
| ទឹកដប/ទឹកពិសាដប | ៩,១ | ៤,៣ | ១១,៦ | ៩,៤ |
| **ប្រភពទឹកមិនបានកែលម្អ** | **២០,៣** | **៥,៥** | **១៦,១** | **២៥,៣** |
| អណ្តូងជីកគ្មានគម្របការពារ | ៤,៤ | ០,៤ | ២,៣ | ៦,១ |
| ទឹកចេញក្រោមដីគ្មានការការពារ | ០,១ | ០,០ | ០,៣ | ០,១ |
| ទឹកទិញឡានស៊ីទែន | ៣,៩ | ២,៩ | ៤,៧ | ៣,៩ |
| ទឹកទិញធុងរទេះ | ២,៩ | ០,១ | ៣,៤ | ៣,៥ |
| ទឹកលើដី(ទឹកទន្លេ/ស្ទឹង/ព្រែក/បឹង/ស្រះ/អូរ/ត្រពាំង) | ៨,៦ | ២,០ | ៥,១ | ១១,៥ |
| ផ្សេងទៀត | ០,៣ | ០,១ | ០,៤ | ០,៣ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

បើពិនិត្យមើលភាពខុសគ្នាទៅតាមតំបន់នីមួយៗ ឃើញថាមានគ្រួសារប្រមាណ ៨២ ភាគរយ រស់នៅរាជធានីភ្នំពេញប្រើប្រាស់ទឹកបណ្តាញក្នុងលំនៅដ្ឋាន។ នៅតាមតំបន់ទីប្រជុំជនផ្សេងៗ គ្រួសារប្រមាណ ៣៣ ភាគរយ គឺប្រើប្រាស់ទឹកបណ្តាញក្នុងលំនៅដ្ឋាន បើប្រៀបធៀបនឹងតំបន់ជនបទមានគ្រួសារប្រមាណតែ ១០ ភាគរយប៉ុណ្ណោះដែលប្រើប្រាស់ទឹកបណ្តាញក្នុងលំនៅដ្ឋាន។ ទោះជាយ៉ាងណា អណ្តូងស្នប់ ឬអណ្តូងខួងក៏ជាប្រភពទឹកដែលនិយមប្រើច្រើននៅតាមតំបន់ប្រជុំជនផ្សេងៗ និងតំបន់ជនបទ ដែលមានគ្រួសារប្រមាណ ២៤ ភាគរយ និង ៣៨ ភាគរយ តាមលំដាប់រៀងគ្នា។ ទោះជាបែបនេះក៏ដោយ នៅតែមានគ្រួសារជាច្រើននៅតាមតំបន់ជនបទប្រើប្រាស់ប្រភពទឹកពីស្រះ ទន្លេ ស្ទឹង ត្រពាំង អូរ សម្រាប់យកមកបរិភោគ ដែលមានប្រមាណ ១២ ភាគរយ។ (សូមមើលតារាង៩ សម្រាប់ព័ត៌មានបន្ថែម) ។

រូបភាព៤. គ្រួសារដែលបានប្រើប្រាស់ប្រភពទឹកបានកែលម្អ ឆ្នាំ២០០៤ ២០០៩ ២០១៤ និង២០១៩/២០ (គិតជាភាគរយ)




រូបភាព៤ បង្ហាញពីទិន្នន័យស្តីពីប្រភពទឹកបរិភោគដែលបានកែលម្អ តួលេខបានបង្ហាញថា ប្រភពទឹកដែលបានកែលម្អបានកើនឡើងបន្តិចក្នុងរយៈពេលប្រាំឆ្នាំពីរដងដំបូង ពី ៤៦ ភាគរយ នៅក្នុងឆ្នាំ២០០៤ កើនដល់ ៤៩ ភាគរយ នៅក្នុងឆ្នាំ ២០០៩ និងដល់ ៥៥ ភាគរយក្នុងឆ្នាំ២០១៤។ ប៉ុន្តែបានកើនឡើងយ៉ាងខ្លាំងរហូតដល់ ៨០ភាគរយក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។

## ការដាំ/ការបន្សុទ្ធទឹកសម្រាប់បរិភោគ

តាមលទ្ធផលក្នុងតារាង១០ បង្ហាញថានៅប្រទេសកម្ពុជាមានគ្រួសារប្រមាណ ៦៧ភាគរយ ដែលពួកគាត់បានដាំ/បន្សុទ្ធទឹកសម្រាប់បរិភោគរៀងរាល់ពេល ចំណែកគ្រួសារប្រមាណ ១៣ ភាគរយដែលពួកគាត់បានដាំ/បន្សុទ្ធទឹកនៅពេលខ្លះ(ម្តងម្កាល)សម្រាប់បរិភោគ និងមាន ២០ ភាគរយ ដែលពួកគាត់មិនដែលដាំ/បន្សុទ្ធទឹកសម្រាប់បរិភោគសោះ។

តារាង១០ ក៏បានបង្ហាញផងដែរថា មានគ្រួសារប្រមាណ ៧៧ ភាគរយរស់នៅរាជធានីភ្នំពេញ និងមាន ៦៧ ភាគរយនៅតាមតំបន់ទីប្រជុំជនផ្សេងៗ និងមានប្រមាណ ៦៤ ភាគរយនៅតាមតំបន់ជនបទ បានដាំ/បន្សុទ្ធទឹកសម្រាប់បរិភោគទៀងទាត់គ្រប់ពេល។

តារាង១០. គ្រួសារដែលបានដាំ/បន្សុទ្ធទឹកសម្រាប់បរិភោគ បែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| ការដាំ/ការបន្សុទ្ធទឹក | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| ដាំ/បន្សុទ្ធទឹករៀងរាល់ពេល | ៦៦,៦ | ៧៦,៥ | ៦៧,១ | ៦៤,១ |
| ដាំ/បន្សុទ្ធទឹកនៅពេលខ្លះ | ១៣,៣ | ១៥,៣ | ១៣,៤ | ១២,៨ |
| មិនដែលដាំ/បន្សុទ្ធទឹក | ២០,២ | ៨,៣ | ១៩,៥ | ២៣,២ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានគ្រួសារប្រមាណ ២៣ ភាគរយដែលរស់នៅតាមតំបន់ជនបទ និងមានប្រហែល ២០ ភាគរយរស់នៅតាមតំបន់ទីប្រជុំជនផ្សេងៗ មិនដែលបានដាំ/បន្សុទ្ធទឹកសម្រាប់បរិភោគទេ។ ដោយឡែកនៅក្នុងរាជធានីភ្នំពេញ អត្រានេះមានប្រហែល ៨ ភាគរយ តែប៉ុណ្ណោះ។

រូបភាព៥. គ្រួសារដែលបានដាំ/បន្សុទ្ធទឹកសម្រាប់បរិភោគ ឆ្នាំ២០០៤ ២០០៩ ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)




រូបភាព៥ បង្ហាញពីភាគរយនៃគ្រួសារដែលបានដាំទឹក/បន្សុទ្ធទឹកសម្រាប់បរិភោគជារៀងរាល់ពេលក្នុងកំឡុងពេល១៥ឆ្នាំចុងក្រោយនៅកម្ពុជា។ ផ្អែកតាមលទ្ធផលបានបង្ហាញថា និន្នាការនៃការដាំ/បន្សុទ្ធទឹកសម្រាប់បរិភោគមានការកើនឡើងជាលំដាប់កំឡុងពេល១០ឆ្នាំដំបូង ពោលគឺកើនពីប្រមាណ ៥៣ ភាគរយ នៅឆ្នាំ២០០៤ កើនដល់ ៦០ ភាគរយនៅក្នុងឆ្នាំ២០០៩ និងដល់ ៧១ភាគរយនៅឆ្នាំ២០១៤។ ប៉ុន្តែវាបានថយចុះបន្តិចវិញក្នុងរយៈពេល៥ឆ្នាំចុងក្រោយដែលមានកំណើនប្រមាណ ៦៧ ភាគរយនៅក្នុងឆ្នាំ២០១៩/២០។

## ៣.៦. បង្គន់អនាម័យ

បង្គន់អនាម័យកែលម្អ គឺជាបង្គន់ដែលប្រើប្រាស់ជាលក្ខណៈឯកជននៅតាមគ្រួសារ ហើយអាចញែកចេញនូវកាកសំណល់លាមក(អាចម៍)ប្រកបដោយប្រសិទ្ធភាព ដើម្បីការពារកុំឱ្យមានការប៉ះពាល់ដល់មនុស្ស។

### បង្គន់អនាម័យនៅតាមលំនៅដ្ឋាន

ប្រភេទបង្គន់អនាម័យ ត្រូវបានប្រើប្រាស់ជាមធ្យោបាយ ដើម្បីវាស់វែងអំពីស្ថានភាពអនាម័យ។ និយមន័យ កំណត់អំពីបង្គន់អនាម័យដែលបានកែលម្អ រួមមានបីប្រភេទដូចជា "បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកតភ្ជាប់ទៅប្រព័ន្ធលូ" "បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកតភ្ជាប់ទៅអាងស្តុក/រណ្តៅ" និង "បង្គន់រណ្តៅមានផែនបង្គន់សម្រាប់បត់ជើង"។ ដូចបានបង្ហាញនៅក្នុងតារាង១១ នៅទូទាំងប្រទេសកម្ពុជាមានគ្រួសារប្រមាណ ៨០ភាគរយ ក្នុងចំណោមគ្រួសារសរុប បានប្រើប្រាស់បង្គន់អនាម័យដែលបានកែលម្អ។ ក្នុងនោះគ្រួសារស្ទើរតែទាំងអស់ មានបង្គន់ទំនើបភ្ជាប់ជាមួយប្រព័ន្ធលូ ឬ អាងស្តុក/រណ្តៅនៅក្នុងលំនៅដ្ឋានរបស់ពួកគេ។

**តារាង១១. បង្គន់អនាម័យបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភេទបង្គន់អនាម័យ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទផ្សេងៗ |
|---|---|---|---|---|
| **បង្គន់អនាម័យ បានកែលម្អ** | **៨០,៤** | **៩៧,៨** | **៨៦,១** | **៧៤,២** |
| បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកតភ្ជាប់ទៅប្រព័ន្ធលូ | ១៧,៦ | ៨១,២ | ១២,០ | ៤,៨ |
| បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកតភ្ជាប់ទៅអាងស្តុក/រណ្តៅ | ៦១,៩ | ១៥,៨ | ៧៣,៦ | ៦៨,៤ |
| បង្គន់រណ្តៅមានផែនបង្គន់សម្រាប់បត់ជើង | ០,៩ | ០,៨ | ០,៥ | ១,០ |
| **បង្គន់គ្មានអនាម័យមិនបានកែលម្អ** | **១៩,៦** | **២,៣** | **១៣,៩** | **២៥,៨** |
| បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកទៅកន្លែងផ្សេង | ២,២ | ០,៨ | ២,១ | ២,៦ |
| បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បត់ជើង | ០,២ | ០,០ | ០,០ | ០,៣ |
| បង្គន់បត់ជើងទម្លាក់ទៅទីវាល ឬក្នុងទឹក | ១,៣ | ០,១ | ១,០ | ១,៧ |
| គ្មានបង្គន់ | ១៥,៨ | ១,៤ | ១០,៧ | ២១,០ |
| បង្គន់ផ្សេងទៀត (សូមបញ្ជាក់) | ០,២ | ០,០ | ០,១ | ០,៣ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

បើយើងពិនិត្យមើលភាពខុសគ្នាទៅតាមតំបន់នីមួយៗ ឃើញថាគ្រួសារដែលរស់នៅតាមតំបន់ជនបទប្រមាណ ២៦ ភាគរយ បានប្រើប្រាស់បង្គន់គ្មានអនាម័យ(មិនបានកែលម្អ)។ តួលេខនេះមានអត្រាទាបជាងនៅតាមតំបន់ទីប្រជុំជនផ្សេងៗមានប្រមាណ ១៤ ភាគរយ និងនៅរាជធានីភ្នំពេញ មានប្រមាណ ២ ភាគរយ។ ចំណែកការប្រើប្រាស់បង្គន់អនាម័យកែលម្អនៅតាមតំបន់ទីប្រជុំជនផ្សេងៗ និងតាមតំបន់ជនបទនៅមានកម្រិតទាបជាងច្រើន បើប្រៀបធៀបនឹងនៅរាជធានីភ្នំពេញដែលមានប្រមាណ ៨៦ភាគរយ និង ៧៤ ភាគរយ តាមលំដាប់រៀង។ ម៉្យាងវិញទៀត គេសង្កេតឃើញថាមានគ្រួសារភាគច្រើនដែលរស់នៅតាមតំបន់ជនបទ គឺនៅតែ

ប្រើប្រាស់បង្គន់គ្មានអនាម័យ ពោលគឺគ្មានបង្គន់បន្ទោរបង់ (បន្ទោរបង់នៅទីវាល) ក៏នៅតែជាបញ្ហាប្រឈមដ៏សំខាន់ផងដែរ(សម្រាប់ព័ត៌មានបន្ថែម សូមមើលតារាង១១)។

**រូបភាព៦. ការប្រើប្រាស់បង្គន់អនាម័យកែលម្អ ឆ្នាំ២០០៤ ២០០៩ ២០១៤ និង២០១៩/២០ (គិតជាភាគរយ)**




រូបភាព៦ បង្ហាញថា ចំណែកភាគរយនៃគ្រួសារក្នុងប្រទេសកម្ពុជាដែលមានលទ្ធភាពប្រើប្រាស់បង្គន់អនាម័យកែលម្អ បានកើនឡើងជាលំដាប់ក្នុងរយៈពេល១៥ឆ្នាំចុងក្រោយ។ តួលេខបង្ហាញថាភាគរយបានកើនឡើងប្រមាណ ៣១ ភាគរយ ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៤ ហើយបន្តកើនឡើងប្រមាណ ២៤ ភាគរយទៀត ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០។

## ៣.៧ ឧបករណ៍លាងដៃ

តារាង១២ បង្ហាញថានៅទូទាំងប្រទេសកម្ពុជា មានគ្រួសារប្រមាណ ៨៩ ភាគរយ ដែលបានប្រើប្រាស់ឧបករណ៍ផ្សេងៗសម្រាប់លាងដៃនៅក្នុងបរិវេណផ្ទះ។ ក្នុងចំណោមឧបករណ៍សម្រាប់លាងដៃដែលបានប្រើប្រាស់ញឹកញាប់ជាងគេនោះ មានប្រមាណ ៥៩ ភាគរយ នៅជិតបង្គន់(ចម្ងាយតិចជាង៣ម៉ែត្រ) និងមាន៣៩ ភាគរយនៅជិតបង្គន់(ចម្ងាយឆ្ងាយជាង៣ម៉ែត្រ)។ នៅក្នុងតារាងក៏បានបង្ហាញផងដែរថាឧបករណ៍សម្រាប់លាងដៃនៅក្នុងបរិវេណផ្ទះប្រមាណ៩៥ ភាគរយ និង ៨៥ ភាគរយ មានទឹក និងសាប៊ូនៅកន្លែងលាងដៃ តាមលំដាប់រៀង។

បើគេពិនិត្យមើលភាពខុសគ្នាទៅតាមតំបន់នីមួយៗឃើញថា គ្រួសារដែលរស់នៅក្នុងរាជធានីភ្នំពេញមានប្រមាណ ៧១ ភាគរយ បានប្រើប្រាស់ឧបករណ៍សម្រាប់លាងដៃ ដែលតភ្ជាប់ជាមួយចរន្តទឹកចេញពីប្រព័ន្ធបំពង់ ឬអាងទឹក។ ផ្ទុយពីនៅរាជធានីភ្នំពេញ ចំពោះគ្រួសារដែលរស់នៅតាមតំបន់ជនបទ និងទីប្រជុំជនផ្សេងៗប្រមាណ ៧៣ ភាគរយ និង ៦៤ភាគរយបានប្រើប្រាស់ឧបករណ៍សម្រាប់លាងដៃ ដែលមានប្រព័ន្ធទឹកដងដោយដៃ តាមលំដាប់រៀង។ (សម្រាប់ព័ត៌មានលម្អិត សូមមើលតារាង១២)។

**តារាង១២. ឧបករណ៍សម្រាប់លាងដៃនៅក្នុងបរិវេណផ្ទះបែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| ឧបករណ៍សម្រាប់លាងដៃនៅក្នុងបរិវេណផ្ទះ | | | | |
| មិនមាន | ១១,០ | ២,២ | ១០,០ | ១៣,៥ |
| ទឹកមានចរន្តចេញពីប្រព័ន្ធបំពង់ ឬអាង | ១៨,៦ | ៧០,៧ | ២០,៦ | ៥,៧ |
| ប្រព័ន្ធទឹកដងដោយដៃ | ៦៣,៨ | ២៤,៣ | ៦៤,៤ | ៧២,៨ |
| ធុង/អាង | ៦,៦ | ២,៩ | ៥,០ | ៨,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ឧបករណ៍សម្រាប់លាងដៃដែលប្រើញឹកញាប់ | | | | |
| នៅជិតបង្គន់ (តិចជាង ៣ម៉ែត្រ) | ៥៩,២ | ៨២,៥ | ៦៦,០ | ៥០,៣ |
| នៅជិតបង្គន់(តិចជាង ៣ម៉ែត្រ)ឬនៅកន្លែងផ្សេង | ៣៨,៥ | ១៥,៥ | ៣២,១ | ៤៧,០ |
| មិនត្រូវបានសង្កេតដោយសារគ្មានការអនុញ្ញាត | ១,៦ | ១,៧ | ១,២ | ១,៧ |
| មិនត្រូវបានសង្កេតដោយសារមូលហេតុផ្សេងទៀត | ០,៨ | ០,២ | ០,៧ | ០,៩ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| មានទឹកនៅកន្លែងលាងដៃ | | | | |
| មាន | ៩៤,៨ | ៩៤,១ | ៩៦,៤ | ៩៤,៣ |
| គ្មាន | ៥,២ | ៥,៩ | ៣,៦ | ៥,៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| មានសាប៊ូនៅកន្លែងលាងដៃ | | | | |
| មាន | ៨៥,២ | ៨៩,៤ | ៩០,៧ | ៨២,០ |
| គ្មាន | ១៤,៨ | ១០,៦ | ៩,៣ | ១៨,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| មានទឹកនិងសាប៊ូនៅកន្លែងលាងដៃ | | | | |
| មាន | ៧៥,០ | ៨៦,៦ | ៨១,០ | ៧០,១ |
| គ្មាន | ២៥,០ | ១៣,៤ | ១៩,០ | ២៩,៩ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

## ៣.៨ ប្រភពថាមពលសម្រាប់បំភ្លឺ និងចម្អិនអាហារ

### ប្រភពថាមពលសម្រាប់បំភ្លឺ

តារាង១៣ បង្ហាញថានៅឆ្នាំ២០១៩/២០ មានប្រភពថាមពលសំខាន់ៗ សម្រាប់បំភ្លឺនៅតាមលំនៅដ្ឋានរបស់គ្រួសារនៅក្នុងប្រទេសកម្ពុជា គឺមានគ្រួសារប្រើប្រាស់អគ្គិសនីផ្គត់ផ្គង់សាធារណៈ ឬអគ្គិសនីរដ្ឋ (៨៦ភាគរយ) ពន្លឺព្រះអាទិត្យ(៨ភាគរយ) និងគ្រួសារប្រើប្រាស់អាគុយមានប្រមាណ ៤ ភាគរយ។ ចំណែកឯប្រភពបំភ្លឺផ្សេងទៀតមានតិចជាង ១ ភាគរយ ដែលគ្រួសារនៅកម្ពុជានៅប្រើប្រាស់ប្រភពបំភ្លឺទាំងនេះនៅឡើយ។

**តារាង១៣. ប្រភពថាមពលសំខាន់ៗសម្រាប់បំភ្លឺ បែងចែងតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភពថាមពលសម្រាប់បំភ្លឺ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| អគ្គិសនីផ្គត់ផ្គង់សាធារណៈ/អគ្គិសនីរដ្ឋ | ៨៥,៧ | ៩៨,៥ | ៩៥,៦ | ៧៩,០ |
| ម៉ាស៊ីនភ្លើង | ០,៧ | ០,៥ | ០,៥ | ០,៨ |
| អាគុយ | ៤,១ | ០,០ | ១,៤ | ៦,០ |
| ចង្កៀងប្រេងកាត | ០,៥ | ០,៥ | ០,១ | ០,៦ |
| ទៀន | ០,១ | ០,១ | ០,១ | ០,១ |
| ពន្លឺព្រះអាទិត្យ | ៨,៤ | ០,០ | ២,០ | ១២,៧ |
| គ្មាន | ០,១ | ០,០ | ០,១ | ០,១ |
| ផ្សេងទៀត | ០,៥ | ០,៤ | ០,២ | ០,៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

បើគេពិនិត្យមើលភាពខុសគ្នាទៅតាមតំបន់នីមួយៗ ឃើញថានៅក្នុងរាជធានីភ្នំពេញស្ទើរតែគ្រប់គ្រួសារទាំងអស់ គឺបានប្រើប្រាស់អគ្គិសនីផ្គត់ផ្គង់សាធារណៈ ឬអគ្គិសនីរដ្ឋសម្រាប់ជាប្រភពបំភ្លឺ។ គ្រួសារដែលបានប្រើប្រាស់អគ្គិសនីផ្គត់ផ្គង់សាធារណៈ ឬអគ្គិសនីរដ្ឋ នៅតាមតំបន់ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទ នៅមានកម្រិតទាបជាង បើប្រៀបធៀបជាមួយនឹងគ្រួសារដែលរស់នៅក្នុងរាជធានីភ្នំពេញ គឺមានប្រមាណ ៩៦ ភាគរយ និង ៧៩ ភាគរយ តាមលំដាប់រៀង។ គ្រួសារនៅតាមតំបន់ជនបទ នៅតែប្រើប្រាស់ពន្លឺព្រះអាទិត្យ និងអាគុយ សម្រាប់ធ្វើជាប្រភពបំភ្លឺបន្ទាប់ពីអគ្គិសនី ដែលមានប្រមាណ ១៣ ភាគរយ និង ៦ ភាគរយ តាមលំដាប់រៀង។ (សម្រាប់ព័ត៌មានលម្អិត សូមមើលតារាង១៣)។

រូបភាព៧. ប្រភពថាមពលអគ្គិសនីផ្គត់ផ្គង់សាធារណៈ/អគ្គិសនីរដ្ឋសម្រាប់បំភ្លឺ ឆ្នាំ២០០៤ ២០០៩ ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)




រូបភាព៧ បង្ហាញពីភាគរយនៃគ្រួសារដែលប្រើប្រាស់អគ្គិសនីផ្គត់ផ្គង់សាធារណៈ ឬអគ្គិសនីរដ្ឋ មានការកើនឡើងខ្ពស់ពី១៤ភាគរយ នៅឆ្នាំ២០០៤ ដល់ ២៦ ភាគរយនៅឆ្នាំ២០០៩។ ចាប់តាំងពីឆ្នាំ២០០៩ ភាគរយគ្រួសារដែលប្រើប្រាស់ អគ្គិសនីផ្គត់ផ្គង់សាធារណៈ ឬអគ្គិសនីរដ្ឋ គឺមានការកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលដប់ឆ្នាំចុងក្រោយ គឺកើនពី ២៦ភាគរយ ដល់ ៨៦ ភាគរយ នៅឆ្នាំ២០១៩/២០។

## ប្រភពថាមពលសម្រាប់ចម្អិនអាហារ

នៅប្រទេសកម្ពុជា មានគ្រួសារប្រមាណ ៥១ ភាគរយប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ និងមានគ្រួសារ ៤២ ភាគរយប្រើប្រាស់ឧស្ម័នហ្គាស និងមាន ៦ ភាគរយផ្សេងទៀត ប្រើប្រាស់ធ្យូងសម្រាប់ចម្អិនអាហារ។

នៅតាមតំបន់ជនបទ មានគ្រួសារប្រមាណជាង ៦៨ ភាគរយ ប្រើប្រាស់អុសជាប្រភពឥន្ធនៈសម្រាប់ចម្អិនអាហារ។ ចំណែកនៅតាមតំបន់ទីប្រជុំជនផ្សេងៗ គ្រួសារប្រមាណ ៣៨ ភាគរយប្រើប្រាស់អុស។ គ្រួសារនៅរាជធានីភ្នំពេញបានប្រើឧស្ម័នហ្គាសគឺជាប្រភពឥន្ធនៈសំខាន់បំផុតសម្រាប់ចម្អិនអាហារ ក្នុងនោះមានគ្រួសារប្រមាណ ៩២ ភាគរយបានប្រើប្រាស់ប្រភពនេះសម្រាប់ចម្អិនអាហារ។ សម្រាប់គ្រួសារដែលប្រើប្រាស់អុស និងធ្យូងសម្រាប់ចម្អិនអាហារនៅរាជធានីភ្នំពេញ គឺមានកម្រិតទាបប្រមាណ ៤ ភាគរយ និងមាន ២ភាគរយប៉ុណ្ណោះតាមលំដាប់រៀង។ (សូមមើលតារាង១៤សម្រាប់ព័ត៌មានបន្ថែម)

តារាង១៤. ប្រភេទឥន្ធនៈសំខាន់ៗសម្រាប់ចម្អិនអាហារ បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| ប្រភេទឥន្ធនៈ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| អុស | ៥១,៣ | ៤,២ | ៣៧,៦ | ៦៧,៥ |
| ធ្យូង | ៥,៦ | ២,៤ | ៥,៦ | ៦,៣ |
| ឧស្ម័នហ្គាស | ៤១,៩ | ៩២,៤ | ៥៥,៨ | ២៤,៩ |

| | | | | |
|---|---|---|---|---|
| អគ្គិសនីផ្គត់ផ្គង់សាធារណៈ/អគ្គិសនីរដ្ឋ | ១,០ | ០,៩ | ០,៧ | ១,០ |
| ផ្សេងទៀត | ០,២ | ០,១ | ០,២ | ០,៣ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | ៣.៦៣៦,១ | ៥៣១,៦ | ៨៤២,៦ | ២.២៦១,៩ |

រូបភាព៨. ប្រភេទឥន្ទនៈសំខាន់ៗសម្រាប់ចម្អិនអាហារ ឆ្នាំ២០០៤ ២០០៩ ២០១៤ និង២០១៩/២០ (គិតជាភាគរយ)




រូបភាព៨ បានបង្ហាញអំពីភាគរយនៃគ្រួសារដែលប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ មានការធ្លាក់ចុះបន្តិចមានប្រមាណ ២ ភាគរយនៅក្នុងរយៈពេលដប់ឆ្នាំ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ ហើយនិងបន្តធ្លាក់ចុះ៦ភាគរយ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤។ ប៉ុន្តែចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០ ភាគរយគ្រួសារដែលប្រើប្រាស់អុសសម្រាប់ចម្អិនអាហារ មានការធ្លាក់ចុះច្រើនប្រមាណ ២៤ ភាគរយបន្ថែមទៀត ដែលវាមានលក្ខណៈផ្ទុយពីការប្រើប្រាស់ឧស្ម័នហ្គាសរបស់គ្រួសារសម្រាប់ការចម្អិនអាហារ ដែលមានការកើនឡើងប្រមាណ ៣ ភាគរយ នៅក្នុងកំលុងពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៩ ហើយបន្តកើនប្រមាណ៦ភាគរយ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤។ ប៉ុន្តែក្នុងកំលុងពេលរយៈពេល៥ឆ្នាំចុងក្រោយនេះ(ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០) បានកើនឡើងគួរឱ្យកត់សំគាល់មានអត្រាប្រមាណ ២៦ ភាគរយ។

# ផ្នែកទី៤ ផ្នែកកសិកម្ម

## ៤.១ សេចក្តីផ្តើម

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺជាការអង្កេតមួយមានពហុគោលបំណង ដែលបានគ្របដណ្តប់លើផ្នែកផលិតកម្មរបស់គ្រួសារ។ ផ្នែកផលិតកម្មកសិកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកផ្តល់ចំណេះដឹងអំពីកសិកម្មបានយ៉ាងល្អប្រសើរផងដែរ។ ទិន្នន័យដែលយកពីផ្នែកកសិកម្ម នៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺជាតម្រូវការដ៏ចាំបាច់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានគណនេយ្យជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ និងធនាគារពិភពលោក ចង់បានយកទិន្នន័យមកប្រើប្រាស់។ ស្ថិតិបែងចែកតាមយេនឌ័រ (គ្រួសារមានស្ត្រីជាមេគ្រួសារ ឬបុរសជាមេគ្រួសារ) ផ្តល់នូវព័ត៌មានដែលមានសារៈសំខាន់នៅក្នុងពហុវិស័យ។ អង្គការ ស្ថាប័ននានាដូចជាវិទ្យាស្ថានជាតិស្ថិតិ អង្គការស្បៀង និងកសិកម្ម នៃអង្គការសហប្រជាជាតិ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងកិច្ចការនារី បានបញ្ជាក់ផងដែរអំពីការប្រើប្រាស់ទិន្នន័យដ៏មានសារៈសំខាន់នេះ ជាពិសេសទិន្នន័យទាក់ទងនឹងទស្សនវិស័យយេនឌ័រ។ ការបង្ហាញលទ្ធផលវិភាគទិន្នន័យ ត្រូវបានបែងចែកជា៦ផ្នែក និងមានឧបសម្ព័ន្ធ១បន្ថែមតារាងមួយចំនួនទៀត៖

- កម្មសិទ្ធិដីធ្លី
- ការដាំដុះដំណាំ (រួមមានផ្លែឈើ និងបន្លែ)
- ការចំណាយសម្រាប់ដាំដុះដំណាំ (រួមមានផ្លែឈើ និងបន្លែ)
- ការចិញ្ចឹមសត្វពាហនៈ និងបសុបក្សី
- ការចិញ្ចឹមត្រី និងការនេសាទ
- ព្រៃឈើ និងការបរបាញ់សត្វ

ស្ថិតិត្រូវបានបែងចែកជាប្រាំតំបន់ធំៗរួមមាន៖ រាជធានីភ្នំពេញ តំបន់វាលទំនាប តំបន់ទន្លេសាប តំបន់ឆ្នេរសមុទ្រ និង តំបន់ភ្នំនិងខ្ពង់រាប។

### ផលិតផលដំណាំ

ការចាត់ចំណាត់ថ្នាក់ដំណាំរបស់វិទ្យាស្ថានជាតិស្ថិតិ បានផ្អែកលើចំណាត់ថ្នាក់របស់អង្គការស្បៀងនិងកសិកម្ម នៃអង្គការសហប្រជាជាតិ ដែលមានចំនួន២៣ក្រុម។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីទទួលបាននូវការប៉ាន់ស្មានឱ្យមានភាពជឿជាក់បន្ថែមទៀត ក្រុមសំខាន់ៗចំនួន ៦ ត្រូវបានយកមកប្រើប្រាស់ដូចខាងក្រោម៖

- ធញ្ញជាតិ (រួមមានជាសំខាន់ គឺ អង្ករ និងគ្រាប់ធញ្ញជាតិផ្សេងទៀត)
- មើម និងដំណាំពពួកសណ្តែក (រួមមាន មើម ឫស និងដំណាំពពួកសណ្តែក ជាសំខាន់សម្រាប់គ្រាប់ធញ្ញជាតិ លើកលែងតែសណ្តែកសៀង និងសណ្តែកដីចេញ)។
- ដំណាំឧស្សាហកម្មបណ្តោះអាសន្ន (រួមមានដំណាំដែលមានជាតិស្ករ ដំណាំដែលមានផ្លែជាតិប្រេង គ្រឿងទេស ដំណាំមានក្លិនក្រអូប និងរុក្ខជាតិអាចធ្វើជាឱសថ រុក្ខជាតិសរសៃសាញ និងដំណាំឧស្សាហកម្មផ្សេងៗទៀត)។
- បន្លែ (រួមមាន ស្លឹក ឬទង បន្លែមានផ្លែ ឫស និងមើម បន្លែពពួកសណ្តែក មានពណ៌

បែតង បន្លែផ្សេងៗទៀត និងដំណាំសាកវប្បកម្មពិសេស)។

- ផ្លែឈើ និងគ្រាប់ (រួមមាន ផ្លែប្រភេទក្រូច ផ្លែឈើផ្សេងៗ និងគ្រាប់ដែលអាចបរិភោគបាន) និង
- ដំណាំឧស្សាហកម្មអចិន្ត្រៃយ៍ (រួមមាន គ្រឿងទេស ដំណាំដែលមានក្លិនក្រអូប កៅស៊ូ និងដំណាំមានជាតិស្ពៃក និងដំណាំដែលមានផ្កា)។

## ៤.២ កម្មសិទ្ធិដីធ្លី

ដីកសិកម្មនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា សំដៅទៅលើដីដែលគ្រួសារបានកាន់កាប់ធ្វើជាម្ចាស់កម្មសិទ្ធិផ្ទាល់ខ្លួន ឬបានប្រើប្រាស់ដូចជា ដីជួលពីគេ ដីជួលឱ្យគេ ដីប្រើប្រាស់មិនគិតថ្លៃ…ជាដើម ដើម្បីប្រើប្រាស់សម្រាប់ដាំដំណាំ ឬក៏ប្រើប្រាស់សម្រាប់ការងារកសិកម្ម ឬកសិដ្ឋាន ដូចជាការដាំដំណាំ ការចិញ្ចឹមសត្វ ការនេសាទ និងការចិញ្ចឹមត្រី និងការដាំព្រៃឈើជាលក្ខណៈឯកជន។ ផ្នែកនេះមិនរាប់បញ្ចូលដីវាលស្មៅអចិន្ត្រៃយ៍ ដីព្រៃឈើ និងដីមិនមែនកសិកម្មផ្សេងៗដែលប្រើប្រាស់សម្រាប់លំនៅដ្ឋាន ឬក៏សម្រាប់សកម្មភាពអាជីវកម្មផ្សេងៗឡើយ។

ដីកម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់នៅក្នុងឆ្នាំ១៩៨៩ ក្រោយមកគ្រួសារដែលប្រកបមុខរបរកសិកម្មត្រូវបានតម្រូវឱ្យដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីចំពោះដីដែលពួកគាត់បានបង្កបង្កើនផល។ ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លីប្រមាណ ៤លានច្បាប់ ត្រូវបានដាក់ស្នើឡើង ហើយមានគោលបំណងសុំឱ្យអាជ្ញាធរសុរិយោដីថ្នាក់កណ្ដាលរៀបចំឯកសារឱ្យបានឆាប់រហ័ស។ គ្រួសារដែលមានមុខរបរកសិកម្មជាចម្បងបានទទួលដីអាស្រ័យលើទំហំគ្រួសារ និងលក្ខណៈផ្សេងៗរបស់គ្រួសារ ហើយចាប់តាំងពីពេលនោះមកកម្ពុជាមានការផ្លាស់ប្ដូរសេដ្ឋកិច្ចសង្គមកិច្ចគួរឱ្យកត់សម្គាល់ (ដូចជាមានការធ្វើមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួន ការធ្វើនគរូបនីយកម្ម កំណើនសេដ្ឋកិច្ច និងកំណើនប្រជាជន) ដែលបង្កើតឱ្យមាននូវតម្រូវការផ្សេងៗចំពោះដីធ្លី។

តារាង១ បង្ហាញថា តំបន់ទន្លេសាប មានភាគចំណែកធំបំផុត នៃផ្ទៃដីកសិកម្មក្នុងឆ្នាំ២០១៩/២០២០ បន្ទាប់មកតំបន់វាលទំនាប។ ចំណែកនៅរាជធានីភ្នំពេញ ផ្ទៃដីកសិកម្មមានសល់ចំនួនតិចតួចបំផុត ព្រោះតែផ្ទៃដីទាំងនោះគ្របដណ្ដប់ភាគច្រើនទៅដោយតំបន់ឧស្សាហកម្ម តំបន់ពាណិជ្ជកម្ម និងសេវាកម្ម។ ផ្ទៃដីកសិកម្មមានប្រមាណ ១២ ភាគរយ (៤៤៨ ពាន់ហិកតា) នៃផ្ទៃដីកសិកម្មសរុបចំនួន ៣.៨១៩ ពាន់ហិកតា នៅកម្ពុជាត្រូវបានកាន់កាប់ជាកម្មសិទ្ធិដោយគ្រួសារមានស្ត្រីជាមេគ្រួសារ។ (សូមមើលតារាង១ និងរូបភាព១សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១. ផ្ទៃដីកសិកម្មបែងចែកតាមភេទនៃមេគ្រួសារ និងតាមតំបន់ ឆ្នាំ២០១៩/២០ (គិតជាពាន់ហិកតា និងភាគរយ)**

| តំបន់ | ស្ត្រី | | បុរស | | ទាំងពីរភេទ |
|---|---|---|---|---|---|
| | ហិកតា | ភាគរយ | ហិកតា | ភាគរយ | ហិកតា |
| កម្ពុជា | ៤៤៨ | ១១,៧ | ៣.៣៧១ | ៨៨,៣ | ៣.៨១៩ |
| រាជធានីភ្នំពេញ | ៥ | ១៨,០ | ២៤ | ៨២,០ | ២៩ |
| តំបន់វាលទំនាប | ១៧០ | ១៤,៨ | ៩៨២ | ៨៥,២ | ១.១៥២ |
| តំបន់ទន្លេសាប | ១៨៥ | ១២,១ | ១.៣៤៣ | ៨៧,៩ | ១.៥២៧ |
| តំបន់ឆ្នេរសមុទ្រ | ១៩ | ១១,១ | ១៥៣ | ៨៨,៩ | ១៧២ |
| តំបន់ភ្នំនិងខ្ពង់រាប | ៦៩ | ៧,៤ | ៨៦៩ | ៩២,៦ | ៩៣៨ |

រូបភាព១. ផ្ទៃដីកសិកម្មបែងចែកតាមភេទនៃមេគ្រួសារ និងតាមតំបន់ ឆ្នាំ២០១៩/២០២០ (គិតជាភាគរយ)




តារាង២ បង្ហាញថាផ្ទៃដីកសិកម្មប្រហែល ២ លានហិកតា ត្រូវបានប្រើប្រាស់នៅរដូវវស្សា ក្នុងនោះផ្ទៃដី ២៧៣ ពាន់ហិកតាត្រូវបានប្រើប្រាស់ដោយគ្រួសារមានស្ត្រីជាមេគ្រួសារហើយផ្ទៃដី១.៦៨២ ពាន់ហិកតា ត្រូវបានប្រើប្រាស់ដោយគ្រួសារមានបុរសជាមេគ្រួសារ។ នៅរដូវប្រាំងផ្ទៃដីកសិកម្មដែលបានប្រើប្រាស់ដោយស្ត្រីគឺ ៣៦ ពាន់ហិកតាតិចជាងនៅរដូវវស្សា និង ៣៣៦ ពាន់ហិកតាប្រើប្រាស់ដោយបុរសជាមេគ្រួសារ។ ប្រភេទដីធំទីពីរ គឺជាដីចម្ការដែលមានផ្ទៃដី ៤៤២ ពាន់ហិកតា បើរាប់បញ្ចូលទាំងក្បាលដីស្ត្រី និងបុរសដែលជាមេគ្រួសារ ដោយមិនរាប់បញ្ចូលផ្ទៃដីប្រាំងនិងវស្សាទេ។ បើប្រៀបធៀបផ្ទៃដីទាំងប្រាំតំបន់ ទាំងនៅរដូវវស្សា និងរដូវប្រាំបញ្ចូលគ្នានោះ តំបន់ទន្លេសាបមានផ្ទៃដីធំជាងគេមានប្រមាណ ១.៥២៨ ពាន់ហិកតា បន្ទាប់មកតំបន់វាលទំនាបមាន ១.១៥២ ពាន់ហិកតា និង តំបន់ភ្នំនិងខ្ពង់រាប មាន ៩៣៨ ពាន់ហិកតា។ (សូមមើលតារាង២ សម្រាប់ព័ត៌មានបន្ថែម)។

តារាង២. ផ្ទៃដីកសិកម្មបែងចែកតាមភេទនៃមេគ្រួសារ តាមប្រភេទដី និងតាមតំបន់ ឆ្នាំ២០១៩/២០២០

(គិតជាពាន់ ហិកតា និងភាគរយ)

| ប្រភេទដី | កម្ពុជា | | រាជធានីភ្នំពេញ | | តំបន់វាលទំនាប | | តំបន់ទន្លេសាប | | តំបន់ឆ្នេរសមុទ្រ | | តំបន់ភ្នំនិងខ្ពង់រាប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| | ពាន់ហិកតា | | | | | | | | | | | |
| ដីរដូវវស្សា | ២៧៣ | ១៦៨២ | ២ | ៨ | ១០៤ | ៤៣០ | ១១០ | ៧២២ | ១៣ | ១០០ | ៤៥ | ៤២២ |
| ដីរដូវប្រាំង | ៣៦ | ៣៣៦ | ០ | ០ | ១៥ | ១៧៩ | ២០ | ១៤២ | ០ | ៥ | ១ | ១០ |
| ដីរដូវប្រាំងនិងរដូវវស្សា | ៣៨ | ៣៨២ | ៤ | ៣ | ១១ | ១៤៥ | ២១ | ១៩២ | ១ | ១២ | ២ | ៣០ |
| ដីចម្ការ | ៤៨ | ៣៩៤ | ០ | ៣ | ២៣ | ៥៥ | ១៦ | ១៧២ | ១ | ៦ | ៨ | ១៥៩ |
| ដីសួនបន្លែ | ៣២ | ៤៦១ | ០ | ៤ | ៥ | ១៥២ | ១៧ | ៨១ | ២ | ២៤ | ៨ | ២០០ |
| ដីដំណាំអចិន្ត្រៃយ៍ | ២ | ៤ | ០ | ០ | ២ | ២ | ០ | ០ | ០ | ១ | ០ | ០ |
| ដីព្រៃឯកជន | ០ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ |
| ដីទំនេរ | ២០ | ១០៩ | ០ | ៥ | ១០ | ១៩ | ១ | ៣៣ | ២ | ៥ | ៦ | ៤៦ |
| ដីដទៃទៀត | ០ | ១ | ០ | ០ | ០ | ០ | ០ | ១ | ០ | ០ | ០ | ១ |
| សរុប | ៤៤៨ | ៣.៣៧១ | ៥ | ២៤ | ១៧០ | ៩៨២ | ១៨៥ | ១.៣៤៣ | ១៩ | ១៥៣ | ៦៩ | ៨៦៩ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ភាគរយ | | | | | | | | | | | |
| ដីរដូវវស្សា | ៦០,៩ | ៤៩,៩ | ២៩,៥ | ៣៥,០ | ៦១,១ | ៤៣,៨ | ៥៩,៦ | ៥៣,៧ | ៦៦ | ៦៥,៤ | ៦៥,១ | ៤៨,៦ |
| ដីរដូវប្រាំង | ៨,០ | ១០ | ០ | ០ | ៨,៨ | ១៨,២ | ១០,៧ | ១០,៦ | ១ | ៣,២ | ១,៥ | ១,១ |
| ដីរដូវប្រាំងនិងរដូវវស្សា | ៨,៥ | ១១,៣ | ៦៦,៩ | ១២,២ | ៦,៧ | ១៤,៧ | ១១,២ | ១៤,៣ | ៤,២ | ៧,៧ | ២,៤ | ៣,៥ |
| ដីចម្ការ | ១០,៦ | ១១,៧ | ០ | ១៣,៥ | ១៣,៦ | ៥,៦ | ៨,៦ | ១២,៨ | ៤,៤ | ៤ | ១១,៣ | ១៨,៣ |
| ដីសួនបន្លែ | ៧,២ | ១៣,១ | ០ | ១៧,៥ | ៣,១ | ១៥,៥ | ៩,១ | ៦ | ១២,៩ | ១៥,៤ | ១១ | ២៣ |
| ដីដំណាំអចិន្ត្រៃយ៍ | ០៤១ | ០,១ | ០,២ | ០ | ១,០ | ០,២ | ០ | ០ | ០ | ០,៨ | ០ | ០ |
| ដីព្រៃឯកជន | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០,៣ | ០ | ០,១ |
| ដីទំនេរ | ៤,៤ | ៣,២ | ៣,៥ | ២១,៨ | ៥,៧ | ២ | ០,៨ | ២,៥ | ១១,៤ | ៣,២ | ៨,៧ | ៥,៣ |
| ដីដទៃទៀត | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

តារាង៣ បង្ហាញពីចំនួនគ្រួសារដែលរាយការណ៍អំពីភាពជាម្ចាស់កម្មសិទ្ធិនៃដីកសិកម្មនៅក្នុងឆ្នាំ២០១៩/២០ ដូចបានបង្ហាញថា មានគ្រួសារប្រមាណ ៧៥ ភាគរយ នៃគ្រួសារទាំងអស់នៅកម្ពុជា មានដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួនតិចជាង ១០.០០០ម៉ែត្រការ៉េ (១០.០០០ម៉ែត្រការ៉េ ស្មើនឹងមួយហិកតា) បន្ទាប់មកមានគ្រួសារប្រហែល ១៧ ភាគរយ នៃគ្រួសារមានផ្ទៃដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលមានទំហំផ្ទៃដីចន្លោះពី ១០.០០០ ម៉ែត្រការ៉េ ដល់ ៣០.០០០ ម៉ែត្រការ៉េ។ ប្រសិនបើប្រៀបធៀបផ្ទៃដីនៅក្នុងប្រាំតំបន់ ឃើញថាភាគរយនៃគ្រួសាររស់នៅរាជធានីភ្នំពេញមានផ្ទៃដីកសិកម្មដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនតិចជាង ១០.០០០ ម៉ែត្រការ៉េ គឺមានភាគរយខ្ពស់ជាងបួនតំបន់ផ្សេងទៀត ដែលអត្រានេះមានប្រមាណ ៩២ ភាគរយ។ (សូមមើលតារាង៣សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៣. ចំនួនគ្រួសារមានផ្ទៃដីកសិកម្មបែងចែកតាមផ្ទៃដី និងតាមតំបន់ ឆ្នាំ២០១៩/២០ (គិតជាពាន់គ្រួសារ និង ភាគរយ)**

| ផ្ទៃដី | កម្ពុជា | រាជធានីភ្នំពេញ | តំបន់វាលទំនាប | តំបន់ទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|---|
| | ចំនួន | | | | | |
| តិចជាង១០.០០០ម$^{២}$ | ១.៦៩៧ | ៤២ | ៧៥២ | ៤៩៨ | ១៣២ | ២៧៣ |
| ១០.០០០ម២–១៩.៩៩៩ម$^{២}$ | ១៩៩ | ១ | ៧៥ | ៧១ | ៩ | ៤៥ |
| ២០.០០០ម២–២៩.៩៩៩ម$^{២}$ | ១៩៣ | ១ | ៥០ | ៧៩ | ៦ | ៥៦ |
| ៣០.០០០ម២–៣៩.៩៩៩ម$^{២}$ | ៧២ | ០ | ១៤ | ៣៣ | ២ | ២៣ |
| ៤០.០០០ម២–៤៩.៩៩៩ម$^{២}$ | ៣៦ | ១ | ៥ | ១៨ | ១ | ១១ |
| ៥០.០០០ម២–៩៩.៩៩៩ម$^{២}$ | ៤៨ | ១ | ១០ | ២១ | ២ | ១៣ |
| ១០០.០០០ម២ ឡើងទៅ | ១២ | ០ | ៣ | ៥ | ០ | ៤ |
| សរុប | ២.២៥៦ | ៤៦ | ៩០៧ | ៧២៥ | ១៥២ | ៤២៥ |
| | ភាគរយ | | | | | |
| តិចជាង១០.០០០ម$^{២}$ | ៧៥,២ | ៩១,៧ | ៨២,៨ | ៦៨,៧ | ៨៦,៦ | ៦៤,២ |
| ១០.០០០ម២–១៩.៩៩៩ម$^{២}$ | ៨,៨ | ១,៤ | ៨,៣ | ៩,៨ | ៥,៦ | ១០,៥ |
| ២០.០០០ម២–២៩.៩៩៩ម$^{២}$ | ៨,៥ | ២,៣ | ៥,៥ | ១០,៩ | ៤,២ | ១៣,២ |
| ៣០.០០០ម២–៣៩.៩៩៩ម$^{២}$ | ៣,២ | ០,៨ | ១,៥ | ៤,៦ | ១,២ | ៥,៤ |
| ៤០.០០០ម២–៤៩.៩៩៩ម$^{២}$ | ១,៦ | ១,៥ | ០,៥ | ២,៥ | ០,៩ | ២,៧ |
| ៥០.០០០ម២–៩៩.៩៩៩ម$^{២}$ | ២,១ | ២,២ | ១,១ | ២,៩ | ១,៣ | ៣,១ |
| ១០០.០០០ម២ ឡើងទៅ | ០,៥ | ០ | ០,៣ | ០,៧ | ០,១ | ០,៩ |
| **សរុប** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |

តារាង៤ បង្ហាញថា ភាគចំណែកនៃក្បាលដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួនដែលគ្រួសារទាំងអស់ បានកាន់កាប់ គឺជាប្រភេទដីកម្មសិទ្ធិដែលមានលក្ខណៈទូទៅបំផុតនៅប្រទេសកម្ពុជា។ ភាគចំណែកនៃក្បាលដីជាកម្មសិទ្ធិមិនបានជួលឱ្យគេមានប្រមាណ ៨៨ ភាគរយ នៅឆ្នាំ២០១៩/២០ ចំណែកក្បាលដីដែលជាកម្មសិទ្ធិនៅតំបន់ឆ្នេរ និងតំបន់ភ្នំ និងខ្ពង់រាបខ្ពស់ជាងតំបន់បីផ្សេងទៀត គឺមានប្រមាណ៩៣ ភាគរយ បើប្រៀបធៀបនឹងនៅក្នុងតំបន់ផ្សេងទៀតដែលមាន ៧៥ ភាគរយ ឬច្រើនជាងនេះ។ ដោយឡែក ភាគចំណែកនៃក្បាលដីដែលបានជួលដោយគ្រួសារនៅតំបន់វាលទំនាប និងនៅតំបន់ទន្លេសាប សឹងតែមានអត្រាប្រហាក់ប្រហែលគ្នាមានប្រមាណ ៤ភាគរយ និង ៥ភាគរយ តាមលំដាប់រៀងគ្នា ក៏ប៉ុន្តែសម្រាប់ថ្លៃដីជួលនៅរាជធានីភ្នំពេញ តំបន់ឆ្នេរសមុទ្រ និងតំបន់ភ្នំនិងខ្ពង់រាប ភាគរយនៃក្បាលដីដែលបានជួលដោយគ្រួសារមានកម្រិតទាបជាង។(សូមមើលតារាង៤សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៤. ចំនួនផ្ទៃដីកសិកម្មបែងចែកតាមលក្ខណៈកម្មសិទ្ធិ និងតាមតំបន់ ឆ្នាំ២០១៩/២០ (គិតជាពាន់ និងភាគរយ)**

| ការកាន់កាប់ដីធ្លី | កម្ពុជា | រាជធានីភ្នំពេញ | តំបន់វាលទំនាប | តំបន់ទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|---|
| | | | ចំនួន | | | |
| ដីកម្មសិទ្ធិផ្ទាល់ខ្លួន | ៣.៣៥១ | ៤០ | ១.៣១៧ | ១.០៥៥ | ២៣៥ | ៧០៣ |
| ដីកម្មសិទ្ធិតែជួលឱ្យគេ | ២៥៣ | ១៣ | ១២៦ | ៧៦ | ១២ | ២៥ |
| ដីជួលពីគេ | ១៤១ | ១ | ៦៧ | ៥៨ | ៣ | ១៣ |
| ដីប្រើប្រាស់មិនគិតថ្លៃ | ៧២ | ០ | ៣០ | ២៩ | ២ | ១២ |
| ដីកាន់កាប់ផ្សេងៗ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | ៣.៨១៧ | ៥៣ | ១.៥៤០ | ១.២១៨ | ២៥២ | ៧៥៣ |
| | | | ភាគរយ | | | |
| ដីកម្មសិទ្ធិផ្ទាល់ខ្លួន | ៨៧,៨ | ៧៥,១ | ៨៥,៥ | ៨៦,៧ | ៩៣,២ | ៩៣,៣ |
| ដីកម្មសិទ្ធិតែជួលឱ្យគេ | ៦,៦ | ២៣,៧ | ៨,២ | ៦,៣ | ៤,៨ | ៣,៤ |
| ដីជួលពីគេ | ៣,៧ | ១,២ | ៤,៣ | ៤,៧ | ១,៣ | ១,៧ |
| ដីប្រើប្រាស់មិនគិតថ្លៃ | ១,៩ | ០,០ | ១,៩ | ២,៤ | ០,៧ | ១,៦ |
| ដីកាន់កាប់ផ្សេងៗ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ គ្រួសារត្រូវបានសួរអំពីជម្លោះដីកសិកម្ម(ក្បាលដី) ជម្លោះសំដៅលើប្រភេទនៃការទាមទារណាមួយសម្រាប់កម្មសិទ្ធិដីធ្លី។ យោងតាមលទ្ធផលទិន្នន័យក្នុងតារាង៥ បានបង្ហាញថា ចំនួនគ្រួសារប្រមាណ ១,៩ ភាគរយ ដែលបានជួបប្រទះនូវជម្លោះកាលពីពេលមុនៗទាក់ទងនឹងដីធ្លីជាកម្មសិទ្ធិ។ ជម្លោះកាលពីពេលមុនៗទាក់ទងនឹងដីធ្លីជាកម្មសិទ្ធិ គឺមានភាគរយខ្ពស់សម្រាប់គ្រួសារដែលរស់នៅរាជធានីភ្នំពេញជាងគ្រួសារដែលរស់នៅតាមតំបន់ផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ ក្បាលដីជាកម្មសិទ្ធិបាននឹងកំពុងមានជម្លោះនាពេលបច្ចុប្បន្នមានកម្រិតតិចតួចបំផុត គឺស្ទើរតែពុំមានជម្លោះ (០.៤ភាគរយ) នៅទូទាំងប្រទេសក្នុងឆ្នាំ២០១៩/២០។ (សូមមើលតារាង៥សម្រាប់ព័ត៌មានបន្ថែម)

**តារាង៥. ចំនួនគ្រួសារបែងចែកតាមជម្លោះក្បាលដីកសិកម្ម និងតាមតំបន់ ឆ្នាំ២០១៩/២០២០(គិតជាពាន់គ្រួសារ និងភាគរយ)**

| ស្ថានភាពជម្លោះ | កម្ពុជា | រាជធានីភ្នំពេញ | តំបន់វាលទំនាប | តំបន់ទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|---|
| | | | ចំនួន | | | |
| ជម្លោះពេលបច្ចុប្បន្ន | ១៤ | ០ | ៦ | ៥ | ២ | ១ |
| ជម្លោះពីមុន | ៧៤ | ២ | ៣១ | ២០ | ៣ | ១៨ |
| មិនមានជម្លោះ | ៣.៧២៨ | ៥២ | ១.៥០៣ | ១.១៩៣ | ២៤៨ | ៧៣៤ |
| សរុប | ៣.៨១៧ | ៥៣ | ១.៥៤០ | ១.២១៨ | ២៥២ | ៧៥៣ |
| | | | ភាគរយ | | | |
| ជម្លោះពេលបច្ចុប្បន្ន | ០,៤ | ០ | ០,៤ | ០,៤ | ០,៨ | ០,២ |
| ជម្លោះពីមុន | ១,៩ | ៣,៦ | ២ | ១,៧ | ១ | ២,៤ |
| មិនមានជម្លោះ | ៩៧,៧ | ៩៦,៤ | ៩៧,៦ | ៩៧,៩ | ៩៨,១ | ៩៧,៤ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

តារាង៦ បង្ហាញថា នៅក្នុងផ្ទៃដីកសិកម្មសរុប គឺមានជិត៨៦ភាគរយ ជាដីកសិកម្មកម្មសិទ្ធិផ្ទាល់ខ្លួននិងប្រមាណ ៧ភាគរយ ជាដីកសិកម្មកម្មសិទ្ធិដែរ ប៉ុន្តែជួលឱ្យគេប្រើប្រាស់។ ដូចនេះសរុបផ្ទៃដីកសិកម្មទាំងអស់ដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់គ្រួសារមានប្រមាណ ៨៦ភាគរយ នៅក្នុងឆ្នាំ២០១៩/២០។ បើប្រៀបធៀបផ្ទៃដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួនក្នុងតំបន់ទាំងប្រាំ ឃើញថា ភាគចំណែកនៃផ្ទៃដីកសិកម្មជាកម្មសិទ្ធិផ្ទាល់ខ្លួននៅតំបន់ភ្នំនិងខ្ពង់រាបមានប្រមាណ ៩៣ភាគរយ ដែលចំនួននេះខ្ពស់ជាងតំបន់ទាំងបួនផ្សេងទៀត។ ចំពោះផ្ទៃដីកសិកម្មដែលជួលពីគេដោយគ្រួសារ គឺមានកម្រិតខ្ពស់នៅតំបន់វាលទំនាបដែលមានប្រមាណ ៨ ភាគរយ និងនៅតំបន់ទន្លេសាបមានប្រហែល ៧ភាគរយ។ (សូមមើលតារាង៦សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៦. ផ្ទៃដីកសិកម្មបែងចែកតាមលក្ខណៈកម្មសិទ្ធិ និងតាមតំបន់ ឆ្នាំ២០១៩/២០ (គិតជាពាន់ហិកតា និងភាគរយ)**

| ការកាន់កាប់ដី | កម្ពុជា | រាជធានីភ្នំពេញ | តំបន់វាលទំនាប | តំបន់ទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|---|
| | | | ហិកតា | | | |
| ដីកម្មសិទ្ធិផ្ទាល់ខ្លួន | ៣.២៦៩ | ១៤ | ៩២៥ | ១.២៤៩ | ១៥៥ | ៩២៦ |
| ដីកម្មសិទ្ធិតែជួលឱ្យគេ | ២៦១ | ១១ | ១០៣ | ១០៣ | ៧ | ៣៨ |
| ដីជួលពីគេ | ២២៧ | ០ | ៧៩ | ១២៦ | ៣ | ១៨ |
| ដីប្រើប្រាស់មិនគិតថ្លៃ | ៦២ | . | ១៨ | ២៥ | ៣ | ១៦ |
| ដីកាន់កាប់ផ្សេងៗ | . | . | . | . | . | . |
| សរុប | ៣.៨១៩ | ២៥ | ១.១២៥ | ១.៥០៤ | ១៦៧ | ៩៩៧ |
| | | | ភាគរយ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ដីកម្មសិទ្ធិផ្ទាល់ខ្លួន | ៨៥,៦ | ៥៤,៥ | ៨២,២ | ៨៣,១ | ៩២,៦ | ៩២,៩ |
| ដីកម្មសិទ្ធិតែជួលឱ្យគេ | ៦,៨ | ៤៤ | ៩,១ | ៦,៩ | ៣,៩ | ៣,៨ |
| ដីជួលពីគេ | ៥,៩ | ១,៥ | ៧ | ៨,៤ | ១,៩ | ១,៨ |
| ដីប្រើប្រាស់មិនគិតថ្លៃ | ១,៦ | ០ | ១,៦ | ១,៧ | ១,៥ | ១,៦ |
| ដីកាន់កាប់ផ្សេងៗ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

តារាង៧ បង្ហាញថា ក្នុងផ្ទៃដីកសិកម្មសរុបនៅឆ្នាំ២០១៩/២០ គឺមានផ្ទៃដីកសិកម្មប្រមាណ ៥១ភាគរយ ត្រូវបានប្រើប្រាស់នៅរដូវវស្សា។ ផ្ទៃដីកសិកម្មត្រូវបានប្រើប្រាស់ប្រមាណ ១០ ភាគរយតែប៉ុណ្ណោះនៅរដូវប្រាំង។ ប្រភេទដីកសិកម្មលំដាប់ទីពីរ គឺផ្ទៃដីចម្ការដែលមានប្រមាណ១៣ភាគរយនៃផ្ទៃដីកសិកម្មសរុប។ បើប្រៀបធៀបផ្ទៃដីកសិកម្មទាំងប្រាំតំបន់ ទាំងនៅរដូវវស្សានិងរដូវប្រាំងបញ្ចូលគ្នានោះ នៅរាជធានីភ្នំពេញ និងតំបន់វាលទំនាប មានភាគរយទាបជាងបីតំបន់ផ្សេងទៀត គឺមានប្រមាណ ៣៤ ភាគរយ និង៤៦ភាគរយ តាមលំដាប់រៀង។ (សូមមើលតារាង៧សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៧. ផ្ទៃដីកសិកម្មបែងចែកតាមប្រភេទដី និងតំបន់ ឆ្នាំ២០១៩/២០ គិតជាពាន់ហិកតា និងភាគរយ**

| ប្រភេទដីធ្លី | កម្ពុជា | រាជធានីភ្នំពេញ | តំបន់វាលទំនាប | តំបន់ទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|---|
| | ហិកតា | | | | | |
| ផ្ទៃដីរដូវវស្សា | ១.៩៥៦ | ១០ | ៥៣៤ | ៨២៣ | ១១២ | ៤៦៨ |
| ផ្ទៃដីរដូវប្រាំង | ៣៧២ | ០ | ១៩៤ | ១៦២ | ៥ | ១១ |
| ផ្ទៃដីរដូវវស្សា និងប្រាំង | ៤២០ | ៦ | ១៥៦ | ២១៣ | ១២ | ៣២ |
| ដីចម្ការ | ៤៤២ | ៣ | ៧៨ | ១៨៧ | ៧ | ១៦៧ |
| ដីសួនដំណាំ | ៤៩៣ | ៤ | ១៥៨ | ៩៨ | ២៦ | ២០៨ |
| ដីដំណាំអចិន្ត្រៃយ៍ | ៦ | ០ | ៤ | ០ | ១ | ០ |
| ដីព្រៃឈើឯកជន | ១ | ០ | ០ | ០ | ០ | ១ |
| ដីទំនេរ (មិនប្រើការ) | ១២៨ | ៥ | ២៩ | ៣៥ | ៧ | ៥២ |
| ដីដទៃទៀត | ១ | ០ | ០ | ១ | ០ | ១ |
| សរុប | ៣.៨១៩ | ២៩ | ១.១៥២ | ១.៥២៧ | ១៧២ | ៩៣៨ |
| | ភាគរយ | | | | | |
| ផ្ទៃដីរដូវវស្សា | ៥១,២ | ៣៤,០ | ៤៦,៣ | ៥៤,៥ | ៦៥,៤ | ៤៩,៨ |
| ផ្ទៃដីរដូវប្រាំង | ៩,៧ | ០ | ១៦,៨ | ១០,៦ | ៣,០ | ១,២ |
| ផ្ទៃដីរដូវវស្សា និងប្រាំង | ១១,០ | ២២,០ | ១៣,៦ | ១៤,០ | ៧,៣ | ៣,៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ដីចម្ការ | ១១,៦ | ១១,១ | ៦,៧ | ១២,៣ | ៤,០ | ១៧,៨ |
| ដីសួនដំណាំ | ១២,៩ | ១៤,៤ | ១៣,៧ | ៦,៤ | ១៥,១ | ២២,២ |
| ដីដំណាំអចិន្ត្រៃយ៍ | ០,១ | ០ | ០,៣ | ០ | ០,៨ | ០ |
| ដីព្រៃឈើឯកជន | ០ | ០ | ០ | ០ | ០,៣ | ០,១ |
| ដីទំនេរ (មិនប្រើការ) | ៣,៤ | ១៨,៥ | ២,៥ | ២,៣ | ៤,១ | ៥,៦ |
| ដីដទៃទៀត | ០ | ០ | ០ | ០ | ០ | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

តារាង៨ បង្ហាញថា ផ្ទៃដីកសិកម្មមានប្រមាណ ៤៨ ភាគរយ នៃផ្ទៃដីកសិកម្មសរុបនៅក្នុងឆ្នាំ២០១៩/២០ មានប្រព័ន្ធធារាសាស្ត្រស្រោចស្រព។ នៅរដូវវស្សាមានប្រមាណ ២៧ ភាគរយ នៃផ្ទៃដីកសិកម្មសរុប ត្រូវបានស្រោចស្រពសម្រាប់ដាំដំណាំនិងរុក្ខជាតិ។ បើសិនប្រៀបធៀបផ្ទៃដីកសិកម្មនៅក្នុងប្រាំតំបន់ឃើញថា តំបន់ភ្នំនិងខ្ពង់រាបមានការលំបាកជាងតំបន់ផ្សេងៗ ក្នុងដំណើរការរៀបចំស្រោចស្រពឱ្យចូលទៅដល់ដែលភាគរយនៃផ្ទៃដីកសិកម្មអាចស្រោចស្រពបានមានប្រមាណ ៣១ ភាគរយ តែប៉ុណ្ណោះ។ ចំពោះនៅរាជធានីភ្នំពេញវិញផ្ទៃដីកសិកម្មទទួលបានការស្រោចស្រពខ្ពស់ជាងគេមានប្រមាណ ៧០ ភាគរយ ដោយសារផ្ទៃដីមួយភាគធំនៅក្នុងរាជធានីភ្នំពេញហ៊ុមព័ទ្ធជុំវិញដោយទន្លេ បឹង ស្ទឹង។ល។

**តារាង៨. ផ្ទៃដីកសិកម្មបែងចែកតាមការស្រោចស្រព និងតាមតំបន់ ឆ្នាំ២០១៩/២០ (គិតជាពាន់ហិកតា និងភាគរយ)**

| ការស្រោចស្រព | កម្ពុជា | រាជធានីភ្នំពេញ | តំបន់វាលទំនាប | តំបន់ទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|---|
| | | | ពាន់ហិកតា | | | |
| ការស្រោចស្រពនៅរដូវវស្សា | ១.០៣៨ | ១១ | ៣៥៧ | ៤១៦ | ៥១ | ២០២ |
| ការស្រោចស្រពនៅរដូវប្រាំង | ២៩៤ | ៣ | ១៤៤ | ១២២ | ៣ | ២១ |
| ការស្រោចស្រពទាំងពីររដូវ | ៥១៦ | ៦ | ១៨៣ | ២២៩ | ២៩ | ៧០ |
| មិនមានការស្រោចស្រព ឬបូម | ១.៩៧១ | ៩ | ៤៦៩ | ៧៦០ | ៨៩ | ៦៤៥ |
| សរុប | ៣.៨១៩ | ២៩ | ១.១៥២ | ១.៥២៧ | ១៧២ | ៩៣៨ |
| | | | ភាគរយ | | | |
| ការស្រោចស្រពនៅរដូវវស្សា | ២៧,២ | ៣៨,៦ | ៣១,០ | ២៧,២ | ២៩,៨ | ២១,៦ |
| ការស្រោចស្រពនៅរដូវប្រាំង | ៧,៧ | ១១,៦ | ១២,៥ | ៨,០ | ១,៩ | ២,៣ |
| ការស្រោចស្រពទាំងពីររដូវ | ១៣,៥ | ១៩,៦ | ១៥,៩ | ១៥,០ | ១៦,៧ | ៧,៤ |
| មិនមានការស្រោចស្រព ឬបូម | ៥១,៦ | ៣០,១ | ៤០,៧ | ៤៩,៨ | ៥១,៦ | ៦៨,៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ៤.៣ ការដាំដុះដំណាំ (រួមមានផ្លែឈើ និងបន្លែ)

វិទ្យាស្ថានជាតិស្ថិតិ បានធ្វើចំណាត់ថ្នាក់ដំណាំផ្អែកតាមចំណាត់ថ្នាក់របស់អង្គការស្បៀង និងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO) ដោយបែងចែកជា ២៣ ក្រុម។ ម្យ៉ាងវិញទៀត ដើម្បីឱ្យការប៉ាន់ស្មានកាន់តែមានភាពជឿជាក់ថែមទៀត ចំណាត់ថ្នាក់ដំណាំ គឺត្រូវបានបែងចែកជាប្រាំមួយក្រុមធំៗសំខាន់។

តារាង៩ បង្ហាញតួលេខស្ដីពីផលិតផលដំណាំដែលគ្រួសារបានដាំរយៈពេលពេញមួយឆ្នាំនៅក្នុងអំឡុងពេលទាំងរដូវវស្សានិងរដូវប្រាំងនៅឆ្នាំ២០១៩/២០។ ចំនួនសកម្មភាពគ្រួសារសរុបដែលបានដាំដំណាំនៅក្នុងឆ្នាំ ២០១៩/២០ គឺមានចំនួនប្រមាណ ៤.៦១៧ ពាន់គ្រួសារ ដែលក្នុងនោះនៅរដូវប្រាំងមាន១.៣២៥ ពាន់គ្រួសារ។ ទោះជាយ៉ាងណាក៏ដោយ ប្រភេទដំណាំដែលបានបែងចែកនេះពុំមានការប្រែប្រួលច្រើនគួរឱ្យកត់សម្គាល់នោះឡើយ នៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ។ សម្រាប់ផលិតផលដំណាំទូទៅបំផុតដែលគ្រួសារបានដាំនៅកម្ពុជា គឺដំណាំធញ្ញជាតិមានទិន្នផលប្រមាណ ៥៥ ភាគរយ នៃសកម្មភាពគ្រួសារដែលបានដាំដុះទាំងអស់។ក្រុមផលិតផលដំណាំសំខាន់ទីពីរ គឺដំណាំផ្លែឈើនិងដំណាំគ្រាប់ដែលមានប្រមាណ ២៤ ភាគរយ។ (សូមមើលតារាង៩សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៩. ចំនួនសកម្មភាពគ្រួសារបែងចែកតាមក្រុមផលិតផលដំណាំសំខាន់ៗ និងតាមរដូវ ឆ្នាំ២០១៩/២០ (គិតជាពាន់សកម្មភាព និងភាគរយ)**

| ក្រុមផលិតផលដំណាំសំខាន់ៗ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ | | |
|---|---|---|---|
| | សរុប | រដូវវស្សា | រដូវប្រាំង |
| | ពាន់សកម្មភាព | | |
| ដំណាំធញ្ញជាតិ | ២.៥៤០ | ២.១៥៩ | ៣៨១ |
| ដំណាំមើម | ៣៥២ | ២០៤ | ១៤៧ |
| ដំណាំឧស្សាហកម្មបណ្ដោះអាសន្ន | ៩៧ | ៥៧ | ៤០ |
| បន្លែ | ២៥៥ | ១៣៨ | ១១៧ |
| ផ្លែឈើ និងដំណាំគ្រាប់ | ១.១០៧ | ៥៩២ | ៥១៥ |
| ដំណាំឧស្សាហកម្មអចិន្ត្រៃយ៍ | ២៥៣ | ១៣៤ | ១១៩ |
| ដំណាំផ្សេងទៀតមិនរាប់បញ្ចូល | ១៣ | ៨ | ៥ |
| សរុប | ៤.៦១៧ | ៣.២៩២ | ១.៣២៥ |
| | ភាគរយ | | |
| ដំណាំធញ្ញជាតិ | ៥៥ | ៦៥,៦ | ២៨,៨ |
| ដំណាំមើម | ៧,៦ | ៦,២ | ១១,១ |
| ដំណាំឧស្សាហកម្មបណ្ដោះអាសន្ន | ២,១ | ១,៧ | ៣ |
| បន្លែ | ៥,៥ | ៤,២ | ៨,៨ |
| ផ្លែឈើ និងដំណាំគ្រាប់ | ២៤ | ១៨ | ៣៨,៩ |
| ដំណាំឧស្សាហកម្មអចិន្ត្រៃយ៍ | ៥,៥ | ៤,១ | ៩ |
| ដំណាំផ្សេងទៀតមិនរាប់បញ្ចូល | ០,៣ | ០,២ | ០,៤ |
| សរុប | ១០០ | ១០០ | ១០០ |

តារាង១០បង្ហាញថា ដំណាំធញ្ញជាតិ ដូចជាដំណាំស្រូវដែលបានប្រមូលផលនៅក្នុងរដូវវស្សា គឺមានប្រមាណ៥.០១៨ពាន់តោន។ នៅរដូវប្រាំងបរិមាណផលិតផលធញ្ញជាតិមានប្រមាណ ២.១១៨ពាន់តោន គឺស្មើជិតពាក់កណ្តាល បើធៀបនឹងបរិមាណផលនៅក្នុងរដូវវស្សា។ នៅរដូវវស្សា ដំណាំធញ្ញជាតិដែលបានប្រមូលផលមានភាគចំណែកខ្ពស់បំផុតប្រមាណ៦៦ភាគរយ ចំណែកដំណាំមើមមាន២៣ភាគរយ។ នៅរដូវប្រាំង ភាគចំណែកនៃដំណាំធញ្ញជាតិនិងដំណាំមើម គឺមានប្រហាក់ប្រហែលគ្នាប្រមាណ ៣៨ ភាគរយ និង ៤២ ភាគរយ។ បើប្រៀបធៀបបរិមាណផលិតផលដំណាំតាមតំបន់នីមួយៗឃើញថា ដំណាំធញ្ញជាតិត្រូវបានប្រមូលផលខ្ពស់ជាងគេទាំងនៅរដូវវស្សានិងរដូវប្រាំង គឺនៅក្នុងរាជធានីភ្នំពេញ និងតំបន់វាលទំនាប។ ចំណែកបីតំបន់ផ្សេងទៀត រួមមានតំបន់ភ្នំនិងខ្ពង់រាប តំបន់វាលទំនាប តំបន់ឆ្នេរសមុទ្រ និងដំណាំធញ្ញជាតិ ត្រូវបានប្រមូលផលខ្ពស់ជាងប្រភេទដំណាំដទៃទៀតតែនៅរដូវវស្សា គឺមានប្រមាណ៦១ ភាគរយ ៧៣ភាគរយ និង៧៥ភាគរយ តាមលំដាប់រៀងនៃតំបន់នីមួយៗ។(សូមមើលតារាង១០សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១០. ផលិតផលដំណាំបែងចែកតាមក្រុមសំខាន់ៗ តាមរដូវកាល និងតាមតំបន់ ឆ្នាំ២០១៩/២០២០**

**(គិតជាពាន់តោន និងភាគរយ)**

| ក្រុមផលិតផលដំណាំសំខាន់ៗ | កម្ពុជា | | រាជធានីភ្នំពេញ | | តំបន់វាលទំនាប | | តំបន់ទន្លេសាប | | តំបន់ឆ្នេរសមុទ្រ | | តំបន់ភ្នំនិងខ្ពង់រាប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង |
| | ពាន់តោន | | | | | | | | | | | |
| ដំណាំធញ្ញជាតិ | ៥.០១៨ | ២.១១៨ | ២១ | ០ | ១.៧៣២ | ១.០៩១ | ២.១៧១ | ៩៧៩ | ២៨៩ | ២៧ | ៨០៤ | ២២ |
| ដំណាំមើម | ១.៧៦២ | ២.៣៦៤ | ០ | ០ | ២៤២ | ១៧៥ | ១.១៧១ | ១.៣២២ | ០ | ០ | ៣៤៩ | ៨៦៧ |
| ដំណាំឧស្សាហកម្មបណ្តោះអាសន្ន | ៨១ | ១១៨ | ០ | ០ | ៣០ | ៩៤ | ២៣ | ៨ | ៣ | ១០ | ២៦ | ៦ |
| បន្លែ | ១០៧ | ១២៥ | ០ | ០ | ៦៨ | ៦០ | ២៧ | ៥១ | ៣ | ៥ | ១០ | ៩ |
| ផ្លែឈើ និងដំណាំគ្រាប់ | ៣៩៤ | ៦៦១ | ៤ | ១ | ១៦៣ | ២១៤ | ៧៦ | ២២៥ | ៨៤ | ៣៦ | ៦៧ | ១៨៥ |
| ដំណាំឧស្សាហកម្មអចិន្ត្រៃយ៍ | ២៧២ | ២៦០ | ០ | ០ | ១២២ | ១០៥ | ៦៩ | ៧១ | ៨ | ៧ | ៧៣ | ៧៧ |
| ដំណាំផ្សេងទៀតមិនរាប់បញ្ចូល | ៥ | ២ | ០ | ០ | ៥ | ១ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | ៧.៦៣៨ | ៥.៦៤៨ | ២៤ | ១ | ២.៣៦១ | ១.៧៤១ | ៣.៥៣៧ | ២.៦៥៥ | ៣៨៧ | ៨៤ | ១.៣២៩ | ១.១៦៦ |
| | ភាគរយ | | | | | | | | | | | |
| ដំណាំធញ្ញជាតិ | ៦៥,៧ | ៣៧,៥ | ៨៤,៣ | ០ | ៧៣,៤ | ៦២,៧ | ៦១,៤ | ៣៦,៩ | ៧៤,៧ | ៣១,៦ | ៦០,៥ | ១,៩ |
| ដំណាំមើម | ២៣,១ | ៤១,៩ | ០ | ០ | ១០,២ | ១០ | ៣៣,១ | ៤៩,៨ | ០ | ០ | ២៦,២ | ៧៤,៣ |
| ដំណាំឧស្សាហកម្មបណ្តោះអាសន្ន | ១,១ | ២,១ | ០ | ០ | ១,៣ | ៥,៤ | ០,៦ | ០,៣ | ០,៧ | ១១,៧ | ១,៩ | ០,៥ |
| បន្លែ | ១,៤ | ២,២ | ០ | ០ | ២,៩ | ៣,៥ | ០,៨ | ១,៩ | ០,៧ | ៥,៩ | ០,៧ | ០,៨ |
| ផ្លែឈើ និងដំណាំគ្រាប់ | ៥,២ | ១១,៧ | ១៥,៧ | ១០០ | ៦,៩ | ១២,៣ | ២,១ | ៨,៥ | ២១,៧ | ៤២,២ | ៥,១ | ១៥,៩ |
| ដំណាំឧស្សាហកម្មអចិន្ត្រៃយ៍ | ៣,៦ | ៤,៦ | ០ | ០ | ៥,២ | ៦,១ | ១,៩ | ២,៧ | ២,១ | ៨,៧ | ៥,៥ | ៦,៦ |
| ដំណាំផ្សេងទៀតមិនរាប់បញ្ចូល | ០,១ | ០ | ០ | ០ | ០,២ | ០,១ | ០ | ០ | ០ | ០ | ០ | ០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ៤.៤ ការចំណាយសម្រាប់ដាំដុះដំណាំ (រួមមានផ្លែឈើ និងបន្លែ)

នៅទូទាំងប្រទេសកម្ពុជា ការចំណាយសម្រាប់ផលិតផលដំណាំទាំងពីររដូវ(វស្សានិងប្រាំង) ត្រូវបានប៉ាន់ស្មានមានចំនួន ៤.៧៧៩ ពាន់លានរៀល នៅក្នុងឆ្នាំ២០១៩/២០។ ទោះជាយ៉ាងណាក៏ដោយ ការចំណាយលើការ

ដាំដុះមានភាពខុសគ្នាយ៉ាងជាក់ច្បាស់រវាងរដូវទាំងពីរ។ តារាង១១ និង តារាង១២ បង្ហាញអំពីការចំណាយនៃផលិតផលដំណាំបែងចែកតាមតំបន់ទៅតាមលំដាប់សម្រាប់រដូវវស្សា និងរដូវប្រាំងក្នុងឆ្នាំ២០១៩/២០។

ផ្អែកតាមទិន្នន័យអង្កេត បង្ហាញថាការចំណាយសម្រាប់ផលិតផលដំណាំដាំដុះ មានចំនួនប្រមាណ ៣៧៦២ ពាន់លានរៀល នៅក្នុងរដូវវស្សា និង១០១៧ ពាន់លានរៀល នៅក្នុងរដូវប្រាំង។ មុខចំណាយខ្ពស់បំផុតនៅរដូវវស្សា គឺការចំណាយលើជីគីមី ថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅ និងថ្នាំសម្លាប់ផ្សិត ដែលមានចំនួនប្រមាណ ១០៩៣ ពាន់លានរៀល ស្មើនឹង ២៩ ភាគរយនៃចំណាយថ្លៃដើមសរុប មុខចំណាយបន្ទាប់មកគឺចំណាយលើថ្លៃឈ្នួលពលកម្មមានចំនួន ៣៥៣ ពាន់លានរៀល ស្មើនឹង ៣៥ ភាគរយនៃចំណាយថ្លៃដើមសរុប និងចំណាយលើថ្លៃជួលក្ជួររាស់ចំនួន ៦៧៣ ពាន់លានរៀល ស្មើនឹង ១៨ភាគរយនៃចំណាយថ្លៃដើមសរុប និងចំណាយវត្ថុធាតុដើមសម្រាប់ដាំដុះមានប្រមាណ ៧៥១ ពាន់លានរៀល ស្មើនឹង ២០ភាគរយនៃចំណាយថ្លៃដើមសរុប។ ចំណែកនៅរដូវប្រាំងវិញ ការចំណាយលើជីគីមី ថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅ និងថ្នាំសម្លាប់ផ្សិត វត្ថុធាតុដើមដាំដុះក៏ដូចជាថ្លៃឈ្នួលពលកម្ម គឺមានភាគរយខ្ពស់ តាមលំដាប់រៀងផងដែរ បើសិនប្រៀបធៀបនឹងសមាសភាគនៃថ្លៃដើមផលិតផលដំណាំផ្សេងៗទៀត។ បើសង្កេតនៅគ្រប់តំបន់ទាំងអស់នៃប្រទេសកម្ពុជា ការចំណាយលើជីគិមី វត្ថុធាតុដើមដាំដុះនិងថ្លៃឈ្នួលពលកម្ម គឺនៅតែជាសមាសភាគចំណាយសំខាន់ជាងគេនៃផលិតផលដំណាំដាំដុះសម្រាប់ទាំងពីររដូវ (វស្សានិងប្រាំង)។ (សូមមើលតារាង១១ និងតារាង១២ សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១១. ថ្លៃដើមផលិតផលដំណាំនៅរដូវវស្សាបែងចែកតាមក្រុមចំណាយ និងតាមតំបន់ ឆ្នាំ២០១៩/២០ (គិតជាលានរៀល និងភាគរយ)**

| មុខចំណាយ | កម្ពុជា | រាជធានី ភ្នំពេញ | តំបន់ វាលទំនាប | តំបន់ ទន្លេសាប | តំបន់ ឆ្នេរសមុទ្រ | តំបន់ ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|---|
| | លានរៀល | | | | | |
| វត្ថុធាតុដើមសម្រាប់ដាំដុះ | ៧៥១.៣៦៦ | ៨៩១ | ២៤៤.៦៤០ | ៣៦៣.១៦៨ | ១៩.៧២៧ | ១២២.៩៤០ |
| គ្មានគ្រូ/គ្មានសម្ភារៈសិក្សា | | | |
| ថ្លៃសាលាខ្ពស់ពេក | ០,៤ | ០,១ | ០,២ |
| ត្រូវជួយរកចំណូលឱ្យគ្រួសារ | ៤៤,៨ | ៤៦,៥ | ៤៥,៨ |
| ត្រូវជួយធ្វើការងារផ្ទះ | ៦,៧ | ៣,៣ | ៤,៨ |
| ស្ថានភាពរស់នៅក្រលំបាកពេក (ក្រីក្រពេក) | ៦,៨ | ៦,៥ | ៦,៦ |
| ដោយសារពិការភាព/មានជំងឺរយៈពេលយូរ (ពី៣ខែឡើងទៅ) | ២,២ | ១,៧ | ១,៩ |
| មានអាយុក្មេងពេក | ៤,៤ | ១,៥ | ២,៨ |
| មានបញ្ហាផ្សេងៗទៀតដែលបានបញ្ជាក់ | ៤,៧ | ១,៨ | ៣,១ |
| សរុប | ១០០ | ១០០ | ១០០ |

## ការសិក្សាអប់រំក្រៅប្រព័ន្ធ

តារាង១៧ បង្ហាញអំពីភាគរយនៃប្រជាជនដែលកំពុងរៀនបច្ចុប្បន្ននៅថ្នាក់អប់រំក្រៅប្រព័ន្ធ ឧទាហរណ៍ដូចជា កម្មវិធីអក្ខរកម្ម កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ភាសាបរទេសជាដើម។ល។ ដូចបានបង្ហាញឃើញថា ប្រជាជនអាយុចាប់ពី៦ឆ្នាំ ដល់ ២៤ឆ្នាំ មានប្រមាណ ១៣ភាគរយ បានចូលរៀននៅថ្នាក់អប់រំក្រៅប្រព័ន្ធនៅឆ្នាំ២០១៤ និងមានអត្រាប្រហែលគ្នានៅឆ្នាំ២០១៩/២០ (១៣ភាគរយ)។ ដោយឡែកប្រជាជននៅក្នុងក្រុមអាយុ១៥ឆ្នាំ ដល់ ២៤ឆ្នាំ មានអត្រាចូលរៀននៅថ្នាក់អប់រំក្រៅប្រព័ន្ធខ្ពស់ជាងក្រុមអាយុ៦ឆ្នាំ ដល់ ១៤ឆ្នាំ។ សម្រាប់គ្រប់ក្រុមអាយុទាំងអស់ អត្រាចូលរៀននៅថ្នាក់អប់រំក្រៅប្រព័ន្ធសម្រាប់ប្រជាជនទាំងពីរភេទ គឺមានការប្រែប្រួលបន្តិចបន្តួចនៅក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយនេះ(ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០)។ (សូមមើលតារាង១៧សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១៧. ការចូលរៀននៅថ្នាក់ក្រៅប្រព័ន្ធបែងចែកតាមក្រុមអាយុនិងតាមភេទ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ក្រុមអាយុ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | |
|---|---|---|---|---|---|---|
| | ២០១៤ | | | ២០១៩/២០ | | |
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| ពី៦ឆ្នាំ ដល់ ១៤ឆ្នាំ | ៦,៧ | ៥,៥ | ៦,១ | ១៥,៤ | ១២,៧ | ១៤,០ |
| ពី១៥ឆ្នាំ ដល់ ២៤ឆ្នាំ | ៧,៤ | ៧,៣ | ៧,៤ | ១១,២ | ១១,៥ | ១១,៣ |
| ពី៦ឆ្នាំ ដល់ ២៤ឆ្នាំ | ៧,១ | ៦,៥ | ៦,៨ | ១៣,៣ | ១២,១ | ១២,៧ |

តារាង១៨ បង្ហាញអំពីប្រភេទនៃការសិក្សានៅថ្នាក់ក្រៅប្រព័ន្ធដែលប្រជាជនបច្ចុប្បន្នបានចូលរៀន។ ដូចបានបង្ហាញថា ជាង៨៦ភាគរយ សម្រាប់ស្ត្រី ក៏ដូចជាបុរស បានចូលរៀនភាសាបរទេសនៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ (ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០)។ អត្រានេះមានកម្រិតទាបនៅថ្នាក់ក្រៅប្រព័ន្ធផ្សេងទៀតដែលពួកគេបានចាប់អារម្មណ៍ ដូចជា កម្មវិធីបណ្តុះបណ្តាលកុំព្យូទ័រ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។ល។ (សូមមើលតារាង១៨សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១៨. អត្រាអ្នកចូលរៀនបច្ចុប្បន្ន(អាយុ៦ឆ្នាំ ដល់ ២៤ឆ្នាំ) នៅថ្នាក់ក្រៅប្រព័ន្ធបែងចែកតាមភេទ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភេទថ្នាក់ក្រៅប្រព័ន្ធ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | |
|---|---|---|---|---|---|---|
| | ២០១៤ | | | ២០១៩/២០ | | |
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| កុំព្យូទ័រ | ៥,៧ | ៦,៧ | ៦,២ | ៣,៩ | ៣,៨ | ៣,៩ |
| បណ្តុះបណ្តាលវិជ្ជាជីវៈ | ៤,១ | ៣,៨ | ៣,៩ | ១,៤ | ២,៦ | ២,០ |
| ភាសាបរទេស | ៨៨,០ | ៨៦,១ | ៨៧,០ | ៩០,៦ | ៨៨,២ | ៨៩,៥ |
| កម្មវិធីអក្ខរកម្ម និងវគ្គបណ្តុះបណ្តាលផ្សេងៗ | ២,២ | ៣,៤ | ២,៨ | ៤,០ | ៥,៣ | ៤,៧ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ៥.៤ ការទទួលបានការសិក្សាអប់រំ

ក្នុងផ្នែកនេះ ការទទួលបានការសិក្សាអប់រំ ត្រូវបានបង្ហាញសម្រាប់ប្រជាជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ។

### ការបញ្ចប់កម្រិតបឋមសិក្សា

តារាង១៩ខាងក្រោម បង្ហាញថាភាគរយនៃប្រជាជនដែលបានបញ្ចប់កម្រិតបឋមសិក្សាពេញលេញមានការកើនឡើង គឺប្រមាណ ៥៥ភាគរយ នៅក្នុងឆ្នាំ២០១៩/២០ បើប្រៀបធៀបនឹងឆ្នាំ២០១៤ មានតែ ៥៣ភាគរយប៉ុណ្ណោះ។ អត្រាបញ្ចប់យ៉ាងតិចកម្រិតបឋមសិក្សាសម្រាប់បុរស មានកម្រិតខ្ពស់ជាងស្ត្រីនៅឆ្នាំ២០១៩/២០ ហើយគម្លាតប្រជាជនរវាងភេទទាំងពីរនៅតែមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ គឺនៅចន្លោះពី ១២ភាគរយ ទៅ ១៥ ភាគរយ បើគិតចាប់ពីឆ្នាំ២០១៤មក។ (សូមមើលតារាង១៩និងរូបភាព៧សម្រាប់ព័ត៌មានបន្ថែម)។

តារាង១៩. អត្រាអ្នកបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សា(អាយុ១៥ឆ្នាំឡើង)បែងចែងតាមភេទ ឆ្នាំ២០១៤-២០១៧ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| ភេទ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | |
|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| ស្ត្រី | ៤៥,៥ | ៤៦,២ | ៥០,១ | ៤៩,៦ | ៤៨,៨ |
| បុរស | ៦០,១ | ៦០,២ | ៦៣,៥ | ៦២,១ | ៦០,៩ |
| ទាំងពីរភេទ | ៥២,៥ | ៥២,៩ | ៥៦,៥ | ៥៥,៦ | ៥៤,៦ |

រូបភាព៧. អត្រាអ្នកបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សា(អាយុ១៥ឆ្នាំឡើង) បែងចែងតាមភេទ ឆ្នាំ២០១៤ - ២០១៧ និង ឆ្នាំ២០១៩/២០ (គិតជាភាគរយ)



ផ្អែកតាមទិន្នន័យអង្កេតបានបង្ហាញថា អត្រាបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សា គឺមានប្រជាជនភាគច្រើនស្ថិតក្នុងក្រុមអាយុពី១៥ឆ្នាំ ដល់ ២៤ឆ្នាំ បើប្រៀបធៀបក្នុងចំណោមប្រជាជនដែលស្ថិតក្នុងក្រុមអាយុផ្សេងៗទៀត។ នៅឆ្នាំ២០១៩/២០ ភាគរយសម្រាប់ស្ត្រី និងបុរសដែលបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សានៅក្រុមអាយុ១៥ឆ្នាំ ដល់ ២៤ឆ្នាំ គឺមានអត្រាប្រមាណ ៧៨ភាគរយ ប្រហាក់ប្រហែលគ្នាទៅនឹងអត្រានៅឆ្នាំ២០១៤ (៧៣ភាគរយ)។ អត្រាបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សាមានកម្រិតកាន់តែទាបក្នុងចំណោមប្រជាជនដែលមានវ័យចំណាស់ចាប់ពីអាយុ២៥ឆ្នាំឡើងទៅ។ បើសិនពិនិត្យជាទូទៅឃើញថា មានភាពខុសគ្នាច្រើនរវាងស្ត្រី និងបុរស ដែលបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សានៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ យ៉ាងហោចណាស់ការបញ្ចប់ការសិក្សាបឋមសិក្សា ជាទូទៅក្នុងចំណោមប្រជាជនដែលមានអាយុពី១៥ឆ្នាំ ដល់ ២៤ឆ្នាំ មានភាគច្រើនជាងប្រជាជនក្នុងចំណោមក្រុមអាយុផ្សេងៗទៀត។ នៅឆ្នាំ២០១៩/២០ ភាគរយសម្រាប់ស្ត្រី និងបុរសក្នុងក្រុមអាយុនេះដែលបានបញ្ចប់ការសិក្សាបឋមយ៉ាងហោចណាស់មានប្រមាណ ៨១ភាគរយ សម្រាប់ស្ត្រី និងប្រមាណ៧៥ភាគរយសម្រាប់បុរស។ ចំនួនភាគរយដែលដូចគ្នាជាមួយនឹងការអប់រំបឋមសិក្សាយ៉ាងហោចណាស់បញ្ចប់បានក្លាយជាទាបនិងទាបក្នុងចំណោមប្រជាជនវ័យចំណាស់ដែលមានអាយុចាប់ពី២៥ ឆ្នាំឡើងទៅ។ មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងស្ត្រី និងបុរសដែលបានបញ្ចប់ការសិក្សាបឋមសិក្សាយ៉ាងតិចក្នុងរយៈពេល៥ឆ្នាំ (២០១៤ ដល់ ២០១៩/២០)។ ទោះជាយ៉ាងណាក៏ដោយ ចំនួនស្ត្រី និងបុរសដែលបានបញ្ចប់ការសិក្សាបឋមសិក្សាបានកើនឡើងស្ទើរតែគ្រប់ក្រុមអាយុទាំងអស់នៅក្នុងរយៈពេលនេះ។ (សូមមើលតារាងទី ២០ និងរូបភាពទី៨ សម្រាប់ព័ត៌មានលម្អិត)។

**តារាង២០. អត្រាអ្នកបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សា បែងចែងតាមក្រុមអាយុ និងតាមភេទ ឆ្នាំ២០១៤ និង២០១៩/២០ (គិតជាភាគរយ)**

| ក្រុមអាយុ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | |
|---|---|---|---|---|---|---|
| | ២០១៤ | | | ២០១៩/២០ | | |
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| ១៥ឆ្នាំឡើង | ៤៥,៥ | ៦០,១ | ៥២,៥ | ៤៨,៨ | ៦០,៩ | ៥៤,៦ |
| ពី១៥ឆ្នាំ ដល់ ២៤ឆ្នាំ | ៧២,៨ | ៧២,៨ | ៧២,៨ | ៨១,២ | ៧៥,៤ | ៧៨,៣ |
| ពី២៥ឆ្នាំ ដល់ ៣៤ឆ្នាំ | ៥២,០ | ៦៣,៦ | ៥៧,៧ | ៦៥,១ | ៦៩,៦ | ៦៧,៣ |
| ពី៣៥ឆ្នាំ ដល់ ៤៤ឆ្នាំ | ៣៦,៤ | ៥៧,១ | ៤៦,៤ | ៣៩,៧ | ៥៧,៥ | ៤៨,៤ |
| ពី៤៥ឆ្នាំ ដល់ ៥៤ឆ្នាំ | ២១,៥ | ៤៤,៧ | ៣២,២ | ២៩,១ | ៥៣,៧ | ៤០,៧ |
| ពី៥៥ឆ្នាំ ដល់ ៦៤ឆ្នាំ | ២០,៤ | ៤១,៨ | ២៩,១ | ១៦,០ | ៣៤,៨ | ២៤,៣ |
| ៦៥ឆ្នាំឡើង | ៩,៧ | ៣៣,៤ | ១៩,៤ | ១១,២ | ៣៤,៨ | ២០,៥ |

រូបភាព៨. អត្រាអ្នកបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សា បែងចែងតាមក្រុមអាយុ និងតាមភេទ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)




ផ្អែកតាមទិន្នន័យអង្កេតបានបង្ហាញថា អត្រាបញ្ចប់យ៉ាងតិចត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ) ស្ថិតក្នុងក្រុមអាយុពី១៨ឆ្នាំ ដល់ ២៤ឆ្នាំ មានច្រើនជាងក្នុងចំណោមក្រុមអាយុផ្សេងៗទៀត។ នៅឆ្នាំ២០១៩/២០ ភាគរយសម្រាប់ស្ត្រីនិងបុរសដែលបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិនៅក្រុមអាយុ១៨ឆ្នាំ ដល់ ២៤ឆ្នាំ គឺមានអត្រា៤៨ភាគរយ និង៤៥ភាគរយ តាមលំដាប់រៀងគ្នា។ អត្រាបញ្ចប់យ៉ាងតិចត្រឹមកម្រិតបឋមសិក្សា គឺមានកម្រិតកាន់តែទាប នៅក្នុងចំណោមប្រជាជនដែលមានវ័យចំណាស់ចាប់ពីអាយុ២៥ឆ្នាំឡើងទៅ។ មានភាពខុសគ្នាច្រើនរវាងស្ត្រី និងបុរសដែលបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិនៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ(ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០) ជាពិសេសសម្រាប់ប្រជាជនដែលមានអាយុ៣៥ឆ្នាំឡើង។ ទោះជាយ៉ាងនេះក្តី ក៏អត្រាបញ្ចប់យ៉ាងតិចត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិសម្រាប់ស្ត្រី និងបុរសមានការកើនឡើងស្ទើរតែគ្រប់ក្រុមអាយុទាំងអស់នៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ។ (សូមមើលតារាង២១ សម្រាប់ព័ត៌មានបន្ថែម)។

**តារាង២១. អត្រាអ្នកបានបញ្ចប់យ៉ាងតិចត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ(អាយុ១៨ឆ្នាំឡើង)បែងចែកតាមក្រុមអាយុ និងតាមភេទ ឆ្នាំ២០១៤ និង ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ក្រុមអាយុ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | |
|---|---|---|---|---|---|---|
| | ២០១៤ | | | ២០១៩/២០ | | |
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| ១៨ឆ្នាំឡើង | ២១,១ | ៣២,៣ | ២៦,៥ | ២៣,៧ | ៣៣,៧ | ២៨,៤ |
| ពី១៨ឆ្នាំ ដល់ ២៤ឆ្នាំ | ៤១,១ | ៤៣,០ | ៤២,១ | ៤៧,៨ | ៤៥,១ | ៤៦,៥ |
| ពី២៥ឆ្នាំ ដល់ ៣៤ឆ្នាំ | ២៦,៣ | ៣៨,៦ | ៣២,៣ | ៣៤,៧ | ៤១,៥ | ៣៨,០ |
| ពី៣៥ឆ្នាំ ដល់ ៤៤ឆ្នាំ | ១៣,៦ | ២៩,២ | ២១,១ | ១៦,៧ | ៣២,៩ | ២៤,៦ |
| ពី៤៥ឆ្នាំ ដល់ ៥៤ឆ្នាំ | ៨,២ | ២០,០ | ១៣,៧ | ១១,៦ | ២៧,២ | ១៩,០ |
| ពី៥៥ឆ្នាំ ដល់ ៦៤ឆ្នាំ | ៧,៥ | ១៧,៩ | ១១,៧ | ៧,២ | ១៧,០ | ១១,៦ |
| ៦៥ឆ្នាំឡើង | ៣,៥ | ១១,៧ | ៦,៨ | ៣,៣ | ១៣,៨ | ៧,៤ |

## ការទទួលបានការសិក្សាអប់រំ

ដូចបានបង្ហាញក្នុងតារាង២២ខាងក្រោម នៅឆ្នាំ២០១៩/២០នេះ មានប្រជាជនអាយុចាប់ពី២៥ឆ្នាំឡើងប្រមាណ ១៨ភាគរយ មិនបានរៀន ឬក៏បានរៀនសូត្រតិចតួច ដែលក្នុងនោះស្ត្រីមាន ២៤ភាគរយ និងបុរសមាន ១២ភាគរយ។ បុរសមានអត្រាខ្ពស់ជាងស្ត្រីដែលបានបញ្ចប់ការសិក្សានៅក្នុងកម្រិតមធ្យមសិក្សា និងឬក៏ក្រោយមធ្យមសិក្សា។ បើប្រៀបធៀបពីការទទួលបានសិក្សាអប់រំក្នុងអំឡុងពេល ប្រាំឆ្នាំចុងក្រោយនេះ (ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៩/២០) អត្រាបញ្ចប់ការសិក្សាសម្រាប់អ្នកអាយុចាប់ពី២៥ឆ្នាំឡើង ដែលទទួលបានក្នុងកម្រិតសិក្សាទាបបំផុត (មិនបានរៀន ឬក៏បានរៀនសូត្រតិចតួច) មានការថយចុះប្រមាណពី ៣១ភាគរយ ដល់ ២៤ភាគរយ សម្រាប់ស្ត្រី និងពី១៥ភាគរយ ដល់១២ភាគរយ សម្រាប់បុរស។ សម្រាប់ការសិក្សានៅក្នុងកម្រិតខ្ពស់ផ្សេងទៀត មានការប្រែប្រួលផងដែរក្នុងចំណោមស្ត្រី និងបុរស នៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ ក៏ប៉ុន្តែមិនមានអត្រាខុសគ្នាច្រើននោះទេ។ (សូមមើលតារាង២២សម្រាប់ព័ត៌មានបន្ថែម)។

**តារាង២២. ការទទួលបានការសិក្សាសម្រាប់ប្រជាជន(អាយុ២៥ឆ្នាំឡើង)បែងចែកតាមកម្រិតសិក្សាអប់រំ និងតាមភេទ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| កម្រិតសិក្សាអប់រំដែលទទួលបាន | ស្ត្រី | បុរស | ទាំងពីរភេទ |
|---|---|---|---|
| អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ | | | |
| គ្មាន ឬ មានការសិក្សាអប់រំតិចតួច | ៣០,៦ | ១៤,៨ | ២៣,៣ |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ៣៥,៣ | ៣១,៥ | ៣៣,៥ |
| បានបញ្ចប់កម្រិតបឋមសិក្សា | ១៨,៩ | ២៥,២ | ២១,៨ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) | ៨,២ | ១៣,៤ | ១០,៦ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) | ៣,៩ | ៨,២ | ៥,៩ |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៣,១ | ៦,៩ | ៤,៩ |
| ការសិក្សាអប់រំផ្សេងទៀតដែលបានបញ្ជាក់ | ០,០ | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ |

| | | | |
|---|---|---|---|
| អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ | | | |
| គ្មាន ឬ មានការសិក្សាអប់រំតិចតួច | ២៤,០ | ១១,៩ | ១៨,៣ |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ៣៧,២ | ៣២,១ | ៣៤,៨ |
| បានបញ្ចប់កម្រិតបឋមសិក្សា | ២០,៤ | ២៤,៩ | ២២,៥ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) | ៩,៥ | ១៤,៣ | ១១,៨ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) | ៤,២ | ៧,៧ | ៥,៩ |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៤,៧ | ៩,០ | ៦,៧ |
| ការសិក្សាអប់រំផ្សេងទៀតដែលបានបញ្ជាក់ | ០,០ | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ |

ដូចបានបង្ហាញក្នុងតារាង២៣ខាងក្រោម មានភាពខុសគ្នាច្រើនពីកម្រិតសិក្សាអប់រំដែលទទួលបាននៅតាមតំបន់ភូមិសាស្ត្រក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ (ពីឆ្នាំ២០១៤ដល់ ឆ្នាំ២០១៩/២០)។ នៅឆ្នាំ២០១៩/២០ ការសិក្សាអប់រំនៅកម្រិតក្រោយមធ្យមសិក្សាដែលប្រជាជននៅរាជធានីភ្នំពេញទទួលបានជាទូទៅមានកម្រិតអត្រា(២៣ភាគរយ)ខ្ពស់ជាង ប្រជាជនដែលរស់នៅតាមទីប្រជុំជន (៦ភាគរយ) និងជនបទ(២ភាគរយ)។ (សូមមើលតារាង២៣សម្រាប់ព័ត៌មានបន្ថែម)។

**តារាង២៣. ការទទួលបានការសិក្សាសម្រាប់ប្រជាជន(អាយុ២៥ឆ្នាំឡើង)បែងចែកតាមកម្រិតសិក្សាអប់រំ និងតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| កម្រិតសិក្សាអប់រំដែលទទួលបាន | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ | | | | |
| គ្មាន ឬ មានការសិក្សាអប់រំតិចតួច | ២៣,៣ | ៥,៧ | ១៥,៨ | ២៨,០ |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ៣៣.៥ | ១៧,៨ | ២៦,៨ | ៣៧,៧ |
| បានបញ្ចប់កម្រិតបឋមសិក្សា | ២១,៨ | ២៣,៩ | ២៤,៩ | ២០,៩ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) | ១០,៦ | ១៧,៩ | ១៥,១ | ៨,៤ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) | ៥,៩ | ១៣,៦ | ១០,៤ | ៣,៦ |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៤,៩ | ២១,១ | ៦,៩ | ១,៤ |
| ការសិក្សាអប់រំផ្សេងទៀតដែលបានបញ្ជាក់ | ០,០ | ០,០ | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |
| អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ | | | | |
| គ្មាន ឬ មានការសិក្សាអប់រំតិចតួច | ១៨,៣ | ៦,៦ | ១៣,៧ | ២៣,៦ |
| មិនបានបញ្ចប់កម្រិតបឋមសិក្សា | ៣៤,៨ | ១៧,៦ | ៣២,១ | ៤០,៨ |
| បានបញ្ចប់កម្រិតបឋមសិក្សា | ២២,៥ | ២១,៩ | ២៦,០ | ២១,២ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) | ១១,៨ | ១៩,៨ | ១៣,៩ | ៨,៦ |
| បានបញ្ចប់កម្រិតមធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) | ៥,៩ | ១១,០ | ៧,៨ | ៣,៦ |
| ការសិក្សាអប់រំក្រោយមធ្យមសិក្សា | ៦,៧ | ២៣,០ | ៦,៤ | ២,២ |
| ការសិក្សាអប់រំផ្សេងទៀតដែលបានបញ្ជាក់ | ០,០ | - | ០,០ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

## ៥.៥ ការចំណាយសម្រាប់ការសិក្សាអប់រំ

ចំនួនទឹកប្រាក់ដែលបានចំណាយសម្រាប់ការសិក្សាអប់រំ ក្នុងអំឡុងពេលនៃឆ្នាំសិក្សាកន្លងមកសម្រាប់សមាជិកគ្រួសារនីមួយៗ ដែលបានចូលរៀនក្នុងប្រព័ន្ធអប់រំផ្លូវការ ការរៀនបន្ថែមជាលក្ខណៈឯកជនក្រៅម៉ោងក្រោយពេលចេញពីសាលា ឬក៏ការសិក្សាថ្នាក់ក្រៅប្រព័ន្ធ ត្រូវបានកត់ត្រាដាច់ដោយឡែកពីគ្នា។ ការចំណាយសរុប រួមមាន៧ប្រភេទដូចខាងក្រោម ៖

- ចំណាយថ្លៃសាលា
- ចំណាយថ្លៃគ្រូបង្រៀន
- ចំណាយថ្លៃសៀវភៅសិក្សា
- ចំណាយសម្ភារៈសិក្សាផ្សេងៗ
- ចំណាយលើការសិក្សារបស់ក្មេងដែលទៅសិក្សាឆ្ងាយពីផ្ទះ
- ការចំណាយថ្លៃធ្វើដំណើរ
- អំណោយជូនគ្រូ ប្រាក់វិភាគទានបង់សម្រាប់សាងសង់អគារ/ការអភិវឌ្ឍ។ល។

ការចំណាយលើការអប់រំមានភាពខុសគ្នាច្រើនរវាងកម្រិតខុសគ្នានៃការអប់រំ។ នៅតាមសាលាបឋមសិក្សាដែលមានចំនួនសិស្សច្រើនជាងគេ។ នៅឆ្នាំ២០១៩/២០ ចំណាយលើការសិក្សាអប់រំរបស់គ្រួសារមានចំនួន៦១៨ពាន់រៀលគិតជាមធ្យមសម្រាប់កម្រិតថ្នាក់មតេយ្យ។ ការចំណាយចំនួន ៦៥១ ពាន់រៀលជាមធ្យមសម្រាប់នៅថ្នាក់បឋមសិក្សា។ សម្រាប់ការអប់រំនៅអនុវិទ្យាល័យគឺមានចំនួនប្រមាណ១.១៤២ ពាន់រៀលជាមធ្យមហើយក្នុងកម្រិតខ្ពស់បំផុតគឺ«និស្សិតបញ្ចប់ការសិក្សា / បញ្ចប់ការសិក្សា» ៥.៥៤៨ ពាន់រៀលជាមធ្យម។ នៅកម្រិតខ្ពស់អ្នកត្រូវរកថ្លៃសាលានិងចំណាយសិក្សាបន្ថែមដែលអាចពន្យល់ពីភាពខុសគ្នាធំនៃថ្លៃដើមរវាងកម្រិតខុសគ្នា។ ថ្លៃដើមនៃការអប់រំនៅឆ្នាំ ២០១៩/២០ បានកើនឡើងបើប្រៀបធៀបទៅនឹងការចំណាយក្នុងឆ្នាំ២០១៤។ ការពន្យល់មួយអាចថានិស្សិតកាន់តែច្រើនបានសិក្សា នៅកម្រិតខ្ពស់ដែលថ្លៃឈ្នួលត្រូវបង់ប្រាក់។ លទ្ធផលក៏បង្ហាញផងដែរថា ការចំណាយសម្រាប់ការសិក្សានៅកម្រិតខ្ពស់បានកើនឡើង។ (សូមមើលតារាង២៤សម្រាប់ព័ត៌មានបន្ថែម)។

**តារាង២៤. ការចំណាយប្រចាំឆ្នាំគិតជាមធ្យមភាគបែងចែកតាមកម្រិតសិក្សាអប់រំឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាពាន់រៀល)**

| កម្រិតសិក្សាអប់រំ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | |
|---|---|---|
| | ២០១៤ | ២០១៩/២០ |
| មត្តេយសិក្សា | ៣៥៦ | ៦១៨ |
| បឋមសិក្សា | ៣១៤ | ៦៥១ |
| មធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) | ៦៦៩ | ១.១៤២ |
| មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) | ១.២១៤ | ២.២៧២ |
| ថ្នាក់បច្ចេកទេស/បណ្តុះបណ្តាលវិជ្ជាជីវៈ | ២.០៦២ | ៣.០៧៥ |
| ថ្នាក់បរិញ្ញាប័ត្រ/ក្រោយបរិញ្ញាប័ត្រ | ៣.៨៣៧ | ៥.៥៤៨ |

ដោយសារសមាសភាពនៃការសិក្សាអប់រំមានលក្ខណៈខុសគ្នាទៅតាមតំបន់ភូមិសាស្ត្រនៅក្នុងប្រទេសកម្ពុជា ដូចនេះមធ្យមភាគលើការចំណាយក៏មានលក្ខណៈខុសគ្នាផងដែរ។ នៅរាជធានីភ្នំពេញមានការចំណាយខ្ពស់នៅកម្រិតដែលខ្ពស់ជាងបឋមសិក្សា និងភាគច្រើនចំណាយលើសាលាឯកជន។ ដូចបានបង្ហាញក្នុងតារាង ២៥ ខាងក្រោម ការចំណាយគិតជាមធ្យមប្រចាំឆ្នាំនៅឆ្នាំ២០១៩/២០ មានចំនួនកាន់តែខ្ពស់ដែលគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងការចំណាយប្រចាំឆ្នាំនៅឆ្នាំ២០១៤ ដែលមានចំនួន ៣.១៣២ពាន់រៀល សម្រាប់នៅរាជធានីភ្នំពេញ នៅទីប្រជុំជនផ្សេងៗមាន១.៣១២ពាន់រៀល និងនៅតំបន់ជនបទមាន ៨២១ពាន់រៀល។ មានភាពខុសគ្នាច្រើនក្នុងការចំណាយប្រចាំឆ្នាំរវាងរាជធានីភ្នំពេញ និងតំបន់ផ្សេងៗទៀត នៃប្រទេសកម្ពុជានៅក្នុងអំឡុងពេលប្រាំឆ្នាំនេះ(ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០)។ (សូមមើលតារាង២៥សម្រាប់ព័ត៌មានបន្ថែម)។

**តារាង២៥. ការចំណាយប្រចាំឆ្នាំគិតជាមធ្យមភាគបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០១៤និងឆ្នាំ២០១៩/២០ (គិតជាពាន់រៀល)**

| តំបន់ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | |
|---|---|---|
| | ២០១៤ | ២០១៩/២០ |
| កម្ពុជា | ៧៥៩ | ១.២៦៦ |
| រាជធានីភ្នំពេញ | ១.៦៤៣ | ៣.១៣២ |
| ទីប្រជុំជនផ្សេងៗ | ១.១៧៩ | ១.៣១២ |
| ជនបទ | ៥៧៨ | ៨២១ |

ផ្អែកតាមទិន្នន័យអង្កេតក្នុងតារាង២៦ បានបង្ហាញថា ការចំណាយលើការសិក្សាប្រចាំឆ្នាំ គិតជាមធ្យមសម្រាប់ស្ត្រី គឺមានចំនួនខ្ពស់ជាងការចំណាយសម្រាប់បុរសក្នុងឆ្នាំ២០១៩/២០។ ការចំណាយប្រចាំឆ្នាំគិតជាមធ្យមលើការសិក្សានៅក្នុងឆ្នាំ២០១៩/២០ (១.២៦៦ពាន់រៀល) គឺមានចំនួនខ្ពស់ជាងការចំណាយប្រចាំឆ្នាំគិតជាមធ្យមក្នុងឆ្នាំ២០១៤ (៧៥៩ពាន់រៀល) សម្រាប់ទាំងស្ត្រី និងបុរស។ ទោះជាយ៉ាងនេះក្តី ក៏ភាពខុសគ្នានៃការចំណាយប្រចាំឆ្នាំលើការសិក្សាអប់រំនៅក្នុងឆ្នាំសិក្សានីមួយៗសម្រាប់ស្ត្រី និងបុរស មានគម្លាតកាន់តែធំនៅឆ្នាំ២០១៩/២០ ដែលមានប្រមាណ ១១១ ពាន់រៀល ខណៈដែលចំនួននេះមានការខុសគ្នាប្រមាណ១១ពាន់រៀលនៅឆ្នាំ២០១៤។ (សូមមើលតារាងទី ២៦ សម្រាប់ព័ត៌មានលម្អិត)។

**តារាង២៦. ការចំណាយប្រចាំឆ្នាំគិតជាមធ្យម បែងចែកតាមភេទឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាពាន់រៀល)**

| ភេទ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | |
|---|---|---|
| | ២០១៤ | ២០១៩/២០ |
| ស្ត្រី | ៧៥៤ | ១.៣២២ |
| បុរស | ៧៦៥ | ១.២១១ |
| ទាំងពីរភេទ | ៧៥៩ | ១.២៦៦ |

## ៥.៦ សន្ទស្សន៍យុគភាពយេនឌ័រអប់រំ

សន្ទស្សន៍យុគភាពយេនឌ័រអប់រំ (Gender Parity Index - GPI) គឺជាផលធៀប (អនុបាត) នៃតម្លៃសូចនាករអប់រំណាមួយរបស់ស្ត្រី ទៅនឹងតម្លៃសូចនាករអប់រំនោះរបស់បុរស។ បើសន្ទស្សន៍យុគភាពយេឌ័រស្ថិត

នៅក្នុងចន្លោះពី០,៩៧ ទៅ ១,០៣ នោះ បានសេចក្តីថាមានយុគភាពយេនឌ័រ។ ដូចដែលបានបង្ហាញក្នុងតារាង ២៧ ខាងក្រោម សន្ទស្សន៍យុគភាពយេនឌ័រចំពោះអត្រាចូលរៀនពិតនៅគ្រប់កម្រិតសិក្សាទាំងអស់ គឺមានតម្លៃប្រហែល ១ភាគរយ សម្រាប់ឆ្នាំ២០១៤ ឆ្នាំ២០១៩/២០ ដែលហាក់បីដូចជាមិនមានការប្រែប្រួលសោះនៅក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ។ (សូមមើលតារាងទី ២៧ សម្រាប់ព័ត៌មានលម្អិត)។

**តារាង២៧. សន្ទស្សន៍យុគភាពយេនឌ័រអប់រំចំពោះអត្រាចូលរៀនពិតក្នុងកម្រិតសិក្សាអប់រំឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០**

| សន្ទស្សន៍យុគភាពយេនឌ័រអប់រំ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | |
|---|---|---|
| | ២០១៤ | ២០១៩/២០ |
| បឋមសិក្សា | ១.០ | ១.០ |
| មធ្យមសិក្សាបឋមភូមិ (អនុវិទ្យាល័យ) | ១.១ | ១.២ |
| មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យ) | ១.១ | ១.៣ |

# ផ្នែកទី៦ កម្លាំងពលកម្ម

## ៦.១ សេចក្តីផ្តើម

បាតុភូតប្រជាសាស្ត្រពិសេសដែលប្រទេសកម្ពុជាបានជួបប្រទះនៅក្នុងទសវត្សរ៍៧០ និង៨០ ដែលផ្តល់ឱ្យប្រទេសកម្ពុជា នូវទីផ្សារការងារតែមួយគត់នៅទសវត្សរ៍ឆ្នាំ២០០០។ វាងជំរឿនទូទៅនូវប្រជាពលរដ្ឋ របស់ប្រទេសកម្ពុជាឆ្នាំ១៩៩៨ និង២០១៩ ប្រជាជនបានកើនពី១១.៤លាននាក់ ដល់ ១៥.៤លាននាក់ ដែលមានការកើនឡើងប្រចាំឆ្នាំជាមធ្យមគឺ១.៥ភាគរយ។

អត្រាអ្នករស់នៅក្នុងបន្ទុកត្រូវបានកំណត់ជាចំនួននៃកុមារដែលមានអាយុចាប់ពី០-១៤ឆ្នាំ និងមនុស្សចាស់ដែលមានអាយុចាប់ពី៦៥ឆ្នាំឡើងទៅ ចែកនឹងចំនួនប្រជាជនដែលមានអាយុចាប់ពី១៥-៦៤ឆ្នាំ។ ឧទាហរណ៍ អត្រាអ្នកនៅក្នុងបន្ទុកគឺជាផលធៀបរវាងអ្នកដែលមិននៅក្នុងកម្លាំងពលកម្ម (អ្នកនៅក្នុងបន្ទុក) និងអ្នកនៅក្នុងកម្លាំងពលកម្ម។

យោងតាមអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ប្រជាជនដែលគ្រប់អាយុធ្វើការនៅក្នុងក្រុមអាយុចាប់ពី១៥-៦៤ឆ្នាំ មានការកើនឡើងជិត១.៦លាននាក់ ចាប់ពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១៩/២០ (សូមមើលតារាង១)។ ការកើនឡើងនៃប្រជាជនគ្រប់អាយុធ្វើការមានការកើនឡើងបន្តិច។

**រូបភាព១. អត្រាអ្នករស់នៅក្នុងបន្ទុក(ចំនួនមនុស្ស គឺមានអាយុតិចជាង១៥ឆ្នាំឬមនុស្ស ដែល មានអាយុចាប់ពី៦៥ឆ្នាំឡើង ចែកនឹងចំនួនមនុស្សដែលមានអាយុចាប់ពី១៥-៦៤ឆ្នាំ) ២០១៩/២០ គិតជាភាគរយ**




នៅក្នុងរបាយការណ៍នេះ លទ្ធផលស្តីពីការចូលរួមកម្លាំងពលកម្ម (សកម្មជនផ្នែកសេដ្ឋកិច្ច) ត្រូវបានបង្ហាញសម្រាប់ឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៩/២០។ ពេលវេលាសម្រាប់ឆ្នាំទាំងអស់ពីឆ្នាំ២០០៤ ត្រូវបានបន្ថែមនៅក្នុងឧបសម្ព័ន្ធ និងនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

កម្លាំងពលកម្មរួមមានអ្នកទាំងឡាយណាដែលមានការងារធ្វើ និងអ្នកទាំងឡាយណាដែលគ្មានការងារធ្វើ (គ្មានការងារធ្វើ អ្នកដែលកំពុងស្វែងរកការងារ ហើយមានលទ្ធភាពធ្វើការងារបាន)។ នៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០៩ ប្រជាជនមានអាយុចាប់ពី១៥-៦៤ឆ្នាំ ត្រូវបានកំណត់ជាប្រជាជនគ្រប់អាយុធ្វើការនៅពេលដែលការប្រៀបធៀបជាអន្តរជាតិជារឿយៗផ្តោតលើក្រុមអាយុនេះ។ កាលពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចមុនៗត្រូវបានផ្តោតលើអាយុចាប់ពី១០ឆ្នាំឡើង។ ដើម្បីអាចប្រៀបធៀបទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ ដល់ឆ្នាំ២០១៩/២០ ត្រូវបានចងក្រងឡើងដោយផ្អែកលើក្រុមអាយុពី១៥-៦៤ឆ្នាំ។

លទ្ធផលត្រូវបានប្រៀបធៀបមិនត្រឹមតែសម្រាប់នៅទូទាំងប្រទេសកម្ពុជាសរុបប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវបានប្រៀបធៀបសម្រាប់ទីតាំងភូមិសាស្ត្រទាំងបីផងដែរ ដូចជារាជធានីភ្នំពេញ តំបន់ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទ ដែលបានបំបែកតាមក្រុមយេនឌ័រ ក្រុមអាយុ និងកម្រិតនៃការសិក្សាអប់រំ។

លទ្ធផលស្តីពីសកម្មជនផ្នែកសេដ្ឋកិច្ច ផ្អែកលើជំរឿនទូទៅប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ២០១៩ មានការខុសគ្នាពីលទ្ធផលដែលបានបង្ហាញនៅក្នុងរបាយការណ៍ជំរឿន ដោយសារទស្សនាទានខុសគ្នា សម្រាប់ការវាស់វែងសកម្មភាពសេដ្ឋកិច្ច (សូមមើលផ្នែកទី៦.២ខាងក្រោម)។

នៅក្នុងផ្នែកនៃការបែងចែកកម្លាំងពលកម្មកុមារដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅ។

## ៦.២ និយមន័យ

### អ្នកគ្រប់អាយុធ្វើការងារ

នៅក្នុងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ប្រជាជនគ្រប់អាយុធ្វើការងារ ត្រូវបានកំណត់ជាមនុស្សទាំងអស់ដែលមានអាយុពី១៥-៦៤ឆ្នាំ។

### ប្រជាជនសកម្មផ្នែកសេដ្ឋកិច្ច

*ប្រជាជនសកម្មផ្នែកសេដ្ឋកិច្ច* រួមមានមនុស្សទាំងអស់ដែលជាអ្នកផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់ផលិតទំនិញនិងសេវាកម្មសេដ្ឋកិច្ច ដែលបានកំណត់ដោយប្រព័ន្ធគណនេយ្យជាតិរបស់អង្គការសហប្រជាជាតិ និងតុល្យភាពអំឡុងពេលកំណត់ដ៏ជាក់លាក់ណាមួយ។ យោងតាមប្រព័ន្ធទាំងនេះ ការផលិតទំនិញ និងសេវាកម្មសេដ្ឋកិច្ច រាប់បញ្ចូលទាំងការផលិត និងការកែច្នៃនូវផលិតផលបឋមទាំងអស់ មិនថាសម្រាប់លក់ សម្រាប់ដោះដូរ ឬសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននោះឡើយ ការផលិតទំនិញ និងសេវាកម្មផ្សេងៗទាំងអស់ សម្រាប់ទីផ្សារ និងក្នុងករណី នៃគ្រួសារដែលផលិតទំនិញ និងសេវាកម្មបែបនេះសម្រាប់ទីផ្សារ ក៏ដូចជាការផលិតសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។

ឯកសារអន្តរជាតិ[4] សម្រាប់ស្ថិតិពលកម្មប្រើប្រាស់ទស្សនាទានចំនួនពីរសម្រាប់ប្រជាជនសកម្មផ្នែកសេដ្ឋកិច្ច។

១) **សកម្មផ្នែកសេដ្ឋកិច្ចធម្មតា** បានវាស់វែងទាក់ទងនឹងរយៈពេលវែងកំណត់មួយ ដូចជាមួយឆ្នាំ។

២) **សកម្មផ្នែកសេដ្ឋកិច្ចបច្ចុប្បន្ន** ឬដូចគ្នាទៅនឹង "កម្លាំងពលកម្ម" បានវាស់វែងដែលទាក់ទងនឹងរយៈពេលខ្លីកំណត់មួយ ដូចជាមួយសប្តាហ៍ ឬ មួយថ្ងៃ។

នៅក្នុងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជានានា ទស្សនាទាននៃ "ប្រជាជនសកម្មផ្នែកសេដ្ឋកិច្ច" ត្រូវបានប្រើប្រាស់ជាមួយនឹងរយៈកំណត់មួយ គឺ "រយៈពេល៧ថ្ងៃកន្លងមក"។ នៅក្នុងលទ្ធផលនៃជំរឿនទូទៅនូវប្រជារាស្ត្រ

[4] ការិយាល័យពលកម្មអន្តរជាតិ (១៩៩០). អង្កេតប្រជារាស្ត្រសកម្មផ្នែកសេដ្ឋកិច្ច, អ្នកមានការងារធ្វើ, អ្នកគ្មានការងារធ្វើ, អ្នកស្វែងការងារក្រៅម៉ោង។ ឯកសាររបស់អង្គការពលកម្មអន្តរជាតិស្តីពី ទស្សនៈ និងវិធីសាស្ត្រ. អង្គការពលកម្មអន្តរជាតិ ទីក្រុង Geneva,1990. ISBN 92-2-106516-2

របស់ប្រទេសកម្ពុជាឆ្នាំ២០០៨[5] ដែលបានបោះពុម្ពផ្សាយនាពេលកន្លងមក។ ទស្សនាទាននៃ"ប្រជាជនសកម្មផ្នែកសេដ្ឋកិច្ច" ជាមួយនឹងរយៈពេលកំណត់មួយគឺ "រយៈពេល១២ខែកន្លងមក" ត្រូវបានប្រើប្រាស់។

### ប្រជាជានអសកម្មផ្នែកសេដ្ឋកិច្ច

*ប្រជាជនអសកម្មផ្នែកសេដ្ឋកិច្ច* រួមមានមនុស្សទាំងឡាយណាដែលស្ថិតក្នុងក្រុមប្រជាជនដែលគ្រប់អាយុ ធ្វើការ ដែលជាអ្នកមិន "សកម្មផ្នែកសេដ្ឋកិច្ច" ដូចបានកំណត់ខាងលើ។
បុគ្គលដែលមិនស្ថិតក្នុងកម្លាំងពលកម្ម ឬដូចគ្នាទៅនឹង *ប្រជាជនអសកម្មផ្នែកសេដ្ឋកិច្ចបច្ចុប្បន្ន* រួមមានបុគ្គលទាំងឡាយណាដែលមានការងារ ឬ គ្មានការងារអំឡុងពេលកំណត់ដ៏ខ្លីមួយ និងមិនសកម្មនាពេលបច្ចុប្បន្ន ដោយសារការចូលរៀននៅតាមគ្រឹះស្ថានអប់រំនានា ការងារផ្ទះ ការចូលនិវត្តន៍ ឬអាយុច្រើន ឬហេតុផលផ្សេងៗទៀតដូចជា ការមានជំងឺ ឬពិការភាព ដែលអាចត្រូវបាន បញ្ជាក់។

### កម្លាំងពលកម្ម (អ្នកសកម្មផ្នែកសេដ្ឋកិច្ចបច្ចុប្បន្ន)

កម្លាំងពលកម្ម (ប្រជាជនសកម្មបច្ចុប្បន្ន) រួមមានបុគ្គលទាំងឡាយណាដែលមាន *ការងារធ្វើ ឬគ្មានការងារធ្វើ*។

### មានការងារធ្វើ

បុគ្គលទាំងឡាយណា ដែលមានការងារធ្វើយ៉ាងហោចណាស់មួយម៉ោង ក្នុងអំឡុងពេលកំណត់ណាមួយរយៈពេល៧ថ្ងៃកន្លងមក ឬមានការងារ/សកម្មភាពសេដ្ឋកិច្ច ប៉ុន្តែពួកគេឈប់ សំរាកបណ្តោះអាសន្ន ។ ការងារគ្រួសារគ្មានប្រាក់ឈ្នួល ត្រូវរាប់បញ្ចូលថា មានការងារធ្វើដែរ។

### ស្ថានភាពការងារ

ស្ថានភាពការងារ សំដៅលើស្ថានភាពនៃបុគ្គលសកម្មផ្នែកសេដ្ឋកិច្ច ដែលទាក់ទងនឹង ការងាររបស់ពួកគេ។ នោះមានន័យថា ទោះបីពួកគេជានិយោជក អ្នកប្រើប្រាស់ទុនផ្ទាល់ខ្លួន និយោជិក អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់បំណាច់ និងផ្សេងៗទៀតក៏ដោយ។

### មុខរបរចម្បង និងមុខរបរបន្ទាប់បន្សំ

មុខរបរពីរ អាចត្រូវបានរាយការណ៍សម្រាប់រយៈពេលកំណត់នៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គឺ មុខរបរចម្បង និងមុខរបន្ទាប់បន្សំ។ នៅក្នុងរបាយការណ៍នេះ មុខរបរផ្នែកឧស្សាហកម្ម និងស្ថានភាពការងារ គឺផ្អែកយ៉ាងសំខាន់លើមុខរបរចម្បង។

### និកម្មភាព

យោងតាមនិយមន័យអន្តរជាតិ[6] និកម្មភាព រួមមានអ្នកទាំងឡាយណាដែលក្នុងរយៈពេលកំណត់ណាមួយ(រយៈពេល៧ថ្ងៃកន្លងមក) មិនមានការងារ ប៉ុន្តែមានលទ្ធភាពអាចធ្វើការបាន ហើយកំពុងស្វែងរកការងារ

---

5 វិទ្យាស្ថានជាតិស្ថិតិ (២០០៩). ជំរឿនទូទៅនូវប្រជាពស្រ្តរបស់ប្រទេសកម្ពុជាឆ្នាំ២០០៨, របាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយ ខែ សីហា ឆ្នាំ២០០៩

6 ការិយាល័យពលកម្មអន្តរជាតិ (១៩៩០). អង្កេតប្រជាពស្ត្រសកម្មផ្នែកសេដ្ឋកិច្ច, អ្នកមានការងារធ្វើ, អ្នកគ្មានការងារធ្វើ, អ្នកស្វែងការងារក្រៅម៉ោង។ ឯកសាររបស់អង្គការពលកម្មអន្តរជាតិស្តីពី ទស្សនៈ និងវិធីសាស្រ្ត. អង្គការពលកម្មអន្តរជាតិ ទីក្រុង Geneva,1990. ISBN 92-2-106516-2

យ៉ាងសកម្ម។ ភាពអត់ការងារធ្វើ ទាល់តែបំពេញលក្ខណៈវិនិច្ឆ័យទាំងបី ខាងលើនេះព្រមជាមួយគ្នាទើបហៅថា និកម្មភាព។

**អ្នកមិនស្ថិតក្នុងកម្លាំងពលកម្ម (ប្រជាជនអសកម្មផ្នែកសេដ្ឋកិច្ច)**

មនុស្សមិនស្ថិតក្នុងកម្លាំងពលកម្ម (ប្រជាជនអសកម្មបច្ចុប្បន្ន) រួមមានបុគ្គលទាំងឡាយណាដែលមានការងារ ឬគ្មានការងារធ្វើ ឬថាមិនស្ថិតក្នុងកម្លាំងពលកម្ម (ឧទាហរណ៍ សិស្សរៀន ពេញម៉ោង មេផ្ទះ ឬអ្នកចូលនិវត្តន៍...។ល។)។

**អត្រាចូលរួមកម្លាំងពលកម្ម**

អត្រាចូលរួមកម្លាំងពលកម្ម គឺត្រូវបានកំណត់ជាកម្លាំងពលកម្មគិតជាភាគរយនៃប្រជាជនគ្រប់អាយុធ្វើការនៅក្នុងក្រុមអាយុដូចគ្នា។

**អត្រាមានការងារធ្វើ**

អត្រាមានការងារធ្វើ ត្រូវបានកំណត់ ជាចំណែកប្រជាជនដែលមានការងារធ្វើទាក់ទងនឹងប្រជាជនគ្រប់អាយុធ្វើការងារ។

**អត្រានិកម្មភាព**

អត្រានិកម្មភាព គឺត្រូវបានកំណត់ជាចំណែកនៃប្រជាជនដែលគ្មានការងារធ្វើទាក់ទងទៅនឹងកម្លាំងពលកម្ម។ រូបភាព២ខាងក្រោម បង្ហាញអំពីទំនាក់ទំនងរវាងប្រជាជនគ្រប់អាយុធ្វើការនៅក្នុងកម្លាំងពលកម្ម (ប្រជាជនសកម្មផ្នែកសេដ្ឋកិច្ច) និងមិននៅក្នុងកម្លាំងពលកម្ម (ប្រជាជនអសកម្មផ្នែកសេដ្ឋកិច្ច)។

**រូបភាព២. កម្លាំងពលកម្មមានទំនាក់ទំនង នឹងប្រជាជនគ្រប់អាយុធ្វើការងារ ដែលមានអាយុចាប់ពី(១៥-៦៤ឆ្នាំ) ឆ្នាំ២០១៩/២០**



## ៦.៣ កម្លាំងពលកម្ម

តារាង១ បង្ហាញអំពីអត្រាចូលរួមកម្លាំងពលកម្ម គឺជាកម្លាំងពលកម្មដែលទាក់ទងនិងប្រជាជនគ្រប់អាយុធ្វើការ១៥-៦៤ឆ្នាំ។ តារាងនេះក៏បង្ហាញផងដែរនូវអត្រាអ្នកមានការងារធ្វើ និងអត្រាអ្នកគ្មានការងារធ្វើ។ អត្រាអ្នកមានការងារធ្វើ គឺជាចំណែកនៃអ្នកមានការងារធ្វើដែលទាក់ទងនិងប្រជាជនគ្រប់អាយុ ហើយអត្រានិកម្មភាព គឺជាចំណែកនៃនិកម្មភាពដែលទាក់ទងនឹងកម្លាំងពលកម្ម។

ក្នុងឆ្នាំ២០១៩/២០ អត្រាអ្នកចូលរួមកម្លាំងពលកម្មកម្ពុជា មានចំនួនប្រហែល ៨៧ភាគរយ។ ចំនួនប្រហែល ៨៤ភាគរយ សម្រាប់ស្ត្រី និងចំនួនប្រហែល ៩១ភាគរយ សម្រាប់បុរស។ អត្រាទាំងនេះនៅក្នុងតំបន់ជនបទមានចំណែកច្រើនជាងនៅរាជធានីភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងៗ។ នៅក្នុងតំបន់ជនបទ កម្លាំងពលកម្មនៃប្រជាជនសរុបមានប្រហែល ៨៩ភាគរយ បើប្រៀបធៀបទៅនឹងរាជធានីភ្នំពេញប្រហែល ៨១ភាគរយ និងប្រហែល ៨៨ភាគរយ នៅតំបន់ទីប្រជុំជនផ្សេងៗ។

### មានការងារធ្វើ និង និកម្មភាព

តារាង១ អត្រាចូលរួមកម្លាំងពលកម្ម បានបង្ហាញអំពីភាពខុសគ្នារវាងស្ត្រី និងបុរស ដោយសារអត្រាចូលរួមកម្លាំងពលកម្មសម្រាប់បុរស គឺមានការកើនឡើងជាងស្ត្រីនៅក្នុងគ្រប់តំបន់ភូមិសាស្ត្រ។

ភាពខុសគ្នារវាងស្ត្រី និងបុរស(យេនឌ័រ)ខ្លះ គឺទំនងជានៅរាជធានីភ្នំពេញច្រើនជាង បើប្រៀបធៀបទៅនិងតំបន់ភូមិសាស្ត្រផ្សេងៗទៀត។

អត្រាមានការងារធ្វើដែលទាក់ទងទៅនិងប្រជាជនគ្រប់អាយុធ្វើការ១៥-៦៤ឆ្នាំ គឺមានប្រហែល៨៥ភាគរយក្នុងឆ្នាំ២០១៩/២០។ នៅក្នុងប្រទេសកម្ពុជាមានភាពខុសគ្នារវាងស្ត្រី និងបុរសប្រមាណ ៩ភាគរយដែលទាក់ទងទៅនិងអត្រាមានការងារធ្វើ ប្រមាណ៨១ភាគរយ សម្រាប់ស្ត្រី និងមានប្រមាណ ៩០ភាគរយ សម្រាប់បុរស។ នៅក្នុងតំបន់ទីជនបទអត្រាកម្មភាពខ្ពស់បំផុតមានប្រមាណ ៨៨ភាគរយ អនុលោមទៅតាមតំបន់ទីប្រជុំជនផ្សេងៗមានប្រមាណ ៨៥ភាគរយ និងនៅរាជធានីភ្នំពេញប្រមាណ ៧៦ភាគរយ។

អត្រានិកម្មភាពនៅក្នុងឆ្នាំ២០១៩/២០ មានប្រមាណ ២,៤ភាគរយ នៃអ្នកចូលរួមកម្លាំងពលកម្មសរុបដោយការគណនាវាស់វែងផ្អែកតាមនិយមន័យអន្តរជាតិថ្មី[7] ដែលចេញផ្សាយខែមករា ឆ្នាំ២០២០ និង សៀវភៅណែនាំស្តីពីរូបមន្តគណនាកម្លាំងពលកម្ម[8] ដោយអង្គការអន្តរជាតិខាងការងារ(ឬ ILO)។ នៅក្នុងរាជធានីភ្នំពេញមានអត្រានិកម្មភាពមាន ៣,៩ភាគរយតាមតំបន់ទីប្រជុំជនផ្សេងៗ មាន ២,៨ភាគរយ និងតំបន់ទីជនបទមាន១.៩ភាគរយ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាងទី១)។

[7] ប្រភពៈទស្សនៈទាន និងវិធីសាស្ត្រគណនាអត្រានិកម្មភាពរបស់អង្គការអន្តរជាតិខាងការងារ (ILO_PAPI_LFS_VARIABLE_DERIVATION_GUIDE(A1V3))

[8] ប្រភពៈ https://ilostat.ilo.org/resources/methods/#standards និង https://www.ilo.org/wcmsp5/groups/public/---dgreports/---stat/documents/publication/wcms_651746.pdf

**តារាង១. ប្រជាជន និងកម្លាំងពលកម្មដែលមានអាយុចាប់ពី(១៥-៦៤ឆ្នាំ) បែងចែកតាមភេទ និងតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ ចំនួនប្រជាជន (គិតជាពាន់នាក់ និងភាគរយ)**

| កម្លាំងពលកម្ម និងភេទ | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
| ប្រជាជនសរុប | **១៥.៩៥៥** | **២.៣៤០** | **៣.៩៥៣** | **៩.៦៦១** | **១០០.០** | **១៤,៧** | **២៤,៨** | **៦០,៦** |
| ប្រជាជនគ្រប់អាយុ ធ្វើការ | **១០.៣១៦** | **១.៦៨៤** | **២.៦៣២** | **៦.០០០** | **៦៤,៧** | **៧២,០** | **៦៦,៦** | **៦២,១** |
| កម្លាំងពលកម្ម | **៩.០២០** | **១.៣៥៥** | **២.៣០៤** | **៥.៣៦១** | **៨៧,៤** | **៨០,៥** | **៨៧,៥** | **៨៩,៤** |
| **អត្រាចូលរួមកម្លាំងពលកម្ម** | | | | | | | | |
| ស្ត្រី | ៤.៤៨៤ | ៦៦៦ | ១.១៣០ | ២.៦៨៧ | ៨៤,១ | ៧៦,៣ | ៨៤,១ | ៨៦,៣ |
| បុរស | ៤.៥៣៧ | ៦៨៩ | ១.១៧៤ | ២.៦៧៤ | ៩១,០ | ៨៥,០ | ៩១,២ | ៩២,៧ |
| ទាំងពីភេទ | **៩.០២០** | **១.៣៥៥** | **២.៣០៤** | **៥.៣៦១** | **៨៧,៤** | **៨០,៥** | **៨៧,៥** | **៨៩,៤** |
| **អត្រាកម្មភាព** | | | | | | | | |
| ស្ត្រី | ៤.៣១៨ | ៦២៤ | ១.០៨២ | ២.៦១២ | ៨១,០ | ៧១,៤ | ៨០,៥ | ៨៣,៩ |
| បុរស | ៤.៤៨៧ | ៦៨១ | ១.១៥៨ | ២.៦៤៨ | ៩០,០ | ៨៤,០ | ៩០,០ | ៩១,៨ |
| ទាំងពីភេទ | **៨.៨០៥** | **១.៣០៥** | **២.២៤០** | **៥.២៦០** | **៨៥,៤** | **៧៧,៥** | **៨៥,១** | **៨៧,៧** |
| **អត្រានិកម្មភាព** | | | | | | | | |
| ស្ត្រី | ១៦៦ | ៤២ | ៤៨ | ៧៥ | ៣,៧ | ៦,៣ | ៤,២ | ២,៨ |
| បុរស | ៥០ | ៩ | ១៦ | ២៦ | ១,១ | ១,២ | ១,៣ | ១,០ |
| ទាំងពីភេទ | **២១៥** | **៥១** | **៦៤** | **១០១** | **២,៤** | **៣,៧** | **២,៨** | **១,៩** |

តារាង២ អត្រាចូលរួមកម្លាំងពលកម្ម ស្ត្រី និងបុរស ត្រូវបានបង្ហាញសម្រាប់ក្រុមអាយុផ្សេងគ្នាផងដែរ។ ក្នុងឆ្នាំ២០១៩/២០ អត្រាចូលរួមខ្ពស់ជាងគេទាំងស្ត្រី និងបុរសនៅក្នុងក្រុមអាយុ ៣៥-៤៤ឆ្នាំ មានប្រមាណ ៩២ភាគរយ សម្រាប់ស្ត្រី និងមាន ៩៩ភាគរយ សម្រាប់បុរស។

អត្រាចូលរួមកម្លាំងពលកម្មនៅក្នុងក្រុមអាយុក្មេងបំផុត១៥-១៩ឆ្នាំ សម្រាប់ទាំងស្ត្រី និងបុរស មានអត្រាប្រហាក់ប្រហែលគ្នា គឺ៥៩ភាគរយ។ អត្រាចូលរួមកម្លាំងពលកម្មក្រុមអាយុចាប់ពី១៥ឆ្នាំឡើង ចំពោះស្ត្រីគឺមានទាបជាងបុរសនៅគ្រប់ក្រុមអាយុទាំងអស់។ ភាពខុសគ្នាធំបំផុតរវាងស្ត្រី និងបុរស គឺនៅក្នុងក្រុមអាយុ៥៥-៦៤ឆ្នាំ មានប្រមាណ ៧៥ភាគរយ សម្រាប់ស្ត្រី និងមាន ៩១ភាគរយ សម្រាប់បុរសនៅក្នុងកម្លាំងពលកម្ម។

**តារាង២. អត្រាចូលរួមកម្លាំងពលកម្ម បែងចែកតាមក្រុមអាយុ និងភេទ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ក្រុមអាយុ | ចំនួន | | | ភាគរយ | | |
|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| ១៥–១៩ ឆ្នាំ | ៣៩៨ | ៤៣៤ | ៨៣២ | ៥៦,០ | ៦១,០ | ៥៨,៥ |
| ២០–២៤ ឆ្នាំ | ៥៩៩ | ៥៩៣ | ១.១៩២ | ៨៧,៥ | ៩០,២ | ៨៨,៨ |
| ២៥–៣៤ ឆ្នាំ | ១.២៩២ | ១.៣១៥ | ២.៦០៧ | ៩២,១ | ៩៨,០ | ៩៥,០ |
| ៣៥–៤៤ ឆ្នាំ | ១.០១២ | ១.០៣៣ | ២.០៤៥ | ៩២,៤ | ៩៨,៨ | ៩៥,៥ |
| ៤៥–៥៤ ឆ្នាំ | ៦៩៧ | ៦៩៧ | ១.៣៩៤ | ៨៨,១ | ៩៧,៥ | ៩២,៦ |
| ៥៥–៦៤ ឆ្នាំ | ៤៨៥ | ៤៦៥ | ៩៥១ | ៧៤,៩ | ៩០,៩ | ៨២,០ |
| សរុប (១៥–៦៤ឆ្នាំ) | **៤.៤៨៤** | **៤.៥៣៧** | **៩.០២០** | **៨៤,១** | **៩១,០** | **៨៧,៤** |
| ក្នុងនោះ | | | | | | |
| ១៥–២៤ ឆ្នាំ | ៩៩៧ | ១.០២៦ | ២.០២៣ | ៧១,៤ | ៧៥,០ | ៧៣,២ |

ដូចបានបង្ហាញក្នុងរូបភាព៣ខាងក្រោម អត្រាចូលរួមកម្លាំងពលកម្មក្រុមអាយុ ១៥-៦៤ឆ្នាំ និងភេទ សម្រាប់ឆ្នាំ២០១៩/២០។ ក្នុងអំឡុងពីឆ្នាំ២០០៩ដល់២០១៣ បានបង្ហាញថាអត្រាចូលរួមកម្លាំងពលកម្មសម្រាប់ស្ត្រី គឺមានការកើនឡើងជាងបុរស ប៉ុន្តែចាប់ពីឆ្នាំ២០១៤ ដល់២០១៩/២០ អត្រានេះបានថយចុះមកវិញ។ ការថយចុះនេះអាចបណ្តាលមកពីស្ថានភាពការងារដោយសារផលប៉ះពាល់តាមរដូវ និងការចំណាកស្រុក។

**រូបភាព៣. អត្រាចូលរួមកម្លាំងពលកម្មបែងចែកតាមក្រុមអាយុ( ១៥-៦៤ឆ្នាំ )និងភេទ ឆ្នាំ២០០៩-២០១៩/២០ ភាគរយ**




តារាង៣ បង្ហាញអំពីអត្រាចូលរួមកម្លាំងពលកម្មផ្សេងៗគ្នាតាមក្រុមអាយុ និងតំបន់ភូមិសាស្ត្រ។ អត្រាចូលរួមខ្ពស់បំផុតនៅក្នុងតំបន់ភូមិសាស្ត្រទាំងបី គឺប្រជាជនស្ថិតនៅក្នុងក្រុមអាយុ៣៥-៤៤ឆ្នាំ។ ភាពខុសគ្នានៅតាមតំបន់ភូមិសាស្ត្រ មានចំណែកអត្រាចូលរួមកម្លាំងពលកម្មធំបំផុតនៅក្នុងក្រុមអាយុក្មេងជាងគេ។ នៅក្នុងតំបន់ជនបទ បានចូលរួមកម្លាំងពលកម្មនៅក្នុងក្រុមអាយុ១៥-១៩ឆ្នាំ មានប្រមាណ ៦៥ភាគរយ ចំណែកឯនៅតំបន់ទីប្រជុំជនមានប្រមាណ៥៦ភាគរយ និងរាជធានីភ្នំពេញ មានប្រមាណ ៣០ភាគរយ។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង៣)

**តារាង៣. អត្រាចូលរួមកម្លាំងពលកម្ម បែងចែកតាមក្រុមអាយុ និង តំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ក្រុមអាយុ | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
| ១៥–១៩ ឆ្នាំ | ៨៣២ | ៥៥ | ១៩៣ | ៥៨៤ | ៥៨,៥ | ២៩,៦ | ៥៦,២ | ៦៥,៣ |
| ២០–២៤ ឆ្នាំ | ១.១៩២ | ១៨៣ | ៣១៧ | ៦៩២ | ៨៨,៨ | ៧៨,៦ | ៨៩,៩ | ៩១,៤ |
| ២៥–៣៤ ឆ្នាំ | ២.៦០៧ | ៤៩៦ | ៧១០ | ១.៤០០ | ៩៥,០ | ៩៣,៥ | ៩៥,៣ | ៩៥,៤ |
| ៣៥–៤៤ ឆ្នាំ | ២.០៤៥ | ៣៥១ | ៥៣២ | ១.១៦២ | ៩៥,៥ | ៩២,១ | ៩៦,១ | ៩៦,៣ |
| ៤៥–៥៤ ឆ្នាំ | ១.៣៩៤ | ១៨១ | ៣២៥ | ៨៨៨ | ៩២,៦ | ៨៦,៣ | ៩០,៩ | ៩៤,៦ |
| ៥៥–៦៤ ឆ្នាំ | ៩៥១ | ៨៩ | ២២៦ | ៦៣៥ | ៨២,០ | ៦១,៤ | ៨១,២ | ៨៦,៤ |
| **សរុប (១៥–៦៤ឆ្នាំ)** | **៩.០២០** | **១.៣៥៥** | **២.៣០៤** | **៥.៣៦១** | **៨៧,៤** | **៨០,៥** | **៨៧,៥** | **៨៩,៤** |
| ក្នុងនោះ | | | | | | | | |
| ១៥–២៤ ឆ្នាំ | ២.០២៣ | ២៣៧ | ៥១០ | ១.២៧៦ | ៧៣,២ | ៥៦,៩ | ៧៣,៣ | ៧៧,៣ |

តារាង៤ បង្ហាញអំពីអត្រាចូលរួមកម្លាំងពលកម្មបែងចែកតាមភេទ និងតំបន់ភូមិសាស្ត្រនៅឆ្នាំ២០១៩/២០។ ចំពោះស្ត្រីនៅក្នុងរាជធានីភ្នំពេញ មានអត្រាចូលរួមកម្លាំងពលកម្មទាបជាងតំបន់ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទនៅគ្រប់ក្រុមអាយុទាំងអស់។ អត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រីនៅក្នុងក្រុមអាយុទាំងអស់ ក៏នៅតែមានអត្រាទាបជាងបុរសសម្រាប់នៅតាមតំបន់ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទ។ ជារួមបុរសមានអត្រាចូលរួមកម្លាំងពលកម្មខ្ពស់ជាងស្ត្រីនៅស្ទើរតែគ្រប់អាយុ និងគ្រប់តំបន់។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង៤)។

**តារាង៤. អត្រាចូលរួមកម្លាំងពលកម្ម បែងចែកតាមអាយុ តំបន់ភូមិសាស្ត្រ និង ភេទឆ្នាំ២០១៩/២០**
**គិតជាពាន់នាក់ និងភាគរយ**

| ក្រុមអាយុ | កម្ពុជា | | រាជធានីភ្នំពេញ | | ទីប្រជុំជនផ្សេងៗ | | ជនបទ | |
|---|---|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| | | | | ចំនួន | | | | |
| ១៥–១៩ ឆ្នាំ | ៣៩៨ | ៤៣៤ | ៣៤ | ២១ | ៩៣ | ១០០ | ២៧១ | ៣១៣ |
| ២០–២៤ ឆ្នាំ | ៥៩៩ | ៥៩៣ | ៩៩ | ៨៤ | ១៦២ | ១៥៥ | ៣៣៨ | ៣៥៤ |
| ២៥–៣៤ ឆ្នាំ | ១.២៩២ | ១.៣១៥ | ២៥០ | ២៤៦ | ៣៤៤ | ៣៦៦ | ៦៩៧ | ៧០៣ |
| ៣៥–៤៤ ឆ្នាំ | ១.០១២ | ១.០៣៣ | ១៦២ | ១៩០ | ២៦៤ | ២៦៨ | ៥៨៧ | ៥៧៥ |
| ៤៥–៥៤ ឆ្នាំ | ៦៩៧ | ៦៩៧ | ៧៩ | ១០៣ | ១៥៧ | ១៦៩ | ៤៦២ | ៤២៦ |
| ៥៥–៦៤ ឆ្នាំ | ៤៨៥ | ៤៦៥ | ៤២ | ៤៧ | ១១១ | ១១៥ | ៣៣២ | ៣០៣ |
| សរុប (១៥–៦៤ឆ្នាំ) | **៤.៤៨៤** | **៤.៥៣៧** | **៦៦៦** | **៦៨៩** | **១.១៣០** | **១.១៧៤** | **២.៦៨៧** | **២.៦៧៤** |
| ក្នុងនោះ | | | | | | | | |
| ១៥–២៤ ឆ្នាំ | ៩៩៧ | ១.០២៦ | ១៣៣ | ១០៤ | ២៥៥ | ២៥៦ | ៦០៩ | ៦៦៦ |
| | | | | ភាគរយ | | | | |
| ១៥–១៩ ឆ្នាំ | ៥៦,០ | ៦១,០ | ៣៥,០ | ២៣,៦ | ៥៤,៧ | ៥៧,៦ | ៦១,១ | ៦៩,៥ |
| ២០–២៤ ឆ្នាំ | ៨៧,៥ | ៩០,២ | ៨០,៧ | ៧៦,៣ | ៨៩,៣ | ៩០,៥ | ៨៨,៨ | ៩៤,០ |
| ២៥–៣៤ ឆ្នាំ | ៩២,១ | ៩៨,០ | ៨៩,៨ | ៩៧,៥ | ៩២,៣ | ៩៨,៤ | ៩៣,០ | ៩៧,៩ |
| ៣៥–៤៤ ឆ្នាំ | ៩២,៤ | ៩៨,៨ | ៨៥,៣ | ៩៨,៩ | ៩៣,១ | ៩៩,១ | ៩៤,២ | ៩៨,៦ |
| ៤៥–៥៤ ឆ្នាំ | ៨៨,១ | ៩៧,៥ | ៧៤,៦ | ៩៨,១ | ៨៥,២ | ៩៦,៩ | ៩២,០ | ៩៧,៦ |
| ៥៥–៦៤ ឆ្នាំ | ៧៤,៩ | ៩០,៩ | ៥៣,០ | ៧១,៦ | ៧២,៣ | ៩២,១ | ៨០,២ | ៩៤,៤ |
| សរុប (១៥–៦៤ឆ្នាំ) | **៨៤,១** | **៩១,០** | **៧៦,៣** | **៨៥,០** | **៨៤,១** | **៩១,២** | **៨៦,៣** | **៩២,៧** |
| ក្នុងនោះ | | | | | | | | |
| ១៥–២៤ ឆ្នាំ | ៧១,៤ | ៧៥,០ | ៦០,៥ | ៥៣,០ | ៧២,៦ | ៧៣,៩ | ៧៣,៩ | ៨០,៧ |

## ៦.៤ កម្រិតសិក្សាអប់រំ នៃកម្លាំងពលកម្ម

កម្រិតសិក្សាអប់រំនៃកម្លាំងពលកម្ម គឺត្រូវបានបង្ហាញនៅក្នុងតារាង៥ខាងក្រោម។ នៅក្នុងតារាងត្រូវបានបង្ហាញអំពីភាពខុសគ្នា នៃកម្រិតសិក្សាអប់រំ បែងចែកកម្លាំងពលកម្មតាមក្រុមអាយុនីមួយៗ។ ផ្អែកតាមស្ថិតិអប់រំ គឺមានការកើនឡើងនៃអត្រាចុះឈ្មោះចូលរៀននៅក្នុងសាលារៀន ទន្ទឹមនឹងមានការធ្លាក់ចុះនៃការចូលរួមកម្លាំងពលកម្មរបស់ប្រជាជនដែលមានការអប់រំត្រឹមតែបន្តិចបន្តួច ឬគ្មានការអប់រំ។ អត្រានៃការចុះឈ្មោះចូលរៀនអាចត្រូវបានមើលឃើញតាមការប្រៀបធៀបនៃក្រុមអាយុចូលរួមក្នុងកម្លាំងពលកម្មដែលមានការអប់រំត្រឹមតែបន្តិចបន្តួច ឬគ្មានការអប់រំ។ ផ្អែកតាមទិន្នន័យអង្កេតមានប្រមាណ១២ភាគរយនៃកម្លាំងពលកម្មនៅក្នុងក្រុមអាយុ ១៥-៦៤ឆ្នាំ មានការអប់រំត្រឹមតែបន្តិចបន្តួច ឬគ្មានការអប់រំ។ ក៏ប៉ុន្តែចំណែកនៅក្នុងក្រុមអាយុក្មេងបំផុតគឺមាន

៤ភាគរយ តែប៉ុណ្ណោះ ខណៈពេលដែលនៅក្នុងក្រុមអាយុដែលចាស់ជាងគេមានប្រមាណ២៩ភាគរយ។ ចំពោះកម្រិតអប់រំ "មិនបញ្ចប់បឋមសិក្សា" និង "បញ្ចប់បឋមសិក្សា" អត្រាដែលត្រូវគ្នានឹងកម្លាំងពលកម្ម គឺខ្ពស់ជាងគេ បើប្រៀបធៀបទៅនឹងកម្រិតផ្សេងៗទៀត មានប្រមាណ ៣២ភាគរយ និង២៦ភាគរយ តាមលំដាប់រៀង។

**តារាង៥. អត្រាចូលរួមកម្លាំងពលកម្មអាយុ (១៥-៦៤ឆ្នាំ) បែងចែកតាមអាយុ និងកម្រិតអប់រំ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ក្រុមអាយុ | គ្មាន ឬមានការអប់រំត្រឹមតែតិចតួច | មិនបញ្ចប់បឋមសិក្សា | បញ្ចប់បឋមសិក្សា | បញ្ចប់មធ្យមសិក្សាបឋមភូមិ | បញ្ចប់មធ្យមសិក្សាទុតិយភូមិ | ក្រោយមធ្យមសិក្សា | សរុប |
|---|---|---|---|---|---|---|---|
| | | | | ចំនួន | | | |
| ១៥–១៩ ឆ្នាំ | ២៩ | ២០២ | ៣៤១ | ២១៧ | ៣៥ | ៩ | ៨៣២ |
| ២០–២៤ ឆ្នាំ | ៥៨ | ២៥១ | ៣៨៨ | ២២១ | ១៥៣ | ១២០ | ១១៩២ |
| ២៥–៣៤ ឆ្នាំ | ១៩១ | ៦៥៦ | ៧៥២ | ៤២០ | ២៥៥ | ៣៣២ | ២៦០៧ |
| ៣៥–៤៤ ឆ្នាំ | ៣១៤ | ៧៣៧ | ៤៧៨ | ២៥៣ | ១២១ | ១៤២ | ២០៤៥ |
| ៤៥–៥៤ ឆ្នាំ | ២៤៨ | ៥៧៦ | ៣០៤ | ១៤៩ | ៧២ | ៤៧ | ១៣៩៤ |
| ៥៥–៦៤ ឆ្នាំ | ២៧៥ | ៤៤៣ | ១២២ | ៨១ | ១៨ | ១៣ | ៩៥១ |
| សរុប (១៥–៦៤ឆ្នាំ) | **១.១១៥** | **២.៨៦៥** | **២.៣៨៤** | **១.៣៤០** | **៦៥៣** | **៦៦៣** | **៩.០២០** |
| ក្នុងនោះ | | | | | | | |
| ១៥–២៤ ឆ្នាំ | ៨៧ | ៤៥៣ | ៧២៨ | ៤៣៨ | ១៨៨ | ១២៩ | ២.០២៣ |
| | | | | ភាគរយ | | | |
| ១៥–១៩ ឆ្នាំ | ៣,៥ | ២៤,៣ | ៤០,៩ | ២៦,១ | ៤,២ | ១,១ | ១០០ |
| ២០–២៤ ឆ្នាំ | ៤,៩ | ២១,១ | ៣២,៥ | ១៨,៥ | ១២,៩ | ១០,១ | ១០០ |
| ២៥–៣៤ ឆ្នាំ | ៧,៣ | ២៥,២ | ២៨,៩ | ១៦,១ | ៩,៨ | ១២,៨ | ១០០ |
| ៣៥–៤៤ ឆ្នាំ | ១៥,៤ | ៣៦,០ | ២៣,៤ | ១២,៤ | ៥,៩ | ៦,៩ | ១០០ |
| ៤៥–៥៤ ឆ្នាំ | ១៧,៨ | ៤១,៣ | ២១,៨ | ១០,៧ | ៥,១ | ៣,៤ | ១០០ |
| ៥៥–៦៤ ឆ្នាំ | ២៨,៩ | ៤៦,៦ | ១២,៨ | ៨,៥ | ១,៩ | ១,៣ | ១០០ |
| សរុប (១៥–៦៤ឆ្នាំ) | **១២,៤** | **៣១,៨** | **២៦,៤** | **១៤,៩** | **៧,២** | **៧,៤** | **១០០** |
| ក្នុងនោះ | | | | | | | |
| ១៥–២៤ ឆ្នាំ | ៤,៣ | ១២២,៤ | ៣៦,០ | ២១,៦ | ៩,៣ | ៦,៤ | ១០០ |

តារាង៦ បង្ហាញអំពីអត្រាចូលរួមកម្លាំងពលកម្ម បែងចែកតាមភេទ និងតំបន់ភូមិសាស្ត្រនៅឆ្នាំ២០១៩/២០។ គេសង្កេតឃើញថាភាពខុសគ្នានៃកម្រិតអប់រំសម្រាប់ស្ត្រី "មិនបញ្ចប់បឋមសិក្សា"ខ្ពស់ជាងបុរស បើប្រៀបធៀបនឹងកម្រិតផ្សេងៗទៀតដែលមានប្រហែល ៣៤ភាគរយ សម្រាប់ស្ត្រី និងបុរស៣០ភាគរយ។ បន្ទាប់មកគឺកម្លាំងពលកម្មដែលបានបញ្ចប់កម្រិតថ្នាក់បឋមសិក្សា (២៥ភាគរយ) និងមិនមានការសិក្សា ឬសិក្សាតិចតួច (១៥ភាគរយ) សម្រាប់ស្ត្រី។ ទោះជាយ៉ាងណា ភាពខុសគ្នានៃកម្លាំងពលកម្មរវាងស្ត្រី និងបុរស ក្នុងកម្រិតខ្ពស់បំផុតនៅថ្នាក់ "មិនបញ្ចប់បឋមសិក្សា" "មិនមានការសិក្សា ឬសិក្សាតិចតួច" និង "បញ្ចប់កម្រិតថ្នាក់បឋមសិក្សា" មានប្រមាណ ៣០ភាគរយ ២៨ភាគរយ និង ១៦ភាគរយ តាមលំដាប់រៀង។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាងទី៦)

**តារាង៦.អត្រាចូលរួមកម្លាំងពលកម្ម អាយុ (១៥-៦៤ឆ្នាំ) បែងចែកតាមកម្រិតអប់រំ និងភេទឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| កំរិតសិក្សា និងភេទ | គ្មាន ឬមាន ការអប់រំត្រឹមតែតិចតួច | មិនបញ្ចប់បឋមសិក្សា | បញ្ចប់ បឋមសិក្សា | បញ្ចប់មធ្យមសិក្សាបឋមភូមិ | បញ្ចប់មធ្យមសិក្សាទុតិយភូមិ | ក្រោយ មធ្យមសិក្សា | សរុប |
|---|---|---|---|---|---|---|---|
| | | | ២០១៩/២០២០ | | | | |
| ស្ត្រី | ៦៨៤ | ១៥២៣ | ១១២៧ | ៦០២ | ២៨២ | ២៦៦ | ៤៤៨៤ |
| បុរស | ៤៣១ | ១៣៤១ | ១២៥៧ | ៧៣៨ | ៣៧២ | ៣៩៨ | ៤៥៣៧ |
| **ទាំងពីរភេទ** | **១១១៥** | **២៨៦៥** | **២៣៨៤** | **១៣៤០** | **៦៥៣** | **៦៦៣** | **៩០២០** |
| | | | ភាគរយ | | | | |
| ស្ត្រី | ១៥,២ | ៣៤,០ | ២៥,១ | ១៣,៤ | ៦,៣ | ៥,៩ | ១០០ |
| បុរស | ៩,៥ | ២៩,៦ | ២៧,៧ | ១៦,៣ | ៨,២ | ៨,៨ | ១០០ |
| **ទាំងពីរភេទ** | **១២,៤** | **៣១,៨** | **២៦,៤** | **១៤,៩** | **៧,២** | **៧,៤** | **១០០** |

## ៦.៥ ស្ថានភាពការងារ

នៅក្នុងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បច្ចុប្បន្នប្រជាជនដែលបានធ្វើការក្នុងកំលុងពេល៧ថ្ងៃកន្លងមកនៅក្នុងការរួមចំណែកសកម្មភាពគ្រួសាររបស់ពួកគេ ហើយប្រជាជនទាំងនេះកំពុងប្រតិបត្តិនៅក្នុងសហគ្រាសផ្ទាល់ខ្លួនរបស់ពួកគេ (ឧទាហរណ៍៖ កសិករដែលបង្កបង្កើនផលលើដីរបស់ពួកគាត់ផ្ទាល់ អ្នកលក់ដូរតូចតាច ឬអាហារដ្ឋានតូចៗ) ដែលគ្មានការបង់ថ្លៃ ឬជួលពីខាងក្រៅ ត្រូវបានចាត់ចំណាត់ថ្នាក់ជាអ្នកធ្វើការដោយប្រើទុនផ្ទាល់ខ្លួន ឬធ្វើការដោយខ្លួនឯង។ ការចាត់ចំណាត់ថ្នាក់សំខាន់ គឺមានឥទ្ធិពលដល់ស្ត្រី។

តារាង៧ បង្ហាញអំពីប្រជាជនដែលមានការងារធ្វើអាយុ១៥-៦៤ឆ្នាំ បែងចែកតាមស្ថានភាពការងារសម្រាប់ឆ្នាំ២០១៩/២០។ ស្ថានភាពការងារនៅក្នុងតារាងនានាផ្អែកសំខាន់លើមុខរបរ។ ក្នុងចំណោមស្ថានភាពការងារទាំងប្រាំប្រភេទ គឺមាននិយោជិតភាគច្រើនជាងគេ(៤៧ភាគរយ) បន្ទាប់មកកម្មករធ្វើការផ្ទាល់ខ្លួន (៣៨ភាគរយ) និងកម្មករធ្វើការតាមផ្ទះមិនយកប្រាក់ឈ្នួល (១៥ភាគរយ)។ ក្នុងចំណោមនិយោជិតទាំងអស់ទទួលបានប្រាក់ឈ្នួល គឺមានប្រមាណ៤១ភាគរយ (ស្ត្រី) និង៥៣ភាគរយ (បុរស)។ បន្ទាប់មកគឺអ្នកធ្វើការដោយប្រើទុនផ្ទាល់ខ្លួនមានប្រមាណ ៣៨ភាគរយសម្រាប់ស្ត្រី និងប្រមាណ ៣៧ភាគរយសម្រាប់បុរស។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង៧)

**តារាង៧. ស្ថានភាពការងារ មុខរបរចម្បងរបស់ប្រជាជនដែលមានអាយុ (១៥-៦៤ឆ្នាំ) បែងចែកតាមភេទ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ស្ថានភាពការងារ និង ភេទ | ចំនួន | | | ភាគរយ | | |
|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| និយោជិតទទួលប្រាក់ឈ្នួល | ១.៧៦៧ | ២.៣៨៣ | ៤.១៤៩ | ៤០,៩ | ៥៣,១ | ៤៧,១ |
| និយោជក | ១១ | ២៤ | ៣៥ | ០,៣ | ០,៥ | ០,៤ |
| អ្នកធ្វើការងារដោយប្រើទុនផ្ទាល់ខ្លួន | ១.៦៦៥ | ១.៦៦៥ | ៣.៣៣០ | ៣៨,៦ | ៣៧,១ | ៣៧,៨ |
| អ្នកធ្វើការឲ្យគ្រួសារគ្មានប្រាក់ឈ្នួល | ៨៧៤ | ៤១៤ | ១.២៨៨ | ២០,២ | ៩,២ | ១៤,៦ |
| ផ្សេងៗ/មិនដឹង | ១ | ២ | ៣ | ០,០ | ០,០ | ០,០ |
| សរុប | ៤.៣១៨ | ៤.៤៨៧ | ៨.៨០៥ | ១០០ | ១០០ | ១០០ |

តារាង៨ បង្ហាញអំពីចំនួនប្រជាជនដែលមានកម្មភាពធ្វើនៅក្នុងក្រុមអាយុ១៥-៦៤ឆ្នាំ បែងចែកតាមស្ថានភាពការងារភេទ និងតំបន់ភូមិសាស្ត្រនៅឆ្នាំ២០១៩/២០។ ផ្អែកលើមុខរបរចម្បង មិនរាប់បញ្ចូលលើអ្នកធ្វើការនៅរាជធានីភ្នំពេញអ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួលមានអត្រាខ្ពស់ (៦៦ភាគរយ) បើប្រៀបធៀបទៅនឹងទីប្រជុំជនផ្សេងៗ និងទីជនបទ។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាងទី៨)

**តារាង៨. ស្ថានភាពការងារ មុខរបរចម្បងរបស់ប្រជាជនដែលមានអាយុ (១៥-៦៤ឆ្នាំ) បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ស្ថានភាពការងារ និង តំបន់ភូមិសាស្ត្រ | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
| និយោជិតទទួលប្រាក់ឈ្នួល | ៤.១៤៩ | ៨៦៥ | ១.២៤៧ | ២.០៣៨ | ៤៧,១ | ៦៦,៣ | ៥៥,៧ | ៣៨,៧ |
| និយោជក | ៣៥ | ៤ | ១៣ | ១៩ | ០,៤ | ០,៣ | ០,៦ | ០,៤ |
| អ្នកធ្វើការងារដោយប្រើទុនផ្ទាល់ខ្លួន | ៣.៣៣០ | ៣៥៥ | ៧៤៦ | ២.២២៩ | ៣៧,៨ | ២៧,២ | ៣៣,៣ | ៤២,៤ |
| អ្នកធ្វើការឲ្យគ្រួសារគ្មានប្រាក់ឈ្នួល | ១.២៨៨ | ៨១ | ២៣៤ | ៩៧៣ | ១៤,៦ | ៦,២ | ១០,៤ | ១៨,៥ |
| ផ្សេងៗ/មិនដឹង | ៣ | ០ | ១ | ២ | ០,០ | ០,០ | ០,១ | ០,០ |
| សរុប | **៨.៨០៥** | **១.៣០៥** | **២.២៤០** | **៥.២៦០** | **១០០** | **១០០** | **១០០** | **១០០** |

ដូចបានឃើញក្នុងតារាង៩ ចំនួនអ្នកចូលរួមការងារមានអាយុ១៥-៦៤ឆ្នាំបែងចែកតាមភេទ និងតំបន់ភូមិសាស្ត្រនៅក្នុងឆ្នាំ២០១៩/២០។ ភាពខុសគ្នារវាងស្ត្រី និងបុរសនៅក្នុងស្ថានភាពការងារ "និយោជិតទទួលបានប្រាក់ឈ្នួល" មានប្រមាណ ១៣ភាគរយនៅរាជធានីភ្នំពេញ បើប្រៀបធៀបទៅនឹងនៅទីប្រជុំជនផ្សេងៗទៀតមាន៩ភាគរយ និងទីជនបទមាន១៣ភាគរយ។ ភាគខុសគ្នានេះគឺស្ត្រីមានអត្រាទាបជាងបុរស។ ក្រុមនិយោជិតដែលមានប្រាក់ឈ្នួល មានស្ថានភាពការងារ"អ្នកធ្វើការឱ្យគ្រួសារគ្មានប្រាក់ឈ្នួល" ស្ត្រីមានលក្ខណៈខ្ពស់ជាងបុរសនៅគ្រប់តំបន់ភូមិសាស្ត្រទាំងបីដែលមាន១១ភាគរយ នៅរាជធានីភ្នំពេញ(៤ភាគរយ) នៅទីប្រជុំជនផ្សេងៗ (៧ភាគរយ) និងនៅជនបទ (១៤ភាគរយ)។ ចំពោះកម្មករមិនយកប្រាក់ឈ្នួល និងកម្មករធ្វើការទុនផ្ទាល់ខ្លួនមានភាពស្រដៀងគ្នាដែរ គឺការចូលរួមកម្លាំងពលកម្មរបស់ស្ត្រីមានអត្រាខ្ពស់ជាងបុរសនៅគ្រប់តំបន់លើកលែងតែនៅតំបន់ជនបទ។(សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង៩)

**តារាង៩. ស្ថានភាពការងារ មុខរបរចម្បងរបស់ប្រជាជនដែលមានអាយុ(១៥-៦៤ឆ្នាំ) បែងចែកតាមតំបន់ភូមិសាស្ត្រ និងភេទ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ស្ថានភាពការងារ និង តំបន់ភូមិសាស្ត្រ | កម្ពុជា | | រាជធានីភ្នំពេញ | | ទីប្រជុំជនផ្សេងៗ | | ជនបទ | |
|---|---|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| | ចំនួន | | | | | | | |
| និយោជិតទទួលប្រាក់ឈ្នួល | ១.៧៦៧ | ២.៣៨៣ | ៣៧២ | ៤៩៣ | ៥៥០ | ៦៩៧ | ៨៤៥ | ១.១៩៣ |
| និយោជក | ១១ | ២៤ | ១ | ៣ | ៤ | ៨ | ៦ | ១២ |
| អ្នកធ្វើការងារដោយប្រើទុនផ្ទាល់ខ្លួន | ១.៦៦៥ | ១.៦៦៥ | ២០១ | ១៥៤ | ៣៧៥ | ៣៧១ | ១.០៩០ | ១.១៣៩ |
| អ្នកធ្វើការឲ្យគ្រួសារគ្មានប្រាក់ឈ្នួល | ៨៧៤ | ៤១៤ | ៥១ | ៣០ | ១៥៣ | ៨១ | ៦៧០ | ៣០៣ |
| ផ្សេងៗ/មិនដឹង | ១ | ២ | ០ | ០ | ១ | ០ | ០ | ១ |
| សរុប | **៤.៣១៨** | **៤.៤៨៧** | **៦២៤** | **៦៨១** | **១.០៨២** | **១.១៥៨** | **២.៦១២** | **២.៦៤៨** |
| | ភាគរយ | | | | | | | |
| និយោជិតទទួលប្រាក់ឈ្នួល | ៤០,៩ | ៥៣,១ | ៥៩,៦ | ៧២,៤ | ៥០,៨ | ៦០,២ | ៣២,៤ | ៤៥,០ |
| និយោជក | ០,៣ | ០,៥ | ០,១ | ០,៥ | ០,៤ | ០,៧ | ០,២ | ០,៥ |
| អ្នកធ្វើការងារដោយប្រើទុនផ្ទាល់ខ្លួន | ៣៨,៦ | ៣៧,១ | ៣២,២ | ២២,៧ | ៣៤,៦ | ៣២,១ | ៤១,៧ | ៤៣,០ |
| អ្នកធ្វើការឲ្យគ្រួសារគ្មានប្រាក់ឈ្នួល | ២០,២ | ៩,២ | ៨,១ | ៤,៥ | ១៤,១ | ៧,០ | ២៥,៧ | ១១,៥ |
| ផ្សេងៗ/មិនដឹង | ០,០ | ០,០ | ០,០ | ០,០ | ០,១ | ០,០ | ០,០ | ០,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ៦.៦ ការងារបែងចែកតាមមុខរបរ

ការងារបែងចែកតាមមុខរបរត្រូវបានបង្ហាញនៅក្នុងតារាង១០ខាងក្រោម។ លទ្ធផលបង្ហាញអំពីប្រជាជនដែលមានការងារធ្វើសរុបនៅក្នុងអាយុ១៥-៦៤ឆ្នាំ បែងចែកតាមមុខរបរចម្បងសម្រាប់ស្ត្រី និងបុរសក្នុងឆ្នាំ២០១៩/២០។ ចំនួនប្រជាជនកម្ពុជាមានប្រមាណមួយភាគបី (៣០ភាគរយ) ដែលមានការងារធ្វើជាបុគ្គលិកដែលមានជំនាញ ក្នុងវិស័យកសិកម្ម ព្រៃឈើ និងនេសាទ។ ក្នុងប្រទេសកម្ពុជាមានស្ត្រីប្រមាណ ៣៣ភាគរយ (នៃស្ត្រីទាំងអស់) បានធ្វើការក្នុងផ្នែកកសិកម្ម ព្រៃឈើនិងនេសាទ បើប្រៀបធៀបទៅនឹងបុរសមានតែ ២៨ភាគរយ។ នៅផ្នែកសេវាកម្ម និងអ្នកលក់ដូរ មានស្ត្រីច្រើនជាងបុរសជិតពីរដង (ស្ត្រីមានប្រមាណ ២៥ភាគរយ និងបុរស ១៣ភាគរយ)។ ប្រជាជនមានប្រមាណ ២៣ភាគរយ ដែលបានធ្វើការក្នុងផ្នែកសិប្បកម្ម និងការងារដែលទាក់ទង ក្នុងនោះស្ត្រីមាន ២២ភាគរយ និងបុរសមាន ២៤ភាគរយ។ នៅក្នុងប្រភេទមុខរបរបន្ថែមផ្សេងទៀតមានចំណែកតិចតួចបំផុត។ ការគណនា អំពីភាពខុសគ្នានៃចំនួនរវាងស្ត្រី និងបុរស គឺតិចតួចបំផុត។ លើកលែងតែការីបញ្ជាម៉ាស៊ីន ម៉ាស៊ីនរោងចក្រ និងអ្នកផ្គុំតម្លើង និងកម្លាំងប្រដាប់អាវុធ ដែលអត្រាចូលរួមរបស់បុរស និងស្ត្រី មានភាពខុសគ្នាគួរឱ្យកត់សម្គាល់។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១០)

**តារាង១០. អ្នកមានការងារធ្វើអាយុ (១៥-៦៤ឆ្នាំ) បែងចែកតាមមុខរបរចម្បង និងភេទ ឆ្នាំ២០១៩/២០**
**គិតជាពាន់នាក់ និងភាគរយ**

| មុខរបរចម្បង | ស្ត្រី | បុរស | ទាំងពីរភេទ |
|---|---|---|---|
| | | ចំនួន | |
| កម្លាំងប្រដាប់អាវុធ | ៥ | ៨៥ | ៩១ |
| អ្នកគ្រប់គ្រង | ៣៦ | ៦៤ | ១០១ |
| វិជ្ជាជីវៈ | ១៦២ | ១៧៣ | ៣៣៥ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរួមគ្នា | ៧៤ | ១៣០ | ២០៤ |
| ស្មៀន | ១៣៣ | ១៧៩ | ៣១២ |
| អ្នកធ្វើការខាងសេវាកម្ម និងអ្នកលក់ដូរ | ១.០៥៧ | ៥៦៣ | ១.៦២០ |
| អ្នកធ្វើការខាងជំនាញកសិកម្ម ព្រៃឈើ និងនេសាទ | ១.៤៣៣ | ១.២៣៩ | ២.៦៧២ |
| អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ៩៣០ | ១.០៨២ | ២.០១២ |
| ការីបញ្ជាម៉ាស៊ីនរោងចក្រនិងម៉ាស៊ីន និងអ្នកផ្គុំដំឡើង | ៣៨ | ៣៦៨ | ៤០៦ |
| មុខរបរងាយៗ | ៤៤៨ | ៦០៤ | ១.០៥២ |
| សរុប | **៤.៣១៨** | **៤.៤៨៧** | **៨.៨០៥** |
| | | ភាគរយ | |
| កម្លាំងប្រដាប់អាវុធ | ០,១ | ១,៩ | ១,០ |
| អ្នកគ្រប់គ្រង | ០,៨ | ១,៤ | ១,១ |
| វិជ្ជាជីវៈ | ៣,៧ | ៣,៩ | ៣,៨ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរួមគ្នា | ១,៧ | ២,៩ | ២,៣ |
| ស្មៀន | ៣,១ | ៤,០ | ៣,៥ |
| អ្នកធ្វើការខាងសេវាកម្ម និងអ្នកលក់ដូរ | ២៤,៥ | ១២,៥ | ១៨,៤ |
| អ្នកធ្វើការខាងជំនាញកសិកម្ម ព្រៃឈើ និងនេសាទ | ៣៣,២ | ២៧,៦ | ៣០,៣ |
| អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ២១,៥ | ២៤,១ | ២២,៩ |
| ការីបញ្ជាម៉ាស៊ីនរោងចក្រនិងម៉ាស៊ីន និងអ្នកផ្គុំដំឡើង | ០,៩ | ៨,២ | ៤,៦ |
| មុខរបរងាយៗ | ១០,៤ | ១៣,៥ | ១១,៩ |
| សរុប | **១០០** | **១០០** | **១០០** |

តារាង១១ បង្ហាញអំពីប្រជាជនដែលមានការងារធ្វើ បែងចែកតាមមុខរបរចម្បង និងតំបន់ភូមិសាស្ត្រ នៅក្នុងឆ្នាំ២០១៩/២០។ ចំណែកនៃប្រជាជនដែលមានការងារធ្វើ បែងចែកតាមមុខរបរចម្បង មានការប្រែប្រួលអាស្រ័យទៅតាមតំបន់ភូមិសាស្ត្រ។ លក្ខណៈមុខរបរផ្នែកអ្នកគ្រប់គ្រង និងស្មៀននៅរាជធានីភ្នំពេញ មានអត្រាខ្ពស់ជាងគេ បើប្រៀបធៀបទៅនឹងតំបន់ទីប្រជុំជន និងតំបន់ជនបទ ដែលមានអត្រា៣២ភាគរយសម្រាប់អ្នកធ្វើការខាងសេវាកម្ម និងអ្នកលក់ដូរ ១១ភាគរយសម្រាប់ស្មៀន ៨ភាគរយសម្រាប់វិជ្ជាជីវៈ ៦ភាគរយសម្រាប់ អ្នកបច្ចេកទេស និងវិជ្ជាជីវៈរួមគ្នា និងមាន ៣ភាគរយសម្រាប់អ្នកគ្រប់គ្រង។ អ្នកធ្វើការងារខាងជំនាញកសិកម្ម ព្រៃឈើ និងនេសាទ នៅតំបន់ទីប្រជុំជន និងជនបទ មានចំណែកភាគរយប្រមាណ ១៦ភាគរយ និង៤៤ភាគរយតាមលំដាប់រៀង។(សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១១)

**តារាង១១. អ្នកមានការងារធ្វើ ក្រុមអាយុ១៥-៦៤ឆ្នាំ បែងចែកតាមមុខរបរចម្បង និងតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| មុខរបរចម្បង | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| | | ចំនួន | | |
| កម្លាំងប្រដាប់អាវុធ | ៩១ | ២៨ | ៣០ | ៣៣ |
| អ្នកគ្រប់គ្រង | ១០១ | ៣៨ | ៣១ | ៣២ |
| វិជ្ជាជីវៈ | ៣៣៥ | ១០២ | ១១១ | ១២២ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរួមគ្នា | ២០៤ | ៧៩ | ៦៣ | ៦៣ |
| ស្មៀន | ៣១២ | ១៤៧ | ៩១ | ៧៤ |
| អ្នកធ្វើការខាងសេវាកម្ម និងអ្នកលក់ដូរ | ១.៦២០ | ៤១៥ | ៥៣៣ | ៦៧២ |
| អ្នកធ្វើការខាងជំនាញកសិកម្ម ព្រៃឈើ និងនេសាទ | ២.៦៧២ | ៩ | ៣៤៨ | ២.៣១៤ |
| អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ២.០១២ | ៣០៧ | ៦៤៩ | ១.០៥៦ |
| ការបញ្ជាម៉ាស៊ីនរោងចក្រនិងម៉ាស៊ីន និងអ្នកផ្គុំដំឡើង | ៤០៦ | ៨៩ | ១៣៦ | ១៨១ |
| មុខរបរងាយៗ | ១.០៥២ | ៩១ | ២៤៨ | ៧១៣ |
| សរុប | **៨.៨០៥** | **១.៣០៥** | **២.២៤០** | **៥.២៦០** |
| | | ភាគរយ | | |
| កម្លាំងប្រដាប់អាវុធ | ១,០ | ២,២ | ១,៣ | ០,៦ |
| អ្នកគ្រប់គ្រង | ១,១ | ២,៩ | ១,៤ | ០,៦ |
| វិជ្ជាជីវៈ | ៣,៨ | ៧,៨ | ៤,៩ | ២,៣ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរួមគ្នា | ២,៣ | ៦,០ | ២,៨ | ១,២ |
| ស្មៀន | ៣,៥ | ១១,៣ | ៤,០ | ១,៤ |
| អ្នកធ្វើការខាងសេវាកម្ម និងអ្នកលក់ដូរ | ១៨,៤ | ៣១,៨ | ២៣,៨ | ១២,៨ |
| អ្នកធ្វើការខាងជំនាញកសិកម្ម ព្រៃឈើ និងនេសាទ | ៣០,៣ | ០,៧ | ១៥,៦ | ៤៤,០ |
| អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ២២,៩ | ២៣,៥ | ២៩,០ | ២០,១ |
| ការបញ្ជាម៉ាស៊ីនរោងចក្រនិងម៉ាស៊ីន និងអ្នកផ្គុំដំឡើង | ៤,៦ | ៦,៨ | ៦,១ | ៣,៤ |
| មុខរបរងាយៗ | ១១,៩ | ៧,០ | ១១,១ | ១៣,៦ |
| សរុប | **១០០** | **១០០** | **១០០** | **១០០** |

ចំណែកនៃប្រជាជនដែលមានការងារធ្វើ បែងចែកតាមមុខរបរចម្បងនៅតាមតំបន់ភូមិសាស្ត្រ (រាជធានីភ្នំពេញ ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទ) និងតាមភេទ ត្រូវបានបង្ហាញនៅក្នុងតារាង១២។ នៅក្នុងប្រទេសកម្ពុជា ចំណែកនៃការងារបែងចែកតាមមុខរបរមានការខុសគ្នារវាងស្ត្រី និងបុរស។ ភាពខុសគ្នាខ្លាំងរវាងស្ត្រី និងបុរស គឺស្ត្រីដែលធ្វើការនៅក្នុងមុខរបរខាងសេវាកម្ម និងអ្នកលក់ដូរ មានជិតពីរដងច្រើនជាងចំណែកនៃបុរស។

នៅតាមតំបន់ជនបទ អ្នកធ្វើការខាងជំនាញកសិកម្ម ព្រៃឈើនិងនេសាទ មានលក្ខណៈខុសគ្នាច្រើនរវាងអ្នកនៅរាជធានីភ្នំពេញ និងតាមទីប្រជុំជនផ្សេងៗដទៃទៀត សម្រាប់ស្ត្រី និងបុរស មានប្រមាណ៤៨ភាគរយ និង៤០ភាគរយ តាមលំដាប់រៀងៗ។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាងទី១២)

**តារាង១២. អ្នកមានការងារធ្វើក្រុមអាយុ១៥-៦៤ឆ្នាំ បែងចែកតាមមុខរបរចម្បង និងតំបន់ភូមិសាស្ត្រ និងតាមភេទ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| មុខរបរចម្បង | កម្ពុជា | | រាជធានីភ្នំពេញ | | ទីប្រជុំជនផ្សេងៗ | | ជនបទ | |
|---|---|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| | | | | ចំនួន | | | | |
| កម្លាំងប្រដាប់អាវុធ | ៥ | ៨៥ | ១ | ២៧ | ២ | ២៧ | ២ | ៣២ |
| អ្នកគ្រប់គ្រង | ៣៦ | ៦៤ | ១៩ | ១៩ | ១០ | ២២ | ៨ | ២៣ |
| វិជ្ជាជីវៈ | ១៦២ | ១៧៣ | ៤៥ | ៥៧ | ៥១ | ៥៩ | ៦៥ | ៥៧ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរួមគ្នា | ៧៤ | ១៣០ | ២៦ | ៥២ | ២៥ | ៣៩ | ២៣ | ៣៩ |
| ស្មៀន | ១៣៣ | ១៧៩ | ៥៤ | ៩៣ | ៤៣ | ៤៨ | ៣៥ | ៣៩ |
| អ្នកធ្វើការខាងសេវាកម្ម និងអ្នកលក់ដូរ | ១.០៥៧ | ៥៦៣ | ២៦៨ | ១៤៧ | ៣៣៤ | ២០០ | ៤៥៥ | ២១៦ |
| អ្នកធ្វើការខាងជំនាញកសិកម្ម ព្រៃឈើ និងនេសាទ | ១.៤៣៣ | ១.២៣៩ | ៤ | ៦ | ១៨១ | ១៦៧ | ១.២៤៩ | ១.០៦៦ |
| អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ៩៣០ | ១.០៨២ | ១៥៩ | ១៤៨ | ៣១៥ | ៣៣៤ | ៤៥៦ | ៦០០ |
| ការិបញ្ជាម៉ាស៊ីនរោងចក្រនិងម៉ាស៊ីន និងអ្នកផ្គុំដម្លើង | ៣៨ | ៣៦៨ | ៥ | ៨៤ | ១៣ | ១២៤ | ២០ | ១៦១ |
| មុខរបរងាយៗ | ៤៤៨ | ៦០៤ | ៤១ | ៤៩ | ១០៩ | ១៣៩ | ២៩៨ | ៤១៥ |
| សរុប | **៤.៣១៨** | **៤.៤៨៧** | **៦២៤** | **៦៨១** | **១.០៨២** | **១.១៥៨** | **២.៦១២** | **២.៦៤៨** |
| | | | | ភាគរយ | | | | |
| កម្លាំងប្រដាប់អាវុធ | ០,១ | ១,៩ | ០,២ | ៣,៩ | ០,២ | ២,៣ | ០,១ | ១,២ |
| អ្នកគ្រប់គ្រង | ០,៨ | ១,៤ | ៣,០ | ២,៨ | ០,៩ | ១,៩ | ០,៣ | ០,៩ |
| វិជ្ជាជីវៈ | ៣,៧ | ៣,៩ | ៧,៣ | ៨,៣ | ៤,៧ | ៥,១ | ២,៥ | ២,២ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរួមគ្នា | ១,៧ | ២,៩ | ៤,២ | ៧,៧ | ២,៣ | ៣,៣ | ០,៩ | ១,៥ |
| ស្មៀន | ៣,១ | ៤,០ | ៨,៧ | ១៣,៦ | ៤,០ | ៤,១ | ១,៤ | ១,៥ |
| អ្នកធ្វើការខាងសេវាកម្ម និងអ្នកលក់ដូរ | ២៤,៥ | ១២,៥ | ៤៣,០ | ២១,៥ | ៣០,៨ | ១៧,៣ | ១៧,៤ | ៨,២ |
| អ្នកធ្វើការខាងជំនាញកសិកម្ម ព្រៃឈើ និងនេសាទ | ៣៣,២ | ២៧,៦ | ០,៦ | ០,៨ | ១៦,៧ | ១៤,៤ | ៤៧,៨ | ៤០,២ |
| អ្នកធ្វើការខាងសិប្បកម្ម និងការងារដែលទាក់ទង | ២១,៥ | ២៤,១ | ២៥,៥ | ២១,៧ | ២៩,១ | ២៨,៨ | ១៧,៤ | ២២,៧ |
| ការិបញ្ជាម៉ាស៊ីនរោងចក្រនិងម៉ាស៊ីន និងអ្នកផ្គុំដម្លើង | ០,៩ | ៨,២ | ០,៨ | ១២,៣ | ១,២ | ១០,៧ | ០,៨ | ៦,១ |
| មុខរបរងាយៗ | ១០,៤ | ១៣,៥ | ៦,៦ | ៧,២ | ១០,០ | ១២,០ | ១១,៤ | ១៥,៧ |
| សរុប | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |

## ៦.៧ ការងារបែងចែកតាមវិស័យសេដ្ឋកិច្ច

នៅក្នុងតារាង១៣ បានបង្ហាញអំពីអ្នកមានការងារធ្វើ បែងចែកតាមវិស័យសេដ្ឋកិច្ច(មុខរបរចម្បង)។ អត្រាអ្នកមានការងារធ្វើ នៅក្នុងវិស័យសេវាកម្ម និងវិស័យកសិកម្មក្នុងឆ្នាំ២០១៩/២០ មានអត្រា ៣៨ភាគរយ និង

៣៦ភាគរយ តាមលំដាប់រៀង។ ជាទូទៅអត្រាអ្នកមានការងារធ្វើ រវាងស្ត្រី និងបុរសនៅក្នុងវិស័យសេដ្ឋកិច្ចទាំងបីនេះមានភាពខុសគ្នាបន្តិចបន្តួច។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១៣)

**តារាង១៣. អ្នកមានការងារធ្វើ ក្រុមអាយុ១៥-៦៤ឆ្នាំ បែងចែកតាមវិស័យសេដ្ឋកិច្ច(មុខរបរ ចម្បង) និងភេទ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| វិស័យសេដ្ឋកិច្ច (មុខរបរចម្បង) | ចំនួន | | | ភាគរយ | | |
|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| កសិកម្ម (វិស័យទី១) | ១.៦៤៣ | ១.៤៨១ | ៣.១២៣ | ៣៨,០ | ៣៣,០ | ៣៥,៥ |
| ឧស្សាហកម្ម (វិស័យទី២) | ១.០៤៤ | ១.២៥៤ | ២.២៩៧ | ២៤,២ | ២៧,៩ | ២៦,១ |
| សេវាកម្ម (វិស័យទី៣) | ១.៦៣២ | ១.៧៥៣ | ៣.៣៨៤ | ៣៧,៨ | ៣៩,១ | ៣៨,៤ |
| សរុប | **៤.៣១៨** | **៤.៤៨៧** | **៨.៨០៥** | **១០០** | **១០០** | **១០០** |

តារាង១៤ បង្ហាញអំពីអ្នកមានការងារធ្វើ បែងចែកតាមវិស័យសេដ្ឋកិច្ច និងតំបន់ភូមិសាស្ត្រសម្រាប់ឆ្នាំ ២០១៩/២០។ ដូចការគិតទុកមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងតំបន់ភូមិសាស្ត្រនានា។ ចំណែកអ្នកមានការងារធ្វើនៅក្នុងវិស័យសេវាកម្ម នៅក្នុងរាជធានីភ្នំពេញ និងតំបន់ទីប្រជុំជនផ្សេងៗ មានភាគរយខ្ពស់បំផុត គឺមាន ៧៣ ភាគរយ និង ៤៩ភាគរយ តាមលំដាប់រៀង។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១៤)

**តារាង១៤. អ្នកមានការងារធ្វើ អាយុ១៥-៦៤ឆ្នាំ បែងចែកតាមវិស័យសេដ្ឋកិច្ច (មុខរបរចម្បង) និងតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| វិស័យសេដ្ឋកិច្ច (មុខរបរចម្បង) | ចំនួន | | | | ភាគរយ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
| កសិកម្ម (វិស័យទី១) | ៣.១២៣ | ១២ | ៤១០ | ២.៧០២ | ៣៥,៥ | ០,៩ | ១៨,៣ | ៥១,៤ |
| ឧស្សាហកម្ម (វិស័យទី២) | ២.២៩៧ | ៣៤០ | ៧៣៨ | ១.២១៩ | ២៦,១ | ២៦,១ | ៣៣,០ | ២៣,២ |
| សេវាកម្ម (វិស័យទី៣) | ៣.៣៨៤ | ៩៥៣ | ១.០៩២ | ១.៣៣៩ | ៣៨,៤ | ៧៣,០ | ៤៨,៨ | ២៥,៥ |
| សរុប | ៨.៨០៥ | ១.៣០៥ | ២.២៤០ | ៥.២៦០ | ១០០ | ១០០ | ១០០ | ១០០ |

រូបភាព៣៤ បង្ហាញអំពីលទ្ធផលចំនួនប្រជាជននៅក្នុងក្រុមអាយុធ្វើការងារ១៥-៦៤ឆ្នាំសម្រាប់ឆ្នាំ២០០៩ ដល់២០១៧ និងឆ្នាំ២០១៩/២០តាមវិស័យសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ២០០៩ អ្នកមានការងារធ្វើនៅក្នុងវិស័យកសិកម្មមានការថយចុះគួរឱ្យកត់សម្គាល់ នៅខណៈពេលអ្នកមានការងារធ្វើនៅក្នុង វិស័យឧស្សាហកម្ម និងសេវាកម្មមានការកើនឡើងជាលំដាប់ក្នុងរយៈពេល៩ឆ្នាំកន្លងមក។ (សម្រាប់ព័ត៌មានលម្អិតសូមមើលរូបភាព៣៤)

រូបភាព៤. អ្នកមានការងារធ្វើក្រុមអាយុ ១៥-៦៤ឆ្នាំ បែងចែកតាមវិស័យសេដ្ឋកិច្ច ឆ្នាំ២០០៩-២០១៩/២០ ជាភាគរយ




តារាង១៥ បង្ហាញអំពីអ្នកមានការងារធ្វើ បែងចែកតាមវិស័យសេដ្ឋកិច្ច តាមតំបន់ភូមិសាស្ត្រ និងភេទ។ ចំពោះស្ត្រី និងបុរស ដែលធ្វើការងារក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម គឺមានភាពខុសគ្នាបន្តិចបន្តួច នៅក្នុងតំបន់ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទ។ នៅក្នុងរាជធានីភ្នំពេញមានភាពខុសគ្នារវាងស្ត្រី និងបុរស (យេនឌ័រ) ដោយសារស្ត្រីមានការងារធ្វើមានសមាមាត្រខ្ពស់ជាងបុរសនៅក្នុងវិស័យឧស្សាហកម្មមានប្រមាណ ២៧ ភាគរយ ធៀបនឹងបុរស២៥ភាគរយ។ ចំណែកស្ត្រីធ្វើការក្នុងវិស័យសេវាកម្ម គឺមានអត្រាទាបជាងបុរស (ស្ត្រី ៧២ភាគរយ បើប្រៀបធៀបទៅនឹងបុរស ៧៤ភាគរយ) នៅរាជធានីភ្នំពេញ។ ចំពោះនៅតំបន់ទីប្រជុំជន និងទីជនបទ គឺពុំមានភាពខុសគ្នាខាងយេនឌ័រ(ប្រហាក់ប្រហែលគ្នា) នៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មនោះទេ។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១៥)

**តារាង១៥. អ្នកមានការងារធ្វើ ក្រុមអាយុ១៥-៦៤ឆ្នាំ បែងចែកតាមវិស័យសេដ្ឋកិច្ច (មុខរបរចម្បង) តំបន់ភូមិសាស្ត្រ និងភេទ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| វិស័យសេដ្ឋកិច្ច (មុខរបរចម្បង) | កម្ពុជា | | រាជធានីភ្នំពេញ | | ទីប្រជុំជនផ្សេងៗ | | ជនបទ | |
|---|---|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| | | | | ចំនួន | | | | |
| កសិកម្ម (វិស័យទី១) | ១.៦៤៣ | ១.៤៨១ | ៧ | ៥ | ២០៩ | ២០០ | ១.៤២៦ | ១.២៧៦ |
| ឧស្សាហកម្ម (វិស័យទី២) | ១.០៤៤ | ១.២៥៤ | ១៦៩ | ១៧១ | ៣៥០ | ៣៨៨ | ៥២៤ | ៦៩៥ |
| សេវាកម្ម (វិស័យទី៣) | ១.៦៣២ | ១.៧៥៣ | ៤៤៨ | ៥០៥ | ៥២៣ | ៥៧០ | ៦៦២ | ៦៧៨ |
| សរុប | ៤.៣១៨ | ៤.៤៨៧ | ៦២៤ | ៦៨១ | ១.០៨២ | ១.១៥៨ | ២.៦១២ | ២.៦៤៨ |
| | | | | ភាគរយ | | | | |
| កសិកម្ម (វិស័យទី១) | ៣៨,០ | ៣៣,០ | ១,១ | ០,៧ | ១៩,៣ | ១៧,៣ | ៥៤,៦ | ៤៨,២ |
| ឧស្សាហកម្ម (វិស័យទី២) | ២៤,២ | ២៧,៩ | ២៧,១ | ២៥,១ | ៣២,៤ | ៣៣,៥ | ២០,១ | ២៦,២ |
| សេវាកម្ម (វិស័យទី៣) | ៣៧,៨ | ៣៩,១ | ៧១,៨ | ៧៤,២ | ៤៨,៣ | ៤៩,២ | ២៥,៣ | ២៥,៦ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ៦.៨ ការងារមានប្រាក់ឈ្នួលរបស់ស្ត្រី

តារាង១៦ បង្ហាញអំពីប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារដែលមានអាយុចាប់ពី១៨ឆ្នាំឡើង នៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មក្នុងឆ្នាំ២០១៩/២០។ នៅក្នុងប្រទេសកម្ពុជា ប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យឧស្សាហកម្ម មានប្រមាណ២៥ភាគរយ បន្ទាប់មកវិស័យកសិកម្មមាន ៣៦ភាគរយ និងវិស័យសេវាកម្មមាន៣៩ភាគរយ។ នៅរាជធានីភ្នំពេញ ការងារមានប្រាក់ឈ្នួលរបស់ស្ត្រីក្នុងវិស័យសេវាកម្ម មានចំណែកច្រើន (៧៣ភាគរយ) បើប្រៀបធៀបនឹងតំបន់ពីរផ្សេងទៀត។ វិស័យឧស្សាហកម្មក៏ជាវិស័យបន្ទាប់ដែលស្ត្រីបានចូលរួមចំណែកក្នុងកម្មភាពប្រាក់ឈ្នួល។ ទោះជាយ៉ាងណា ចំណែកភាគនៃការងារមានប្រាក់ឈ្នួលរបស់ស្ត្រី មានកម្រិតខ្ពស់ស្ថិតក្នុងវិស័យកសិកម្មនៅតំបន់ជនបទ។ ចំណែកការងារមានប្រាក់ឈ្នួលរបស់ស្ត្រីនៅតំបន់ទីប្រជុំជន ក្នុងវិស័យសេវាកម្មមានប្រមាណ៤៩ភាគរយ និង វិស័យឧស្សាហកម្មមានប្រមាណ ៣២ភាគរយ។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១៦)

**តារាង១៦. ប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារ អាយុ១៨ឆ្នាំឡើង បែងចែកតាមវិស័យសេដ្ឋកិច្ច (មុខរបរចម្បង) និងតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ស្ត្រីចូលរួមការងារតាមវិស័យ និងតំបន់ភូមិសាស្ត្រ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| | | ចំនួន | | |
| កសិកម្ម (វិស័យទី១) | ១.៤១៩ | ៧ | ១៩០ | ១.២២១ |
| ឧស្សាហកម្ម (វិស័យទី២) | ៩៧៩ | ១៦០ | ៣២៨ | ៤៩១ |
| សេវាកម្ម (វិស័យទី៣) | ១.៥៦១ | ៤៥៣ | ៥០០ | ៦០៨ |
| សរុប | **៣.៩៦០** | **៦២០** | **១.០១៩** | **២.៣២១** |
| | | ភាគរយ | | |
| កសិកម្ម (វិស័យទី១) | ៣៥,៨ | ១,២ | ១៨,៧ | ៥២,៦ |
| ឧស្សាហកម្ម (វិស័យទី២) | ២៤,៧ | ២៥,៧ | ៣២,២ | ២១,២ |
| សេវាកម្ម (វិស័យទី៣) | ៣៩,៤ | ៧៣,១ | ៤៩,១ | ២៦,២ |
| សរុប | **១០០** | **១០០** | **១០០** | **១០០** |

តារាង១៧ បង្ហាញអំពីប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅ នៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មនៅក្នុងឆ្នាំ២០១៩/២០។ ដូចបានបង្ហាញនៅក្នុងតារាង១៧ ប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យនីមួយៗ(កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម) គឺមិនមានការផ្លាស់ប្តូរទេ បើប្រៀបធៀបទៅនឹងប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារដែលបានពិពណ៌នានៅក្នុងតារាង១៦ ទោះបីប្រាក់ឈ្នួលការងាររបស់ប្រជាជនដែលមានអាយុ៥-១៧ឆ្នាំ ក៏ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងផងដែរ។ (ព័ត៌មានលម្អិតសូមមើលតារាង១៧)

**តារាង១៧. ប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារ អាយុ៥ឆ្នាំឡើង បែងចែកតាមវិស័យសេដ្ឋកិច្ច (មុខរបរចម្បង) និងតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ស្ត្រីចូលរួមការងារតាមវិស័យ និងតំបន់ភូមិសាស្ត្រ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| | | ចំនួន | | |
| កសិកម្ម (វិស័យទី១) | ១.៥២២ | ៨ | ២០៤ | ១.៣១០ |
| ឧស្សាហកម្ម (វិស័យទី២) | ១.០៣០ | ១៦៨ | ៣៤២ | ៥២០ |
| សេវាកម្ម (វិស័យទី៣) | ១.៦២៤ | ៤៥៦ | ៥២៤ | ៦៤៤ |
| សរុប | ៤.១៧៦ | ៦៣៣ | ១.០៦៩ | ២.៤៧៤ |
| | | ភាគរយ | | |
| កសិកម្ម (វិស័យទី១) | ៣៦.៤ | ១,៣ | ១៩,១ | ៥២,៩ |
| ឧស្សាហកម្ម (វិស័យទី២) | ២៤.៧ | ២៦,៦ | ៣១,៩ | ២១,០ |
| សេវាកម្ម (វិស័យទី៣) | ៣៨.៩ | ៧២,១ | ៤៩,០ | ២៦,០ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

តារាង១៨ បង្ហាញអំពីប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារ ដែលមានអាយុចាប់ពី១៥-៦៤ឆ្នាំ ក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មក្នុងឆ្នាំ២០១៩/២០។ ដូចបង្ហាញនៅក្នុងតារាង១៨ អំពីប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យនីមួយៗ(កសិកម្ម ឧស្សាហកម្មនិងសេវាកម្ម) គឺមិនមានការផ្លាស់ប្តូរទេ បើប្រៀបធៀបទៅនឹងប្រាក់ឈ្នួលរបស់ស្ត្រី ដែលបានបង្ហាញក្នុងតារាង១៦ និង១៧ ទោះបីប្រាក់ឈ្នួលការងាររបស់ប្រជាជនក្នុងក្រុមអាយុពី៥-១៤ឆ្នាំ និងប្រាក់ឈ្នួលការងាររបស់ប្រជាជនដែលមានអាយុចាប់ពី៦៥ឆ្នាំឡើងទៅ ដែលមិនត្រូវបានរាប់បញ្ចូលក្នុងការគណនាវាស់វែងនោះទេ។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១៨)

**តារាង១៨. ប្រាក់ឈ្នួលរបស់ស្ត្រីចូលរួមក្នុងវិស័យការងារ អាយុ(១៥-៦៤ឆ្នាំ)បែងចែកតាមវិស័យ សេដ្ឋកិច្ច (មុខរបរចម្បង) និងតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| ស្ត្រីចូលរួមការងារតាមវិស័យ និងតំបន់ភូមិសាស្ត្រ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---|---|---|---|
| | | ចំនួន | | |
| កសិកម្ម (វិស័យទី១) | ១.៣៥១ | ៧ | ១៧៤ | ១.១៧០ |
| ឧស្សាហកម្ម (វិស័យទី២) | ១.០១៣ | ១៦៦ | ៣៣៩ | ៥០៨ |
| សេវាកម្ម (វិស័យទី៣) | ១.៥៤៨ | ៤៤៤ | ៤៩៦ | ៦០៨ |
| សរុប | ៣.៩១៣ | ៦១៨ | ១.០០៩ | ២.២៨៧ |
| | | ភាគរយ | | |
| កសិកម្ម (វិស័យទី១) | ៣៤,៥ | ១,១ | ១៧,៣ | ៥១,២ |
| ឧស្សាហកម្ម (វិស័យទី២) | ២៥,៩ | ២៦,៩ | ៣៣,៦ | ២២,២ |
| សេវាកម្ម (វិស័យទី៣) | ៣៩,៦ | ៧១,៩ | ៤៩,២ | ២៦,៦ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

## ៦.៩ ការងាររបស់កុមារ

តារាង១៩ បង្ហាញអំពីភាគរយនៃចំនួនកុមារដែលបានធ្វើការ។ ក្នុងចំនួនប្រជាជនដែលមានអាយុពី៥-១៧ឆ្នាំ ក្នុងឆ្នាំ២០១៩/២០។ កុមារចូលរួមការងារមានប្រមាណ ១៨ភាគរយ និងកុមារដែលមិនស្ថិតនៅក្នុងកម្លាំងពលកម្មមាន ៨២ភាគរយ។ យើងសង្កេតឃើញថាការចូលរួមការងារកុមារស្រី និងប្រុស គឺពុំមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ទេ។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង១៩)

**តារាង១៩. កុមារចូលរួមក្នុងការងារអាយុ៥-១៧ឆ្នាំ បែងចែកតាមភេទ ឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និង ភាគរយ**

| កុមារចូលរួមការងារ | ក្មេងស្រី | ក្មេងប្រុស | ទាំងពីរភេទ | ក្មេងស្រី | ក្មេងប្រុស | ទាំងពីរភេទ |
|---|---|---|---|---|---|---|
| | | ចំនួន | | | ភាគរយ | |
| កុមារចូលរួមការងារ | ៣២៥ | ៤១៦ | ៧៤១ | ១៦,៤ | ១៩,៩ | ១៨,២ |
| កុមារមិនស្ថិតក្នុងកម្លាំងពលកម្ម | ១.៦៦៣ | ១.៦៧៦ | ៣.៣៣៩ | ៨៣,៦ | ៨០,១ | ៨១,៨ |
| សរុប | **១.៩៨៩** | **២.០៩២** | **៤.០៨១** | **១០០** | **១០០** | **១០០** |

តារាង២០ បង្ហាញអំពីនិន្នាការថយចុះនៃចំនួនកុមារដែលធ្វើការក្នុងរយៈពេលប្រាំពីរឆ្នាំកន្លងនេះ។ ចំនួនកុមារដែលបានធ្វើការក្នុងឆ្នាំ២០១២ មានប្រមាណ២៤ភាគរយ និងថយចុះមកនៅត្រឹម១៨ភាគរយក្នុងឆ្នាំ២០១៩/២០។ អត្រានៃកុមារដែលបានធ្វើការបានថយចុះ ៦ភាគរយ ក្នុងរយៈពេល៧ឆ្នាំកន្លងមក។ (សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង២០)

**តារាង២០. កុមារចូលរួមក្នុងការងារ អាយុ៥-១៧ឆ្នាំ ពីឆ្នាំ២០១២-២០១៩/២០ ភាគរយ**

| កុមារចូលរួមការងារ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
|---|---|---|---|---|---|---|---|
| កុមារចូលរួមការងារ | ២៣,៦ | ១៨,៤ | ១៩,៣ | ១៩,៣ | ១៨,៥ | ១៨,៦ | ១៨,២ |
| កុមារមិនស្ថិតក្នុងកម្លាំងពលកម្ម | ៧៦,៤ | ៨១,៦ | ៨០,៧ | ៨០,៧ | ៨១,៥ | ៨១,៤ | ៨១,៨ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

តារាង២១ បង្ហាញអំពីចំនួនកុមារដែលកំពុងធ្វើការមានក្រុមអាយុ៥-១៧ឆ្នាំ កំពុងសិក្សាក្នុងពេលបច្ចុប្បន្ន។ ផ្អែកលើលទ្ធផលអង្កេតបានបង្ហាញថាកុមារមានប្រមាណ ៥២ភាគរយ ដែលកំពុងធ្វើការផង និងសិក្សាផង។ នៅកម្ពុជាចំនួនកុមារមានប្រមាណ ៤៨ភាគរយ ដែលកំពុងធ្វើការតែមិនបានសិក្សា ក្នុងនោះមានស្រី ៤៦ភាគរយ និងប្រុស ៤៩ភាគរយ។(សម្រាប់ព័ត៌មានលម្អិតសូមមើលតារាង២១)

**តារាង២១. កុមារចូលរួមក្នុងការងារ ក្រុមអាយុ៥-១៧ឆ្នាំ បច្ចុប្បន្នកំពុងសិក្សាឆ្នាំ២០១៩/២០ គិតជាពាន់នាក់ និងភាគរយ**

| កុមារចូលរួមការងារ និង ភេទ | ស្រី | ប្រុស | ទាំងពីរភេទ | ស្រី | ប្រុស | ទាំងពីរភេទ |
|---|---|---|---|---|---|---|
| | | ចំនួន | | | ភាគរយ | |
| កុមារធ្វើការងារផងសិក្សាផង | ២០៣ | ១៦៩ | ៣៧៣ | ៥១,១ | ៥៣,៧ | ៥២,៣ |
| កុមារធ្វើការងារមិនបានសិក្សា | ១៩៥ | ១៤៦ | ៣៤០ | ៤៨,៩ | ៤៦,៣ | ៤៧,៧ |
| សរុប | ៣៩៨ | ៣១៥ | ៧១៣ | ១០០ | ១០០ | ១០០ |

# ផ្នែកទី៧ សុខភាព និងជនមានពិការភាព

## ៧.១ សេចក្តីផ្តើម

នៅក្នុងផ្នែកនេះ មានការបង្ហាញទិន្នន័យសំខាន់ៗ ស្តីពីពិការភាព ជំងឺ និងការស្វែងរកការថែទាំសុខភាព។ ទិន្នន័យស្តីពីសុខភាពមាតា មិនត្រូវបានប្រមូលនៅក្នុងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ទេ ពីព្រោះមានសំណួរស្រដៀងគ្នាហើយមានលក្ខណៈលម្អិតជាងបានដាក់បញ្ចូល ដើម្បីសួរនៅក្នុងអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០១៤ ផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏លទ្ធផលមួយចំនួនអាចធ្វើការប្រៀបធៀបគ្នាបាននៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ ២០១៤ និងឆ្នាំ២០១៩/២០ ដែលត្រូវបានបរិយាយនៅក្នុងរបាយការណ៍អង្កេតនេះ។

ការសម្ភាសស្តីពីបញ្ហាសុខភាព ត្រូវបានធ្វើឡើងដោយមន្ត្រីសម្ភាសន៍ដែលទទួលបានការបណ្តុះបណ្តាល ក៏ប៉ុន្តែអ្នកទាំងនោះមិនមានជំនាញវិជ្ជាពេទ្យទេ។ សំណួរផ្នែកសុខភាពត្រូវបានសួរក្នុងខែសម្ភាសន៍នៃការធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០។ កម្រងសំណួរផ្នែកសុខភាពត្រូវបានបែងចែកជាបីផ្នែកគឺៈ "ការស្វែងរកការថែទាំសុខភាព និងការចំណាយ" "សុខភាពកុមារ" និង "ពិការភាព"។

### ការផ្តល់សេវាផ្នែកសុខភាព

គឺសំដៅដល់ការផ្តល់សេវាសុខភាពលើកដំបូង ដែលត្រូវបានពិគ្រោះដោយសារហេតុផល សុខភាព ហើយប្រសិនបើមានការពិគ្រោះជំងឺលើសពីម្តង ត្រូវបានធ្វើឡើងនៅក្នុងរយៈពេល៣០ថ្ងៃកន្លងមក មានន័យថាសំដៅដល់ការផ្តល់សេវានាពេលថ្មីៗបំផុត/ពេលចុងក្រោយបំផុត។ ការផ្តល់សេវាសុខភាព ត្រូវបានផ្តុំជាប្រាំក្រុមដូចខាងក្រោម ៖

- ផ្នែកសេវាសាធារណៈ៖
    - មន្ទីរពេទ្យជាតិ
    - មន្ទីរពេទ្យបង្អែកខេត្ត
    - មន្ទីរពេទ្យបង្អែកស្រុក
    - មណ្ឌលសុខភាព
    - ប៉ុស្តិ៍សុខភាព
    - មណ្ឌលស្តារនិតិសម្បទាខេត្ត/មណ្ឌលស្តារនិតិសម្បទាសហគមន៍
    - ផ្នែកសាធារណៈផ្សេងៗ (ដែលបានសរសេរបញ្ជាក់)
- ផ្នែកសេវាឯកជន៖
    - មន្ទីរពេទ្យឯកជន
    - គ្លីនិកឯកជន
    - ឱសថស្ថានឯកជន
- ការព្យាបាលដោយខ្លួនឯង៖
    - នៅផ្ទះ/ការិយាល័យរបស់បុគ្គលិកសុខាភិបាល/គិលានុប្បដ្ឋាកដែលបានបណ្តុះបណ្តាល

- ការចុះត្រួតពិនិត្យរបស់បុគ្គលិកសុខាភិបាល/គិលានុប្បដ្ឋាក
- សេវាពេទ្យឯកជនផ្សេងៗ (ដែលបានសរសេរបញ្ជាក់)
- តូបលក់ថ្នាំពេទ្យ/ផ្សារ

- ការព្យាបាលតាមបែបបុរាណៈ
  - គ្រូខ្មែរ/គ្រូមន្តអាគម
  - លោកសង្ឃ/មេសាសនា
  - ឆ្មបបុរាណ
- ផ្នែកសេវាព្យាបាលនៅក្រៅប្រទេស
  - សេវាពេទ្យនៅក្រៅប្រទេស

## ៧.២ ជនមានពិការភាព

### ជនមានពិការភាពក្នុងចំណោមប្រជាជន(នៅក្នុងគ្រួសារធម្មតា)

ជនមានពិការភាពត្រូវបានឱ្យនិយមន័យថា ជាឧបសគ្គ ឬក៏ជាកង្វះខាតផ្នែកសមត្ថភាពណាមួយក្នុងការអនុវត្តសកម្មភាពនៅក្នុងលក្ខណៈឬនៅក្នុងកម្រិតមួយដែលមនុស្សធម្មតាអាចធ្វើបាន។ វាជាល័ក្ខខ័ណ្ឌមួយ ដែលក្នុងនោះមនុស្សម្នាក់មានបញ្ហាលើរូបរាង្គកាយរបស់គាត់ មានបញ្ហាក្នុងផ្លូវអារម្មណ៍ ឬក៏អាកប្បកិរិយារបស់គាត់ ដែលអាចដាក់កំហិតពីលទ្ធភាពរបស់គាត់ក្នុងការចូលរួមជាធម្មតាក្នុងការងារ ក្នុងការសិក្សា និងក្នុងជីវិតរស់នៅក្នុងសង្គម។ វាគឺជាល័ក្ខខ័ណ្ឌរយៈពេលវែង ឬជាអចិន្ត្រៃយ៍ ដែលមិនអាចរាប់បញ្ចូលនូវការរងរបួស ឬការមានជំងឺក្នុងស្ថានភាពបណ្តោះអាសន្ននោះទេ។

### ប្រេវ៉ាឡង់នៃជនមានពិការភាព

អត្រាពិការភាព មានប្រមាណ៤ភាគរយ នៃចំនួនប្រជាជនកម្ពុជាសរុបនៃគ្រួសារដែលមិនមែនជាគ្រួសារស្ថាប័ន។ ចំនួនអ្នកពិការមានប្រមាណ៧២២.៦៤៣នាក់នៅក្នុងឆ្នាំ២០១៩/២០។ តារាង១ បានបង្ហាញអំពីប្រេវ៉ាឡង់នៃប្រភេទជនមានពិការភាព/ការពិបាកទៅតាមស្ថានភាពផ្សេងៗគ្នា។ អ្នកឆ្លើយតបអាចរាយការណ៍អំពីស្ថានភាពពិបាករហូតដល់បីករណីសំខាន់ជាងគេបំផុត ប្រសិនបើការពិបាកនោះមានលើសពីបីករណី។ តាមទិន្នន័យនៅក្នុងតារាងបានបង្ហាញអំពីអត្រានៃប្រជាជនយ៉ាងតិចណាស់ ដែលមានពិការភាព/ការពិបាកចំនួនមួយនៅក្នុងឆ្នាំ២០០៤ ២០០៩ ឆ្នាំ២០១៤ និង ឆ្នាំ២០១៩/២០។ ប្រភេទនៃជនមានពិការភាព/ការពិបាកនោះ គឺផ្អែកទៅលើការពិការភាពដែលបានរាយការណ៍មុនដំបូង ឬក៏សំខាន់ជាងគេបំផុត។ តារាង១ ក៏បានបង្ហាញផងដែរថា ពិការភាព/ការពិបាកក្នុងការមើល គឺជាបញ្ហាដែលមានស្ថានភាពទូទៅបំផុត សម្រាប់ប្រជាជនកម្ពុជាក្នុងរយៈពេលជាង១៥ឆ្នាំចុងក្រោយ (២០០៤-២០១៩/២០)។ (សូមមើលតារាង១សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១. ប្រជាជន(នៅក្នុងគ្រួសារមិនមែនស្ថាប័ន) មានពិការភាព/ការពិបាកយ៉ាងតិចណាស់ចំនួនមួយករណី ឆ្នាំ២០០៤ ឆ្នាំ២០០៩ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភេទនៃការពិបាក | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | |
|---|---|---|---|---|
| | ២០០៤ | ២០០៩ | ២០១៤ | ២០១៩/២០ |
| ការមើល | ១,៥ | ៣,៩ | ១,៧ | ២,៨ |
| ការស្តាប់ | ០,៥ | ១,២ | ០,៧ | ០,៥ |
| ការនិយាយ | ០,២ | ០,៣ | ០,២ | ០,២ |
| ការធ្វើចលនា | ១,១ | ១,៦ | ១,១ | ០,៨ |
| ខាងកាយវិញ្ញាណ ឬអារម្មណ៍ចំឡែក* | ០,៤ | ០,៤ | ០,២ | ០,២ |
| ខាងផ្លូវចិត្ត | ០,៣ | ០,៤ | ០,២ | ០,២ |
| ការរៀនសូត្រ | ០,១ | ០,១ | ០,១ | ០,០ |
| ប្រកាច់ | ០,១ | ០,១ | ០,១ | ០,០ |

សម្គាល់: * សម្រាប់ឆ្នាំ២០០៤ និងឆ្នាំ២០១៩: "ខាងកាយវិញ្ញាណ" សម្រាប់ឆ្នាំ២០០៩: "ខាងកាយវិញ្ញាណ ឬអារម្មណ៍ចំឡែក"

តាមទិន្នន័យក្នុងតារាង២ បានបង្ហាញថា អត្រាប្រេវ៉ាឡង់នៃជនមានពិការភាព/ការពិបាកមានការកើនឡើងតាមក្រុមអាយុ។ នៅក្រុមប្រជាជនក្មេងបំផុតដែលមានអាយុ(០-១៤ឆ្នាំ) អត្រានេះមានប្រមាណ១ភាគរយប៉ុណ្ណោះដែលមានពិការភាព/ការពិបាក ខណៈដែលក្រុមប្រជាជនវ័យចាស់បំផុតចាប់ពីអាយុ៦០ឆ្នាំឡើងទៅ មានអត្រាប្រេវ៉ាឡង់នៃពិការភាព/ការពិបាកខ្ពស់ ស្ទើរតែស្មើនឹងមួយភាគបី (ប្រមាណ២៩%)។ ម៉្យាងទៀតក្នុងចំណោមប្រជាជនវ័យចាស់បំផុត អត្រានេះសម្រាប់ស្ត្រី និងបុរស មានកម្រិតប្រហាក់ប្រហែលគ្នា ។ (សូមមើលតារាង២សម្រាប់ព័ត៌មានបន្ថែម)។

**តារាង២. ប្រជាជន (នៅក្នុងគ្រួសារមិនមែនស្ថាប័ន) មានពិការភាព/ការពិបាកយ៉ាងតិចណាស់ចំនួនមួយករណី បែងចែកតាមក្រុមអាយុ និងតាមភេទ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ក្រុមអាយុ | ឆ្នាំ២០១៩/២០ | | |
|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ |
| គ្រប់អាយុទាំងអស់ | ៤,៩ | ៤,៥ | ៤,៧ |
| ០ - ១៤ | ០,៥ | ០,៧ | ០,៦ |
| ១៥ - ២៩ | ១,០ | ១,៣ | ១,១ |
| ៣០ - ៤៤ | ១,៦ | ២,៥ | ២,១ |
| ៤៥ - ៥៩ | ៧,០ | ៨,៣ | ៧,៦ |
| ៦០ឆ្នាំឡើង | ២៩,១ | ២៩,៦ | ២៩,៣ |

## កម្រិតនៃការពិបាក

តារាង៣ ខាងក្រោមបង្ហាញអំពីកម្រិតនៃការពិបាកដែលមានស្ថានភាពទូទៅបំផុត ដូចជា (ពិបាកក្នុងការមើលពិបាកក្នុងការធ្វើចលនា និងពិបាកក្នុងការស្តាប់)ទៅតាមកម្រិតនៃពិការភាព។ តាមទិន្នន័យបានបញ្ជាក់ថានៅឆ្នាំ២០១៩/២០ មានប្រជាជនប្រមាណ ៣ភាគរយ បានប្រឈមនឹងការពិបាកក្នុងការមើល (សូមមើល

តារាង១ខាងលើ)។ សម្រាប់ស្ថានភាពពិបាកក្នុងការមើលក្នុងកម្រិតមធ្យម (កម្រិតល្មម) មានប្រមាណ ១,៥ ភាគរយនៃចំនួនប្រជាជនសរុប និងស្ថានភាពពិបាកការមើលកម្រិតធ្ងន់ធ្ងរ មានអត្រាទាបបំផុតប្រមាណ០,២ ភាគរយនៃចំនួនប្រជាជនសរុប។ ចំពោះការពិបាកក្នុងការធ្វើចលនា និងការពិបាកក្នុងការស្តាប់គឺជាទូទៅស្ថិតក្នុងកម្រិតស្ថានភាពមធ្យម។ (សូមមើលតារាង៣សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៣. កម្រិតនៃការពិបាកដែលមានលក្ខណៈទូទៅបំផុត ឆ្នាំ២០០៩ ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភេទនៃការពិបាក | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ២០០៩ | | | ២០១៤ | | | ២០១៩/២០ | | |
| | ស្រាល | មធ្យម | ធ្ងន់ធ្ងរ | ស្រាល | មធ្យម | ធ្ងន់ធ្ងរ | ស្រាល | មធ្យម | ធ្ងន់ធ្ងរ |
| ក្នុងការមើល | ២,១ | ១,៦ | ០,៣ | ០,៦ | ០,៩ | ០,២ | ១,០ | ១,៥ | ០,២ |
| ក្នុងការធ្វើចលនា | ០,៤ | ០,៨ | ០,៤ | ០,១ | ០,៧ | ០,៣ | ០,២ | ០,៤ | ០,២ |
| ក្នុងការស្តាប់ | ០,៤ | ០,៦ | ០,២ | ០,១ | ០,៤ | ០,១ | ០,១ | ០,២ | ០,១ |

## មូលហេតុនៃការពិបាក

តារាងសំណួរបានបង្ហាញនូវមូលហេតុចំនួន១៨ផ្សេងៗគ្នា។ មន្ត្រីសម្ភាសន៍បានសួរសំណួរអំពីមូលហេតុនីមួយៗដែលទាក់ទងទៅនឹងស្ថានភាពពិបាក។ តារាង៤ បានបង្ហាញអំពីមូលហេតុចម្បងនៃពិការភាព/ការពិបាកក្នុងចំណោមប្រជាជនសរុបនៃគ្រួសារដែលមិនមែនជាគ្រួសារស្ថាប័ន សម្រាប់គ្រប់ប្រភេទនៃពិការភាព/ការពិបាកទាំងអស់ដែលបានរាយការណ៍។ បើពិនិត្យជាទូទៅឃើញថា ស្ថានភាពនៃប្រជាជនវ័យចំណាស់និងស្ថានភាពជំងឺត្រូវបានរាយការណ៍ថា ជាមូលហេតុចម្បងដែលបណ្តាលឱ្យមានពិការភាព/ការពិបាក ក្នុងអត្រាប្រមាណជាង ២ភាគរយ និង១ភាគរយនៃប្រជាជនសរុប ចំពោះមូលហេតុចម្បងទាំងពីរនេះ។ ស្ត្រីបានទទួលរងនូវការពិបាកដែលបណ្តាលមកពីស្ថានភាពវ័យចំណាស់ក្នុងអត្រាខ្ពស់ជាងបុរស។ ចំពោះមូលហេតុបណ្តាលមកពីបញ្ហាគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ ឬការរងរបួសដោយសារសង្គ្រាម គ្រោះថ្នាក់ចរាចរណ៍ ឬក៏គ្រោះថ្នាក់នៅក្នុងការងារ បុរសបានទទួលរងនូវការពិបាកក្នុងអត្រាខ្ពស់ជាងស្ត្រីបន្តិច។ (សូមមើលតារាង៤សម្រាប់ព័ត៌មានបន្ថែម)។

តារាង៤. មូលហេតុនៃការពិបាកមួយចំនួន បែងចែកតាមភេទ ឆ្នាំ២០០៩ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| មូលហេតុនៃការពិបាក | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ២០០៩ | | | ២០១៤ | | | ២០១៩/២០ | | |
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| គ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ | ០,១ | ០,៦ | ០,៤ | ០,១ | ០,៤ | ០,២ | ០,០ | ០,៣ | ០,១ |
| គ្រោះថ្នាក់ចរាចរណ៍ឬក្នុងការងារ | ០,៣ | ០,៧ | ០,៥ | ០,១ | ០,២ | ០,១ | ០,១ | ០,៤ | ០,៣ |
| ស្ថានភាពមានជំងឺ | ១,៩ | ១,៦ | ១,៨ | ១,០ | ០,៩ | ១,០ | ១,២ | ១,១ | ១,២ |
| វ័យចំណាស់(អាយុច្រើន) | ៣,៤ | ២,៤ | ២,៩ | ២,៥ | ១,៣ | ១,៩ | ២,៨ | ១,៨ | ២,៣ |
| ស្ថានភាពជំងឺមានពីកំណើត | ០,៥ | ០,៧ | ០,៦ | ០,៥ | ០,៧ | ០,៦ | ០,៣ | ០,៥ | ០,៤ |

## ៧.៣ ជំងឺ របួស ឬ បញ្ហាសុខភាពផ្សេងៗក្នុងរយៈពេល៣០ថ្ងៃកន្លងមក

ក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ មេគ្រួសារទាំងអស់ត្រូវបានសាកសួរព័ត៌មានអំពីសមាជិកគ្រួសារនីមួយៗ ថាតើពួកគាត់បានឈឺ មានជំងឺ ឬបានទទួលរងនូវរបួសដែរឬទេក្នុងរយៈពេល៣០ថ្ងៃកន្លងមក។ បើសិនជាមានអ្នកណាម្នាក់បានឈឺ ឬបានទទួលរងនូវរបួសស្នាម នោះប្រភេទជំងឺ(ចំនួន១០ករណីសំខាន់ៗ) ត្រូវបានកត់ត្រាយក។ មានសំណួរមួយបានសួរអំពីការពិគ្រោះយោបល់ ឬការស្វែងរកការព្យាបាលជំងឺ ឬរបួស។ មានសំណួរដាច់ដោយឡែកផ្សេងមួយទៀតសួររកមូលហេតុដែលតម្រូវឱ្យទៅរកកន្លែងផ្តល់សេវាសុខភាព (ដូចជាមន្ទីរពេទ្យ) ឬក៏ការស្វែងរកសេវាថែទាំសុខភាព។

ផ្អែកតាមទិន្នន័យក្នុងតារាង៥ មានប្រជាជនប្រមាណ ១៦ភាគរយ មានជំងឺ/របួសនៅពេលណាមួយក្នុងរយៈពេល៣០ថ្ងៃកន្លងមក។ ក្នុងចំណោមស្ត្រីទាំងអស់មានប្រមាណ ១៩ភាគរយ មានជំងឺ ឬរបួស ខណៈដែលបុរសមានតែ១៣ភាគរយប៉ុណ្ណោះ។ ម្យ៉ាងទៀតបើគិតជាចំនួនជាក់ស្តែងវិញអាចបញ្ជាក់បានថា ប្រជាជនកម្ពុជាជិត២.៥លាននាក់មានបញ្ហាសុខភាព។ អត្រានេះ គឺមានកម្រិតខ្ពស់បន្តិចនៅតាមតំបន់ជនបទជាងនៅរាជធានីភ្នំពេញនិងទីប្រជុំជនផ្សេងៗ។

តារាង៥. ជំងឺ/របួសក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមតំបន់ភូមិសាស្ត្រនិងតាមភេទ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| តំបន់ | ស្ត្រី | បុរស | ទាំងពីរភេទ |
|---|---|---|---|
| កម្ពុជា | ១៨,៥ | ១៣,៤ | ១៦,០ |
| រាជធានីភ្នំពេញ | ៩,១ | ៨,៩ | ៩,០ |
| ទីប្រជុំជនផ្សេងៗ | ១៩,៦ | ១៣,៣ | ១៦,៥ |
| ជនបទ | ២០,៣ | ១៤,៦ | ១៧,៥ |

រូបភាព១ បង្ហាញអំពីស្ថានភាពជំងឺ និងរបួសរបស់ប្រជាជននៅតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នាក្នុងឆ្នាំ២០០៩ ២០១៤ និងឆ្នាំ២០១៩/២០។ នៅប្រទេសកម្ពុជា ប្រជាជនដែលមានជំងឺ ឬរបួសមានការកើនឡើងរវាងឆ្នាំ២០០៩ ២០១៤ និងឆ្នាំ២០១៩/២០ គឺមានប្រមាណ១៦ភាគរយ នៅក្នុងឆ្នាំ២០១៩/២០ ខណៈដែលនៅក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១៤ មានប្រមាណ១៥ភាគរយ។ នៅឆ្នាំ២០១៩/២០ នៅតំបន់ជនបទស្ថានភាព

ជំងឺ និងរបួស របស់ប្រជាជនមានការកើនឡើងច្រើន (១៨ភាគរយ) បើប្រៀបធៀបនឹងប្រជាជនដែលរស់នៅតាមតំបន់ទីប្រជុំជនផ្សេងៗ(១៤ភាគរយ)។ (សូមមើលរូបភាព១សម្រាប់ព័ត៌មានបន្ថែម)។

**រូបភាព១. ជំងឺ/របួសក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០០៩ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)**




រូបភាព២ បង្ហាញអំពីស្ថានភាពជំងឺនិងរបួសក្នុងចំណោមប្រជាជន ដោយបែងចែកតាមក្រុមអាយុ និងភេទនៅឆ្នាំ២០១៩/២០។ ផ្អែកតាមទិន្នន័យអង្កេតឃើញថា បញ្ហាសុខភាពមានកម្រិតខ្ពស់នៅក្នុងចំណោមប្រជាជនដែលមានអាយុចាស់(វ័យចំណាស់)។ ឧទាហរណ៍ដូចជា ស្ថានភាពជំងឺ ឬរបួសក្នុងរយៈពេល៣០ថ្ងៃកន្លងមក សម្រាប់ប្រជាជនមានវ័យចំណាស់ដែលមានអាយុចាប់ពី៦០ឆ្នាំឡើង គឺមានអត្រាប្រមាណ៤២ភាគរយ ចំពោះស្ត្រី និងបុរសមាន៣៩ភាគរយ។ ចំណែកប្រជាជននៅក្នុងចំណោមក្រុមអាយុវ័យក្មេងបំផុត(០-១៤ឆ្នាំ) បញ្ហាសុខភាពសម្រាប់ស្ត្រីនិងបុរស ហាក់បីដូចជាមានកម្រិតអត្រាប្រហាក់ប្រហែលគ្នា។ បើពិនិត្យជាទូទៅប្រជាជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ គឺបញ្ហាសុខភាពស្ត្រីមានអត្រាខ្ពស់ជាងបុរស។ (សូមមើលរូបភាព២សម្រាប់ព័ត៌មានបន្ថែម)។

រូបភាព១២. ជំងឺ/របួសក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមក្រុមអាយុ និងតាមភេទ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)




## ៧.៤ ការពិនិត្យសុខភាព

តារាង៦ បង្ហាញថាមានប្រជាជនប្រមាណ៨៩ភាគរយ ក្នុងចំណោមប្រជាជនមានជំងឺ ឬរបួសដែលបានស្វែងរកសេវាថែទាំសុខភាពចំនួន១ដង ឬក៏ច្រើនដងនៅក្នុងរយៈពេល៣០ថ្ងៃកន្លងមក ក្នុងនោះស្ត្រីមានអត្រាខ្ពស់ជាងបុរសនៅគ្រប់តំបន់ភូមិសាស្ត្រទាំងអស់នៃប្រទេសកម្ពុជា។ អត្រាទៅពិនិត្យសុខភាពចំនួន១ដង ឬក៏ច្រើនដងសម្រាប់ប្រជាជននៅតាមតំបន់ទីប្រជុំជនផ្សេងៗ មានកម្រិតខ្ពស់ជាងប្រជាជននៅរាជធានីភ្នំពេញ និងជនបទផ្សេងៗដែលមានប្រមាណ ៩២,៧ភាគរយ ៩២,៦ភាគរយ និង៩២,៤ភាគរយ តាមលំដាប់រៀង។

តារាង៦. ការទៅពិនិត្យសុខភាព(១ដងឬច្រើនដង)ក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមតំបន់ភូមិសាស្ត្រ និងតាមភេទ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| តំបន់ | ស្ត្រី | បុរស | ទាំងពីរភេទ |
|---|---|---|---|
| កម្ពុជា | ៩០,៥ | ៨៨,១ | ៨៩,៣ |
| រាជធានីភ្នំពេញ | ៩៣,៣ | ៩១,៥ | ៩២,៦ |
| ទីប្រជុំជនផ្សេងៗ | ៩៣,១ | ៩២,២ | ៩២,៧ |
| ជនបទ | ៩២,៩ | ៩១,៦ | ៩២,៤ |

តារាង៧ បង្ហាញអំពីការទៅពិនិត្យសុខភាពបែងចែកតាមភេទ ក្រុមអាយុ និងចំនួនដងនៃការទៅពិនិត្យសុខភាព។ តាមទិន្នន័យអង្កេតបង្ហាញថា មានប្រមាណ៨៩ភាគរយនៃប្រជាជន ដែលស្វែងរកសេវាថែទាំសុខភាព (ការព្យាបាល)ក្នុងអំឡុងពេល៣០ថ្ងៃកន្លងមកបានស្វែងរកត្រឹមតែ១ដងប៉ុណ្ណោះ។ ប្រជាជនមានវ័យចំណាស់បានស្វែងរកការថែទាំសុខភាពច្រើនជាងប្រជាជនវ័យក្មេង។ ម្យ៉ាងទៀតប្រជាជន (មានវ័យ៦០ឆ្នាំឡើង) ប្រមាណ៣៨ភាគរយ បានស្វែងរកការថែទាំសុខភាពយ៉ាងតិចណាស់ក៏ចំនួន១ដងដែរ នៅក្នុងរយៈពេល៣០ថ្ងៃកន្លងមក ខណៈដែលប្រជាជនមានអាយុក្រោម៦០ឆ្នាំមានអត្រាទាបជាងគេ។ បើពិនិត្យលើបញ្ហាយេនឌ័រ គឺស្ត្រីក្នុងក្រុម

អាយុនីមួយៗ បានស្វែងរកសេវាថែទាំសុខភាព (ការព្យាបាល) ប្រហាក់ប្រហែលគ្នា។ (សូមមើលតារាង៧សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៧. ការទៅពិនិត្យសុខភាពក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមក្រុមអាយុ និងតាមភេទ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ភេទ និង ក្រុមអាយុ | ១ដង | ២-៥ ដង | ច្រើនជាង៦ដង | ១ដង ឬ ច្រើនម្តង |
|---|---|---|---|---|
| ស្ត្រី | | | | |
| ០-១៤ | ១២,២ | ៦,០ | ០,២ | ១៨,៤ |
| ១៥-២៩ | ៣,៤ | ១,៥ | ០,០ | ៥,០ |
| ៣០-៤៤ | ៥,៩ | ២,៦ | ០,១ | ៨,៦ |
| ៤៥-៥៩ | ១១,៨ | ៥,០ | ០,២ | ១៧,០ |
| ៦០ឆ្នាំឡើង | ២១,៥ | ១០,៩ | ០,៧ | ៣៣,១ |
| បុរស | | | | |
| ០-១៤ | ១២,៥ | ៥,៧ | ០,២ | ១៨,៣ |
| ១៥-២៩ | ៥,៨ | ៣,០ | ០,១ | ៨,៩ |
| ៣០-៤៤ | ៩,៧ | ៥,០ | ០,១ | ១៤,៨ |
| ៤៥-៥៩ | ១៩,៧ | ៩,០ | ០,៣ | ២៩,០ |
| ៦០ឆ្នាំឡើង | ២៦,៥ | ១៣,៨ | ០,៩ | ៤១,២ |
| ទាំងពីរភេទ | | | | |
| ០-១៤ | ១២,៣ | ៥,៩ | ០,២ | ១៨,៤ |
| ១៥-២៩ | ៤,៦ | ២,៣ | ០,១ | ៧,០ |
| ៣០-៤៤ | ៧,៨ | ៣,៨ | ០,១ | ១១,៨ |
| ៤៥-៥៩ | ១៦,០ | ៧,១ | ០,៣ | ២៣,៤ |
| ៦០ឆ្នាំឡើង | ២៤,៥ | ១២,៦ | ០,៨ | ៣៨,០ |

## ៧.៥ អ្នកផ្តល់សេវាថែទាំសុខភាព

សមាជិកគ្រួសារនីមួយៗដែលមានបញ្ហាសុខភាព និងបានស្វែងរកការថែទាំសុខភាព ត្រូវបានសាកសួរថា តើការថែទាំសុខភាពប្រភេទណាដែលពួកគេបានស្វែងរកសម្រាប់ការព្យាបាល (អ្នកផ្តល់សេវាថែទាំសុខភាព)។ សំណួរដំបូងត្រូវបានសួរអំពីអ្នកផ្តល់សេវាថែទាំសុខភាពក្នុងការព្យាបាលដំបូង និងសម្រាប់អ្នកទាំងឡាយណាដែលទទួលបាននូវការព្យាបាលច្រើនជាង១ដង នៅក្នុងរយៈពេល៣០ថ្ងៃកន្លងមក ហើយក៏សួររកអ្នកផ្តល់សេវាថែទាំសុខភាពលើកចុងក្រោយបង្អស់ផងដែរ។ អ្នកផ្តល់សេវាថែទាំសុខភាពត្រូវបានបែងចែកតាមផ្នែកផ្សេងៗដូចជា ផ្នែកសាធារណៈ ផ្នែកឯកជន ផ្នែកព្យាបាលដោយខ្លួនឯង ផ្នែកព្យាបាលតាមបែបបុរាណ និងផ្នែកព្យាបាលនៅក្រៅប្រទេស។

ដូចទិន្នន័យបានបង្ហាញក្នុងតារាង៨ខាងក្រោម អ្នកផ្តល់សេវាថែទាំសុខភាពដំបូង ដែលត្រូវបានសមាជិកគ្រួសារស្វែងរកពេលមានជំងឺ មានរបួស ឬមានបញ្ហាសុខភាពផ្សេងៗនៅក្នុងរយៈពេល៣០ថ្ងៃកន្លងមក គឺមានកម្រិតខ្ពស់បំផុតនៅក្នុងផ្នែកអ្នកផ្តល់សេវាថែទាំសុខភាពឯកជន ដែលមានប្រមាណ៦៩ភាគរយ និង ២៣ភាគ

រយនៅក្នុងផ្នែកអ្នកផ្តល់សេវាថែទាំសុខភាពសាធារណៈ។ ចំពោះវិធីព្យាបាលតាមបែបបុរាណដែលសមាជិកគ្រួសារបានប្រើសម្រាប់ព្យាបាល ជំងឺ ឬរបួស មានប្រមាណ ៧ភាគរយ តែប៉ុណ្ណោះ។ ទិន្នន័យក៏បានបង្ហាញផងដែរចំពោះការស្វែងរកអ្នកផ្តល់សេវាដើម្បីថែទាំសុខភាពរវាងស្ត្រីនិងបុរសនៅក្នុងរយៈពេល៣០ថ្ងៃកន្លងមក គឺពុំមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់នោះឡើយ។ (សូមមើលតារាង៨សម្រាប់ព័ត៌មានបន្ថែម) ។

**តារាង៨. អ្នកផ្តល់សេវាថែទាំសុខភាពដំបូងក្នុងចំណោមសមាជិកគ្រួសារដែលបានស្វែងរកក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមភេទ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| អ្នកផ្តល់សេវាថែទាំសុខភាព | ស្ត្រី | បុរស | ទាំងពីរភេទ |
|---|---:|---:|---:|
| ផ្នែកសេវាសាធារណៈ | ២៣,៧ | ២១,៣ | ២២,៧ |
| ផ្នែកសេវាឯកជន | ៦៧,៧ | ៧១,១ | ៦៩,១ |
| ផ្នែកព្យាបាលតាមបែបបុរាណ | ៧,៧ | ៦,៩ | ៧,៤ |
| ផ្នែកព្យាបាលនៅក្រៅប្រទេស | ០,៥ | ០,៥ | ០,៥ |
| ផ្សេងៗ | ០,៤ | ០,២ | ០,៣ |
| សរុប | ១០០ | ១០០ | ១០០ |

សម្គាល់: *ព្យាបាលដោយខ្លួនឯងមានដូចជាកន្លែងលក់ថ្នាំពេទ្យ/ផ្សារ

ដូចបានបង្ហាញទិន្នន័យក្នុងតារាង៩ខាងក្រោម អ្នកផ្តល់សេវាថែទាំសុខភាពដំបូង ដែលត្រូវបានសមាជិកគ្រួសារស្វែងរកពេលមានជំងឺ មានរបួស ឬមានបញ្ហាសុខភាពផ្សេងៗនៅក្នុងរយៈពេល៣០ថ្ងៃកន្លងមក នៅតាមតំបន់ភូមិសាស្ត្រក្នុងឆ្នាំ២០១៩/២០ គឺមានកម្រិតខ្ពស់បំផុតក្នុងផ្នែកអ្នកផ្តល់សេវាថែទាំសុខភាពឯកជន នៅរាជធានីភ្នំពេញ ក៏ដូចជានៅតាមតំបន់ទីប្រជុំជន និងជនបទ ដែលទិន្នន័យបានបង្ហាញ គឺមានប្រមាណជា៧៦ភាគរយ ៧១ភាគរយ និង៦៨ភាគរយ តាមលំដាប់រៀង។ ចំពោះផ្នែកសាធារណៈ និងផ្នែកព្យាបាលតាមបែបបុរាណគឺមានកម្រិតខ្ពស់បំផុតនៅតាមតំបន់ជនបទផ្សេងៗជាង នៅទីប្រជុំជនផ្សេងៗ និងរាជធានីភ្នំពេញ។ (សូមមើលតារាង៩ សម្រាប់ព័ត៌មានបន្ថែម) ។

**តារាង៩. អ្នកផ្តល់សេវាថែទាំសុខភាពដំបូងក្នុងចំណោមសមាជិកគ្រួសារដែលបានស្វែងរកក្នុងរយៈពេល៣០ថ្ងៃកន្លងមក បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| អ្នកផ្តល់សេវាថែទាំសុខភាព | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
|---|---:|---:|---:|---:|
| ផ្នែកសេវាសាធារណៈ | ២២,៧ | ២៣,៤ | ២១,៧ | ២៣,០ |
| ផ្នែកសេវាឯកជន | ៦៩,១ | ៧៦,៣ | ៧០,៩ | ៦៧,៥ |
| ផ្នែកព្យាបាលតាមបែបបុរាណ | ៧,៤ | ០,៣ | ៦,៥ | ៨,៦ |
| ផ្នែកព្យាបាលនៅក្រៅប្រទេស | ០,៥ | ០,០ | ០,២ | ០,៤ |
| ផ្សេងៗ | ០,៣ | ០,០ | ០,៨ | ០,៤ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

ចំណាំ៖ ការថែទាំផ្ទាល់ខ្លួនរួមមានហាងលក់ថ្នាំនៅផ្សារ (ឱសថស្ថាន)

## ៧.៦ ប្រភពថវិកាចំណាយសម្រាប់ការថែទាំសុខភាព

ដោយហេតុថាប្រព័ន្ធសុខាភិបាលនៅក្នុងប្រទេសកម្ពុជា គឺជាប្រព័ន្ធបង់ថ្លៃសេវា។ វាមានសារៈសំខាន់ណាស់ដើម្បីយល់ដឹងអំពីប្រភពថវិកាដែលបានប្រើប្រាស់សម្រាប់ការចំណាយលើការថែទាំសុខភាព។ គោលបំណងមួយសម្រាប់ប្រព័ន្ធថែទាំសុខភាព គឺត្រូវមានយន្តការផ្តល់មូលនិធិសមស្រប សម្រាប់ឱ្យប្រជាជនអាចប្រើប្រាស់សេវាថែទាំសុខភាពបាន ហើយដែលអាចជួយសម្រាលបានដល់ស្ថានភាពក្រីក្ររបស់ពួកគេ។ ទិន្នន័យក្នុងតារាង១០ បានបង្ហាញអំពីប្រភពថវិកាផ្សេងៗដែលសមាជិកគ្រួសារបានចំណាយក្នុងការស្វែងរកសេវាថែទាំសុខភាព។

ប្រភពថវិកាប្រមាណ ៧៦ភាគរយ ដែលចំណាយលើការថែទាំសុខភាពនៅឆ្នាំ២០១៩/២០ ដែលបានមកពីប្រាក់ចំណូលគ្រួសារ១៩ភាគរយបានមកពីប្រាក់សន្សំ និងប្រមាណ២ភាគរយបានមកពីការខ្ចីប្រាក់គេ។ មានប្រភពថវិកាសំខាន់ពីរ ដែលប្រជាជននៅគ្រប់តំបន់ភូមិសាស្ត្រទាំងអស់ក្នុងប្រទេសកម្ពុជា បានប្រើប្រាស់សម្រាប់ការថែទាំសុខភាព គឺប្រាក់ចំណូលគ្រួសារ និងប្រាក់សន្សំ។ នៅរាជធានីភ្នំពេញមានប្រជាជនប្រើប្រាស់ប្រាក់ចំណូលគ្រួសារសម្រាប់ការថែទាំសុខភាព មានកម្រិតខ្ពស់ជាងប្រជាជននៅតាមតំបន់ទីប្រជុំជន និងជនបទផ្សេងៗ ប្រាក់សន្សំគឺមានកម្រិតខ្ពស់ជាង ការសន្សំរបស់ប្រជាជននៅតាមតំបន់ជនបទប្រមាណ ២២ភាគរយ និងតំបន់ទីប្រជុំជនផ្សេងៗមានប្រមាណ១៧ភាគរយ។ (សូមមើលតារាង១០សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១០. ប្រភពថវិកាចំណាយសម្រាប់អ្នកដែលបានស្វែងរកការថែទាំសុខភាព បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភពថវិកាសម្រាប់ថែទាំសុខភាព | កម្ពុជា | រាជធានី ភ្នំពេញ | ទីប្រជុំជន ផ្សេងៗ | ជនបទ |
|---|---|---|---|---|
| ចំណូលគ្រួសារ | ៧៥,៥ | ៩៤,៩ | ៧៨,៤ | ៧២,០ |
| ប្រាក់សន្សំ | ១៩,៣ | ២,០ | ១៧,១ | ២២,៣ |
| ប្រាក់ខ្ចីគេ | ១,៩ | ០,៥ | ១,៤ | ២,៣ |
| លក់ទ្រព្យសម្បត្តិ | ០,២ | ០,២ | ០,១ | ០,៣ |
| លក់ផលិតផលគ្រួសារមុនការកំណត់ | ០,១ | ០,០ | ០,០ | ០,១ |
| ផ្សេងៗ | ៣,០ | ២,៣ | ៣,០ | ៣,១ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ |

## ៧.៧ អាហារូបត្ថម្ភរបស់កុមារ

### ការចិញ្ចឹមក្មេង និងកុមារតូច (ទារក)

គោលការណ៍នៃការចិញ្ចឹមក្មេង និងកុមារតូច (ឬហៅកាត់ថា IYCF) ផ្តល់អនុសាសន៍ដល់ការបំបៅដោះតែមួយមុខសម្រាប់រយៈពេល៦ខែដំបូងនៃអាយុរបស់កុមារ ពីព្រោះទឹកដោះម្តាយមានសារជាតិដែលធ្វើឱ្យកុមារជំធាត់ត្រូវការសម្រាប់ដំណាក់កាលនៃការអភិវឌ្ឍរបស់ពួកគាត់ និងការការពារជំងឺឆ្លង និងមេរោគនានានៅក្នុងបរិស្ថាន។ ចាប់ពី៦ខែ កុមារគួរបន្តបៅដោះ និងបន្ថែមនូវអាហារបំប៉នដែលសមស្របសម្រាប់ផ្គត់ផ្គង់ថាមពល និងតម្រូវការសារជាតិរបស់ពួកគេ។ ភាពញឹកញាប់នៃអាហារបំប៉នទាំងនេះគួរតែបង្កើនទៅតាមអាយុ។ គោលការណ៍នៃការចិញ្ចឹមក្មេង និងកុមារតូច ផ្តល់អនុសាសន៍ដល់ការបំបៅដោះ សម្រាប់កុមារទាំងអស់រហូតដល់អាយុ២ឆ្នាំ និងលើសពីនេះ ដើម្បីជំរុញការអភិវឌ្ឍរាងកាយ និងខួរក្បាល។

អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បានសួរម្តាយអំពីការអនុវត្តការបំបៅដោះរបស់ពួកគាត់ជាមួយកូនក្មេងបំផុតដែលមានអាយុពី០-២៣ខែ។ ផ្អែកតាមលទ្ធផលអង្កេត មាន៩៤ភាគរយនៃស្ត្រី បានរាយការណ៍ថាពួកគាត់ធ្លាប់បំបៅដោះកូនក្មេងបំផុតរបស់ពួកគាត់។ តួលេខនេះមានផ្លាស់ប្តូរបន្តិចបន្តួចផ្អែកតាមទីតាំងកន្លែងសម្រាល ដែលបានបង្ហាញថាការបំបៅដោះ គឺមានស្មើរតែទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ស្ត្រីទាំងនេះ ត្រូវបានសួរផងដែរថា តើរយៈពេលប៉ុន្មានក្រោយកើតដែលអ្នកបំបៅដោះកូន។ មានស្ត្រីច្រើនជាងមួយភាគពីរ (៥៤ភាគរយ) បានរាយការណ៍ថា ពួកគេបានចាប់ផ្តើមបំបៅដោះកូនក្នុងពេលមួយម៉ោងបន្ទាប់ពីសម្រាល ដែលជាអំឡុងពេលមួយត្រូវបានផ្តល់អនុសាសន៍ផងដែរ។

**តារាង១១. ការបំបៅដោះលើកដំបូង បែងចែកតាមភាគរយនៃកូនដែលបានកើតចុងក្រោយ អាយុ (០-២៣ខែ) និងតាមពេលវេលាដែលបានចាប់ផ្តើមបំបៅដោះ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ចរិកលក្ខណៈ | ក្នុងចំណោមកូនដែលបានកើតចុងក្រោយ | | ក្នុងចំណោមកុមារដែលមិនធ្លាប់កើតចុងក្រោយ បំបៅដោះនិង ពេលវេលាផ្តួចផ្តើមបំបៅដោះកូនៈ | | | |
|---|---|---|---|---|---|---|
| | ធ្លាប់បៅដោះ | ចំនួនកូន | រយៈពេលពីកើតបានមួយម៉ោង | រយៈពេលពីកើតបានមួយថ្ងៃ | បន្ទាប់ពីថ្ងៃទីមួយ | ចំនួនកូន |
| **ភេទ** | | | | | | |
| កុមារី | ៩៤,២ | ៦៩៣ | ៥៥,០ | ៣៣,១ | ១១,៨ | ៦៩៣ |
| កុមារា | ៩៣,៣ | ៧០០ | ៥២,៧ | ៣៥,៩ | ១១,៤ | ៧០០ |
| **តំបន់** | | | | | | |
| រាជធានីភ្នំពេញ | ៩៣,០ | ៧៩ | ៤៤,១ | ៥០,២ | ៥,៨ | ៧៩ |
| ទីប្រជុំជនផ្សេងៗ | ៨៩,៥ | ៣៩២ | ៥១,៩ | ៣៨,៤ | ៩,៧ | ៣៩២ |
| ជនបទ | ៩៥,៤ | ៩២២ | ៥៦,០ | ៣០,៨ | ១៣,២ | ៩២២ |
| **កម្ពុជា** | **៩៣,៧** | **១.៣៩៣** | **៥៣,៩** | **៣៤,៥** | **១១,៦** | **១.៣៩៣** |

## ៧.៨ សុខភាពរបស់កុមារ

### ការចាក់វ៉ាក់សាំង

អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ ម្តាយត្រូវបានគេស្នើសុំឱ្យបង្ហាញប័ណ្ណចាក់ថ្នាំបង្ការ (ប័ណ្ណលឿង របស់កុមារទាំងអស់ដែលមានអាយុតិចជាងពីរឆ្នាំដល់មន្ត្រីសម្ភាសន៍។ បន្ទាប់មកមន្ត្រីសម្ភាសន៍កត់ត្រាកាលបរិច្ឆេទនៃការចាក់ថ្នាំបង្ការផ្សេងៗដែលបានទទួលកន្លងមក។ កុមារត្រូវបានទទួលថ្នាំបង្ការពេញលេញប្រសិនបើគាត់ ឬនាង បានទទួលវ៉ាក់សាំងគ្រប់ប្រភេទ។ ឧទាហរណ៍ ការចាក់វ៉ាក់សាំងមួយដូស សម្រាប់ការពារជំងឺកញ្ជ្រឹល។ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បានរកឃើញភាពខុសគ្នាពីការអង្កេតថ្នាក់ជាតិដទៃទៀតដែលមិនបានហៅម្តាយមមកសួរឡើងវិញ អំពីការចាក់ថ្នាំបង្ការក្នុងករណីដែលគ្មានប័ណ្ណចាក់វ៉ាក់សាំង។ ដូច្នេះលទ្ធផលទាំងនេះ តំណាងឱ្យអត្រាគ្របដណ្តប់ដែលត្រូវបានវាស់វែងទាំងស្រុងពីប័ណ្ណចាក់ថ្នាំបង្ការ។

ក្នុងចំណោមកុមារទាំងអស់ដែលមានអាយុពី ០-២៣ខែ មានប្រមាណ៩៨,០ ភាគរយ ដែលបានទទួលការចាក់វ៉ាក់សាំងដើម្បីការពារជំងឺ។ ផ្អែកតាមលទ្ធផលទិន្នន័យអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០

ឃើញថាក្នុងចំណោមកុមារដែលមានម្តាយកំពុងរស់នៅ មានប្រមាណ ៩៨,៤ ភាគរយ ដែលបានទទួលការចាក់វ៉ាក់សាំងសម្រាប់នៅតំបន់ជនបទ។

**តារាង១២. ការចាក់ថ្នាំបង្ការ បែងចែកភាគរយនៃកុមារដែលមានអាយុ១២-២៣ខែ ដែលបានទទួលថ្នាំបង្ការជាក់លាក់នៅពេលណាមួយមុនអង្កេត (យោងតាមប័ណ្ណលឿង)។**

| ចរិកលក្ខណៈ | | ភាគរយការចាក់ថ្នាំបង្ការ តាមប័ណ្ណលឿង | ចំនួនកូន |
|---|---|---|---|
| **ភេទ** | | | |
| | កុមារា | ៩៨,២ | ៧១៦ |
| | កុមារី | ៩៧,៧ | ៧២៩ |
| **តំបន់** | | | |
| | ភ្នំពេញ | ៩៦,៩ | ៨១ |
| | ទីប្រជុំជន | ៩៧,២ | ៤០១ |
| | ជនបទ | ៩៨,៤ | ៩៦៣ |
| **កម្ពុជា** | | **៩៨,០** | **១.៤១៩** |

# ផ្នែកទី៨ ការទទួលរងគ្រោះ

## ៨.១ សេចក្ដីផ្ដើម

នៅក្នុងផ្នែកនេះ របកគំហើញនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា បានបង្ហាញអំពីបទឧក្រិដ្ឋ ការទទួលរងគ្រោះ និងអារម្មណ៍សុវត្ថិភាព។ ចំណុចដែលបានសិក្សារួមបញ្ចូលនូវការទទួលរងគ្រោះបែងចែកតាមអំពើហិង្សា ការទទួលរងគ្រោះបែងចែកតាមបទឧក្រិដ្ឋទ្រព្យសម្បត្តិ (ការលួច/ឆក់/ការលួចចូលផ្ទះ/ការប្លន់) ការទទួលរងគ្រោះបែងចែកតាមឧបទ្ទវហេតុនានា និង អារម្មណ៍សុវត្ថិភាព។

សំណួរស្ដីពីអំពើហិង្សា បទឧក្រិដ្ឋទ្រព្យសម្បត្តិ និងឧបទ្ទវហេតុផ្សេងៗ អាស្រ័យទៅលើការទទួលរងគ្រោះនៅក្នុងរយៈពេល១២ខែកន្លងមក។ សំណួរស្ដីពីអំពើហិង្សាត្រូវបានសួរដល់សមាជិកគ្រួសារនីមួយៗដែលមានអាយុ៥ឆ្នាំឡើង (ចំពោះកុមារ ត្រូវសួរឪពុក ម្ដាយ) ខណៈដែលសំណួរអំពីបទឧក្រិដ្ឋទ្រព្យសម្បត្តិ ឧបទ្ទវហេតុ និងសុវត្ថិភាព ត្រូវបានសួរដល់មេគ្រួសារ។ សំណួរសំខាន់ៗដែលទាក់ទងនៅក្នុងផ្នែកនេះរួមមាន៖

- តើមានប៉ុន្មានគ្រួសារ និង/ឬប៉ុន្មាននាក់នៅកម្ពុជា បានទទួលរងគ្រោះដោយសារអំពើហឹង្សា និងបទឧក្រិដ្ឋទ្រព្យសម្បត្តិ?
- តើមានប៉ុន្មានគ្រួសារនៅកម្ពុជា បានទទួលរងគ្រោះដោយឧបទ្ទវហេតុនានា?
- តើមានប៉ុន្មានគ្រួសារនៅកម្ពុជា មានអារម្មណ៍សុវត្ថិភាពទាក់ទងនឹងបទឧក្រិដ្ឋនានា?
- តើមានភាពខុសគ្នាអ្វីខ្លះនៅក្នុងសំណួរខាងលើ អាចត្រូវបានរកឃើញនៅពេលប្រៀបធៀបជាមួយប្រជាជនក្រុម និងតាមឆ្នាំផ្សេងៗគ្នានោះ?

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីផ្ដល់នូវព័ត៌មានជាមូលដ្ឋាននៃគ្រួសារ និងបុគ្គលជាសមាជិកគ្រួសារដែលទទួលរងគ្រោះ នៅក្នុងបរិការណ៍នៃលក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គមកិច្ចរបស់គ្រួសារតែប៉ុណ្ណោះ។ ដើម្បីទទួលបាននូវការវាយតម្លៃដ៏ទូលំទូលាយនៃប្រជាជនដែលទទួលរងគ្រោះដោយអំពើហិង្សា ព័ត៌មានលម្អិតត្រូវបានប្រមូលយក និងធ្វើការវិភាគនៅក្នុងរបាយការណ៍នៃអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាឆ្នាំ២០១៤ និងអង្កេតដទៃទៀត។

## ៨.២ ការទទួលរងគ្រោះសរុប

នៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ចំនួនសរុបនៃប្រជាជន ឬក៏គ្រួសារដែលបានទទួលរងគ្រោះមិនត្រូវបានមើលឃើញថាជាចំនួនសរុបនៃប្រជាជនរងគ្រោះ ឬក៏គ្រួសារដែលទទួលរងគ្រោះនៅកម្ពុជានោះទេ។ ការសិក្សានេះ មិនអាចគ្រប់ដណ្ដប់នូវរាល់បទល្មើសនោះឡើយ ហើយការសិក្សាបែបនេះ វាពិបាកក្នុងប៉ាន់ប្រមាណនូវបទល្មើស ពីព្រោះប្រជាជនជាច្រើនមិនមានអារម្មណ៍កក់ក្ដៅក្នុងការរៀបរាប់អំពីបទពិសោធន៍ ដែលពួកគាត់ធ្លាប់បានជួបប្រទះកន្លងមក។ លើសពីនេះទៀត បទពិសោធន៍មួយចំនួនដែលកំណត់ដោយប្រជាជនរងគ្រោះថាជាបទឧក្រិដ្ឋនោះ ការពិតវាអាចមិនមែនជាបទល្មើសដូចដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌនោះឡើយ។

រូបភាព១ បានបង្ហាញពីទិន្នន័យនៃផ្នែកភាពរងគ្រោះដោយសារបទល្មើសទ្រព្យសម្បត្តិ និងភាពរងគ្រោះដោយសារឧបទ្ទវហេតុនានាសម្រាប់ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ ។

គ្រួសារមានប្រមាណ ៩ភាគរយ ដែលត្រូវបានរងគ្រោះដោយបទល្មើសចោរកម្ម (ការលួច ការឆក់ ការលបលួចចូលផ្ទះ ឬការប្លន់) នៅក្នុងឆ្នាំ២០១៩/២០ ។ អត្រានេះ គឺមានកម្រិតខ្ពស់ជាងបន្តិច បើធៀបនឹងឆ្នាំ២០១៤ ដែលមានប្រមាណ ២ភាគរយ តែប៉ុណ្ណោះ។ ដោយឡែកគ្រួសារដែលបានទទួលរងគ្រោះដោយសារឧបទ្ទវហេតុនៅឆ្នាំ២០១៩/២០ មានប្រមាណ ៤ភាគរយតែប៉ុណ្ណោះ (សូមមើលរូបភាព១ សម្រាប់ព័ត៌មានបន្ថែម)។

**រូបភាព១. គ្រួសារដែលទទួលរងគ្រោះ ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០**




## ៨.៣ អ្នកទទួលរងគ្រោះដោយសារអំពើហិង្សា

នៅក្នុងផ្នែកនេះ ការទទួលរងគ្រោះដោយអំពើហិង្សា ត្រូវបានសិក្សាលម្អិតបន្ថែម។ សំណួរត្រូវបានសួរដល់ប្រជាជនគ្រប់រូបដែលមានអាយុចាប់ពី៥ឆ្នាំឡើង ហើយភាគរយនៃអ្នកដែលមានបទពិសោធន៍លើបញ្ហានេះ ត្រូវបានបង្ហាញក្នុងតារាង១ខាងក្រោម។ ផ្អែកតាមលទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា បង្ហាញភាពខុសគ្នានៃអំពើហិង្សាដែលបែងចែកទៅតាមភេទ និងតាមប្រភេទ តាមទីកន្លែងរស់នៅ តាមក្រុមប្រជាជនផ្សេងៗ តាមស្ថានភាពនៃអំពើហិង្សាដែលកើតឡើងញឹកញាប់ តាមសកម្មភាពដែលទាក់ទងនឹងជនល្មើស និងឥរិយាបថក្នុងការរាយការណ៍ពីអំពើហិង្សា។

តារាង១ បង្ហាញអំពីប្រជាជនទាំងអស់ដែលបានទទួលរងគ្រោះ ដោយសារអំពើហិង្សាក្នុងចំណោមប្រជាជនសរុបដែលមានអាយុ៥ឆ្នាំឡើង។ នៅឆ្នាំ២០១៩/២០ អត្រាប្រជាជនទទួលរងគ្រោះដោយអំពើហិង្សាមានប្រមាណ ១,១ភាគរយ ដែលក្នុងនោះ ជនទទួលរងគ្រោះជាបុរសមានប្រមាណ ១,២ ភាគរយ ខណៈអត្រាស្ត្រីទាបជាងបន្តិច គឺមានប្រមាណ ១,០ ភាគរយ។ ទោះជាយ៉ាងណា បើសិនប្រៀបធៀបទៅនឹងឆ្នាំ២០១៤ ជនរងគ្រោះនៃអំពើហិង្សាមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងឆ្នាំ២០១៩/២០។

តារាង១. ជនរងគ្រោះដោយអំពើហិង្សា បែងចែកតាមភេទ គិតជាភាគរយនិងចំនួនប្រជាជនដែលទទួលរងគ្រោះ

| | ២០១៤ | | | ២០១៩/២០ | | |
|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| ប្រជាជនដែលទទួលរងគ្រោះគិតជាភាគរយក្នុងចំណោមប្រជារាស្ត្រសរុបអាយុ៥ឆ្នាំឡើង | ០,៥ | ០,៤ | ០,៤ | ១,០ | ១,២ | ១,១ |
| ចំនួនប្រជាជនដែលទទួលរងគ្រោះ | ៣៦.២៨៨ | ២៨.៨៥៣ | ៦៥.១៤១ | ៧១.៣៩៧ | ៨១.១០៤ | ១៥២.៥០១ |
| ភាគរយស្ត្រី និងបុរសដែលទទួលរងគ្រោះក្នុងចំណោមប្រជាជនទទួលរងគ្រោះទាំងអស់ | ៥៥,៧ | ៤៤,៣ | ១០០ | ៤៦,៨ | ៥៣,២ | ១០០ |

## ប្រភេទនៃអំពើហិង្សា

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ផ្តល់នូវលទ្ធភាពផងដែរក្នុងការសិក្សាអំពីភាគចំណែក នៃប្រភេទអំពើហិង្សាខុសៗគ្នា។ ទិន្នន័យត្រូវបានប្រមូលដោយផ្អែកលើព្រឹត្តិការណ៍នៃហិង្សាចុងក្រោយបង្អស់ ប្រសិនបើមានព្រឹត្តិការណ៍ហិង្សាកើតឡើងច្រើនជាងមួយលើក។ បើយោងតាមលទ្ធផលអង្កេតឆ្នាំ២០១៩/២០ ឃើញថា ប្រភេទនៃអំពើហិង្សាដែលកើតឡើងទីមួយ គឺ "ប្រើ ឬគំរាមអ្នកដោយកាំបិទ ឬអាវុធផ្សេងទៀត" មានអត្រា៦៨ភាគរយ។ ប្រភេទនៃអំពើហិង្សាដែលកើតឡើងទីពីរ គឺ "ការទះកំផ្លៀង ឬការរុញ" ដែលមានអត្រាប្រមាណ១៤,៧ភាគរយ និងទីបីគឺប្រភេទនៃអំពើហិង្សាដែលកើតឡើងទាក់ទងនឹង "ការដាល់ ទាត់ ការវាត់ ឬវាយនឹងវត្ថុ" មានអត្រាប្រមាណ១៤,៤ភាគរយ។ (សូមមើលតារាង២សម្រាប់ព័ត៌មានបន្ថែម)។

ដូចបានបង្ហាញនៅក្នុងតារាង២ខាងក្រោម ឃើញថាស្ត្រីភាគច្រើនមានភាគរយខ្ពស់ក្នុងការទទួលរងនូវអំពើហិង្សាស្ទើរតែគ្រប់ប្រភេទដែលបានសួរសម្ភាសន៍។ ប្រភេទនៃអំពើហិង្សាដូចជា "ការប្រើ ឬការគំរាមនឹងកាំបិត ឬដោយអាវុធផ្សេងទៀត" ត្រូវបានចែករំលែកប្រមាណ ៦៥ភាគរយ សម្រាប់ស្ត្រី និង ៧១ភាគរយសម្រាប់បុរស។ អំពើហិង្សាមាន៣ប្រភេទគឺ "ការធ្វើឱ្យថប់ដង្ហើម យកវត្ថុគ្របមុខ ព្យាយាមចាប់ជ្រមុជទឹក ឬ ដុតដោយចេតនា" "ប៉ះអ្នកតាមរបៀបផ្លូវភេទ ដោយគ្មានការអនុញ្ញាតពីអ្នក ប៉ុន្តែមនុស្សនោះមិនបានបង្ខំឱ្យរួមភេទទេ" "ការព្យាយាមរួមរ័កជាមួយ អ្នកតាមវិធីណាមួយដោយគ្មានការអនុញ្ញាត" ត្រូវបានពិសោធន៍ដោយស្ត្រីដែលមានភាគរយតិចជាង១ភាគរយ។ (សូមមើលតារាង២សម្រាប់ព័ត៌មានបន្ថែម) ។

## តារាង២. ព្រឹត្តិការណ៍អំពើហិង្សា បែងចែកតាមប្រភេទនៃអំពើហិង្សា និងតាមភេទ (គិតជាភាគរយ)

| អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | ២០១៩/២០ | | |
|---|---|---|---|
| ប្រភេទអំពើហិង្សា | ស្ត្រី | បុរស | ទាំងពីរភេទ |
| អំពើហិង្សាគ្រប់ប្រភេទ | ១០០ | ១០០ | ១០០ |
| ព្រឹត្តិការណ៍អំពើហិង្សាបែងចែកតាមប្រភេទនៃអំពើហិង្សា | | | |
| ការទះ ឬ រុញច្រាន | ១៦,៧ | ១២,៩ | ១៤,៧ |
| ការដាល់ ទាត់ វាត់ ឬ វាយនឹងវត្ថុ | ១៣,៩ | ១៤,៨ | ១៤,៤ |
| ការធ្វើឱ្យថប់ដង្ហើម យកវត្ថុគ្របមុខ ព្យាយាមចាប់ជ្រមុជទឹក ឬ ដុតដោយចេតនា | ០,៣ | ០,០ | ០,១ |
| ការប្រើ ឬ គំរាមនឹងកាំបិត ឬ ដោយអាវុធផ្សេងទៀត | ៦៥,៣ | ៧០,៥ | ៦៨,០ |
| ការប៉ះបៀតបៀនផ្លូវភេទដោយគ្មានការអនុញ្ញាតពីអ្នក ប៉ុន្តែមនុស្សនោះមិនបានបង្ខំឱ្យរួមភេទទេ | ០,៥ | ០,០ | ០,២ |
| ការព្យាយាមរួមរ័កជាមួយអ្នកតាមវិធីណាមួយដោយគ្មានការអនុញ្ញាត | ០,៦ | ០,០ | ០,៣ |
| អំពើហិង្សាផ្សេងៗទៀត | ២,៧ | ១,៨ | ២,២ |

## ទីកន្លែងរស់នៅ

តារាង៣បង្ហាញអំពីអត្រានៃភាពទទួលរងគ្រោះ បែងចែកតាមតំបន់ទីប្រជុំជន និងជនបទ ភេទនិងអាយុចាប់ពី៥ឆ្នាំឡើង មានអ្នកទទួលរងគ្រោះ១,១ភាគរយ សម្រាប់ទូទាំងប្រទេសកម្ពុជា នៅទីជនបទផ្សេងៗមានអ្នករងគ្រោះច្រើនជាង (០,២ភាគរយ) នៅទីប្រជុំជននៅក្នុងឆ្នាំ២០១៩/២០។ នៅទីប្រជុំជនមានស្ត្រីទទួលរងគ្រោះប្រមាណ០,៨ភាគរយ ទាបជាងបុរសទទួលរងគ្រោះប្រមាណ១.១ភាគរយ។ នៅតំបន់ជនបទមានអត្រាអ្នករងគ្រោះទាំងពីរភេទស្មើរតែដូចគ្នាប្រហែល១.០ភាគរយ។ ទោះជាយ៉ាងណា អត្រាជនរងគ្រោះមានអត្រាកម្រិតខ្ពស់បន្តិចនៅក្នុងឆ្នាំ២០១៩/២០ បើសិនប្រៀបធៀបទៅនឹងលទ្ធផលទិន្នន័យអង្កេតនៅឆ្នាំ២០១៤។

តារាង៣. អ្នកដែលទទួលរងគ្រោះដោយអំពើហិង្សា បែងចែកតាមភេទ និងអាយុ (៥ឆ្នាំឡើង) តាមតំបន់ (គិតជាភាគរយ)

| | ២០១៤ | | | ២០១៩/២០ | | |
|---|---|---|---|---|---|---|
| ទីកន្លែងរស់នៅ | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| កម្ពុជា | ០,៥ | ០,៤ | ០,៤ | ១,០ | ១,២ | ១,១ |
| ទីប្រជុំជន | ០,៥ | ០,៤ | ០,៤ | ០,៨ | ១,១ | ០,៩ |
| ជនបទ | ០,៥ | ០,៤ | ០,៤ | ១,១ | ១,២ | ១,១ |

បើប្រៀបធៀបប្រជាជនដែលបានទទួលរងគ្រោះដោយបែងចែកតាមភេទនៅក្នុងតំបន់ចំនួនប្រាំនៅកម្ពុជា ឃើញថានៅរាជធានីភ្នំពេញ មានអត្រាជនរងគ្រោះទាបបំផុតសម្រាប់ស្ត្រី(១,១ភាគរយ) នៅឆ្នាំ២០១៩/២០ ខណៈដែលតំបន់ឆ្នេរសមុទ្រមានអត្រាខ្ពស់បំផុត(១,៨ភាគរយ)សម្រាប់ទាំងស្ត្រី និងបុរស តំបន់វាលទំនាប(១,៣ភាគរយ) តំបន់ភ្នំ និងខ្ពង់រាប(១,២ភាគរយ)។ នៅតំបន់ឆ្នេរសមុទ្រមានស្ត្រី និងបុរសទទួលរងគ្រោះមានអត្រាខ្ពស់ជាងតំបន់ផ្សេងៗទៀត (ស្ត្រី១,៧ភាគរយ និងបុរស១,៨ភាគរយ)។ ទោះជាយ៉ាងណាក៏ដោយ អត្រារងគ្រោះនៅឆ្នាំ២០១៩/២០ គឺមានខ្ពស់ជាង បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។

តារាង៤. ប្រជាជនដែលទទួលរងគ្រោះដោយអំពើហិង្សាបែងចែកតាមភេទ និងតាមតំបន់ (គិតជាភាគរយ)

| តំបន់ | ២០១៤ | | | ២០១៩/២០ | | |
|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| កម្ពុជា | ០,៥ | ០,៤ | ០,៤ | ១,០ | ១,២ | ១,១ |
| រាជធានីភ្នំពេញ | ០,១ | ០ | 0.0 | 0.0 | ០,១ | ០,១ |
| តំបន់វាលទំនាប | ០,៧ | ០,៥ | ០,៦ | ១,១ | ១,៥ | ១,៣ |
| តំបន់ទន្លេសាប | ០,៤ | ០,៥ | ០,៤ | ១,០ | ១,១ | ១,០ |
| តំបន់ឆ្នេរសមុទ្រ | ០,៣ | ០,៥ | ០,៤ | ១,៧ | ១,៨ | ១,៨ |
| តំបន់ភ្នំ និងខ្ពង់រាប | ០,៥ | ០,៤ | ០,៤ | ១,២ | ១,២ | ១,២ |

## ស្ថានភាពអាពាហ៍ពិពាហ៍ ការសិក្សា និង អក្ខរភាព

តារាង៥ បង្ហាញអំពីអត្រានៃភាពទទួលរងគ្រោះ បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ សម្រាប់ប្រជាជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើង។ ផ្អែកតាមលទ្ធផលឃើញថា ស្ត្រីនិងបុរសដែលមិនធ្លាប់បានរៀបការហាក់ដូចជាមានអត្រានៃភាពទទួលរងគ្រោះខ្ពស់បន្តិចមានប្រមាណ ១,១ភាគរយ និង ១,២ភាគរយ នៅក្នុងឆ្នាំ២០១៩/២០ តាមលំដាប់រៀង។ ចំពោះស្ថានភាពអាពាហ៍ពិពាហ៍ផ្សេងទៀត លទ្ធផលទិន្នន័យអង្កេតបានបង្ហាញថាមានប្រមាណ ០,៦ភាគរយ(ទាំងពីរភេទ) ០,៧ភាគរយ(ស្ត្រី) និង០,៥ភាគរយ(បុរស)។ (សូមមើលតារាង៥សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៥. ប្រជាជនដែលទទួលរងគ្រោះដោយអំពើហិង្សាអាយុចាប់ពី១៥ឆ្នាំឡើង បែងចែកតាមស្ថានភាពអាពាហ៍ពិពាហ៍ (គិតជាភាគរយ)**

| | ២០១៤ | | | ២០១៩/២០ | | |
|---|---|---|---|---|---|---|
| ស្ថានភាពអាពាហ៍ពិពាហ៍ | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| រៀបការហើយ/រស់នៅជាមួយដៃគូ | ០,៦ | ០,៣ | ០,៤ | ០,៧ | ០,៥ | ០,៦ |
| លែងលះ/បែកបាក់គ្នា | ០,៤ | – | ០,៣ | ០,៥ | – | ០,៣ |
| ពោះម៉ាយ/មេម៉ាយ | ០,៤ | ០,៣ | ០,៤ | ០,៣ | ០,៥ | ០,៣ |
| មិនដែលរៀបការ | ០,៤ | ០,៥ | ០,៤ | ១,១ | ១,២ | ១,២ |

តារាង៦ បង្ហាញពីហានិភ័យនៃភាពទទួលរងគ្រោះ គឺមានលក្ខណៈខ្ពស់បន្តិច ចំពោះប្រជាជនដែលមិនអាចអាននិងសរសេរអក្សរ (ប្រជាជនដែលជាអនក្ខរជន)មានអាយុចាប់ពី១៥ឆ្នាំឡើង។ សម្រាប់ប្រជាជនដែលមិនបានបញ្ចប់ថ្នាក់បឋមសិក្សា ដែលមានអត្រាទាបបំផុតមានប្រមាណ ០,៤ភាគរយ ចំណែកអ្នកដែលបានបញ្ចប់បឋមសិក្សាមានអត្រាខ្ពស់បំផុត១,០ភាគរយ។ (សូមមើលតារាង៦ សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៦. ប្រជាជនដែលទទួលរងគ្រោះ ដោយអំពើហិង្សាអាយុចាប់ពី១៥ឆ្នាំឡើង បែងចែកតាមអក្ខរកម្មរបស់មនុស្សពេញវ័យ និងកម្រិតសិក្សាខ្ពស់បំផុត (គិតជាភាគរយ)**

| | ២០១៤ | ២០១៩/២០ |
|---|---|---|
| អាចអាន និងសរសេរបាន | ០,៤ | ០,៧ |
| មិនអាចអាន និងសរសេរបាន | ០,៥ | ០,៨ |
| គ្មាន ឬ មានការសិក្សាតិចតួច | ០,២ | _ |
| មិនបានបញ្ចប់បឋមសិក្សា | ០,៧ | ០,៤ |
| បានបញ្ចប់បឋមសិក្សា | ០,៣ | ១,០ |
| មធ្យមសិក្សា និងកម្រិតខ្ពស់ជាង | ០,៤ | ០,៧ |
| ផ្សេងៗ | _ | _ |

## ភាពទទួលរងគ្រោះនៃអំពើហិង្សាញឹកញាប់ និងការជាប់ទាក់ទងនឹងជនល្មើស

តារាង៧ បង្ហាញអំពីភាពទទួលរងគ្រោះញឹកញាប់ ដោយអំពើហិង្សាបែងចែកតាមភេទ។ តាមលទ្ធផលទិន្នន័យអង្កេតក្នុងឆ្នាំ២០១៩/២០ បង្ហាញថាប្រជាជនដែលទទួលរងគ្រោះច្រើនជាងម្តងមានប្រមាណ៩៤ភាគរយ នៃប្រជាជនរងគ្រោះសរុប។ អត្រានៃភាពទទួលរងគ្រោះដោយអំពើហិង្សាញឹកញាប់សម្រាប់ស្ត្រី (អត្រា៩៥ភាគរយ) គឺមានកម្រិតខ្ពស់ជាងបុរស(៩៣ភាគរយ)។ សម្រាប់ប្រជាជនដែលទទួលរងគ្រោះញឹកញាប់ដោយអំពើ

ហិង្សាចាប់ពីពីរទៅបួន-ប្រាំបួនដងគឺបុរសមានភាគរយច្រើនជាងស្ត្រី ប៉ុន្តែប្រជាជនដែលទទួលរងគ្រោះញឹកញាប់ដោយអំពើហិង្សាចាប់ពីមួយដង ដល់ដប់ដង ឬច្រើនជាងនេះឡើងទៅ គឺស្ត្រីមានភាគរយខ្ពស់ជាងបុរសវិញ។ ជាទូទៅអត្រានៃភាពទទួលរងគ្រោះញឹកញាប់ដោយអំពើហិង្សាមានលក្ខណៈខុសគ្នាច្រើនដែលគួរឱ្យកត់សម្គាល់ បើពិនិត្យមើលតាមទ្រឹស្តីស្ថិតិ។ (សូមមើលតារាង៧ សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៧. ភាពទទួលរងគ្រោះដោយអំពើហិង្សាញឹកញាប់ បែងចែកតាមភេទ (គិតជាភាគរយ)**

| | ២០១៤ | | | ២០១៩/២០ | | |
|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ |
| ការទទួលរងគ្រោះញឹកញាប់ (>១) | ៨១,៧ | ៧៣,៧ | ៧៨,១ | ៩៤,៩ | ៩២,៩ | ៩៣,៩ |
| រងគ្រោះម្តង | ១៨,៣ | ២៦,៣ | ២១,៩ | ៥,០ | ៧,១ | ៦,២ |
| រងគ្រោះពីរដង | ១៨,៩ | ២០,៩ | ១៩,៨ | ២៦,៩ | ២២,៣ | ២៤,៤ |
| រងគ្រោះបីដង | ១៩,៥ | ២៥,៣ | ២២,១ | ៣៤,៩ | ៣០,៣ | ៣២,៥ |
| រងគ្រោះចាប់ពី៤ដង ដល់៩ដង | ១៨,៥ | ១២,៨ | ១៦,០ | ២២,៤ | ២១,៩ | ២២,១ |
| រងគ្រោះលើសពី១០ដង | ២៤,៨ | ១៤,៧ | ២០,៣ | ១០,៧ | ១៨,៤ | ១៤,៨ |
| ប្រជាពលរដ្ឋរងគ្រោះសរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ការរាយការណ៍អំពីអំពើហិង្សា និងការដាក់ពាក្យបណ្តឹងទៅតុលាការ

តារាង៨បានបង្ហាញអ្នកដែលបានប្រើនៅអំពើហឹង្សាបានរាយការណ៍អំពីអំពើហិង្សា ក្នុងចំណោមអ្នករងគ្រោះនៅឆ្នាំ២០១៩/២០(ប្រហែល១ភាគរយ ឬ ចំនួន១៥១.៩៨៥នាក់) មានប្រមាណ៦ភាគរយសម្រាប់សំណួរត្រូវបានសួរដោយយោងលើព្រឹត្តិការណ៍ នៃអំពើហិង្សាកើតឡើងចុងក្រោយបំផុតដែលប្រព្រឹត្តិដោយជនល្មើស(បើសិនមានព្រឹត្តិការណ៍លើសពីម្តង)។ចំពោះការរាយការណ៍ពីសកម្មភាពហិង្សារវាងស្ត្រី និងបុរស ដែលបានទទួលរងគ្រោះឃើញថាមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់។ ករណីស្ត្រីទទួលរងគ្រោះដោយអំពើហិង្សា (៨ភាគរយ) ដែលបានរាយការណ៍ច្រើនជាងបុរសទទួលរងគ្រោះ (៣ភាគរយ)។ (សូមមើលតារាង៨សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៨. ប្រជាជនដែលទទួលរងគ្រោះដោយអំពើហិង្សា ហើយបានរាយការណ៍ពីសកម្មភាពនៃអំពើហិង្សា (គិតជាភាគរយ)**

| | ២០១៩/២០ | | |
|---|---|---|---|
| ការរាយការណ៍ពីសកម្មភាពអំពើហិង្សា | ស្ត្រី | បុរស | ទាំងពីរភេទ |
| ប្រជាជនដែលទទួលរងគ្រោះគិតជាភាគរយក្នុងចំណោមប្រជាជនសរុប (អាយុ៥ឆ្នាំឡើង) | ១,០ | ១,២ | ១,១ |
| ចំនួនប្រជាជនដែលទទួលរងគ្រោះ | ៧០.៨៨១ | ៨១.១០៤ | ១៥១.៩៨៥ |
| ប្រជាជនរងគ្រោះដែលបានរាយការណ៍ពីសកម្មភាពអំពើហិង្សាគិតជាភាគរយក្នុងចំណោមប្រជាជនរងគ្រោះសរុប | ៨,១ | ៣,៤ | ៥,៦ |

នៅក្នុងតារាង៩ បានបង្ហាញការបែងចែកប្រជាជនទទួលរងគ្រោះ ដោយអំពើហិង្សាដែលបានរាយការណ៍អំពីបទល្មើស។ អត្រានៃប្រជាជនទទួលរងគ្រោះដែលបានរាយការណ៍អំពីបទល្មើសជូនដល់អាជ្ញាធរមួយចំនួនដូច

ជា(នគរបាល មេភូមិ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត) ហាក់ដូចជាមានកម្រិតខ្ពស់នៅតំបន់ជនបទ ជាងនៅតំបន់ទីប្រជុំជន។ នៅតំបន់ជនបទ ស្ត្រីដែលទទួលរងគ្រោះ (១០ភាគរយ) បានរាយការណ៍អំពីបទល្មើសទៅកាន់អាជ្ញាធរ មានសមត្ថកិច្ចច្រើនជាងបុរសមានអត្រាប្រមាណ ២ភាគរយ នៅក្នុងឆ្នាំ២០១៩/២០។

**តារាង៩. ប្រជាជនរងគ្រោះដោយអំពើហិង្សា ហើយបានរាយការណ៍ពីបទល្មើសជូនដល់អាជ្ញាធរ បែងចែកតាមទីកន្លែងរស់នៅ និងតាមភេទ (គិតជាភាគរយ)**

| | ២០១៩/២០ | | |
|---|---|---|---|
| បែងចែកតាមតំបន់ | ស្ត្រី | បុរស | ទាំងពីរភេទ |
| កម្ពុជា | ៨,១ | ៣,៤ | ៥,៦ |
| ទីប្រជុំជន | ៤,៣ | ៦,៥ | ៥,៦ |
| ជនបទ | ១០,១ | ១,៦ | ៥,៧ |

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា ក៏បានបង្ហាញផងដែរពីបទពិសោធន៍របស់ប្រជាជនដែលទទួលរងគ្រោះនូវសកម្មភាពនៃអំពើហិង្សា។ ជារឿយៗមានពីរប្រភេទនៃបទពិសោធន៍ពីសកម្មភាព នៃអំពើហិង្សាដែលពួកគេបានប្រឈមគឺ "ការភ័យខ្លាច ឬស្រេស" ដែលមានអត្រាប្រមាណ ៨៧ភាគរយ ។ សម្រាប់បទពិសោធន៍ទាំងស្ត្រី និងបុរសដែលទទួលរងគ្រោះនូវសកម្មភាព នៃអំពើហឹង្សាតាមប្រភេទនីមួយៗ មានអត្រាប្រហាក់ប្រហែលគ្នា ដែលស្ត្រីមានប្រមាណ ៨២ភាគរយ និងបុរសមានប្រមាណ៩៣ភាគរយ ។ (សូមមើលតារាង១០សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១០. បទពិសោធន៍ពីអំពើហិង្សា បែងចែកតាមភេទ (គិតជាភាគរយ)**

| លទ្ធផលពីអំពើហិង្សាគ្រប់ប្រភេទ | អសសក ២០១៩/២០ | | |
|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ |
| ប្រជាជនរងគ្រោះដែលជាលទ្ធផលពីអំពើហិង្សាគ្រប់ប្រភេទ | ១០០ | ១០០ | ១០០ |
| ការភ័យខ្លាច ឬការថប់បារម្ភ | ៨២,១ | ៩២,៦ | ៨៧,៤ |
| ការដាច់ រលាត់ ជាំ ឈឺចាប់ ស្នាមក្រហម ហើម ឬស្លាកស្នាមតិចតួចផ្សេងទៀត | ១៤,៨ | ៦,៤ | ១០,៥ |
| ការគ្រេច ភ្លាត់ឆ្អឹង ឬពងស្បែក | ២,៣ | 0.0 | ១,១ |
| ការរងរបួសជ្រៅ បាក់ឆ្អឹង បាក់ធ្មេញ ឬធ្វើឱ្យខ្លោច ឬខ្មៅស្បែក | ០,៩ | ១,០ | ០,៩ |
| ការរងរបួសអចិន្ត្រៃយ៍ ឬខូចសម្ផស្ស | 0.0 | 0.0 | 0.0 |
| ការរលូតកូន | 0.0 | 0.0 | 0.0 |

តារាង១១បង្ហាញអំពីជនរងគ្រោះដែលបានរាយការណ៍អំពីអំពើហិង្សាក្នុងឆ្នាំ២០១៩/២០ មានប្រមាណ៦ភាគរយ។ ផ្អែកតាមលទ្ធផលបានបង្ហាញថាប្រជាជនដែលទទួលរងគ្រោះពីទង្វើនៃអំពើហិង្សាប្រមាណ ២៤ភាគរយ នៃប្រជាជនរងគ្រោះទាំងអស់ បានរាយការណ៍ជូននគរបាល ខណៈដែលមាន៤១ភាគរយផ្សេងទៀតបានរាយការណ៍

ជូនមេភូមិ។ ដោយឡែកមាន៣៥ភាគរយបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងអំពើបទល្មើស។ ចំពោះការអនុវត្តនូវនីតិវិធីតុលាការ ប្រជាជនដែលទទួលរងគ្រោះមានប្រមាណ១៣ភាគរយបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងជនល្មើសអំពីទង្វើហិង្សា ដើម្បីបញ្ចប់រឿងក្តី។ សម្រាប់ស្ត្រីព្រឹត្តិការណ៍នៃអំពើហិង្សា(១៤ភាគរយ)ដែលបានទទួលរងមានច្រើនជាងបុរស( ១២ភាគរយ) ចំពោះករណីមានដាក់បណ្តឹងទៅកាន់តុលាការ។ (មើលតារាង១១សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១១. ព្រឹត្តិការណ៍អំពើហិង្សាដែលបានរាយការណ៍បែងចែកតាមភេទ (គិតជាភាគរយ)**

| ការរាយការណ៍ពីសកម្មភាពអំពើហិង្សា | អសសក ២០១៩/២០ | | |
|---|---|---|---|
| | ស្ត្រី | បុរស | ទាំងពីរភេទ |
| ប្រជាជនដែលទទួលរងគ្រោះដោយអំពើហិង្សាគិតជាភាគរយ | ១,០ | ១,២ | ១,១ |
| ប្រជាជនដែលបានរាយការណ៍អំពីបទឧក្រិដ្ឋគិតជាភាគរយក្នុងចំណោមប្រជារាស្ត្ររងគ្រោះទាំងអស់ (អាយុ៥ឆ្នាំឡើង) | ៨,១ | ៣,៤ | ៥,៦ |
| ប្រជាជនរងគ្រោះទាំងអស់ដែលបានរាយការណ៍អំពីបទឧក្រិដ្ឋគិតជាភាគរយ | ១០០ | ១០០ | ១០០ |
| ប្រជាជនរងគ្រោះដែលបានរាយការណ៍ជូននគរបាលគិតជាភាគរយក្នុងចំណោមប្រជាជនទាំងអស់ដែលបានរាយការណ៍អំពីបទឧក្រិដ្ឋ | ២៧,០ | ១៨,៧ | ២៤,២ |
| ប្រជាជនរងគ្រោះដែលបានរាយការណ៍ជូនមេភូមិគិតជាភាគរយក្នុងចំណោមប្រជាជនទាំងអស់ដែលបានរាយការណ៍អំពីបទឧក្រិដ្ឋ | ៤១,៣ | ៣៩,១ | ៤០,៦ |
| ប្រជាជនរងគ្រោះដែលបានរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត និងក្រុមគ្រួសារខ្លួនផ្ទាល់គិតជាភាគរយក្នុងចំណោមប្រជាជនទាំងអស់ដែលបានរាយការណ៍អំពីបទឧក្រិដ្ឋ | ៣១,៨ | ៤២,១ | ៣៥,៣ |
| ព្រឹត្តិការណ៍ដែលបានប្តឹងទៅតុលាការគិតជាភាគរយក្នុងចំណោមប្រជាជនរងគ្រោះទាំងអស់ដែលបានរាយការណ៍អំពីបទឧក្រិដ្ឋ | ១៣,៧ | ១២,២ | ១៣,២ |

## ៨.៤ គ្រួសារដែលរងគ្រោះដោយបទល្មើសទ្រព្យសម្បត្តិ

ក្នុងផ្នែកនេះ ទស្សនាទាននៃបទល្មើសទ្រព្យសម្បត្តិត្រូវបានយកមកប្រើ ដោយរួមមានសកម្មភាព លួចឆក់ លបចូលផ្ទះ និងប្លន់ ។ សំណួរដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះត្រូវបានសួរជាមួយមេគ្រួសារ។ ផ្អែកតាមលទ្ធផលបានបង្ហាញថាគ្រួសារដែលទទួលរងគ្រោះដោយបទល្មើសទ្រព្យសម្បត្តិ គឺស្ទើរតែមានអត្រាដូចគ្នាទាំងនៅក្នុងទីប្រជុំជន និងនៅជនបទសម្រាប់ឆ្នាំ២០១៩/២០ ដែលមានប្រមាណ៩ភាគរយ និង១០ភាគរយ តាមលំដាប់រៀង។ ផ្អែកលទ្ធផលបានបង្ហាញថា អត្រានៃភាពទទួលរងគ្រោះដោយគ្រួសារពីបទល្មើសទ្រព្យសម្បត្តិ គឺមានអត្រា ៩,៥ភាគរយ នៅឆ្នាំ២០១៩/២០។ ( សូមមើលតារាង១២ សម្រាប់ព័ត៌មានបន្ថែម)។

តារាង១២. ការទទួលរងគ្រោះដោយបទល្មើសទ្រព្យសម្បត្តិ បែងចែកតាមទីកន្លែងរស់នៅឆ្នាំ២០១៤ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| ទីកន្លែងរស់នៅ | ២០១៩/២០ |
|---|---|
| គ្រួសារដែលទទួលរងគ្រោះគិតជាភាគរយក្នុងចំណោមគ្រួសារទាំងអស់ | ៩,៥ |
| គ្រួសារដែលទទួលរងគ្រោះគិតជាភាគរយក្នុងចំណោមគ្រួសារទាំងអស់ដែលរស់នៅក្នុងតំបន់ | |
| ទីប្រជុំជន | ៩,១ |
| ជនបទ | ៩,៨ |

## ៨.៥ អារម្មណ៍សុវត្ថិភាព

អ្នកផ្តល់ចម្លើយនៅក្នុងផ្នែកនេះគឺជាមេគ្រួសារ ឬប្តី/ប្រពន្ធមេគ្រួសារ។ អ្នកផ្តល់ចម្លើយត្រូវបានសួរថា តើពួកគាត់មានអារម្មណ៍សុវត្ថិភាពពីសកម្មភាពនៃបទល្មើស និងអំពើហិង្សាដែរឬទេ នៅទីកន្លែងដែលពួកគាត់រស់នៅដែលទាក់ទងនឹងសុវត្ថិភាពសម្រាប់គ្រួសារទាំងមូល (សូមមើលផ្នែកភាពទទួលរងគ្រោះនៅក្នុងតារាងសំណួរគ្រួសារ នៃឧបសម្ព័ន្ធ)។ ចរិតលក្ខណៈនៅក្នុងផ្នែកនេះ គឺសំដៅលើការផ្តល់ចម្លើយរបស់មេគ្រួសារ។ តាមលទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បានបង្ហាញថា ជារួមទូទៅមានមេគ្រួសារប្រមាណ ៨៩ភាគរយ មានអារម្មណ៍សុវត្ថិភាពពីសកម្មភាពនៃបទល្មើសនៅទីកន្លែងដែលពួកគាត់រស់នៅ។ ចំពោះអារម្មណ៍សុវត្ថិភាពសម្រាប់ទាំងស្ត្រីនិងបុរសជាមេគ្រួសារ គឺពុំទាន់ឃើញមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់នោះឡើយ។ (សូមមើលតារាង១៣.១ សម្រាប់ព័ត៌មានបន្ថែម)។

តារាង១៣.១ អារម្មណ៍សុវត្ថិភាពពីបទល្មើស បែងចែកតាមទីកន្លែងរស់នៅ និងតាមភេទនៃមេគ្រួសារ (គិតជាភាគរយ)

| អារម្មណ៍សុវត្ថិភាពនិងទីកន្លែងរស់នៅ | អសសក ២០១៩/២០ | | |
|---|---|---|---|
| | ស្ត្រីជាមេគ្រួសារ | បុរសជាមេគ្រួសារ | គ្រួសារទាំងអស់ |
| អារម្មណ៍សុវត្ថិភាពពីបទឧក្រិដ្ឋ និង អំពើហិង្សា នៅទីកន្លែងរស់នៅ | ៨៨,៨ | ៨៩,០ | ៨៩,០ |
| មេគ្រួសារមានអារម្មណ៍សុវត្ថិភាព ពីបទឧក្រិដ្ឋ និងអំពើហិង្សា នៅទីកន្លែងរស់នៅ គិតជាភាគរយក្នុងចំណោមមេគ្រួសារទាំងអស់ដែលរស់នៅក្នុងតបន់: | | | |
| ទីប្រជុំជន | ៨៧,៩ | ៨៩,៦ | ៨៩,១ |
| ជនបទ | ៨៩,៥ | ៨៨,៧ | ៨៨,៨ |

អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ បានបង្ហាញថា ជារួមទូទៅមានមេគ្រួសារប្រមាណ ៨៩ភាគរយ មានអារម្មណ៍សុវត្ថិភាពពីសកម្មភាព នៃអំពើហិង្សានៅទីកន្លែងដែលពួកគាត់រស់នៅ។ ចំពោះអារម្មណ៍សុវត្ថិភាពសម្រាប់ទាំងស្ត្រី និងបុរសជាមេគ្រួសារ គឺពុំទាន់ឃើញមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់នោះឡើយ។ (សូមមើលតារាង១៣.២ សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១៣.២ អារម្មណ៍សុវត្ថិភាពពីអំពើហិង្សា បែងចែកតាមទីកន្លែងរស់នៅ និងតាមភេទនៃមេគ្រួសារ (គិតជាភាគរយ)**

| អារម្មណ៍សុវត្ថិភាពនិងទីកន្លែងរស់នៅ | អសសក ២០១៩/២០ | | |
|---|---|---|---|
| | ស្ត្រីជាមេគ្រួសារ | បុរសជាមេគ្រួសារ | គ្រួសារទាំងអស់ |
| អារម្មណ៍សុវត្ថិភាពពីបទល្មើស និង អំពើហិង្សា នៅទីកន្លែងរស់នៅ | ៨៣,៥ | ៨៣,០ | ៨៣,១ |
| មេគ្រួសារមានអារម្មណ៍សុវត្ថិភាព ពីបទល្មើស និងអំពើហិង្សា នៅទីកន្លែងរស់នៅ គិតជាភាគរយក្នុងចំណោមមេគ្រួសារទាំងអស់ដែលរស់នៅក្នុងតបន់: | | | |
| ទីប្រជុំជន | ៨៥,០ | ៨៤,២ | ៨៤,៤ |
| ជនបទ | ៨២,៥ | ៨២,៣ | ៨២,៣ |

## ៨.៦ គ្រួសារដែលរងគ្រោះដោយឧបទ្ទវហេតុ (គ្រោះថ្នាក់)

រូបភាព៧២ បង្ហាញអំពីអត្រានៃឧបទ្ទវហេតុ (គ្រោះថ្នាក់) នៅតាមតំបន់ភូមិសាស្ត្រក្នុងប្រទេសកម្ពុជាឆ្នាំ ២០១៤ និងឆ្នាំ២០១៩/២០។ ផ្អែកតាមលទ្ធផលឃើញថា មានការកើនឡើងគួរឱ្យកត់សម្គាល់នៃឧបទ្ទវហេតុ (គ្រោះថ្នាក់) នៅតាមតំបន់ភូមិសាស្ត្រទាំងអស់ ចាប់តាំងពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០។ នៅរាជធានីភ្នំពេញ អត្រានៃឧបទ្ទវហេតុ (៨ភាគរយ) មានអត្រាកម្រិតខ្ពស់ជាងនៅតំបន់ទីប្រជុំជនមានប្រមាណ ៤ភាគរយ និងនៅតំបន់ជនបទ មានប្រមាណ ៣ភាគរយ។

**រូបភាព៧២. ឧបទ្ទវហេតុ (គ្រោះថ្នាក់) បែងចែកតាមតំបន់ភូមិសាស្ត្រ (គិតជាភាគរយ) ឆ្នាំ២០១៤ ឆ្នាំ២០១៩/២០**



# ផ្នែកទី៩ ប្រាក់ចំណូល និងបំណុលគ្រួសារ

## ៩.១ និយមន័យ និងវិធីសាស្ត្រនៃការចងក្រងស្ថិតិចំណូលគ្រួសារ

### ទស្សនាទានអំពីចំណូល

នៅឆ្នាំ២០១៩/២០ គ្រួសារដែលបានខ្ចីប្រាក់គឺគោលបំណងចម្បងសម្រាប់តម្រូវការប្រើប្រាស់ក្នុងគ្រួសារមានប្រមាណ ២៦ភាគរយ ក្នុងចំណោមគោលបំណងទាំងអស់។ គោលបំណងទី២នៃការខ្ចីប្រាក់គឺសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពកសិកម្មដែលមានប្រមាណ១៧ភាគរយ និងគោលបំណងទី៣ គឺសម្រាប់សកម្មភាពទិញ/កែលំអរលំនៅដ្ឋានមានប្រមាណ ១៦ភាគរយ។ ប្រាក់កម្ចីសម្រាប់ជាតម្រូវការប្រើប្រាស់ក្នុងគ្រួសារ គឺជាមូលហេតុទូទៅក្នុងចំណោមមូលហេតុទាំងអស់នៅគ្រប់តំបន់ភូមិសាស្ត្រក្នុងប្រទេសកម្ពុជា។ សម្រាប់គ្រួសារនៅរាជធានីភ្នំពេញមានប្រមាណ ២២ភាគរយ សម្រាប់គ្រួសារនៅតំបន់ទីប្រជុំជនផ្សេងៗមានប្រមាណ ២៦ភាគរយ និងគ្រួសារនៅតំបន់ជនបទមានប្រមាណ ២៦ភាគរយ។ (សូមមើលតារាង១០ សម្រាប់ព័ត៌មានបន្ថែម)

**តារាង ១០. សមតុល្យប្រាក់កម្ចី/បំណុលមិនទាន់សងគិតជាមធ្យម បែងចែកតាមគោលបំណងនៃការខ្ចីប្រាក់ និងតាមតំបន់ភូមិសាស្ត្រ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០ (គិតជាពាន់រៀល និងចំណែកភាគរយ)**

| គោលបំណងនៃការខ្ចីប្រាក់ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | |
|---|---|---|---|---|---|
| | សមតុល្យប្រាក់កម្ចី/បំណុលជាមធ្យម គិតជាពាន់រៀល | | | | |
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| **កម្ពុជា** | | | | | |
| សកម្មភាពកសិកម្ម | ៣.៨៤៨ | ៤.៥៤៤ | ៧.៨៦៣ | ៨.០៩៦ | ១៣.២៧៧ |
| សកម្មភាពមិនមែនកសិកម្ម | ៥.៨៨៤ | ៦.៨៩៦ | ១៣.៧៧៦ | ១៣.៧៥២ | ២៩.៥៧០ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ២.៨៣៨ | ៣.៨៩៩ | ៥.២៥៥ | ៦.២៣៩ | ១១.០៩៣ |
| ជំងឺ របួស គ្រោះថ្នាក់ | ២.៦៧១ | ៣.៧២១ | ២.៨៤៨ | ៤.៤៦៥ | ៦.៩៤១ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ១.៥៥១ | ៤.៣០០ | ២.៤០០ | ១២០.៣២០ | ០ |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ៣.៣៨៧ | ៣.៥២២ | ៣.២៦៩ | ៤.៩១៦ | ៧.៦៧០ |
| ទិញ/កែលំអរលំនៅដ្ឋាន | ៥.៥២៥ | ៧.៣១៦ | ៩.២៩៧ | ១៧.៨១៤ | ២៤.៦៦២ |
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ៥.០៨៨ | ៧.៥៥៥ | ៧.៤៣៣ | ៩.៥០៣ | ១៦.៩៨៤ |
| សេវាកម្មនិងការជាប់បំណុល | ៦.៥៨១ | ៩.០២៣ | ១០.៩៧៩ | ១១.២០០ | ២៣.៤១៥ |
| ផ្សេងៗ | ៣.៧៦១ | ៩.២៩៧ | ៨.៩៨២ | ៩.៩៧២ | ២៥.៤៧៣ |
| **រាជធានីភ្នំពេញ** | | | | | |
| សកម្មភាពកសិកម្ម | ៧៨០ | ០ | ០ | ៥.០០០ | ៨.៤៥៣ |
| សកម្មភាពមិនមែនកសិកម្ម | ៨.០៤២ | ៦.៤១០ | ២៦.៦៩៦ | ១៨.៥៥៨ | ៥១.០៥០ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ៣.៨៧៧ | ៨.០៧៥ | ៩.២៩៥ | ១២.២២៩ | ២២.៣៨១ |
| ជំងឺ របួស គ្រោះថ្នាក់ | ៥.១៩២ | ១៣.០៦៣ | ១.៨១៦ | ៣.៨៩៨ | ១៩.៨៦២ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ០ | ៤.៣០០ | ២.៤០០ | ១២០.៣២០ | ០ |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ១០.៥៨២ | ២.៦៩០ | ០ | ០ | ៤២.១៩២ |
| ទិញ/កែលំអរលំនៅដ្ឋាន | ១៤.៤១២ | ១៤.៥១៣ | ១០.៨៩១ | ២៣.៥៩៥ | ៤៤.៩៦៨ |

| | | | | | |
|---|---|---|---|---|---|
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ៥.៩៦៤ | ១០.៧១៦ | ២០.៨៥៧ | ១១.២១៣ | ២១.៣០១ |
| សេវាកម្មនិងការជាប់បំណុល | ៧.០២០ | ១៩.១៥៣ | ២២.៣៧៤ | ៩.៨៧៤ | ៣៨.០៩៩ |
| ផ្សេងៗ | ១៨.០០០ | ២.០០០ | ០ | ២២.០០០ | ២៨.២៤០ |
| **ទីប្រជុំជនផ្សេងៗ** | | | | | |
| សកម្មភាពកសិកម្ម | ៤.០២០ | ៥.៤៦៣ | ៩.០៣២ | ១៧.៤៤១ | ២១.០០៣ |
| សកម្មភាពមិនមែនកសិកម្ម | ១០.៥៣១ | ១២.១៤២ | ១៨.៧៩៣ | ១៨.១០៨ | ៣៦.៦៩៩ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ៤.៨៦៩ | ៥.១១៩ | ៨.៤៩៧ | ៦.៨៨៤ | ១៤.៣៣៥ |
| ជំងឺ របួស គ្រោះថ្នាក់ | ៣.២៤៨ | ៥.០៦៥ | ៣.២២៦ | ៦.១១៤ | ៨.៩៤៦ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ៤.០០០ | ០ | ០ | ០ | ០ |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ២.៦២៤ | ៥.៥០៩ | ៣.៣៩៦ | ៤.៤០២ | ១៣.៣៤៨ |
| ទិញ/កែលំអរលំនៅដ្ឋាន | ១០.០៣០ | ១៥.៥៦២ | ១៩.៦៦៦ | ៣៥.៩៤៣ | ៣១.៣១៥ |
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ៧.៥៦២ | ៥.៤០៧ | ៩.៥៣៥ | ១៤.៩៦៨ | ២១.២៨៨ |
| សេវាកម្មនិងការជាប់បំណុល | ១០.៣០៦ | ១៤.២៧៦ | ១៥.៧៦៤ | ២៧.២៣៣ | ២៥.៦៩០ |
| ផ្សេងៗ | ៨.៧២១ | ៣៣.១៨០ | ៣០.២២២ | ៣៩.៨៩១ | ៣៣.៦៧៩ |
| **ទីជនបទផ្សេងៗ** | | | | | |
| សកម្មភាពកសិកម្ម | ៣.៨៥៧ | ៤.៥០១ | ៧.៨២២ | ៧.៦៤៣ | ១២,៤៣៨ |
| សកម្មភាពមិនមែនកសិកម្ម | ៤.៧៣៧ | ៥.៩៥៨ | ១២.៣៥៨ | ១២.៧៥៩ | ២៣.៨៥៧ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ២.៥២៥ | ៣.៦៧៦ | ៤.៧២៣ | ៥.៦៦៩ | ៨.៦៩២ |
| ជំងឺ របួស គ្រោះថ្នាក់ | ២.៤៨៣ | ៣.៣៤៧ | ២.៨២៦ | ៤.៣៣៧ | ៤.៦៥០ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ១.០៧២ | ០ | ០ | ០ | ០ |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ៣.១៤៣ | ៣.១៤៩ | ៣.២៥៧ | ៤.៩៧៣ | ៤.២៤៦ |
| ទិញ/កែលំអរលំនៅដ្ឋាន | ៤.៤៥៧ | ៥.៧៤៦ | ៧.១៧៧ | ១៣.៩១៥ | ១៥.៩៦៨ |
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ៤.៥៩០ | ៧.៨១៧ | ៦.៦១៧ | ៨.៨៨៧ | ១៣.៨៣៨ |
| សេវាកម្មនិងការជាប់បំណុល | ៦.០៣៧ | ៤.៤២៦ | ៩.៦០៨ | ៩.២០៤ | ១៦.០២១ |
| ផ្សេងៗ | ២.៣៦៤ | ៨០០ | ៧.០៥២ | ៦.៣៨៣ | ១៩.៩០៨ |
| ចំណែក ភាគរយនៃសមតុល្យប្រាក់កម្ចីតាមគោលបំណង | | | | | |
| **កម្ពុជា** | | | | | |
| សកម្មភាពកសិកម្ម | ២៧,១ | ១៩,៧ | ២០,៧ | ១៧,៩ | ១៦,៦ |
| សកម្មភាពមិនមែនកសិកម្ម | ១៣,៣ | ១១,៤ | ១១,៨ | ១១,១ | ១២,៣ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ២៩,១ | ៣៧,៣ | ៣៣,៣ | ២៩,៦ | ២៥,៧ |
| ជំងឺ របួស គ្រោះថ្នាក់ | ៧,៥ | ៧,៤ | ៦,៨ | ៥,៩ | ៤,៦ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ០,១ | ០,១ | ០,០ | ០,០ | - |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ២,៦ | ២,៦ | ១,៨ | ២,២ | ១,២ |
| ទិញ/កែលំអរលំនៅដ្ឋាន | ៩,០ | ៩,៧ | ១០,៣ | ១២,៨ | ១៦,៤ |
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ៨,០ | ៨,៧ | ៩,៩ | ១២,៨ | ១៤,២ |
| សេវាកម្មនិងការជាប់បំណុល | ២,៧ | ២,៩ | ៤,១ | ៦,១ | ៦,១ |

| | | | | | |
|---|---|---|---|---|---|
| ផ្សេងៗ | ០,៧ | ០,២ | ១,៣ | ១,៤ | ៣,១ |
| **រាជធានីភ្នំពេញ** | | | | | |
| សកម្មភាពកសិកម្ម | ៤,៤ | ០,០ | - | ១,២ | ១,៧ |
| សកម្មភាពមិនមែនកសិកម្ម | ១៥,៥ | ១១,៨ | ៧,៨ | ៥,៨ | ១២,១ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ៣៧,៨ | ៤០,៩ | ៤៤,៩ | ៥៥,១ | ២២,០ |
| ជំងឺ របួស គ្រោះថ្នាក់ | ៩,៩ | ៥,៣ | ៥,៩ | ២,៤ | ៥,៥ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ០,០ | ៣,៤ | ១,៨ | ១,៣ | - |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ២,៩ | ២,៣ | - | - | ០,៨ |
| ទិញ/កែលំអរលំនៅដ្ឋាន | ១៣,១ | ១២,៧ | ១៩,៩ | ១៥,៧ | ២២,៧ |
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ៨,៤ | ៨,១ | ១០,៥ | ១៣,៩ | ១៦,៣ |
| សេវាកម្មនិងការជាប់បំណុល | ៧,៤ | ១៣,៣ | ៩,២ | ៣,៦ | ១៧,៧ |
| ផ្សេងៗ | ០,៦ | ២,៣ | - | ១,០ | ១,៣ |
| **ទីប្រជុំជនផ្សេងៗ** | | | | | |
| សកម្មភាពកសិកម្ម | ១៣,១ | ៩,៧ | ៦,៥ | ៨,៧ | ៧,០ |
| សកម្មភាពមិនមែនកសិកម្ម | ២២,៩ | ១៨,៧ | ២០,០ | ១៨,៨ | ១៣,៣ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ៣១,១ | ២៣,០ | ៣១,២ | ២៥,១ | ២៥,៦ |
| ជំងឺ របួស គ្រោះថ្នាក់ | ៦,៥ | ៧,៩ | ៦,៧ | ៤,៦ | ៣,០ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ០,១ | ០,០ | - | - | - |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ១,៤ | ៤,៧ | ១,៥ | ២,៣ | ០,៧ |
| ទិញ/កែលំអរលំនៅដ្ឋាន | ៩,១ | ១៣,៣ | ១៤,៦ | ២០,៨ | ២២,៦ |
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ១១,៩ | ១៣,៥ | ១៤,២ | ១១,៣ | ១៨,៨ |
| សេវាកម្មនិងការជាប់បំណុល | ២,៨ | ៨,៥ | ៤,៣ | ៧,០ | ៤,៣ |
| ផ្សេងៗ | ១,០ | ០,៦ | ១,០ | ១,៤ | ៤,៨ |
| **ទីជនបទផ្សេងៗ** | | | | | |
| សកម្មភាពកសិកម្ម | ២៩,៦ | ២១,៤ | ២៣,០ | ១៩,៧ | ២២,០ |
| សកម្មភាពមិនមែនកសិកម្ម | ១២,០ | ១០,៦ | ១០,៩ | ១០,៥ | ១២,០ |
| តម្រូវការប្រើប្រាស់ក្នុងគ្រួសារ | ២៨,៥ | ៣៨,៧ | ៣៣,២ | ២៩,០ | ២៦,២ |
| ជំងឺ របួស គ្រោះថ្នាក់ | ៧,៦ | ៧,៤ | ៦,៩ | ៦,២ | ៥,០ |
| ការណ៍បន្ទាន់ផ្សេងៗ (ភ្លើងឆេះ ទឹកជំនន់ ចោរកម្ម) | ០,១ | ០,០ | - | - | - |
| ពិធីតាមទំនៀមទម្លាប់ប្រពៃណី (អាពាហ៍ពិពាហ៍ បុណ្យសព)។ល។ | ២,៨ | ២,៤ | ១,៩ | ២,៣ | ១,៥ |
| ទិញ/កែលំអរលំនៅដ្ឋាន | ៨,៨ | ៩,២ | ៩,៥ | ១១,៧ | ១៣,៣ |
| ទិញសម្ភារៈប្រើប្រាស់បានយូរ | ៧,៥ | ៨,២ | ៩,៣ | ១៣,០ | ១២,៣ |
| សេវាកម្មនិងការជាប់បំណុល | ២,៥ | ២,០ | ៣,៩ | ៦,២ | ៥,១ |
| ផ្សេងៗ | ០,៦ | ០,១ | ១,៤ | ១,៤ | ២,៧ |

*កំណត់សម្គាល់ ( * ) :ផ្អែកលើចំនួនគ្រួសារដែលមានបំណុលតាមគោលបំណងនៃប្រាក់កម្ចីឥណទាន*

នៅកម្ពុជា គ្រួសារដែលជំពាក់បំណុលបានខ្ចីប្រាក់ពីអ្នកចងការប្រាក់/ការផ្តល់ប្រាក់កម្ចីពីស្ថាប័ននានា ក្នុងអត្រាការប្រាក់ជាមធ្យមប្រចាំខែ ១,៥ភាគរយនៅក្នុងឆ្នាំ២០១៩/២០។ ហើយអត្រាការប្រាក់នេះបានចាប់ផ្តើមកាត់បន្ថយជាលំដាប់ គិតចាប់តាំងពីឆ្នាំ២០១៤មក។ អត្រាការប្រាក់ជាមធ្យមប្រចាំខែគឺមានលក្ខណៈខុសៗគ្នាទៅតាមតំបន់ភូមិសាស្ត្រនីមួយៗនៅក្នុងប្រទេស ដែលក្នុងនោះនៅរាជធានីភ្នំពេញអត្រាការប្រាក់មាន ១,៧ ភាគរយ នៅតំបន់ទីប្រជុំជនផ្សេងៗ និងនៅតំបន់ជនបទមាន ១,៥ភាគរយ។ (សូមមើលតារាង១១ សម្រាប់ព័ត៌មានបន្ថែម)

**តារាង១១. អត្រាការប្រាក់គិតជាមធ្យមប្រចាំខែពីប្រភពនៃប្រាក់កម្ចី បែងចែកតាមតំបន់ភូមិសាស្ត្រ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| តំបន់ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
|---|---|---|---|---|---|
| កម្ពុជា | ២,៦ | ២,៤ | ២,២ | ១,៩ | ១,៥ |
| រាជធានីភ្នំពេញ | ២,១ | ២,៤ | ១,៨ | ១,៥ | ១,៧ |
| ទីប្រជុំជនផ្សេងៗ | ២,៥ | ២,១ | ២,១ | ១,៧ | ១,៥ |
| ទីជនបទផ្សេងៗ | ២,៦ | ២,៥ | ២,៣ | ១,៩ | ១,៥ |

នៅក្នុងឆ្នាំ២០១៩/២០ រយៈពេលគិតជាមធ្យម(ពេលវេលា)នៃប្រាក់បំណុលរហូតដល់បានសងរួចរាល់ទាំងអស់ គឺមានរយៈពេលប្រហែល ២៤ខែ យោងតាមការរាយការណ៍របស់គ្រួសារដែលបានជំពាក់បំណុលនៅកម្ពុជា។ នៅរាជធានីភ្នំពេញ គ្រួសារដែលបានសងបំណុលរួចរាល់ទាំងអស់នៅក្នុងរយៈពេលជាមធ្យម ២៧ខែ ខណៈដែលគ្រួសាររស់នៅក្នុងតំបន់ទីប្រជុំជនផ្សេងៗ និងតំបន់ជនបទ ត្រូវសងបំណុលឱ្យរួចរាល់ទាំងអស់ក្នុងរយៈពេលជាមធ្យម ២៨ខែ និងរយៈពេល ២១ខែ ប៉ុណ្ណោះតាមតំបន់នីមួយៗ (សូមមើលតារាង១២ សម្រាប់ព័ត៌មានបន្ថែម)

**តារាង ១២. រយៈពេលសំណងគិតជាមធ្យមមកដល់ថ្ងៃត្រូវសងបំណុលអស់ បែងចែកតាមតំបន់ភូមិសាស្ត្រ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០ (គិតជាខែ)**

| តំបន់ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
|---|---|---|---|---|---|
| កម្ពុជា | ១០,៧ | ១៣,២ | ១៥,៩ | ១៧,៨ | ២៣,៥ |
| រាជធានីភ្នំពេញ | ១៥,៦ | ២២,៩ | ២១,៣ | ២៤,៣ | ២៧,៤ |
| ទីប្រជុំជនផ្សេងៗ | ១២,៣ | ១៥,៨ | ១៩,៩ | ២០,៧ | ២៧,៨ |
| ទីជនបទផ្សេងៗ | ១០,៤ | ១២,៧ | ១៥,៣ | ១៧,២ | ២១,៤ |

នៅកម្ពុជា សមតុល្យប្រាក់កម្ចី/បំណុលមិនទាន់សងគិតជាមធ្យមដែលស្ត្រីជាមេគ្រួសារបានជាប់ជំពាក់/មិនទាន់សងឱ្យអស់រួចរាល់នៅឡើយ គឺជារឿយៗមានកម្រិតទាបជាងសមតុល្យប្រាក់កម្ចី/បំណុលមិនទាន់សងដែលបុរសជាមេគ្រួសារបានជាប់ជំពាក់ក្នុងរយៈពេលប្រាំឆ្នាំកន្លងមក(ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០)។

នៅរាជធានីភ្នំពេញ អនុបាតបានចង្អុលបង្ហាញថា ប្រាក់កម្ចីមិនទាន់សងគិតជាមធ្យមដែលមានស្ត្រីជាមេគ្រួសារបានជាប់ជំពាក់ គឺមានកម្រិតខ្ពស់ជាងបើប្រៀបធៀបនឹងឆ្នាំ២០១៧។ ចំណែកនៅតំបន់ទីប្រជុំជនផ្សេងៗ អនុបាតនៃប្រាក់បំណុលមិនទាន់សងសម្រាប់ស្ត្រីជាមេគ្រួសារជាប់ជំពាក់គឺមានកម្រិតទាបនៅគ្រប់ឆ្នាំទាំងអស់។

នៅតំបន់ជនបទ អនុបាតនេះក៏បានបង្ហាញអំពីកម្រិតទាបជាងចំពោះស្ត្រីជាមេគ្រួសារដែលបានជំពាក់បំណុលបើធៀបទៅនឹងបុរសជាមេគ្រួសារ បើប្រៀបធៀបឆ្នាំ២០១៩/២០ ជាមួយនឹងឆ្នាំ២០១៧។ ម៉្យាងទៀត ប្រាក់បំណុលរបស់ពួកគាត់មិនទាន់សងឱ្យអស់រួចរាល់នៅឡើយនៅគ្រប់ឆ្នាំទាំងអស់។ (សូមមើលតារាង១៣ សម្រាប់ព័ត៌មានបន្ថែម)

## តារាង១៣. សមតុល្យប្រាក់កម្ចី/បំណុលមិនទាន់សងគិតជាមធ្យម បែងចែកតាមភេទនៃមេគ្រួសារ និងតាមតំបន់ភូមិសាស្ត្រ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៩/២០ (គិតជាពាន់រៀល និង អនុបាត)

| តំបន់ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | |
|---|---|---|---|---|---|
| | សមតុល្យប្រាក់កម្ចី/បំណុលជាមធ្យម គិតជាពាន់រៀល | | | | |
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| **កម្ពុជា** | | | | | |
| ស្ត្រី | ៣.៥៩៣ | ៤.៤០៤ | ៥.៣៩០ | ៨.៩៣៥ | ១៥.៧៨០ |
| បុរស | ៤.៣២៩ | ៥.៣៣៨ | ៨.០៤០ | ៩.៧២៧ | ១៨.០៩៩ |
| ទាំងពីរភេទ | ៤.១៨៤ | ៥.១៥៧ | ៧.៥១១ | ៩.៥៧៩ | ១៧.៧៣៩ |
| **រាជធានីភ្នំពេញ** | | | | | |
| ស្ត្រី | ៦.៨៥០ | ៨.១៩៧ | ៩.៦១១ | ៧.៩២៨ | ៤៦.០៩៧ |
| បុរស | ៦.៤៩២ | ១១.២៧១ | ១៣.៥០៨ | ១៩.២២៤ | ២៩.៤៣៦ |
| ទាំងពីរភេទ | ៦.៥៨២ | ១០.២៧០ | ១២.៨២៦ | ១៥.២៩០ | ៣៣.៤៤៥ |
| **ទីប្រជុំជនផ្សេងៗ** | | | | | |
| ស្ត្រី | ៥.២៩៩ | ៨.២៨៤ | ១១.៥៤៤ | ១០.២៤៨ | ១៦.៩៣៥ |
| បុរស | ៧.៤៥៧ | ៩.០០១ | ១២.៦៨៦ | ២០.៩១៨ | ២៥.៥២២ |
| ទាំងពីរភេទ | ៧.០៦៤ | ៨.៨៧៣ | ១២.៤៦៥ | ១៨.៦៥២ | ២៤.១៥៨ |
| **ទីជនបទផ្សេងៗ** | | | | | |
| ស្ត្រី | ៣.២៣៥ | ៣.៨១៣ | ៤.៥៤៦ | ៨.៨៤៧ | ៨.៥៤៥ |
| បុរស | ៣.៨៦៩ | ៤.៧៨៦ | ៧.២៩៦ | ៨.១៩៩ | ១៤.១៣៦ |
| ទាំងពីរភេទ | ៣.៧៤៥ | ៤.៦០០ | ៦.៧៤៣ | ៨.៣១៤ | ១៣.៣៣៨ |
| | អនុបាតនៃប្រាក់បំណុលមិនទាន់សង | | | | |
| **កម្ពុជា** | | | | | |
| ស្ត្រី | ០,៨ | ០,៨ | ០,៧ | ០,៩ | ០,៩ |
| បុរស | | | | | |
| ទាំងពីរភេទ | | | | | |
| **រាជធានីភ្នំពេញ** | | | | | |
| ស្ត្រី | ១,១ | ០,៧ | ០,៧ | ០,៤ | ១,៦ |
| បុរស | | | | | |
| ទាំងពីរភេទ | | | | | |
| **ទីប្រជុំជនផ្សេងៗ** | | | | | |
| ស្ត្រី | ០,៧ | ០,៩ | ០,៩ | ០,៥ | ០,៧ |
| បុរស | | | | | |
| ទាំងពីរភេទ | | | | | |
| **ទីជនបទផ្សេងៗ** | | | | | |
| ស្ត្រី | ០,៨ | ០,៨ | ០,៦ | ១,១ | ០,៦ |
| បុរស | | | | | |
| ទាំងពីរភេទ | | | | | |

# ផ្នែកទី១០ ការចំណាយប្រើប្រាស់របស់គ្រួសារ

## ១០.១ សេចក្ដីផ្ដើម

ការប្រមូលទិន្នន័យស្ដីពីការចំណាយប្រើប្រាស់របស់គ្រួសារនៅក្នុងអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា (ហៅកាត់ថា អសសក "CSES") ត្រូវបានប្រើប្រាស់សម្រាប់ការវាស់វែងនូវកម្រិតជីវភាពរស់នៅ ការតាមដាន និងការវិភាគលើភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងលើគោលបំណងពាក់ព័ន្ធផ្សេងៗទៀត។ ទិន្នន័យស្ដីពីការចំណាយប្រើប្រាស់នៅក្នុងការធ្វើអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាត្រូវបានប្រមូលដោយប្រើប្រាស់នូវសំណួររំលឹកឡើងវិញ សម្រាប់អំឡុងពេលប្រាំពីរថ្ងៃកន្លងមក នៅក្នុងតារាងសំណួរគ្រួសារ។ ទិន្នន័យស្ដីពីការចំណាយប្រើប្រាស់ក៏ត្រូវបានប្រមូលតាមវិធីសាស្ត្រកំណត់ត្រាប្រចាំថ្ងៃផងដែរ។

នៅក្នុងរបាយការណ៍នេះ ការចំណាយប្រើប្រាស់ប្រចាំខែ ត្រូវបានគណនាដោយផ្អែកតាមលទ្ធផលបានមកពីសំណួររំលឹកឡើងវិញ ហើយទស្សនាទាន នៃការចំណាយប្រើប្រាស់ដែលត្រូវបានប្រើនៅក្នុងរបាយការណ៍នេះ ខុសគ្នាពីការគណនាចំណាយប្រើប្រាស់សម្រាប់ការប៉ាន់ស្មាន និងវាស់វែងភាពក្រីក្រដែលនៅទីនោះ ការកែសម្រួលខ្លះៗត្រូវបានធ្វើឡើងចំពោះភាពខុសគ្នានៃតម្លៃ និងថ្លៃឈ្នួលផ្ទះ...ជាដើម (សូមមើលផ្នែកនិយមន័យ និងរបាយការណ៍របស់ធនាគារពិភពលោក)។ លទ្ធផលនៅក្នុងរបាយការណ៍នេះផ្អែកលើលទ្ធផលនៃអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០។

## ១០.២ វិធីសាស្ត្រគណនាចំណាយប្រើប្រាស់

### ទស្សនាទាននៃការចំណាយប្រើប្រាស់

លទ្ធផលដែលបានបង្ហាញក្នុងរបាយការណ៍នេះ ត្រូវបានចងក្រងចេញពីទិន្នន័យរំឭកឡើងវិញ។ តារាងសំណួរគ្រួសារមានសំណួរពីរផ្នែកគឺ មួយផ្នែកសម្រាប់ការចំណាយប្រើប្រាស់លើម្ហូបអាហារ ហើយនិងមួយផ្នែកទៀតសម្រាប់ការចំណាយប្រើប្រាស់មិនមែនម្ហូបអាហារ។ តារាងសំណួរនេះត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យលើការចំណាយដោយការទិញជាសាច់ប្រាក់ ការចំណាយប្រើប្រាស់នូវផលិតកម្មរបស់ខ្លួនឯង ការចំណាយប្រើប្រាស់នូវទំនិញដែលបានទទួលពីប្រាក់ឈ្នួលជាសម្ភារៈ។ វាក៏បានរាប់បញ្ចូលផងដែរនូវអំណោយ ការទទួលបាននូវអ្វីមួយដោយមិនចំណាយប្រាក់ ការដោះដូរ និងការចំណាយជាវត្ថុ ឬសម្ភារផ្សេងៗទៀត។ សំណួរផ្នែកចំណាយម្ហូបអាហាររួមមាន៦៤មុខចំណាយ រាប់បញ្ចូលផងដែរនូវភេសជ្ជៈមានជាតិស្រវឹង ថ្នាំជក់ និងម្ហូបអាហារហូបនៅក្រៅផ្ទះ ម្ហូបអាហារទិញពីក្រៅមកហូបក្នុងផ្ទះជាដើម។ ផ្នែកចំណាយមិនមែនម្ហូបអាហាររួមមាន ៤០មុខចំណាយ ដែលគ្របដណ្ដប់រាល់ការចំណាយមិនមែនម្ហូបអាហារទាំងអស់ លើកលែងតែការចំណាយលើលំនៅដ្ឋានដែលត្រូវបានប្រមូលនៅផ្នែកលំនៅដ្ឋាន។ ពេលវេលាយោងចំពោះមុខចំណាយលើម្ហូបអាហារ គឺរយៈពេល៧ថ្ងៃកន្លងមក។ ពេលវេលាយោងចំពោះមុខចំណាយមិនមែនម្ហូបអាហារ គឺគិតចាប់ពីរយៈពេល១ខែ ដល់ ១២ខែកន្លងមក (សូមមើលតារាងសំណួរគ្រួសារនៅក្នុងឧបសម្ព័ន្ធ៣)។

### លំនៅដ្ឋាន

ចំពោះការចំណាយលើលំនៅដ្ឋាន មានដូចជាការចំណាយលើថ្លៃទឹកសម្រាប់បរិភោគ លូទឹកស្អុយ កាកសំណល់ ការប្រមូលសំរាម និងប្រេងឥន្ធនៈសម្រាប់បំភ្លឺ និងចម្អិនអាហារ ត្រូវបានរាប់បញ្ចូល ដោយរួមទាំងការចំណាយថ្លៃឈ្នួលផ្ទះផងដែរ។ ចំពោះការរស់នៅក្នុងផ្ទះកម្មសិទ្ធផ្ទាល់ខ្លួនគ្រួសារក៏បានសម្ភាសន៍ដើម្បីឱ្យគាត់ធ្វើការប៉ាន់ស្មានតម្លៃសម្រាប់ការជួលផ្ទះរបស់គាត់ ប្រៀបដូចជាគាត់ជួលផ្ទះរស់នៅដែរ។ ការចំណាយលើការថែទាំនិងជួសជុលបន្តិចបន្តួចក៏ត្រូវបានរាប់បញ្ចូលផងដែរ។ ទិន្នន័យទាំងអស់នេះ ត្រូវបានប្រមូលនៅក្នុងផ្នែកលំនៅដ្ឋាន (ផ្ទះសម្បែង) សម្រាប់ពេលវេលាយោងក្នុងរយៈពេល១ខែកន្លងមក។

### ការចំណាយប្រើប្រាស់លើម្ហូបអាហារ

រួមបញ្ចូលរាល់ការចំណាយលើម្ហូបអាហារគ្រប់ប្រភេទដែលគ្រួសារបានទិញ ឬប្រើប្រាស់នូវផលិតកម្មរបស់ខ្លួនឯង។ ម្ហូបអាហារហូបនៅខាងក្រៅមានដូចជា ម្ហូបអាហារហូបនៅកន្លែងធ្វើការ នៅសាលារៀន នៅតាមភោជនីយដ្ឋាន។ល។ ហើយនិងម្ហូបអាហារទិញពីក្រៅមកហូបនៅផ្ទះក៏ត្រូវបានរាប់បញ្ចូលផងដែរ រួមទាំងភេសជ្ជៈមានជាតិស្រវឹង និងភេសជ្ជៈគ្មានជាតិស្រវឹង។

### ការចំណាយប្រើប្រាស់សរុប

ការចំណាយប្រើប្រាស់សរុបរួមមាន ការចំណាយលើម្ហូបអាហារ ភេសជ្ជៈមានជាតិស្រវឹង និងគ្មានជាតិស្រវឹង ថ្នាំជក់ និងការចំណាយមិនមែនម្ហូបអាហារទាំងអស់។

### ភាគចំណែកនៃការចំណាយលើម្ហូបអាហារ

ភាគចំណែកនៃការចំណាយលើម្ហូបអាហារត្រូវបានគណនាជាចំណែកមួយនៃការចំណាយប្រើប្រាស់សរុប។ ការចំណាយលើម្ហូបអាហាររាប់បញ្ចូលនូវគ្រប់មុខចំណាយនៃម្ហូបអាហារទាំងអស់ រួមទាំងភេសជ្ជៈមានជាតិស្រវឹង និងភេសជ្ជៈគ្មានជាតិស្រវឹងនានាផងដែរ។

## ១០.៣ ការកែប្រែលើវិសាលភាពនៃនិយមន័យរបស់មុខចំណាយមិនមែនម្ហូបអាហារខ្លះមួយចំនួន

និយមន័យ នៃការចំណាយធ្វើដំណើរ ត្រូវបានពង្រីកវិសាលភាពពីការចំណាយត្រឹមតែលើសេវាដឹកជញ្ជូនក្នុងឆ្នាំ២០០៩ មកការបញ្ចូលបន្ថែម នូវរាល់ការចំណាយដែលទាក់ទងនឹងការដំណើរទាំងអស់ ដូចជាការចំណាយលើការទិញយានយន្តលើការប្រតិបត្តិការនៃបរិក្ខាដឹកជញ្ជូន និងលើសេវាដឹកជញ្ជូនផ្សេងទៀត។ ការចំណាយលើសៀវភៅសិក្សា ឯកសណ្ឋានសាលា និងថ្លៃដឹកជញ្ជូនទៅមកសាលាគឺមិនត្រូវបានគិតបញ្ចូល ទៅក្នុងការចំណាយលើការអប់រំទេ ចំណាយ ទាំងនេះ ត្រូវបញ្ចូលក្នុងការចំណាយលើការលំហែកំសាន្ត ក្នុងប្រទេស ការចំណាយលើសម្លៀកបំពាក់ និងស្បែកជើង និងចំណាយធ្វើដំណើររៀងគ្នាវិញ។ ថ្លៃដឹកជញ្ជូនទៅមកមន្ទីរពេទ្យ មណ្ឌលសុខភាព ឬគ្លីនិកឯកជនត្រូវបានដកចេញ ពីការចំណាយផ្នែកសុខាភិបាល មកបញ្ចូលទៅក្នុងការចំណាយលើការធ្វើដំណើរវិញ។ ការចំណាយលើទំនិញផ្សេងទៀត ត្រូវបានញែកជាការចំណាយក្នុងការរៀបចំពិធីផ្សេងៗ ដូចជាបុណ្យសព អាពាហ៍ពិពាហ៍ និងពិធីជប់លៀងផ្សេងៗ និងការចំណាយ ចូលរួមក្នុងពិធីបែបហ្នឹងនិងការចំណាយផ្សេងទៀតដែលមិនបានលើកឡើងនៅក្នុងចំណុចខាងលើ។

## ១០.៤ ការចំណាយប្រើប្រាស់ប្រចាំខែគិតជាមធ្យម

នៅក្នុងឆ្នាំ២០១៩/២០ ចំណាយប្រើប្រាស់ប្រចាំខែគិតជាមធ្យម គឺមានចំនួន២.២៧៨ពាន់រៀល សម្រាប់មួយគ្រួសារ និងមានចំនួន ៥២៧ ពាន់រៀលសម្រាប់មនុស្សម្នាក់ ខណៈក្នុងឆ្នាំ២០១៤មានចំនួន១.៥២៩ពាន់រៀល សម្រាប់មួយគ្រួសារ និងមានចំនួន៣៧១ពាន់រៀល សម្រាប់មនុស្សម្នាក់ នៅក្នុងប្រទេសកម្ពុជា។ នៅកម្រិតថ្នាក់ជាតិ ការចំណាយប្រើប្រាស់ជាមធ្យមប្រចាំខែសម្រាប់មួយគ្រួសារមានការកើនឡើងជាលំដាប់ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ និងមានកំណើនគួរឱ្យកត់សំគាល់ចាប់ពីឆ្នាំ២០១៥ ដល់ ២០១៧ និងឆ្នាំ២០១៩/២០។ (សូមមើលតារាង១)។

**តារាង១: ការចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ និងសម្រាប់មនុស្សម្នាក់គិតជាមធ្យមប្រចាំខែឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០**

| តំបន់ | ចំណាយប្រើប្រាស់គិតជាពាន់រៀល | | | |
|---|---|---|---|---|
| | ក្នុងមួយគ្រួសារ | | សម្រាប់មនុស្សម្នាក់ | |
| | អសសក ២០១៤ | អសសក ២០១៩/២០ | អសសក ២០១៤ | អសសក ២០១៩/២០ |
| កម្ពុជា | ១.៥២៩ | ២.២៧៨ | ៣៧១ | ៥២៧ |
| រាជធានីភ្នំពេញ | ២.៥៤៥ | ៣.៨២៥ | ៦២២ | ៩២៦ |
| ទីប្រជុំជនផ្សេងៗ | ១.៩០៨ | ២.៥៣៤ | ៤៥៧ | ៥៧៧ |
| ទីជនបទផ្សេងៗ | ១.៣២៥ | ១.៨១៩ | ៣២១ | ៤១០ |

ការចំណាយប្រើប្រាស់ក្នុងមួយគ្រួសារ និងសម្រាប់មនុស្សម្នាក់ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ មាននិន្នាការកើនឡើងជាលំដាប់ សម្រាប់រយៈពេល១០ឆ្នាំពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៩/២០ លើកលែងតែការធ្លាក់ចុះបន្តិចបន្តួចបានកើតមានឡើងនៅក្នុងឆ្នាំ២០១១ សម្រាប់តំបន់ទីប្រជុំជន និងនៅឆ្នាំ២០១២ សម្រាប់នៅរាជធានីភ្នំពេញ។ ហេតុផលមួយគឺដោយសារមានការផ្លាស់ប្តូរផ្នែករដ្ឋបាលក្នុងតំបន់។ ភូមិមួយចំនួននៅនៅតំបន់ជនបទ បានផ្លាស់ចូលទៅជាតំបន់ទីប្រជុំជន និងរាជធានីភ្នំពេញ ដែលធ្វើឱ្យគំរូនៃការចំណាយប្រើប្រាស់របស់គ្រួសារនៅក្នុងតំបន់ជនបទត្រូវបានផ្លាស់ប្តូរភាគចំណែកចូលទៅក្នុងតំបន់ទីប្រជុំជន និងរាជធានីភ្នំពេញផងដែរ កត្តាផ្លាស់ប្តូរចនាសម្ព័ន្ធភូមិសាស្ត្ររដ្ឋបាល បានធ្វើឱ្យការចំណាយប្រើប្រាស់នៅមានកម្រិតទាបនៅតំបន់ទីប្រជុំជន និងរាជធានីភ្នំពេញសម្រាប់បណ្តាឆ្នាំដំបូងៗនោះ។ ឆ្នាំក្រោយៗមកនិន្នាការ នៃការចំណាយប្រើប្រាស់បានចាប់ផ្តើមមានកំណើនឡើងវិញជាបន្តបន្ទាប់ (សូមមើលរូបភាព១ រូបភាព២ និងតារាងទិន្នន័យបន្ថែមក្នុងឧបសម្ព័ន្ធ)។

រូបភាព១.ការចំណាយប្រើប្រាស់ប្រចាំខែជាមធ្យមក្នុងមួយគ្រួសារពីឆ្នាំ២០០៩ដល់ឆ្នាំ២០១៩/២០




រូបភាព២. ការចំណាយប្រើប្រាស់ប្រចាំខែជាមធ្យមសម្រាប់មនុស្សម្នាក់ពីឆ្នាំ២០០៩ ដល់ ឆ្នាំ២០១៩/២០




## ១០.៥ សមាសភាពនៃការចំណាយប្រើប្រាស់

នៅក្នុងតារាង២ ការចំណាយប្រើប្រាស់គិតជាមធ្យមប្រចាំខែសម្រាប់មនុស្សម្នាក់ ត្រូវបានបង្ហាញតាមក្រុមនៃមុខចំណាយផ្សេងៗគ្នា។ ចំណាយទៅលើម្ហូបអាហារ គឺមានស្មើរតែពាក់កណ្ដាលនៃការចំណាយប្រើប្រាស់សរុប។ បើប្រៀបធៀបនឹងការចំណាយប្រើប្រាស់សរុបសម្រាប់ក្របខ័ណ្ឌទូទាំងប្រទេសកម្ពុជា ភាគចំណែកនៃការចំណាយលើម្ហូបអាហារ និងភេសជ្ជៈដែលគ្មានជាតិស្រវឹងបានថយចុះបន្តិចពី៤៤,០ភាគរយនៅឆ្នាំ២០១៤ មកត្រឹម៤១,៧ភាគរយ

នៅឆ្នាំ២០១៩/២០។ ផ្ទុយទៅវិញនៅក្នុងឆ្នាំ២០១៩/២០ ការចំណាយលើផ្ទះសម្បែង (រួមមានការចំណាយលើទឹក ភ្លើង ថាមពល ថ្លៃឈ្នួល...។ល។) ដែលជាចំណែកភាគចំណាយធំបំផុតទីពីរមានការកើនបន្តិចពី១៩,០ភាគរយ នៅឆ្នាំ២០១៤ ទៅ ២១,០ភាគរយ នៅឆ្នាំ២០១៩/២០ សម្រាប់ក្របខ័ណ្ឌទូទាំងប្រទេស។ រីឯនៅរាជធានីភ្នំពេញ ថយចុះពី ៣០,៦ភាគរយនៅឆ្នាំ២០១៤ មកនៅត្រឹម ២៨,៩ភាគរយក្នុងឆ្នាំ២០១៩/២០។ នៅតំបន់ជនបទផ្សេងៗ មានចំណែកភាគចំណាយកើនឡើងបន្តិចពី១៥,៣ភាគរយ ទៅដល់ ១៦,៦ភាគរយ។ ដោយឡែកនៅក្នុងតំបន់ទីប្រជុំជនផ្សេងៗ ហាក់ដូចជានៅទ្រឹង(មិនមានការប្រែប្រួល)។

មានការកែប្រែខ្លះៗទៅលើវិសាលភាពនៃនិយមន័យរបស់មុខចំណាយមួយចំនួននៅក្នុងការចំណាយប្រើប្រាស់មិនមែនម្ហូបអាហារ ដែលនាំឱ្យក្រុមនៃការចំណាយប្រើប្រាស់មួយចំនួនមានការកើនឡើងគួរឱ្យកត់សម្គាល់ និងមួយចំនួនទៀតមានការថយចុះនូវភាគចំណែករបស់វា បើប្រៀបធៀបនឹងការចំណាយប្រើប្រាស់សរុប មានដូចជាការចំណាយលើការធ្វើដំណើរ ការអប់រំ សុខាភិបាល ការកម្សាន្តនិងវប្បធម៌ និងការចំណាយលើមុខទំនិញផ្សេងទៀត។ សម្រាប់ព័ត៌មានលម្អិតសូមមើលផ្នែកទស្សនាទាននៃការចំណាយប្រើប្រាស់។

យោងតាមការកែប្រែវិសាលភាពនៃមុខចំណាយលើទំនិញប្រើប្រាស់ទាំងនេះ នាំឱ្យការចំណាយប្រើប្រាស់លើការធ្វើដំណើរមានការថយចុះបន្តិចពី១០,៨ភាគរយនៅឆ្នាំ២០១៤ មកត្រឹម១០,៧ភាគរយនៅក្នុងឆ្នាំ២០១៩/២០។ រីឯការចំណាយផ្នែកសុខាភិបាលបានកើនឡើងពី៥,២ភាគរយក្នុងឆ្នាំ២០១៤ ទៅ ៥,៩ភាគរយ នៅឆ្នាំ២០១៩/២០។ សម្រាប់ការចំណាយលើការសិក្សាអប់រំវិញ មានកំណើនគួរឱ្យកត់សម្គាល់កើនពី១,៤ភាគរយក្នុងឆ្នាំ២០១៤ ទៅ ២,១ភាគរយ នៅឆ្នាំ២០១៩/២០នៅថ្នាក់ជាតិ។ ចំណែកតំបន់ផ្សេងទៀតក៏មានកើនឡើងដែរ លើកលែងតែតំបន់ទីប្រជុំជនផ្សេងទៀតមានការថយចុះបន្តិច។ ហេតុផលមួយ គឺដោយសារតែចំនួនសិស្ស និស្សិតមានកាន់តែច្រើនបានចូលរៀននៅសាលាកម្រិតខ្ពស់ៗដែលត្រូវបង់ថ្លៃសិក្សា។

នៅរាជធានីភ្នំពេញ ភាគចំណែកនៃការចំណាយលើម្ហូបអាហារទាបជាង នៅតាមតំបន់ភូមិសាស្ត្រផ្សេងៗទៀតក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ។ នៅក្នុងឆ្នាំ២០១៤ មាន ៤០,៥ភាគរយ បានថយចុះមកនៅត្រឹម ៣៩,០ភាគរយ នៅឆ្នាំ២០១៩/២០។ សមាសភាពភាគច្រើននៃការចំណាយប្រើប្រាស់ក្នុងតំបន់នេះមានសមាមាត្រនៅទ្រឹងដូចគ្នារវាងពីរឆ្នាំនេះ លើកលែងតែក្រុមចំណាយមួយចំនួន ដែលត្រូវបានកែប្រែនូវវិសាលភាពនៃនិយមន័យដូចបានបង្ហាញខាងលើប៉ុណ្ណោះ។ (សូមមើលតារាង២សម្រាប់ព័ត៌មានបន្ថែម)។

### តារាង២. សមាសភាពការចំណាយប្រើប្រាស់សម្រាប់មនុស្សម្នាក់ៗគិតជាមធ្យមប្រចាំខែឆ្នាំ២០១៤ និង ឆ្នាំ២០១៩/២០ (គិតជាពាន់រៀល និងភាគរយ)

| សមាសភាពនៃការចំណាយ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | |
|---|---|---|---|---|
| | តម្លៃគិតជាពាន់រៀល | | ភាគរយនៃការចំណាយសរុប | |
| | ២០១៤ | ២០១៩/២០ | ២០១៤ | ២០១៩/២០ |
| កម្ពុជា | | | | |
| ម្ហូបអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹង | ១៦៣ | ២២០ | ៤៤,០ | ៤១,៧ |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ៨ | ១០ | ២,១ | ១,៩ |
| សំលៀកបំពាក់និងស្បែកជើង | ៩ | ១៦ | ២,៥ | ៣,០ |
| ផ្ទះសម្បែង ទឹក អគ្គិសនី.... | ៧០ | ១១១ | ១៩,០ | ២១,០ |

| | | | | |
|---|---|---|---|---|
| សង្ហារឹមតុបតែងផ្ទះ....។ល។ | ៤ | ៤ | ១,១ | ០,៨ |
| ការថែទាំសុខភាព[១] | ១៩ | ៣១ | ៥,២ | ៥,៩ |
| គមនាគមន៍[២] | ៤០ | ៥៤ | ១០,៨ | ១០,២ |
| ទូរគមនាគមន៍ | ៦ | ១១ | ១,៧ | ២,១ |
| ការកម្សាន្តនិងវប្បធម៌ | ៥ | ១៣ | ១,៤ | ២,៥ |
| ការសិក្សាអប់រំ[៣] | ៥ | ១១ | ១,៤ | ២,១ |
| ទំនិញផ្សេងៗទៀត[៤] | ៤០ | ៤៧ | ១០,៨ | ៨,៩ |
| សរុប | ៣៧១ | ៥២៧ | ១០០ | ១០០ |
| **រាជធានីភ្នំពេញ** | | | | |
| ម្ហូបអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹង | ២៤៥ | ៣៦០ | ៣៩,៤ | ៣៨,៩ |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ៧ | ៥ | ១,១ | ០,៥ |
| សំលៀកបំពាក់និងស្បែកជើង | ១២ | ២៤ | ២,០ | ២,៦ |
| ផ្ទះសម្បែង ទឹក អគ្គិសនី.... | ១៩០ | ២៦៨ | ៣០,៦ | ២៨,៩ |
| សង្ហារឹមតុបតែងផ្ទះ....។ល។ | ៦ | ៧ | ០,៩ | ០,៨ |
| ការថែទាំសុខភាព[១] | ១២ | ២៦ | ២,០ | ២,៨ |
| គមនាគមន៍[២] | ៦១ | ៩២ | ៩,៨ | ៩,៩ |
| ទូរគមនាគមន៍ | ១៣ | ១៧ | ២,០ | ១,៨ |
| ការកម្សាន្តនិងវប្បធម៌ | ១២ | ៣១ | ១,៩ | ៣,៣ |
| ការសិក្សាអប់រំ[៣] | ១៥ | ៣៨ | ២,៥ | ៤,១ |
| ទំនិញផ្សេងៗទៀត[៤] | ៤៨ | ៥៨ | ៧,៧ | ៦,៣ |
| សរុប | ៦២២ | ៩២៦ | ១០០ | ១០០ |
| **ទីប្រជុំជនផ្សេងៗ** | | | | |
| ម្ហូបអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹង | ១៨៩ | ២២៦ | ៤១,៣ | ៣៩,១ |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ៩ | ១២ | ២,០ | ២,១ |
| សំលៀកបំពាក់និងស្បែកជើង | ១២ | ១៨ | ២,៦ | ៣,១ |
| ផ្ទះសម្បែង ទឹក អគ្គិសនី.... | ៩៧ | ១២៣ | ២១,៣ | ២១,៣ |
| សង្ហារឹមតុបតែងផ្ទះ....។ល។ | ៦ | ៥ | ១,២ | ០,៩ |
| ការថែទាំសុខភាព[១] | ១៦ | ៣៥ | ៣,៥ | ៦,១ |
| គមនាគមន៍[២] | ៥៥ | ៧១ | ១២,០ | ១២,៣ |
| ទូរគមនាគមន៍ | ៩ | ១៤ | ១,៩ | ២,៤ |
| ការកម្សាន្តនិងវប្បធម៌ | ៧ | ១៣ | ១,៦ | ២,២ |
| ការសិក្សាអប់រំ[៣] | ៩ | ១០ | ១,៩ | ១,៧ |
| ទំនិញផ្សេងៗទៀត[៤] | ៤៩ | ៥១ | ១០,៦ | ៨,៨ |
| សរុប | ៤៥៧ | ៥៧៧ | ១០០ | ១០០ |
| **ជនបទផ្សេងៗ** | | | | |
| ម្ហូបអាហារនិងភេសជ្ជៈគ្មានជាតិស្រវឹង | ១៤៧ | ១៨៤ | ៤៥,៩ | ៤៤,៩ |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ៨ | ១០ | ២,៤ | ២,៤ |
| សំលៀកបំពាក់និងស្បែកជើង | ៨ | ១៤ | ២,៦ | ៣,៤ |
| ផ្ទះសម្បែង ទឹក អគ្គិសនី.... | ៤៩ | ៦៨ | ១៥,៣ | ១៦,៦ |
| សង្ហារឹមតុបតែងផ្ទះ....។ល។ | ៣ | ៣ | ១,១ | ០,៧ |

| | | | | |
|---|---|---|---|---|
| ការថែទាំសុខភាព[១] | ២១ | ៣០ | ៦,៥ | ៧,៣ |
| គមនាគមន៍[២] | ៣៥ | ៣៧ | ១០,៩ | ៩,០ |
| ទូរគមនាគមន៍ | ៥ | ៩ | ១,៥ | ២,២ |
| ការកម្សាន្តនិងវប្បធម៌ | ៤ | ៨ | ១,២ | ២,០ |
| ការសិក្សាអប់រំ[៣] | ៣ | ៥ | ១,០ | ១,២ |
| ទំនិញផ្សេងៗទៀត[៤] | ៣៧ | ៤២ | ១១,៧ | ១០,២ |
| សរុប | ៣២១ | ៤១០ | ១០០ | ១០០ |

ចំណាំ៖ ១, ២, ៣, ៤: វិសាលភាពនៃនិយមន័យនៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៤ត្រូវបានធ្វើការកែសម្រួល។ សូមមើលក្នុងផ្នែកទស្សនាទាននៃការចំណាយប្រើប្រាស់។

តារាង៣ បង្ហាញថាប្រជារាស្ត្រទាំងអស់ត្រូវបានបែងចែកជាប្រាំក្រុមស្មើៗគ្នា (ក្រុមបញ្ចភាគ)ទៅតាមការចំណាយប្រើប្រាស់ជាមធ្យមប្រចាំខែសម្រាប់មនុស្សម្នាក់។ក្រុមបញ្ចភាគទី៥ ដែលស្មើនឹង២០ភាគរយនៃប្រជាជនទាំងអស់ ដែលមានការចំណាយប្រើប្រាស់កម្រិតខ្ពស់បំផុត បានតំណាងឱ្យជាងមួយភាគបីនៃទឹកប្រាក់ចំណាយប្រើប្រាស់សរុបសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០១៤ និងប្រហែលជិតពាក់កណ្តាលក្នុងឆ្នាំ២០១៩/២០ នៅកម្ពុជា។ បំណែកភាគនៃក្រុមនេះបានកើនឡើងនៅគ្រប់តំបន់ភូមិសាស្ត្រទាំងអស់។

**តារាង៣. ក្រុមបញ្ចភាគបែងចែកតាមការចំណាយប្រើប្រាស់គិតជាមធ្យមប្រចាំខែសម្រាប់មនុស្សម្នាក់ឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០**

| សមាសភាពនៃការចំណាយ | តម្លៃគិតជាពាន់រៀល | | ភាគរយនៃការចំណាយសរុប | |
|---|---|---|---|---|
| | អសសក ២០១៤ | អសសក ២០១៩/២០ | អសសក ២០១៤ | អសសក ២០១៩/២០ |
| កម្ពុជា | | | | |
| ក្រុមបញ្ចភាគ | | | | |
| បញ្ចភាគទាបបំផុត | ១៦៦ | ២០៤ | ៩,០ | ៧,៧ |
| បញ្ចភាគទីពីរ | ២៤០ | ៣០៤ | ១៣,០ | ១១,៥ |
| បញ្ចភាគកណ្តាល | ៣០៩ | ៤០៣ | ១៦,៧ | ១៥,៣ |
| បញ្ចភាគទីបួន | ៤០៧ | ៥៥៩ | ២២,០ | ២១,២ |
| បញ្ចភាគខ្ពស់បំផុត | ៧៣១ | ១.១៦៦ | ៣៩,៤ | ៤៤,២ |
| រាជធានីភ្នំពេញ | | | | |
| ក្រុមបញ្ចភាគ | | | | |
| បញ្ចភាគទាបបំផុត | ២៥៦ | ៣៦២ | ៨,២ | ៧,៨ |
| បញ្ចភាគទីពីរ | ៣៩០ | ៥៤៦ | ១២,៥ | ១១,៨ |
| បញ្ចភាគកណ្តាល | ៥១៦ | ៧១៩ | ១៦,៦ | ១៥,៥ |
| បញ្ចភាគទីបួន | ៦៩៧ | ៩៧៧ | ២២,៥ | ២១,១ |
| បញ្ចភាគខ្ពស់បំផុត | ១.២៤៩ | ២.០៣២ | ៤០,២ | ៤៣,៨ |
| ទីប្រជុំជនផ្សេងៗ | | | | |

| | | | | |
|---|---|---|---|---|
| ក្រុមបញ្ចភាគ | | | | |
| បញ្ចភាគទាបបំផុត | ១៨៥ | ២៣៦ | ៨,១ | ៨,២ |
| បញ្ចភាគទីពីរ | ២៧៩ | ៣៥១ | ១២,២ | ១២,២ |
| បញ្ចភាគកណ្តាល | ៣៧៣ | ៤៥៩ | ១៦,៤ | ១៥,៩ |
| បញ្ចភាគទីបួន | ៤៩៧ | ៦១៧ | ២១,៧ | ២១,៤ |
| បញ្ចភាគខ្ពស់បំផុត | ៩៥០ | ១.២២៥ | ៤១,៦ | ៤២,៤ |
| ទីជនបទផ្សេងៗ | | | | |
| ក្រុមបញ្ចភាគ | | | | |
| បញ្ចភាគទាបបំផុត | ១៥០ | ១៨៥ | ៩,៣ | ៩,០ |
| បញ្ចភាគទីពីរ | ២១៣ | ២៧១ | ១៣,៣ | ១៣,២ |
| បញ្ចភាគកណ្តាល | ២៦៩ | ៣៤២ | ១៦,៧ | ១៦,៧ |
| បញ្ចភាគទីបួន | ៣៥១ | ៤៤៨ | ២១,៩ | ២១,៨ |
| បញ្ចភាគខ្ពស់បំផុត | ៦២៤ | ៨០៦ | ៣៨,៨ | ៣៩,៣ |

## ១០.៦ ការចំណាយលើម្ហូបអាហារ និងការចំណាយប្រើប្រាស់សរុបប្រចាំខែ

តារាង៤បង្ហាញអំពីការចំណាយប្រើប្រាស់សរុបប្រចាំខែនៅកម្ពុជាគិតជាពាន់លានរៀល។ តារាងនេះក៏បង្ហាញផងដែរអំពីការបែងចែកនូវការចំណាយប្រើប្រាស់សរុបទៅតាមតំបន់ភូមិសាស្ត្រផ្សេងៗ។ នៅឆ្នាំ២០១៩/២០ ប្រមាណ ៦២ភាគរយនៃគ្រួសារទាំងអស់ដែលរស់នៅតាមតំបន់ជនបទផ្សេងទៀត( សូមមើលតារាងក្នុងឧបសម្ព័ន្ធ ) តែចំពោះបំណែកនៃការចំណាយប្រើប្រាស់សរុបរបស់ពួកគេ គឺមានកម្រិតទាបជាង(ប្រមាណ៤៩,៧ភាគរយ)។ ចំណែកប្រមាណ ១៥ភាគរយ នៃប្រជាជនកម្ពុជាសរុបដែលរស់នៅរាជធានីភ្នំពេញ មានភាគចំណែកនៃការចំណាយប្រើប្រាស់រហូតទៅដល់ ២៤,៥ភាគរយនៃការចំណាយប្រើប្រាស់សរុបទូទាំងប្រទេស។ ការចំណាយប្រើប្រាស់ទៅលើទំនិញមិនមែនម្ហូបអាហារ បើប្រៀបធៀបទៅនឹងការចំណាយប្រើប្រាស់សរុប ហាក់បីដូចជាមានការកើនឡើងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ។ (សូមមើលតារាងទី៤ សម្រាប់ព័ត៌មានបន្ថែម)

### តារាង៤: ការចំណាយប្រើប្រាស់ និងការចំណាយលើម្ហូបអាហារសរុបប្រចាំខែ

| តំបន់ | ការចំណាយប្រើប្រាស់សរុបរបស់គ្រួសារប្រចាំខែ | | | |
|---|---|---|---|---|
| | គិតជាពាន់លានរៀល | | ភាគរយ(%) | |
| | អសសក ២០១៤ | អសសក ២០១៩/២០ | អសសក ២០១៤ | អសសក ២០១៩/២០ |
| កម្ពុជា | ៤.៩៨៥ | ៨.២៨៣ | ១០០,០ | ១០០,០ |
| រាជធានីភ្នំពេញ | ៩៣៨ | ២.០៣៣ | ១៨,៨ | ២៤,៥ |
| ទីប្រជុំជនផ្សេងៗ | ៦៩៩ | ២.១៣៥ | ១៤,០ | ២៥,៨ |
| ជនបទផ្សេងៗ | ៣.៣៤៨ | ៤.១១៥ | ៦៧,២ | ៤៩,៧ |

| តំបន់ | ការចំណាយលើម្ហូបអាហារប្រចាំខែ គិតជាពាន់លានរៀល | | ការចំណាយលើម្ហូបអាហារធៀបនឹងការចំណាយប្រើប្រាស់សរុប ភាគរយ (%) | |
|---|---|---|---|---|
| | អសសក ២០១៤ | អសសក ២០១៩/២០ | អសសក ២០១៤ | អសសក ២០១៩/២០ |
| កម្ពុជា | ២.២៨៨ | ៣.៥៩០ | ៤៥,៩ | ៤៣,៣ |
| រាជធានីភ្នំពេញ | ៣៨០ | ៧៩៣ | ៤០,៥ | ៣៩,០ |
| ទីប្រជុំជនផ្សេងៗ | ៣០២ | ៨៨២ | ៤៣,២ | ៤១,៣ |
| ជនបទផ្សេងៗ | ១.៦០៦ | ១.៩១៦ | ៤៨,០ | ៤៦,៦ |

## ១០.៧ សម្ភារប្រើប្រាស់បានយូរ

យោងតាមលទ្ធផលអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០ សម្ភារប្រើប្រាស់បានយូរសាមញ្ញបំផុតដែលគ្រួសារនៅប្រទេសកម្ពុជាមាន គឺទូរស័ព្ទដៃវីងដែលសម្ភារប្រើប្រាស់បានយូរមិនសាមញ្ញជាងគេ គឺជារថយន្តស៊ីប ឬវ៉ាន។ គ្រួសារជាង ៩០ភាគរយ នៃគ្រួសារសរុប មានទូរស័ព្ទដៃប្រើប្រាស់ក្នុងឆ្នាំ២០១៩/២០ ដែលបានកើនពី ៨៣ភាគរយ ក្នុងឆ្នាំ២០១៤ ដល់ ៩៣ភាគរយ ក្នុងឆ្នាំ២០១៩/២០។ ការកើនឡើងក្នុងភាពជាម្ចាស់កម្មសិទ្ធិលើទូរស័ព្ទដៃនេះ គឺដោយសារមានការកើនឡើង នៃភាពជាម្ចាស់កម្មសិទ្ធិស្ទើរតែនៅគ្រប់តំបន់ភូមិសាស្ត្រ ជាពិសេសនៅតំបន់ជនបទផ្សេងទៀត។

បើប្រៀបធៀបនឹងឆ្នាំ២០១៤ នៅរាជធានីភ្នំពេញមានចំណែក នៃគ្រួសារដែលមានទូរស័ព្ទដៃប្រើប្រាស់ជាកម្មសិទ្ធិ បានកើនឡើងបន្តិចបន្តួចពី ៩៦ភាគរយ ដល់ ៩៧ភាគរយនៅឆ្នាំ២០១៩៩/២០ ក៏ព្រោះតែគ្រួសារនៅក្នុងរាជធានីភ្នំពេញ បានមានទូរស័ព្ទដៃប្រើច្រើនរួចមកហើយ។ កំណើននៃចំណែកក្នុងភាពជាម្ចាស់កម្មសិទ្ធិលើទូរស័ព្ទដៃនៅកម្រិតថ្នាក់ជាតិ ត្រូវបានចូលរួមចំណែក ដោយកំណើនដ៏ច្រើននៅតំបន់ជនបទផ្សេងទៀត (សូមមើលតារាង៥សម្រាប់ព័ត៌មានលម្អិតបន្ថែម)។

ទូរទស្សន៍ និងទោចក្រយានយន្ត គឺជាសម្ភារៈប្រើប្រាស់បានយូរសាមញ្ញបំផុតទីពីរ ដែលគ្រួសារកម្ពុជា មានប្រើនៅឆ្នាំ២០១៩/២០។ កម្មសិទ្ធិលើទូរទស្សន៍មានការកើនឡើងបន្តិចបន្តួចពីអត្រា៦៦ភាគរយនៅក្នុងឆ្នាំ២០១៤ ដល់អត្រា ៦៨ភាគរយ នៅក្នុងឆ្នាំ២០១៩/២០ ខណៈដែលភាពជាម្ចាស់កម្មសិទ្ធិលើទោចក្រយានមានកំណើនគួរឱ្យកត់សម្គាល់ពីអត្រា៦៦ភាគរយ នៅក្នុងឆ្នាំ២០១៤ ដល់អត្រា ៨៣ភាគរយ នៅក្នុងឆ្នាំ២០១៩/២០។

## តារាង៥. សម្ភារប្រើបានយូរសំខាន់ៗ ដែលគ្រួសារមានប្រើប្រាស់ ក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| ឈ្មោះសម្ភារៈប្រើបានយូរ | អសសក ២០១៤ | | | | អសសក ២០១៩/២០ | | | |
|---|---|---|---|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ទីជនបទផ្សេងៗ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ទីជនបទផ្សេងៗ |
| វិទ្យុ | ៣៣ | ៣៤ | ២៨ | ៣៣ | ១៦ | ១៧ | ១៣ | ១៧ |
| ទូរទស្សន៍ | ៦៦ | ៩៥ | ៨៣ | ៥៩ | ៦៨ | ៨៣ | ៧៦ | ៦២ |
| ក្បាលវីដេអូ/ម៉ាស៊ីនថតចំលង/VCD * | ២៣ | ៣៤ | ២៧ | ២១ | ៣ | ២ | ៣ | ៣ |
| ម៉ាញ៉េStereo | ៥ | ១៩ | ៤ | ៣ | ២ | ១ | ៣ | ២ |
| ទូរស័ព្ទដៃ | ៨៣ | ៩៦ | ៩០ | ៨០ | ៩៣ | ៩៧ | ៩៤ | ៩១ |
| ចានបង្កាយរណប | ២ | ០ | ២ | ២ | ៨ | ១ | ៧ | ១០ |
| ទោចក្រយាន (កង់) | ៦១ | ៤២ | ៦០ | ៦៤ | ៥៤ | ៣៦ | ៥៣ | ៥៨ |
| ទោចក្រយានយន្ត (ម៉ូតូ) | ៦៦ | ៩០ | ៧៤ | ៦១ | ៨៣ | ៩០ | ៨៧ | ៨០ |
| រថយន្តធុនតូច | ៥ | ២០ | ៩ | ២ | ១០ | ២៧ | ១៤ | ៥ |
| រថយន្តJeep/រថយន្តវ៉ាន | ១ | ១ | ១ | ១ | ១ | ១ | ២ | ១ |
| កុំព្យូទ័រ(លើតុ ឬយួរដៃ) | ៦ | ២៨ | ១១ | ២ | ៩ | ៣០ | ៩ | ៤ |

* ម៉ាស៊ីនចាក់វីដេអូ/ម៉ាស៊ីនចាក់ DVD ត្រូវបានរាប់បញ្ចូលផងដែរ។

# ផ្នែកទី១១ ការប្រើប្រាស់ស្បៀងអាហាររបស់គ្រួសារ

## ១១.១ ការប្រើប្រាស់ម្ហូបអាហារនៅក្នុងគ្រួសារ

ដើម្បីយល់ដឹងពីការប្រើប្រាស់ម្ហូបអាហារនៅក្នុងគ្រួសារនោះ គ្រួសារគំរូនីមួយៗត្រូវបានសាកសួរពីចំនួនថ្ងៃនៃការប្រើប្រាស់ម្ហូបអាហាររបស់ពួកគាត់នៅក្នុងអំឡុងពេល៧ថ្ងៃកន្លងមក។ គ្រប់ម្ហូបអាហារដែលបានសាកសួរទាំងនោះត្រូវបានធ្វើជាចំណាត់ថ្នាក់ចូលជាក្រុមម្ហូបអាហារផ្សេងៗគ្នា(សូមមើលតារាង១សម្រាប់ព័ត៌មានបន្ថែម)។

**ធញ្ញជាតិ និងមើមៈ** ធញ្ញជាតិ និងមើមរួមមាន បាយ ពោត នំប៉ុង ដំឡូងមី ដំឡូងផ្អែម ដំឡូងបារាំង ដំឡូងជ្វា និងត្រាវ។ បាយគឺជាធញ្ញជាតិចម្បងដែលត្រូវបានប្រើប្រាស់ជាអាហារសម្រាប់បរិភោគស្ទើរតែពេញរយៈពេល៧ថ្ងៃក្នុងមួយសប្តាហ៍។ ជាទូទៅការប្រើប្រាស់ឬការបរិភោគបាយ គឺមានសារៈសំខាន់បំផុត ចំពោះប្រជាជនដែលរស់នៅគ្រប់តំបន់ទាំងអស់ក្នុងប្រទេសកម្ពុជា។

**សណ្តែកៈ** សណ្តែករួមមាន សណ្តែកបាយ សណ្តែកសៀង សណ្តែកបណ្តុះ សណ្តែកដី គ្រាប់ឈូក គ្រាប់ល្ពៅ និងគ្រាប់សណ្តែកផ្សេងៗទៀត។ ការប្រើប្រាស់ ឬការបរិភោគសណ្តែក គឺមិនមានភាពញឹកញាប់ប៉ុន្មានទេសម្រាប់ប្រជាពលរដ្ឋកម្ពុជានៅគ្រប់តំបន់ទាំងអស់។ បើគិតជាមធ្យម ពួកគេបានប្រើប្រាស់តិចជាងមួយថ្ងៃក្នុងមួយសប្តាហ៍។

**បន្លែនិងផ្លែឈើៈ** បន្លែរួមមាន បន្លែពណ៌លឿង បន្លែមានស្លឹកពណ៌បៃតង និងប្រភេទបន្លែផ្សេងៗទៀត។ បើគិតជាមធ្យម បន្លែពណ៌លឿងត្រូវបានពួកគេប្រើប្រាស់ ឬបរិភោគចំនួន១,២ថ្ងៃ ក្នុងមួយសប្តាហ៍ ខណៈដែលបន្លែមានស្លឹកពណ៌បៃតង និងប្រភេទបន្លែផ្សេងៗទៀត ត្រូវបានប្រើប្រាស់ប្រហាក់ប្រហែលគ្នាតាមតំបន់ចំនួន៣,១ថ្ងៃក្នុងមួយសប្តាហ៍។ បើពិនិត្យមើលការប្រើប្រាស់ឬការបរិភោគបន្លែនៅតាមតំបន់នានានៅក្នុងប្រទេសកម្ពុជា ឃើញថាពុំមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់នោះឡើយ។ ចំពោះផ្លែឈើពណ៌លឿង និងប្រភេទផ្លែឈើផ្សេងៗទៀត ត្រូវបានពួកគេប្រើប្រាស់ឬហូបពី១ថ្ងៃ ទៅ២ថ្ងៃ ក្នុងមួយសប្តាហ៍។ (សូមមើលតារាង១សម្រាប់ព័ត៌មានបន្ថែម)។

**តារាង១. ចំនួនថ្ងៃនៃការប្រើប្រាស់ម្ហូបអាហារក្នុងគ្រួសារក្នុងរយៈពេល៧ថ្ងៃកន្លងមក ឆ្នាំ២០១៩/២០ (គិតជាថ្ងៃ)**

| ម្ហូបអាហារនីមួយៗ | ២០១៩/២០២០ | | | |
|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទ |
| ធញ្ញជាតិ/អង្ករៈបាយ បបរ នំបញ្ចុក គុយទាវ (អាហារធ្វើពីអង្ករ) | ៧,០ | ៧,០ | ៧,០ | ៧,០ |
| ឬសនិងមើមៈដំឡូងបារាំង ដំឡូងឈើ(ប្រភេទមើមផ្សេងទៀត) | ០,៧ | ១,០ | ០,៧ | ០,៦ |
| គ្រាប់សណ្តែកនិងគ្រាប់ឈើៈសណ្តែកដីសណ្តែកក្រហម សណ្តែកសៀង | ០,៩ | ១,០ | ០,៩ | ០,៩ |
| បន្លែពណ៌លឿង ឬពណ៌ទឹកក្រូច(បន្លែមានវីតាមីនA) | ១,២ | ១,៥ | ១,៣ | ១,១ |
| បន្លែស្លឹកពណ៌បៃតងៈស្ពៃ ផ្កាស្ពៃ ផ្ទីដូង ស្លឹកបាស | ៣,១ | ២,៨ | ៣,២ | ៣,២ |
| បន្លែដទៃទៀតៈខ្ទឹមបារាំង ប៉េងប៉ោះ ត្រសក់ ផៃថាវ | ២,៤ | ២,៥ | ២,៥ | ២,៤ |

| | | | | |
|---|---|---|---|---|
| ផ្លែឈើពណ៌លឿង ឬ ពណ៌ទឹកក្រូចៈស្វាយទុំ ល្ហុងទុំ ប៉េងប៉ោះទុំ | ១,២ | ១,២ | ១,៣ | ១,១ |
| ផ្លែឈើដទៃទៀតៈ ចេក ប៉ោម ក្រូចពោធិ៍សាត់ | ១,៩ | ១,៨ | ២,១ | ១,៩ |
| សាច់សរីរាង្គឬគ្រឿងក្នុងៈ ថ្លើម ក្រលៀន លំពែង ឈាម បេះដូង | ០,៤ | ០,៨ | ០,៤ | ០,៣ |
| សាច់ និងបក្សីៈ សាច់ជ្រូក សាច់គោ សាច់ក្របី សាច់ចៀម សាច់មាន់ សាច់ទា | ៣,៣ | ៣,៧ | ៣,៥ | ៣,១ |
| ត្រីនិងប្រភេទសត្វក្នុងទឹកផ្សេងៈត្រីទឹកសាបត្រីទឹកប្រៃ ត្រីប្រឡាក់ ត្រីងៀត | ៤,៥ | ៣,៨ | ៤,៥ | ៤,៧ |
| ពងឬស៊ុតៈស៊ុតមាន់ ស៊ុតទា ពងទា ពងក្រួច ពងទាប្រៃ | ២,៤ | ២,៤ | ២,៥ | ២,៣ |
| ទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះ | ១,៧ | ២,៤ | ១,៨ | ១,៤ |
| ប្រេងឆានិងខ្លាញ់ | ៤,៧ | ៥,២ | ៤,៧ | ៤,៦ |
| ស្ករ បង្អែម ទឹកឃ្មុំ | ៤,៤ | ៤,៦ | ៤,៤ | ៤,៣ |
| គ្រឿងទេសឬគ្រឿងផ្សំ | ៦,៦ | ៦,៦ | ៦,៦ | ៦,៦ |
| ប្រហុក ឬផ្អកគ្រប់ប្រភេទ | ២,១ | ១,៦ | ២,២ | ២,៣ |
| សត្វល្អិតៈចង្រិត ពីងពាង | ០,១ | ០,២ | ០,១ | ០,១ |

## សាច់ និងត្រី

ត្រី សាច់ (សាច់គោ សាច់ជ្រូក និងសាច់មាន់) ព្រមទាំងស៊ុត គឺជាប្រភពប្រូតេអ៊ីនសំខាន់ដែលបានមកពីសត្វ។ បើគិតជាមធ្យម ការប្រើប្រាស់ឬការបរិភោគសាច់ត្រីដែលពួកគេបានរាយការណ៍មានចំនួន ៤ថ្ងៃ ក្នុងមួយសប្តាហ៍ ខណៈដែលការប្រើប្រាស់សាច់ច្រើនជាង៣ថ្ងៃក្នុងមួយសប្តាហ៍ និងការប្រើប្រាស់ស៊ុត គឺមានចំនួន២,៤ថ្ងៃ ក្នុងមួយសប្តាហ៍។ ចំនួនថ្ងៃនៃការប្រើប្រាស់ឬការបរិភោគសាច់ត្រី គឺនៅក្នុងរាជធានីភ្នំពេញមានកម្រិតទាបជាងនៅតំបន់ទីប្រជុំជននិងតំបន់ទីជនបទផ្សេងៗ។ ក៏ប៉ុន្តែចំនួនថ្ងៃនៃការប្រើប្រាស់សាច់មានលក្ខណៈប្រហាក់ប្រហែលគ្នាសម្រាប់ប្រជាជននៅគ្រប់តំបន់ក្នុងប្រទេសកម្ពុជា។

## ការប្រើប្រាស់ទឹកដោះគោ និងផលិតផលអាហារប្រចាំថ្ងៃ

ការប្រើប្រាស់ទឹកដោះគោនិងផលិតផលអាហារប្រចាំថ្ងៃ គឺពុំសូវមានភាពញឹកញាប់ប៉ុន្មាននោះទេ ពោលគឺពួកគេបានប្រើប្រាស់ជាមធ្យមច្រើនជាង១ថ្ងៃប៉ុណ្ណោះក្នុងមួយសប្តាហ៍។ គ្រួសាររស់នៅក្នុងរាជធានីភ្នំពេញហាក់ដូចជាបានប្រើប្រាស់ទឹកដោះគោ និងផលិតផលធ្វើពីទឹកដោះ(អាហារប្រចាំថ្ងៃ)ច្រើនជាងគ្រួសារដែលរស់នៅតាមតំបន់ទីប្រជុំជន និងតំបន់ជនបទផ្សេងៗ។

## ប្រេង ខ្លាញ់ និងស្ករ

ប្រេងឆាឬប្រេងបន្លែនិងខ្លាញ់សត្វត្រូវបានប្រើប្រាស់សម្រាប់ចម្អិនម្ហូបអាហារ។ បើគិតជាមធ្យម ពួកគេបានប្រើប្រាស់ចំនួន៤,៧ថ្ងៃក្នុងមួយសប្តាហ៍។ ការប្រើប្រាស់ប្រេងឆានិងខ្លាញ់សត្វសម្រាប់ចម្អិនម្ហូបអាហារ ដែលបានរាយការណ៍តាមតំបន់ផ្សេងៗក្នុងប្រទេសកម្ពុជា ឃើញថាពុំមានភាពខុសគ្នាដែលគួរឱ្យកត់សម្គាល់នោះឡើយ។

## គ្រឿងទេស/គ្រឿងផ្សំ និងសត្វល្អិត

គ្រឿងទេសឬគ្រឿងផ្សំត្រូវបានប្រើប្រាស់ជាញឹកញាប់ ស្ទើរតែ៧ថ្ងៃក្នុងមួយសប្តាហ៍នៅតាមតំបន់ភូមិសាស្ត្រផ្សេងៗនៅក្នុងប្រទេសកម្ពុជា។ ចំណែកការប្រើប្រាស់ ឬការបរិភោគសត្វល្អិតវិញ គឺមានកម្រិតតិចតួចនៅឡើយ បើគិតជាមធ្យមមានត្រឹមតែ ០,១ថ្ងៃ ប៉ុណ្ណោះក្នុងមួយសប្តាហ៍។

## ១១.២ ភាពងាយរងគ្រោះនៃសៀងអាហារនៅក្នុងគ្រួសារ(យុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហា)

ដើម្បីស្វែងយល់ពីភាពងាយរងគ្រោះរបស់គ្រួសារ និងឥរិយាបថរបស់ពួកគេក្នុងការដោះស្រាយនៅពេលជួបបញ្ហាកង្វះម្ហូបអាហារនោះ។ គ្រប់គ្រួសារគំរូទាំងអស់ត្រូវបានសួរសម្ភាសន៍អំពីយុទ្ធសាស្ត្រនានា ដែលបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហា។ តារាង២បង្ហាញពីភាគរយនៃគ្រួសារដែលបានប្រើប្រាស់យុទ្ធសាស្ត្រដើម្បីដោះស្រាយរាល់បញ្ហាតាមរយៈការកាត់បន្ថយការប្រើប្រាស់ក្នុងអំឡុងពេល៧ថ្ងៃមុនកាលបរិច្ឆេទនៃការធ្វើអង្កេត។ បើគិតជាមធ្យមឃើញថា ២,០ភាគរយ នៃគ្រួសារទាំងអស់ បានពឹងផ្អែកលើការបរិភោគម្ហូបអាហារដែលខ្លួនមិនសូវចូលចិត្ត ឬក៏បរិភោគនូវម្ហូបអាហារណាដែលមានតម្លៃទាប(ធូរថ្លៃ)។ សម្រាប់តំបន់ជនបទផ្សេងៗ សមាមាត្រនៃគ្រួសារដែលពឹងផ្អែកលើការបរិភោគម្ហូបអាហារមិនសូវចូលចិត្ត ឬការបរិភោគម្ហូបអាហារដែលមានតម្លៃទាបៗ ដែលមានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ជាងគ្រួសារដែលរស់នៅក្នុងរាជធានីភ្នំពេញ និងគ្រួសាររស់នៅទីប្រជុំជនផ្សេងៗ។ មានគ្រួសារប្រមាណជាង ១ភាគរយ ដែលបានខ្ចីម្ហូបអាហារគេ ឬពឹងផ្អែកលើការជួយពីមិត្តភ័ក្ត្រ ឬបងប្អូនដែលជាសាច់ញាតិ។ (សូមមើលតារាង២សម្រាប់ព័ត៌មានបន្ថែម)។

**តារាង២. ការប្រើប្រាស់យុទ្ធសាស្ត្រកាត់បន្ថយម្ហូបអាហារក្នុងគ្រួសារបែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| យុទ្ធសាស្ត្រដោះស្រាយ | អសសក ២០១៩/២០ | | | |
|---|---|---|---|---|
| | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ទីជនបទផ្សេងៗ |
| ពឹងផ្អែកទៅលើការញុំា ម្ហូបអាហារមិនសូវចូលចិត្ត អាហារដែលមានតម្លៃថោក | ២,០ | ០,២ | ១,៩ | ២,៥ |
| ខ្ចីម្ហូបអាហារគេឬពឹងផ្អែកទៅលើជំនួយពីមិត្តភ័ក្តឬបងប្អូន | ១,២ | ០,២ | ១,២ | ១,៤ |
| កាត់បន្ថយចំនួនដងឬចំនួនពេលនៃការហូបអាហារក្នុងមួយថ្ងៃៗ | ០,៦ | ០,១ | ០,៨ | ០,៦ |
| កាត់បន្ថយបរិមាណអាហារក្នុងមួយពេលៗ | ០,៧ | ០,២ | ០,៨ | ០,៨ |
| ការកាត់បន្ថយបរិមាណញុំាអាហារដោយមនុស្សពេញវ័យឬម្តាយដើម្បីទុកឱ្យក្មេងតូចៗ | ០,៥ | ០,១ | ០,៨ | ០,៦ |

តារាង៣ បង្ហាញអំពីការប្រើប្រាស់យុទ្ធសាស្ត្រ ដើម្បីដោះស្រាយជីវភាពផ្សេងៗគ្នារបស់គ្រួសារក្នុងអំឡុងពេល៣០ថ្ងៃមុនកាលបរិច្ឆេទនៃការធ្វើអង្កេត។ ជារួមមានគ្រួសារប្រមាណ ០,៧ភាគរយ បានចំណាយប្រាក់សន្សំផ្ទាល់ខ្លួនដើម្បីទិញម្ហូបអាហារនៅពេលពួកគាត់ជួបបញ្ហាកង្វះម្ហូបអាហារ។ សម្រាប់គ្រួសាររស់នៅតាមតំបន់ជនបទផ្សេងៗទៀត ដែលមានទំនងជាចំណាយប្រាក់សន្សំរបស់ពួកគាត់ច្រើនជាងគ្រួសារដែលរស់នៅក្នុងរាជធានីភ្នំពេញនិងនៅទីប្រជុំជនដទៃទៀត។ មានគ្រួសារប្រមាណ ១,០ភាគរយដែលបានខ្ចីប្រាក់ឬម្ហូបអាហារពីអ្នកដទៃ ហើយសមាមាត្រគ្រួសារដែលបានកាត់បន្ថយការចំណាយមិនមែនម្ហូបអាហារសំខាន់ៗរបស់ពួកគេ គឺមានភាពប្រហាក់ប្រហែលគ្នា។ ដោយឡែក នៅតំបន់ទីប្រជុំជនផ្សេងៗទៀត គ្រួសារដែលបានខ្ចីប្រាក់ដើម្បីទិញម្ហូបអាហារឬខ្ចីម្ហូបអាហារពីអ្នកដទៃ

គឺមានកម្រិតខ្ពស់ជាងគ្រួសារដែលរស់នៅទីក្រុងភ្នំពេញ និងតាមទីជនបទផ្សេងទៀត។ (សូមមើលតារាង៣សម្រាប់ព័ត៌មានបន្ថែម)

**តារាង៣. ការប្រើប្រាស់យុទ្ធសាស្ត្រដោះស្រាយតាមរបរចិញ្ចឹមជីវិតក្នុងគ្រួសារបែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| យុទ្ធសាស្ត្រដោះស្រាយ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ទីជនបទផ្សេងៗ |
|---|---|---|---|---|
| លក់របស់របរក្នុងផ្ទះ | ០,២ | ០,០ | ០,៥ | ០,១ |
| លក់សម្ភារៈផលិតកម្មនិងមធ្យោបាយធ្វើដំណើរ | ០,១ | ០,០ | ០,៣ | ០,១ |
| កាត់បន្ថយការចំណាយក្រៅពីម្ហូបអាហារ | ០,៣ | ០,០ | ០,៤ | ០,៤ |
| ចំណាយប្រាក់ដែលបានសន្សំទុក | ០,៧ | ០,២ | ០,៦ | ០,៨ |
| ខ្ចីប្រាក់/ម្ហូបអាហារ | ១,០ | ០,១ | ១,៣ | ១,១ |
| លក់ផ្ទះឬដីធ្លី | ០,១ | ០,០ | ០,៣ | ០,១ |
| បញ្ឈប់កូនពីសាលារៀន | ០,១ | ០,០ | ០,៤ | ០,០ |
| បង្កើតចំណូលតាមសកម្មភាពខុសច្បាប់ | ០,១ | ០,០ | ០,៣ | ០,០ |
| បញ្ជូនសមាជិកគ្រួសារពេញវ័យឲ្យស្វែងរកការងារធ្វើនៅកន្លែងផ្សេង | ០,១ | ០,០ | ០,៤ | ០,១ |
| ដើរសុំទាន | ០,១ | ០,០ | ០,៣ | ០,០ |

តារាង៤ បង្ហាញពីភាគរយនៃគ្រួសារដែលបានទទួលនូវប័ណ្ណសមធម៌/ប័ណ្ណអត្តសញ្ញាណក្រីក្រ ប័ណ្ណអាទិភាព និងប័ណ្ណផ្សេងៗទៀតនៅក្នុងរយៈពេល១ឆ្នាំកន្លងមក មកត្រឹមថ្ងៃធ្វើសម្ភាសន៍។ ជារួមនៅប្រទេសកម្ពុជា មានគ្រួសារប្រមាណ១០ភាគរយបានរាយការណ៍ថា ពួកគាត់មានប័ណ្ណសមធម៌/ប័ណ្ណអត្តសញ្ញាណក្រីក្រ។ សម្រាប់គ្រួសាររស់នៅតាមតំបន់ជនបទផ្សេងៗ គឺហាក់ដូចជាបានទទួលនូវបណ្ណ័ទាំងនេះច្រើនជាងគ្រួសារដែលរស់នៅរាជធានីភ្នំពេញ និងនៅទីប្រជុំជនផ្សេងៗ។ ក្រៅពីប័ណ្ណសមធម៌/ប័ណ្ណអត្តសញ្ញាណក្រីក្រ នៅប្រទេសកម្ពុជា ក៏នៅមានប័ណ្ណអាទិភាព ដែលគ្រួសារទទួលបានប្រមាណ ០,៥ភាគរយ និងព្រមទាំងប័ណ្ណផ្សេងៗទៀត មានប្រមាណ១៥ភាគរយ ដូចជា ប័ណ្ណបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)។ល។ បើគិតជាមធ្យមមានគ្រួសារប្រមាណ ៧,០ភាគរយ ធ្លាប់បានប្រើប្រាស់នូវប័ណ្ណអាទិភាពក៏ដូចជាប័ណ្ណផ្សេងៗទៀត ក្នុងការទទួលសេវាថៃទាំសុខភាព និងសេវាសង្គមក្នុងរយៈពេល១ឆ្នាំកន្លងមកនេះ។ ផ្អែកតាមលទ្ធផលអង្កេតបានបង្ហាញថា គ្រួសារដែលរស់នៅតំបន់ទាំងបី (រាជធានីភ្នំពេញ តាមទីប្រជុំជន និងតាមតំបន់ជនបទផ្សេងៗ) មានការប្រើប្រាស់ប័ណ្ណអាទិភាពប្រហាក់ប្រហែលគ្នា បើធៀបនឹងការប្រើប្រាស់ប័ណ្ណអាទិភាពនៅទូទាំងប្រទេសមានប្រមាណ ០,៥ភាគរយ។ (សូមមើលតារាង៤សម្រាប់ព័ត៌មានបន្ថែម)។

**តារាង៤.ការប្រើប្រាស់ប័ណ្ណសមធម៌ ប័ណ្ណអត្តសញ្ញាណក្រីក្រ ប័ណ្ណអាទិភាព និងប័ណ្ណផ្សេងៗក្នុងគ្រួសារ បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភេទប័ណ្ណ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទផ្សេងៗ |
|---|---|---|---|---|
| មានប័ណ្ណសមធម៌/បណ្ណ័អត្តសញ្ញាណក្រីក្រ | ១០,០ | ២,៨ | ៨,៥ | ១២,២ |
| មានប័ណ្ណអាទិភាព | ០,៥ | ០,៥ | ០,៥ | ០,៦ |
| មានប័ណ្ណផ្សេងៗទៀត | ១៤,៩ | ១៥,៩ | ២៣,៥ | ១១,៥ |
| ប្រើប្រាស់ប័ណ្ណណាមួយ | ៦,៨ | ១,៤ | ៨,០ | ៧,៧ |

# ផ្នែកទី១២

# តារាងឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

# តារាងទិន្នន័យបន្ថែមផ្នែកចរិតលក្ខណៈប្រជាសាស្ត្រ

តារាង១.១ ចំនួនប្រជាជនដែលបានគណនាប៉ាន់ស្មាន បែងចែកតាមទីកន្លែងរស់នៅឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០ (គិតជាពាន់នាក់ និងភាគរយ)

| ទីកន្លែងរស់នៅ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ | | | | |
|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| | | | គិតជាពាន់នាក់ | | |
| កម្ពុជា | ១៥.១៨៤ | ១៥.៤០៥ | ១៥.៦២៦ | ១៥.៨៤៨ | ១៥.៩៥៤ |
| ទីប្រជុំជន | ៣.៤១២ | ៣.៥៤១ | ៣.៦៧០ | ៣.៨០១ | ៦.២៩៣ |
| ជនបទ | ១១.៧៧២ | ១១.៨៦៥ | ១១.៩៥៦ | ១២.០៤៧ | ៩.៦៦១ |
| | ២៩,០ | ២៩,៨ | ៣០,៧ | ៣១,៦ | ៦៥,១ |
| | | | គិតជាភាគរយ | | |
| កម្ពុជា | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ទីប្រជុំជន | ២២,៥ | ២៣,០ | ២៣,៥ | ២៤,០ | ៣៩,៤ |
| ជនបទ | ៧៧,៥ | ៧៧,០ | ៧៦,៥ | ៧៦,០ | ៦០,៦ |

តារាង១.២ ចំនួនប្រជាពស្ត្រីដែលបានវាស់វែង ឬប៉ាន់ស្មានបែងចែកតាមភេទឆ្នាំ២០១៤ដល់ឆ្នាំ២០១៩/២០(គិតជាពាន់នាក់ និងភាគរយ)

| ភេទ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ | | | | |
|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| | | | គិតជាពាន់នាក់ | | |
| ស្ត្រី | ៧.៧៤៨ | ៧.៨៦៣ | ៧.៩៥៩ | ៨.០៦៥ | ៨.១៨៦ |
| បុរស | ៧.៤៣៦ | ៧.៥៤២ | ៧.៦៦៨ | ៧.៧៨៤ | ៧.៧៦៨ |
| ទាំងពីរភេទ | ១៥.១៨៤ | ១៥.៤០៥ | ១៥.៦២៦ | ១៥.៨៤៨ | ១៥.៩៥៤ |
| | | | គិតជាភាគរយ | | |
| ស្ត្រី | ៥១,០ | ៥១,០ | ៥០,៩ | ៥០,៩ | ៥១,៣ |
| បុរស | ៤៩,០ | ៤៩,០ | ៤៩,១ | ៤៩,១ | ៤៨,៧ |
| ទាំងពីរភេទ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

តារាង១.៣ ចំនួនគ្រួសារដែលបានគណនាប៉ាន់ស្មាន បែងចែកតាមទីកន្លែងរស់នៅឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៩/២០(គិតជាពាន់គ្រួសារ និងភាគរយ)

| ទីកន្លែងរស់នៅ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ | | | | |
|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៩/២០ |
| | គិតជាពាន់គ្រួសារ | | | | |
| កម្ពុជា | ៣.២៦១ | ៣.៣០៨ | ៣.៣៩០ | ៣.៤៣៨ | ៣.៦៣៦ |
| ទីប្រជុំជន | ៦៩៦ | ៧០៩ | ៧០៥ | ៧១៥ | ១.៣៧៤ |
| ជនបទ | ២.៥៦៥ | ២.៥៩៩ | ២.៦៨៤ | ២.៧២៣ | ២.២៦២ |
| | គិតជាភាគរយ | | | | |
| កម្ពុជា | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ទីប្រជុំជន | ២១,៣ | ២១,៤ | ២០,៨ | ២០,៨ | ៣៧,៨ |
| ជនបទ | ៧៨,៧ | ៧៨,៦ | ៧៩,២ | ៧៩,២ | ៦២,២ |

តារាង១.៤ គ្រួសារដែលមានស្ត្រីជាមេគ្រួសារនៃចំនួនគ្រួសារសរុបបែងចែកតាមតំបន់ភូមិសាស្ត្រឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| តំបន់ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស |
| | គិតជាពាន់គ្រួសារ | | | គិតជាភាគរយ | | |
| កម្ពុជា | ៣.៦៣៦ | ៧៨២ | ២.៨៥៤ | ១០០ | ២១,៥ | ៧៨,៥ |
| រាជធានីភ្នំពេញ | ៥៣២ | ១៦១ | ៣៧១ | ១០០ | ៣០,៣ | ៦៩,៧ |
| ទីប្រជុំជនផ្សេងៗ | ៨៤៣ | ១៧៤ | ៦៦៩ | ១០០ | ២០,៦ | ៧៩,៤ |
| ជនបទផ្សេងៗ | ២.២៦២ | ៤៤៧ | ១.៨១៥ | ១០០ | ១៩,៨ | ៨០,២ |

តារាង១.៥ ក្រុមអាយុបែងចែកតាមភេទ២០១៩/២០( គិតជាភាគរយ )

| ក្រុមអាយុ | អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា | | | | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ស្ត្រី | បុរស | ទាំងពីរភេទ | ស្ត្រី | បុរស |
| | គិតជាពាន់គ្រួសារ | | | គិតជាភាគរយ | | |
| កម្ពុជា | ១៥.៩៥៤ | ៨,១៨៦ | ៧,៧៦៨ | ១០០ | ៥១,៣ | ៤៨,៧ |
| ០-៤ | ១.៤៦៤ | ៧១០ | ៧៥៥ | ១០០ | ៤៨,៥ | ៥១,៥ |
| ៥-៩ | ១,៥៣៤ | ៧៥០ | ៧៨៤ | ១០០ | ៤៨,៩ | ៥១,១ |
| ១០-១៤ | ១,៧១៤ | ៨៣២ | ៨៨២ | ១០០ | ៤៨,៦ | ៥១,៤ |
| ១៥-១៩ | ១,៤២២ | ៧១១ | ៧១២ | ១០០ | ៥០,០ | ៥០,០ |
| ២០-២៤ | ១,៣៤២ | ៦៨៥ | ៦៥៧ | ១០០ | ៥១,០ | ៤៩,០ |
| ២៥-២៩ | ១,៤១១ | ៧២៤ | ៦៨៧ | ១០០ | ៥១,៣ | ៤៨,៧ |
| ៣០-៣៤ | ១,៣៣៤ | ៦៧៨ | ៦៥៦ | ១០០ | ៥០,៨ | ៤៩,២ |
| ៣៥-៣៩ | ១,៣៤៦ | ៦៨៣ | ៦៦៣ | ១០០ | ៥០,៨ | ៤៩,២ |
| ៤០-៤៤ | ៧៩៥ | ៤១២ | ៣៨៣ | ១០០ | ៥១,៩ | ៤៨,២ |
| ៤៥-៤៩ | ៧៨៧ | ៤០៣ | ៣៨៤ | ១០០ | ៥១,២ | ៤៨,៨ |
| ៥០-៥៤ | ៧២០ | ៣៨៨ | ៣៣១ | ១០០ | ៥៤,០ | ៤៦,០ |
| ៥៥-៥៩ | ៦៧១ | ៣៥៩ | ៣១២ | ១០០ | ៥៣,៥ | ៤៦,៥ |
| ៦០-៦៤ | ៤៨៩ | ២៨៩ | ២០០ | ១០០ | ៥៩,១ | ៤០,៩ |
| ៦៥-៦៩ | ៣៥៩ | ២១៦ | ១៤៣ | ១០០ | ៦០,២ | ៣៩,៨ |
| ៧០-៧៤ | ២៦៥ | ១៦៤ | ១០១ | ១០០ | ៦១,៧ | ៣៨,៣ |
| ៧៥-៧៩ | ១៦៤ | ៩៧ | ៦៨ | ១០០ | ៥៨,៧ | ៤១,៣ |
| ៨០⁺ | ១៣៧ | ៨៥ | ៥២ | ១០០ | ៦២,១ | ៣៧,៩ |

តារាង១.៦ ស្ថានភាពអាពាហ៍ពិពាហ៍បែងចែកតាមតំបន់ភូមិសាស្ត្រសម្រាប់ប្រជារាស្ត្រអាយុ១៥ឆ្នាំឡើងឆ្នាំ២០១៩/២០ ( គិតជាពាន់នាក់ )

| ស្ថានភាពអាពាហ៍ពិពាហ៍ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទផ្សេងៗ |
|---|---|---|---|---|
| រៀបការ/រស់នៅជាមួយគ្នា | ៧.១០២ | ១.០២៦ | ១.៨០១ | ៤.២៧៤ |
| លែងលះ/បែកបាក់ | ១៩០ | ២២ | ៥១ | ១១៧ |
| ពោះម៉ាយ/មេម៉ាយ | ៩៦៥ | ១៥៥ | ២៣៤ | ៥៧៦ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២.៩៨៤ | ៥៩៩ | ៧៥៩ | ១.៦២៥ |
| សរុប | ១១.២៤១ | ១.៨០២ | ២.៨៤៦ | ៦.៥៩៣ |

តារាង១.៧ ស្ថានភាពអាពាហ៍ពិពាហ៍បែងចែកតាមតំបន់ភូមិសាស្ត្រសម្រាប់ប្រជារាស្ត្រអាយុ១៥ឆ្នាំឡើង ឆ្នាំ២០១៩/២០ (គិតជាពាន់នាក់ និងភាគរយ)

| ស្ថានភាពអាពាហ៍ពិពាហ៍ | រាជធានីភ្នំពេញ | | ទីប្រជុំជនផ្សេងៗ | | ជនបទផ្សេងៗ | |
|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| | | | គិតជាពាន់គ្រួសារ | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥១៥ | ៥១១ | ៨៩៦ | ៩០៦ | ២.១៦៤ | ២.១១១ |
| លែងលះ/បែកបាក់ | ១៣ | ៩ | ៤០ | ១១ | ៩០ | ២៨ |
| ពោះម៉ាយ/មេម៉ាយ | ១២៣ | ៣២ | ១៩៩ | ៣៥ | ៤៨២ | ៩៤ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ២៩៣ | ៣០៦ | ៣៤០ | ៤១៩ | ៧៣៨ | ៨៨៧ |
| សរុប | ៩៤៥ | ៨៥៨ | ១.៤៧៥ | ១.៣៧១ | ៣.៤៧៤ | ៣.១១៩ |
| | | | គិតជាភាគរយ | | | |
| រៀបការ/រស់នៅជាមួយគ្នា | ៥៤,៥ | ៥៩,៦ | ៦០,៧ | ៦៦,១ | ៦២,៣ | ៦៧,៧ |
| លែងលះ/បែកបាក់ | ១,៤ | ១,០ | ២,៧ | ០,៨ | ២,៦ | ០,៩ |
| ពោះម៉ាយ/មេម៉ាយ | ១៣,០ | ៣,៨ | ១៣,៥ | ២,៥ | ១៣,៩ | ៣,០ |
| មិនដែលរៀបការ/មិនដែលរស់នៅជាមួយដៃគូ | ៣១,១ | ៣៥,៦ | ២៣,១ | ៣០,៦ | ២១,៣ | ២៨,៤ |
| សរុប | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

តារាង១.៨ ភាគរយប្រជាជនបែងចែកតាមជនជាតិ និងតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (ចំនួនសរុប)

| ជនជាតិ | កម្ពុជា | រាជធានីភ្នំពេញ | ទីប្រជុំជនផ្សេងៗ | ជនបទផ្សេងៗ |
|---|---|---|---|---|
| ខ្មែរ | ៥.២១៨.៥៤៥ | ២.២៣០.១៨២ | ៨៧២.៤៨៧ | ៩.១១៥.៨៧៦ |
| ចាម | ៣៧៦.៥៦០ | ៦៦.៨៨៨ | ៤៥.៦១១ | ២៦៤.០៦២ |
| ចិន | ២៤២.៩៣៨ | ៤១ | ៨.៨០៥ | ២៣៤.០៩២ |
| វៀតណាម | ២៧.៤៤៩ | ៩.៧៦២ | ៣.៥៧៥ | ១៤.១១៤ |
| ថៃ | ៧៣.៧៣៦ | ៣១.៩០១ | ១៧.៦៥៨ | ២៤.១៧៨ |
| ឡាវ | ១.៦៩៨ | - | ១.១៩២ | ៥០៦ |
| ជនជាតិផ្សេងៗ | ៧.៨២៨ | - | ២.៨៣៦ | ៤.៩៩២ |
| មិនបានបញ្ជាក់ | ៤.៩៩១ | ១.៥៩៤ | ៧១២ | ២.៦៨៥ |
| សរុប | ១៥.៩៥៣.៧៤៤ | ២.៣៤០.៣៦៦ | ៣.៩៥២.៨៧៦ | ៩.៦៦០.៥០២ |

តារាង១.៩ ការចុះបញ្ជីកំណើត សម្រាប់កុមារអាយុពី០ឆ្នាំដល់៤ឆ្នាំ បែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ និងចំនួនសរុប)

| ក្រុម | សំបុត្រកំណើត | ការចុះបញ្ជី | មិនមាន | មិនដឹង | ចំនួនកុមារសរុប |
|---|---|---|---|---|---|
| អាយុ | | | | | |
| ០ | ៨៥,៧ | ៤,៩ | ៩,៤ | ០,០ | ២៥៧.៦៥១ |
| ១ | ៩៣,៧ | ២,៨ | ៣,២ | ០,៣ | ២៤៣.២៥២ |
| ២ | ៩២,៥ | ៣,០ | ៤,៥ | ០,០ | ២៨៧.១៦០ |
| ៣ | ៩៣,១ | ២,៤ | ៤,៣ | ០,២ | ៣៥៩.៧៧៣ |
| ៤ | ៩៥,១ | ១,៨ | ២,៣ | ០,៧ | ៣១៦.៤៨២ |
| ភេទ | | | | | |
| ស្ត្រី | ៩១,៩ | ២,៦ | ៥,៣ | ០,៣ | ៧០៩.៦៧៦ |
| បុរស | ៩២,៥ | ៣,២ | ៤,០ | ០,២ | ៧៥៤.៦៤១ |
| ទីកន្លែងរស់នៅ | | | | | |
| ទីប្រជុំជន | ៩៤,០ | ៣,១ | ២,៧ | ០,៣ | ៥១៩.៩០៣ |
| ទីជនបទ | ៩១,៣ | ២,៨ | ៥,៧ | ០,២ | ៩៤៤.៤១៤ |
| តំបន់ | | | | | |
| កម្ពុជា | ៩២,២ | ២,៩ | ៤,៦ | ០,៣ | ១.៤៦៤.៣១៧ |
| រាជធានីភ្នំពេញ | ៩៥,៤ | ៣,៣ | ០,៨ | ០,៥ | ១៧៦.០៦៧ |
| ទីប្រជុំជនផ្សេងៗ | ៩៣,៣ | ២,៩ | ៣,៦ | ០,២ | ៣៤៣.៨៣៥ |
| ជនបទផ្សេងៗ | ៩១,៣ | ២,៨ | ៥,៧ | ០,២ | ៩៤៤.៤១៤ |
| តំបន់ | | | | | |
| រាជធានីភ្នំពេញ | ៩៥,៤ | ៣,៣ | ០,៨ | ០,៥ | ១៧៦,០៦៧ |
| ទំនាបកណ្តាល | ៩៣,៩ | ២,២ | ៣,៩ | ០,១ | ៥០៥.១០១ |
| បឹងទន្លេសាប | ៩១,៧ | ២,៨ | ៥,៣ | ០,២ | ៤៣៩.២៥៤ |
| ឆ្នេរសមុទ្រ | ៨៩,៤ | ២,៨ | ៧,៤ | ០,៤ | ៩៥.៩៧២ |
| ខ្ពង់រាប/ភ្នំ | ៨៨,៧ | ៤,៣ | ៦,៥ | ០,៥ | ២៤៧.៩២២ |

# ឧបសម្ព័ន្ធ២

# តារាងទិន្នន័យបន្ថែមផ្នែកលំនៅដ្ឋាន

តារាង២.១ ប្រភពទឹកសំខាន់ៗសម្រាប់បរិភោគបែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)

| ប្រភពទឹក | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| **ប្រភពទឹកបានកែលម្អ** | **៧៩,៧** | **៨៨,០** | **៧៤,៧** |
| ទឹកបំពង់បណ្តាញក្នុងលំនៅដ្ឋាន | ២៥,៨ | ៥១,៨ | ១០,១ |
| ទឹកបំពង់បណ្តាញក្នុងទីធ្លាបរិវេណលំនៅដ្ឋាន/ | ៣,៧ | ៤,៩ | ៣,០ |
| ទឹកបំពង់សាធារណៈ | ១,០ | ១,២ | ០,៨ |
| អណ្តូងស្នប់/អណ្តូងខួង | ៣០,១ | ១៦,៥ | ៣៨,៤ |
| អណ្តូងជីកមានគម្របការពារ | ៤,១ | ២,២ | ៥,៤ |
| ទឹកចេញក្រោមដីមានការការពារ | ០,០ | ០,០ | ០,០ |
| ទឹកភ្លៀង | ៥,៨ | ២,៧ | ៧,៧ |
| ទឹកដប/ទឹកពិសាដប | ៩,១ | ៨,៨ | ៩,៤ |
| **ប្រភពទឹកមិនបានកែលម្អ** | **២០,៣** | **១២,០** | **២៥,៣** |
| អណ្តូងជីកគ្មានគម្របការពារ | ៤,៤ | ១,៥ | ៦,១ |
| ទឹកចេញក្រោមដីគ្មានការការពារ | ០,១ | ០,២ | ០,១ |
| ទឹកទិញឡានស៊ីទែន | ៣,៩ | ៤,០ | ៣,៩ |
| ទឹកទិញធុងរទេះ | ២,៩ | ២,១ | ៣,៥ |
| ទឹកលើដី( ទឹកទន្លេ/ស្ទឹង/ព្រែក/បឹង/ស្រះ/អូរ/ ត្រពាំង ) | ៨,៦ | ៣,៩ | ១១,៥ |
| ផ្សេងទៀត (ដែលបានបញ្ជាក់) | ០,៣ | ០,៣ | ០,៣ |
| ភាគរយសរុប | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | ៣.៦៣៦,១ | ១.៣៧៤,២ | ២.២៦១,៩ |

**តារាង២.២ បង្គន់អនាម័យបែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភេទបង្គន់អនាម័យ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| **បង្គន់អនាម័យ បានកែលម្អ** | **៨០,៤** | **៩០,៦** | **៧៤,២** |
| បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកតភ្ជាប់ទៅប្រព័ន្ធលូ | ១៧,៦ | ៣៨,៧ | ៤,៨ |
| បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកតភ្ជាប់ទៅអាងស្តុក/រណ្តៅ | ៦១,៩ | ៥១,២ | ៦៨,៤ |
| បង្គន់រណ្តៅមានផែនបង្គន់សម្រាប់បទជើង | ០,៩ | ០,៦ | ១,០ |
| **បង្គន់គ្មានអនាម័យមិនបានកែលម្អ** | **១៩,៦** | **៩,៤** | **២៥,៨** |
| បង្គន់ចាក់ទឹក/ចុចបង្ហូរទឹកបង្ហូរទៅកន្លែងផ្សេង | ២,២ | ១,៦ | ២,៦ |
| បង្គន់រណ្តៅគ្មានផែនបង្គន់សម្រាប់បទជើង | ០,២ | ០,០ | ០,៣ |
| បង្គន់បត់ជើងទម្លាក់លើទីវាល ឬក្នុងទឹក | ១,៣ | ០,៧ | ១,៧ |
| គ្មានបង្គន់ | ១៥,៨ | ៧,១ | ២១,០ |
| បង្គន់ផ្សេងទៀត (សូមបញ្ជាក់) | ០,២ | ០,១ | ០,៣ |
| ភាគរយសរុប | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | ៣.៦៣៦,១ | ១.៣៧៤,២ | ២.២៦១,៩ |

**តារាង២.៣ ឧបករណ៍សម្រាប់លាងដៃនៅក្នុងបរិវេណផ្ទះបែងចែកតាមតំបន់ភូមិសាស្ត្រ ឆ្នាំ២០១៩/២០(គិតជាភាគរយ)**

| ឧបករណ៍សម្រាប់លាងដៃ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| **ឧបករណ៍សម្រាប់លាងដៃនៅក្នុងបរិវេណផ្ទះ** | | | |
| មិនមាន | ១១,០ | ៦,៩ | ១៣,៥ |
| ទឹកមានចរន្តចេញពីប្រព័ន្ធបំពង់ ឬអាង | ១៨,៦ | ៤០,០ | ៥,៧ |
| ប្រព័ន្ធទឹកដងដោយដៃ | ៦៣,៨ | ៤៨,៩ | ៧២,៨ |
| ធុង/អាង | ៦,៦ | ៤,២ | ៨,១ |
| ឧបករណ៍ផ្សេងទៀត (ដែលបានបញ្ជាក់) | ០,០ | ០,១ | ០,០ |
| សរុប | ១០០ | ១០០ | ១០០ |
| **ឧបករណ៍សម្រាប់លាងដៃដែលប្រើញឹកញាប់** | | | |
| នៅជិតបង្គន់ (តិចជាង ៣ម៉ែត្រ) | ៥៩,២ | ៧២,៧ | ៥០,៣ |
| នៅជិតបង្គន់ (តិចជាង ៣ម៉ែត្រ) ឬនៅកន្លែងផ្សេង | ៣៨,៥ | ២៥,៣ | ៤៧,០ |
| មិនត្រូវបានសង្កេតដោយសារគ្មានការអនុញ្ញាតិ | ១,៦ | ១,៤ | ១,៧ |
| មិនត្រូវបានសង្កេតដោយសារមូលហេតុផ្សេងទៀត | ០,៨ | ០,៥ | ០,៩ |
| សរុប | ១០០ | ១០០ | ១០០ |
| **មានទឹកនៅកន្លែងលាងដៃ** | | | |
| មាន | ៩៤,៨ | ៩៥,៥ | ៩៤,៣ |
| គ្មាន | ៥,២ | ៤,៥ | ៥,៧ |
| សរុប | ១០០ | ១០០ | ១០០ |
| **មានសាប៊ូនៅកន្លែងលាងដៃ** | | | |
| មាន | ៨៥,២ | ៩០,២ | ៨២,០ |
| គ្មាន | ១៤,៨ | ៩,៩ | ១៨,០ |
| សរុប | ១០០ | ១០០ | ១០០ |
| **មានទឹកនិងសាប៊ូនៅកន្លែងលាងដៃ** | | | |
| មាន | ៧៥,០ | ៨៣,២ | ៧០,១ |
| គ្មាន | ២៥,០ | ១៦,៨ | ២៩,៩ |
| សរុប | ១០០ | ១០០ | ១០០ |

**តារាង២.៤ ប្រភពថាមពលសំខាន់ៗសម្រាប់បំភ្លឺ បែងចែងតាមទីកន្លែងរស់នៅ ឆ្នាំ២០១៩/២០ (គិតជាភាគរយ)**

| ប្រភពថាមពលសម្រាប់បំភ្លឺ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| អគ្គិសនីផ្គត់ផ្គង់សាធារៈ/អគ្គិសនីរដ្ឋ | ៨៥,៧ | ៩៦,៨ | ៧៩,០ |
| ម៉ាស៊ីនភ្លើង | ០,៧ | ០,៥ | ០,៨ |
| អាគុយ | ៤,១ | ០,៩ | ៦,០ |
| ចង្កៀងប្រេងកាត | ០,៥ | ០,៣ | ០,៦ |
| ទៀន | ០,១ | ០,១ | ០,១ |
| គ្មាន | ៨,៤ | ១,២ | ១២,៧ |
| ពន្លឺព្រះអាទិត្យ | ០,១ | ០,០ | ០,១ |
| ផ្សេងទៀត (ដែលបានបញ្ជាក់) | ០,៥ | ០,៣ | ០,៧ |
| សរុប | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | ៣.៦៣៦,១ | ១.៣៧៤,២ | ២.២៦១,៩ |

**តារាង២.៥ ប្រភពថាមពលសំខាន់ៗសម្រាប់ចម្អិនអាហារ បែងចែកតាមទីកន្លែងរស់នៅ ឆ្នាំ ២០១៩/២០ (គិតជាភាគរយ)**

| ប្រភេទឥន្ទនៈ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| អុស | ៥១,៣ | ២៤,៧ | ៦៧,៥ |
| ធ្យូង | ៥,៦ | ៤,៤ | ៦,៣ |
| ឧស្ម័នហ្គាស | ៤១,៩ | ៦៩,៩ | ២៤,៩ |
| ប្រេងកាត | ០,០ | ០,០ | ០,០ |
| អគ្គិសនីផ្គត់ផ្គង់សាធារណៈអគ្គិសនីរដ្ឋ/ | ១,០ | ០,៨ | ១,០ |
| ម៉ាស៊ីនភ្លើងគ្រួសារ | ០,០ | ០,០ | ០,០ |
| គ្មានមិនចម្អិនអាហារ/ | ០,០ | ០,០ | ០,០ |
| ផ្សេងទៀត | ០,២ | ០,២ | ០,៣ |
| សរុប | ១០០ | ១០០ | ១០០ |
| ចំនួនគ្រួសារ (គិតជាពាន់គ្រួសារ) | ៣.៦៣៦,១ | ១.៣៧៤,២ | ២.២៦១,៩ |

# ឧបសម្ព័ន្ធ៣

